# សាសនវិទ្យា និងសេចក្តីជំនឿ នៃការស្តាបនាឡើងវិញ នូវរូបឆ្លុះរបស់ព្រះ

(The Theology and its Faith of Restoration of the Image of God)

[Book II]



2018


លោកបណ្ឌិត វ៉ាយ យ៉ុង ជុន

Dr. White Young Jeon

CRFI

# សាសនវិទ្យា និងសេចក្តីជំនឿ នៃការស្តាបនាឡើងវិញ នូវរូបឆ្លុះរបស់ព្រះ

**(The Theology and its Faith of Restoration of the Image of God)**

លោកបណ្ឌិត វ៉ាយ យ៉ុង ជុន

Author: White Young Jeon

Translator: Sokhen Chea and Sreyleak Kohn

Editor: Charany Yoeun

## អារម្មណ៍កថា

តាំងពីខ្ញុំបានទទួលជឿព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់របស់ខ្ញុំមក ខ្ញុំក៏បានបំរើទ្រង់នៅក្នុងព្រះវិហារ និងស្តាប់បង្គាប់បញ្ញត្តិរបស់ទ្រង់អស់រយះពេល៥០ឆ្នាំមកហើយ (ដោយធ្វើព័ន្ធកិច្ចជាគ្រូគង្វាល៣០ឆ្នាំ ព័ន្ធកិច្ចនៃការអប់រំ និងព័ន្ធកិច្ចបេសកជនចំនួន២០ឆ្នាំ)។ ខ្ញុំចង់បង្ហាញពីការអះអាងរបស់ខ្ញុំនៅ "សាសនវិទ្យា នៃការស្តារឡើងវិញ នូវរូបឆ្លុះរបស់ព្រះ និងសេចក្តីជំនឿ ព្រោះវាជាការធានារបស់ខ្ញុំ ដែលខ្ញុំបានដើរក្នុងសេចក្តីងងឹតនៃការរងទុក្ខវេទនាយ៉ាងយូរ ប៉ុន្តែព្រះបានដាំសេចក្តីពិតនៅក្នុងចិត្តរបស់ខ្ញុំ។

ខ្ញុំបានចាប់ផ្តើមជីវិតនៃសេចក្តីជំនឿរបស់ខ្ញុំ ក្នុងនាមជាអ្នកដែលមានចំណង់ចំណូលចិត្តខាងមេតូឌីសដែលស្ថិតនៅក្រោមការផ្សាយដំណឹងល្អ។ តាមរយះការដឹកនាំរបស់ព្រះ ខ្ញុំបានធ្វើការសិក្សាលើទ្រឹស្តីសាសនវិទ្យាកំណែទំរង់ពួកបរិសុទ្ធ និងសេចក្តីជំនឿនៅក្នុងប្រទេសកូរ៉េខាងត្បូង នៅសហរដ្ឋអាមេរិក ហើយខ្ញុំក៏បានបម្រើព្រះនៅក្នុងព្រះវិហារនៅកូរ៉េខាងត្បូង សហរដ្ឋអាមេរិក និងកម្ពុជា។ រហូតមកដល់ពេលនេះ ខ្ញុំបានជួបសាសនវិទូដ៏ស្មោះត្រង់ជាច្រើន និងគ្រូគង្វាលជាច្រើន អ្នកទាំងនោះមាន លោកគ្រូ យុន សាន់ ផាក (Yun Sun Park), ហាក់ កុន កាំង (Hak Kun Kang) នៅកូរ៉េខាងត្បូង,អឹម ជី ក្លាញ( MG Kline), ក្លោនណេ( Clowney) ចេ អាដាម( Jay Adams) ហ្គតហ្វ្រេ ( Godfrey),ហ្វ្រេម( Frame) ។ ល។ និងគ្រូបង្រៀនរបស់ខ្ញុំ ដែលជាបណ្ឌិតផ្នែកព័ន្ធកិច្ចគឺលោក យ៉ូសែបភីប៉ា (Joseph Pipa) បានធ្វើឱ្យខ្ញុំពង្រឹងសាសនវិទ្យា និងសេចក្តីជំនឿរបស់ខ្ញុំ និងគោលដៅរបស់ខ្ញុំឱ្យកាន់តែស៊ីជម្រៅថែមទៀត។ បន្ទាប់ពីនោះខ្ញុំបានរៀបចំគោលដៅនោះ ដោយបានចែកចាយជាមួយសាស្ត្រាចារ្យនៅសាលា ITCS និងសិស្សនិស្សិត តាមរយៈការបង្រៀនមុខវិជ្ជាមួយចំនួនដូចជា ការអធិប្បាយ ពួកបរិសុទ្ធ និងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសាសនវិទ្យា M. G. Kline ហើយខ្ញុំត្រូវបានលើកទឹកចិត្តដោយ ការអប់រំពីព័ន្ធកិច្ចនៅប្រទេសកម្ពុជា ហើយបេកកម្ម ព័ន្ធកិច្ច សំរាប់ជាប្រយោជន៍ បង្កើតអាណាចក្ររបស់ព្រះនៅកម្ពុជា។

សៀវភៅនេះត្រូវបានធ្វើឡើងដើម្បីប្រកាសដំណឹងល្អ ទៅកាន់ខេត្តចំនួន 26 នៃប្រទេសកម្ពុជានិងបង្កើតព្រះវិហារសាខាព្រះវិហារ ពេនីអែលព្រីប៊ីធើរៀន(Peniel Presbyterian) តាម

រយៈការស្តារឡើងវិញនូវការលូតលាស់នៃក្រុមជំនុំអេភេសូរនិងការជួយខ្លួនឯងនៃពន្ធ័កិច្ចរបស់គ្រូគង្វាល។ គោលដៅនេះចេញមកពីនិមិត្តរបស់ខ្ញុំ ដែលព្រះបានផ្តល់ឱ្យក្នុងដំណើរការនៃការអប់រំព័ន្ធកិច្ចតូចរបស់ខ្ញុំ ដើម្បីចែកចាយនូវបទគម្ពីរ ព្រះបន្ទូលរបស់ព្រះ ទៅកាន់ប្រទេសកម្ពុជាដែលជាប្រទេសដែលមានអាកាសធាតុក្តៅ សើម និងមានសម្រស់ពណ៌បៃតងខ្ចី ប៉ុន្តែប្រទេសនេះ ជាប្រទេសដែលមានប្រវត្តិឈឺចាប់ គឺការសំលាប់រង្គាល់រហូតដល់អាណាចក្ររបស់ព្រះបានតាំងឡើង។

ខ្ញុំក៏បានយល់ពីអត្ថន័យនៃការឈឺចាប់របស់ខ្ញុំអស់រយៈពេល 13 ឆ្នាំក្នុងជីវិតដ៏តិចតួចរបស់ខ្ញុំ ហើយខ្ញុំក៏សរសើរតម្កើងសិរីរុងរឿងរបស់ព្រះ។ ទ្រង់បានរក្សាសេចក្តីសន្យារបស់ទ្រង់« ទ្រង់បានធ្វើឱ្យជើងទូលបង្គំដូចជាសត្វក្តាន់ហើយទ្រង់បានធ្វើឱ្យទូលបង្គំបានជាននៅឯទីខ្ពស់»។ (3:18) តាមរយៈសៀវភៅនេះខ្ញុំនឹងព្យាយាមបង្ហាញពីព្រះដែលស្មោះត្រង់ ទៅកាន់លោកីយ។

អត្ថបទនេះផ្តោតទៅលើប្រវត្តិសាស្រ្តនៃការប្រោសលោះនៃទស្សនវិទ្យា ការបង្រៀនពីទស្សនវិទ្យារបស់ខ្ញុំ គឺមាន លោក William Perkin's ដែលខ្ញុំស្រឡាញ់ពេញមួយជីវិតរបស់ខ្ញុំយ៉ាងជ្រាលជ្រៅហើយថែមផ្តល់ជាសម្ភារៈសិក្សាព្រះគម្ពីរជាច្រើន នឹងការកែតម្រូវគោលលទ្ធិគ្រីស្ទបរិស័ទនឹង បទព្រះគម្ពីផ្ទាល់ខ្លួនរបស់ខ្ញុំ។ កិច្ចការទាំងនេះពឹងផ្អែក ទៅលើការបង្រៀនពីព័ន្ធកិច្ចរបស់ខ្ញុំនៅក្នុងសិក្ខាសាលាកំនែទម្រង់នៃសាសនវិទ្យានៅប្រទេស សហរដ្ឋអាមេរិច CBPCP នឹង KAPC នឹងការថ្វាយបង្គំជាលលក្ខណៈគ្រួសារ សរសេរទៅកាន់ គ្រីស្ទាននៅសហរដ្ឋអាមេរិច។ ហើយឥឡូវបេកជននៅប្រទេសគម្ពុជាបានបង្កើតសាសនវិទ្យាកំនែទម្រង់នៃពួកបរិសុទ្ធនឹង សេចក្តីជំនឿលើចិត្តរបស់គេទាំង២៥ខេត្តក្រុងនៃប្រទេសគម្ពុជា។ វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់សម្រាប់ជំហានដំបូងរបស់ខ្ញុំ ក្នុងគំរោងនៃសាសនវិទ្យាកំនែទម្រង់នៃពួកបរិសុទ្ធ នឹងសេចក្តីជំនឿ នៅចំនុចកណ្តាលនៃអាស៊ីអាគ្នេយ៍ ដែលខ្ញុំបានអធិស្ឋានអស់រយៈពេលជាយូរមកហើយនៅក្នុងជីវិតរបស់ខ្ញុំ។

ខ្ញុំសូមកោតសរសើរចំពោះមិត្តរួមការងារទាំងអស់របស់ខ្ញុំ មិត្តភ័ក្រ្ត សាស្ត្រាចារ្យ សិស្សនៅ ITCS និងបុគ្គលិក CPPC របស់ខ្ញុំនិងក្រុមជំនុំព្រះវិហារ Peniel Presbyterian និងសាខាព្រះវិហារ Peniel សម្រាប់ការអធិស្ឋានដ៏កក់ក្តៅនិងការបម្រើដ៏ស្មោះត្រង់របស់ពួកគេទៅកាន់ព្រះ

យេស៊ូវគ្រីស្ទនិងការលើកទឹកចិត្តដ៏ស្មោះត្រង់ចំពោះព័ន្ធកិច្ចរបស់ខ្ញុំ លើសពីនេះទៅទៀត ប្រពន្ធរបស់ខ្ញុំ(គីមប៊ីលី), កូនស្រីបីនាក់របស់ខ្ញុំអេសធើរសារ៉ុននិងម៉ារា បានលះបង់ ជាច្រើន សំរាប់ខ្ញុំនៅក្នុងព្រះគ្រីស្ទ។ ខ្ញុំជឿថាព្រះនឹងប្រទានព្រះពរនឹងព្រះគុណដ៏អស្ចារ្យដល់ពួកគេ ជាបន្តបន្ទាប់។

ខ្ញុំបានចំណាយពេលជាច្រើនម៉ោងនៅមុខកុំព្យូទ័ររបស់ខ្ញុំដើម្បីសរសេរនិងកែសម្រួល បញ្ចប់នូវការងាររបស់ខ្ញុំ បីភាសាគឺ ភាសាកូរ៉េ អង់គ្លេសនឹងខ្មែរ ដើម្បីចែករំលែកការងារទាំង នេះទៅកាន់ពិភពលោក តាមរយៈគោលដៅរបស់ខ្ញុំ។ ហើយខ្ញុំចាំថាពួកបរិសុទ្ធជាច្រើន អធិស្ឋានសម្រាប់ខ្ញុំ ហើយគាំទ្រនូវបេសកកម្មព័ន្ធកិច្ចជាមួយនឹងអំណោយទានដ៏មានតម្លៃ របស់ពួកគេហើយខ្ញុំថ្វាយសិរីល្អដល់ព្រះដែលមានព្រះជន្មរស់។

នៅខែធ្នូឆ្នាំ 1961 ខ្ញុំបានអធិស្ឋានថា «ព្រះអម្ចាស់អើយសូមប្រោសខ្ញុំឱ្យស្គាល់សេចក្តីពិត ហើយឱ្យខ្ញុំអាចនឹងប្រកាស សេចក្តីពិត ទៅកាន់ពិភពលោក»។ ខ្ញុំបានលុតជង្គង់នៅលើភ្នំទឹក កកនៃរដូវរងា នឹងត្រជាក់ ហើយព្រះទ្រង់បានឆ្លើយតប់នូវការអធិស្ឋានរបស់ខ្ញុំ ដោយ ព្រះ ហាសស្តាំដ៏ស្មោះត្រង់របស់ទ្រង់ មកកាន់ជីវិតរបស់ខ្ញុំ។ ដូច្នេះខ្ញុំគួរតែស្មោះត្រង់នឹងបញ្ញាត្តិរប ស់ទ្រង់នៅក្នុងព័ន្ធកិច្ច នៅកម្ពុជាក្នុងកំឡុងពេលសេសសល់ដែលខ្ញុំនៅរស់។ «ព្រះអម្ចាស់ អើយសូមឱ្យទូលបង្គំសង់ព្រះវិហាររបស់ទ្រង់នៅលើទីវាលពិឃាត! (ម៉ាថាយ 16:18) "

មិថុនា ៣០, ២០១៧

នៅក្នុងបន្ទប់សិក្សារបស់ខ្ញុំនៅ ខាលី វរញ៉ា ប្រទេសសហរដ្ឋអាមេរិក
បេកជនអប់រំកម្ពុជា លោកបណ្ឌិត វ៉ាយយ៉ុងជុន

**មាតិការ**

**លំដាប់លំដោយទី ២**


I. **សាំយ៉ូអែលទី ២**

II. **ពង្សាវតាក្សត្រទី ១**

III. ពង្សាវតាក្សត្រទី ២

IV. របាក្សត្រទី ១

V. របាក្សត្រទី ២

- RGI ហោរាធំនៅក្នុងសៀវភៅមាន

    I. អេសាយ

    II. យេរេមា

    III. បរិទេវ

    IV. អេសេគាល

I សាំយ៉ូអែលទី២

## ផ្ដើមសេចក្ដី

ម៉ាថាយសរសេរថាដាវីឌស្មើនឹងអ័ប្រាហាំនៅក្នុងបញ្ជីរាយនាមពង្សា (ម៉ាថាយ 1:1) ហើយប៉ូលបានធ្វើបន្ទាល់ថា ដាវីឌបានស្គាល់ពីស្នួលនៃដំណឹងល្អ ជាការលន់តួបាប (រ៉ូម 4:7-8) បើទោះជាគាត់បានរស់នៅក្នុងសញ្ញាចាស់ក៏ដោយ ហើយព្រះអម្ចាស់របស់យើងបានពន្យល់ថា ដាវីឌទទួលបានការបើកសម្ដែងដោយព្រះវិញ្ញាណបរិសុទ្ធ នៅពេលដែលទ្រង់បានស្រែករកព្រះគ្រីស្ទថាជាព្រះអម្ចាស់របស់ទ្រង់ (ទំនុកដំកើង 130:1, ម៉ាថាយ 22:43)។ ការគ្រងរាជរបស់ស្ដេចដាវីឌដែលបានរួបរួមជាមួយការគ្រប់គ្រងរបស់ព្រះ ដោយពឹងលើការកំណត់របស់ព្រះអម្ចាស់។ វាបានបញ្ជាក់ដោយឧទាហរណ៍ទីមួយដែលបានបង្ហាញដោយ គោលការណ៍នៃសេចក្ដីប្រោសលោះនៅក្នុងសញ្ញាថ្មី។ វាមានន័យថាដាវីឌបានរីករាយនឹងព្រះគុណយ៉ាងបរិបូរណ៍នៅក្នុងព្រះគ្រីស្ទ តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ យើងអាចគិតពីឧទាហរណ៍នេះនៅក្នុងឥរិយាបថរបស់ទ្រង់ទៅកាន់ហិបសញ្ញា (2 សាំយ៉ូអែល 6: 7 :)។

នៅពេលដែលអូបិត-អេដុម បម្រើហិបសញ្ញាអស់រយៈបីខែនៅក្នុងផ្ទះរបស់គាត់ ព្រះអម្ចាស់បានប្រទានពរដល់គាត់និងគ្រួសាររបស់គាត់។ បន្ទាប់មក ស្ដេចដាវីឌបាននាំយកហិបសញ្ញាទៅកាន់កន្លែងរបស់ទ្រង់ ដោយធ្វើតាមការដឹកនាំរបស់ក្រឹត្យវិន័យ។ បន្ទាប់មកទ្រង់លោតរាំកញ្ឆែងយ៉ាងសប្បាយ។ ហើយទ្រង់បានប្រទានពរដល់គ្រួសាររបស់ខ្លួនដោយសារព្រះគុណរបស់ព្រះវិញ្ញាណបរិសុទ្ធ។ តើគាត់អាចមានសេចក្ដីអំណរយ៉ាងខ្លាំងនៅចំពោះព្រះបានយ៉ាងដូចម្ដេច? ទីមួយ គាត់បានស្នាក់នៅក្នុងកណ្ដាលនៃព្រះបន្ទូលរបស់ព្រះ (12)—ដោយសារការស្លាប់របស់អ៊ូសាបានធ្វើឱ្យដាវីឌមានការភ្ញាក់ផ្អើល ទ្រង់បានរក្សាទុកការនោះដោយស្ងៀមស្ងាត់អស់រយៈពេលបីខែ ហើយបានសម្រេចចិត្តនាំយកហិបសញ្ញាមកក្រុងយេរូសាឡិមវិញ។ និមិត្តសញ្ញារបស់ហិបសញ្ញាមានន័យថាជាព្រះបន្ទូលរបស់ព្រះ ជាព្រះវត្តមានរបស់ព្រះ ជាសួនអេដែន ជាព្រះគ្រីស្ទ និងជាព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ ការទទួលព្រះបន្ទូលរបស់ព្រះ

នោះជាការបម្រើដល់ព្រះវិញ្ញាណបរិសុទ្ធ។ ទាល់តែគាត់គោរពដល់ព្រះបន្ទូលរបស់ព្រះ ទើបព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងនោះ។ ដូចជាលទ្ធផលរបស់បំណងប្រាថ្នាសាច់ឈាមដែរ នោះសាតាំងនិងបំណងប្រាថ្នាសាច់ឈាមធ្វើការនៅក្នុងការទាំងនោះ។ យ៉ាងណាក៏ដោយ ប្រសិនបើពួកគេស្រឡាញ់ព្រះបន្ទូលរបស់ព្រះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការនៅក្នុងគាត់យ៉ាងជោគជ័យ។ យើងអាចរកឃើញការដ៏អស្ចារ្យដូចនេះនៅក្នុងជីវិតរបស់ដាវីឌ។

ទីពីរ គាត់មានអំណាររបស់ព្រះវិញ្ញាណ។ នៅពេលដែលហិបសញ្ញាបានមកដល់ក្រុងយេរូសាឡិម ទង្វើដែលដាវីឌបានរាំនៅចំពោះហ្វូងមនុស្ស បញ្ជាក់ពីសេចក្ដីពិតថាគាត់មានការបើកសម្ដែងមកពីព្រះវិញ្ញាណបរិសុទ្ធ ពីព្រោះព្រះវិញ្ញាណបានផ្ដល់អំណារដល់យើង។ ចម្រៀងរបស់ម៉ារា ចម្រៀងរបស់នាងហាណា ចម្រៀងរបស់ដេបូរ៉ា និងចម្រៀងរបស់មារៀមដើរតាមលំនាំតែមួយរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ចំណងជើងតែមួយនៃចម្រៀងរបស់ពួកគេ គឺផ្ដោតទៅលើមហិទ្ធិឫទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទសម្រាប់សេចក្ដីសង្គ្រោះរបស់រាស្ត្រទ្រង់។ នៅគ្រាចុងក្រោយនៃលោកិយនេះ ព្រះអម្ចាស់នឹងបង្ហាញពីភាពជាអម្ចាស់របស់ព្រះនៅក្នុងលោកិយនេះជាប្រាកដ។ យោងតាមទំនាយរបស់ហោរាអេសាយ បើទោះជាព្រះអម្ចាស់នឹងធ្វើឱ្យទន្លេនីលនៅអេស៊ីព្ទស្ងួតដោយសារអំពើបាបរបស់គេក៏ដោយ ជាចុងក្រោយទ្រង់នឹងស្ដារពួកគេឡើងវិញនៅក្នុងព្រះគ្រីស្ទ ធ្វើឱ្យពួកគេនិយាយភាសារបស់ពួកកាណាន ហើយបង្កើតដំណាក់របស់ព្រះនៅកណ្ដាលប្រទេសអេស៊ីព្ទដោយព្រះហស្ដរបស់ព្រះអម្ចាស់។ ហើយព្រះអម្ចាស់នឹងធ្វើឱ្យពួកគេហៅព្រះអម្ចាស់ថាជាព្រះអម្ចាស់របស់ពួកគេដោយអំណារ ដោយសារវាជាផ្នែកមួយរបស់ព្រះវិញ្ញាណបរិសុទ្ធ។

ទីបី ទ្រង់បានប្រទានពរដល់គ្រួសាររបស់ខ្លួននិងរាស្ត្ររបស់ខ្លួន។ ការអធិស្ឋានទាំបានប្រែក្លាយជាការអរព្រះគុណ។ បើទោះជាទ្រង់បានរងទុក្ខលំបាកដោយការឈឺចាប់ជាច្រើនក៏ដោយ តែទ្រង់បានប្រទានពរដល់ក្រុមគ្រួសារនិងរាស្ត្ររបស់ខ្លួនទៀត។ នៅក្នុងព្រះវិញ្ញាណបរិសុទ្ធ ការ

សម្រេចបំពេញពិតប្រាកដរបស់លោកុប្បត្តិ 12:3 ជាការចាក់បង្ហូរមកនូវព្រះវិញ្ញាណបរិសុទ្ធ (កាឡាទី 3:14)។

នេះជាសំណេរដែលនិយាយពីចំណងជើងដូចតទៅ 1) តួអង្គរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការគ្រប់គ្រងរបស់ស្តេចរបស់ស្តេចដាវីឌ 2) ព្រះពរដែលស្តេចដាវីឌចង់បាន ហើយ3) ការតាំងសញ្ញាអស់កល្បជានិច្ចនៅក្នុងជីវិតរបស់ទ្រង់ ដែលចង់យល់ពីអត្ថន័យនៃការស្តារឡើងវិញនូវរូបផ្លុះរបស់ព្រះនៅក្នុងកណ្ឌគម្ពីរទីពីររបស់សាំយ៉ូអែល។

## ក តួអង្គរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការគ្រប់គ្រងរបស់ស្តេចរបស់ស្តេចដាវីឌ

ជាដំបូង ការរំលឹកពីតួអង្គរបស់ព្រះវិញ្ញាណបរិសុទ្ធមានន័យបំផុតនៅក្នុងទស្សនៈនៃប្រវត្តិសាស្ត្រនៃការប្រោសលោះ ពីព្រោះយើងអាចឃើញរូបភាពទាំងមូលនៅក្នុងការបើកសម្តែង។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងនិក្ខមនំ ជាកិច្ចការតែមួយនៅក្នុងកណ្ឌគម្ពីរកិច្ចការ។ ហើយព្រះវិញ្ញាណនៅក្នុងការបង្កបង្កើត ដូចគ្នានឹងព្រះវិញ្ញាណនៃសេចក្តីប្រោសលោះ។ តើអ្វីទៅជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៃការគ្រប់គ្រងរបស់ស្តេចដាវីឌ?

### 1. ចូរគោរពដល់ព្រះវិញ្ញាណបរិសុទ្ធ (2 សាំយ៉ូអែល 1:1-16)

បុរសជនជាតិអាម៉ាលេកម្នាក់បាននាំយកមកុដនិងខ្សែដៃរបស់ស្តេចសូលមកឱ្យដាវីឌ ជាម្នាក់ដែលបានធ្លាក់ចុះទៅក្នុងសេចក្តីសោកសង្រេង យកមកជាភស្តុតាងនៃការស្លាប់របស់សូលដើម្បីទទួលបានរង្វាន់។ តើអ្វីទៅជាអាកប្បកិរិយារបស់ដាវីឌទៅកាន់ការរាយការណ៍មួយនេះ? តើសេចក្តីជំនឿដែលកោតខ្លាចរបស់គាត់ទៅចំពោះព្រះបានបង្ហាញមកដោយរបៀបណា?

ទីមួយ ទ្រង់បានបង្កើតសេចក្តីសុចរិតរបស់ព្រះអម្ចាស់ ដោយការសម្លាប់បុរសជនជាតិអាម៉ាលេកនោះ ពីព្រោះដាវីឌបានដឹងថា ការដែលមើលងាយដល់អ្នកដែលទទួលបានការចាក់

ប្រេងតាំង មានន័យថាជាការមើលងាយទៅដល់ព្រះ។ គាត់មិនបានទទួលស្គាល់សគុណពីមនុស្សដោយការសម្លាប់ស្តេចសូលនោះទេ តែស្តេចដាវីឌបានដាក់ទោសគាត់វិញ ដោយសារគាត់បានធ្វើការអាក្រក់ទាស់នឹងនគររបស់ព្រះ។ ដាវីឌមានចិត្តមួយយ៉ាងមុតមាំនៅក្នុងការស្វែងរកនគរនិងសេចក្តីសុចរិតរបស់ព្រះជាទីមួយ។

ទីពីរ ឥរិយាបថដែលគួរឱ្យគោរពទៅកាន់អ្នកដែលបានទទួលការចាក់ប្រេងតាំងជាការមួយដែលពិសេស។ ការសោកសង្រេងរបស់ដាវីឌលើការសុគតរបស់ស្តេចសូល បានបង្ហាញយ៉ាងច្បាស់ពីបំណងពិតរបស់ទ្រង់ដែលស្រឡាញ់អាណាចក្ររបស់ព្រះ។ សេចក្តីជំនឿនៃការកោតខ្លាចដល់ព្រះអម្ចាស់ នោះតែងតែដើរនៅលើផ្លូវនៃសេចក្តីពិត។ ការចាក់ប្រេងតាំងចង្អុលទៅកាន់ព្រះវិញ្ញាណបរិសុទ្ធ។ ការគោរពដល់ព្រះវិញ្ញាណបង្ហាញពីសេចក្តីជំនឿពិត។ យើងត្រូវតែទទួលកិច្ចការផ្ទាល់ខ្លួនរបស់ព្រះវិញ្ញាណហើយដើរតាមការដឹកនាំពិតរបស់ទ្រង់គ្រប់ពេលវេលានិងគ្រប់ទីកន្លែង។

**2.ចិត្តរបស់ស្តេចដាវីឌ(2សាំយ៉ូអែល1:17-26)**

ការទួញសោករបស់ស្តេចដាវីឌលើការស្លាប់របស់យ៉ូណាថាន និងសូល បញ្ជាក់ថាចិត្តរបស់ទ្រង់ដូចទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ តើអ្វីទៅដែលបង្ហាញនៅក្នុងចម្រៀងទុក្ខសោករបស់ទ្រង់?

ទីមួយ ទ្រង់បានបង្រៀនថាការត្រាស់ហៅរបស់ពួកគេជាការត្រាស់ហៅដ៏មានតម្លៃបំផុត (19-21)។ ព្រះអម្ចាស់បានត្រាស់ហៅពួកគេធ្វើជាអ្នកចម្បាំងរបស់ពួកអ៊ីស្រាអែល។ ការត្រាស់ហៅរបស់ព្រះជាពេលមួយយ៉ាងសំខាន់ទីមួយ ពីព្រោះទ្រង់បានគោរពដល់សិរីល្អរបស់អ៊ីស្រាអែល។

ទីពីរ ទ្រង់បានទទួលស្គាល់ថាអ៊ីស្រាអែលបានទទួលផលប្រយោជន៍ដោយសារការលះបង់របស់ពួកគេ (24)។ ទ្រង់បានយំសោកលើការស្លាប់របស់ពួកគេ ដោយចងចាំថានឹងនាំយកសេ

ចក្តីសុខសាន្តដល់អ៊ីស្រាអែល។
ទីបី ទ្រង់បានទទួលស្គាល់ថាកិច្ចការនៃការចាក់ប្រេងតាំងបានធ្វើការសម្រាប់ពួកគេ (21)។ ហេតុដែលទ្រង់បានគោរពដល់ការចាក់ប្រេងតាំង ជារបៀបដើម្បីនឹងយកឈ្នះនូវសាច់ឈាមដែលពុករលួយ។ ទ្រង់ប្រាកដថាគ្រប់ព្រះពរទាំងអស់ មានទ្រព្យសម្បត្តិ កិត្តិយស អំណាច និងជីវិតពេញបរិបូរអស់កល្បជានិច្ច នោះបានមកពីការចាក់ប្រេងតាំង។ យើងមិនបានទទួលបានចិត្តដែលភ័យខ្លាច ប៉ុន្តែជាចិត្តនៃសេចក្តីស្រឡាញ់ អំណាច និងស្មោះត្រង់ (2 ធីម៉ូថេ 1:7) ។ យើងគួរតែរក្សាចិត្តដូច្នេះនៅពេលដែលយើងទទួលចិត្តដែលមានការចាក់ប្រេងតាំង។

### 3. ទស្សនៈរបស់ដាវីឌលើព្រះពរ (2 សាំយ៉ូអែល 2:1-11)

តើអ្វីជាសេចក្តីជំនឿដែលកោតខ្លាចដល់ព្រះអម្ចាស់របស់ទ្រង់បានបង្ហាញមក?
ទីមួយ ទ្រង់បានចូលមកសួរព្រះអម្ចាស់គ្រប់យ៉ាងទាំងអស់ (1)។ ដាវីឌបានដើរជាមួយនឹងព្រះអម្ចាស់យ៉ាងសាមញ្ញ ដោយការស្តាប់បង្គាប់របស់កុលសម្ព័ន្ធយ៉ូដាទៅកាន់ការឆ្លើយតបរបស់ព្រះនិងការស្នាក់នៅហេប្រុន។ បន្ទាប់ពីស្តេចសូលបានសុគតហើយភ្លាមៗនោះ ស្តេចដាវីឌបានបោះចោលគ្រប់ការល្បួងដែលដោះស្រាយការគ្រប់យ៉ាងដោយចិត្តរបស់គាត់ ហើយបានដើរតាមបំណងព្រះហឫទ័យរបស់ព្រះដោយស្មោះត្រង់វិញ។ ការដេញតាមព្រះវិញ្ញាណបរិសុទ្ធជាវិធីយកឈ្នះលើការល្បួង។ អ្នកបរិសុទ្ធគួរតែដើរនៅក្នុងផ្លូវនេះនៅក្នុងជីវិតរបស់គេ។
ទីពីរ គាត់មានជំនឿដែលស្មោះត្រង់ដោយបានឱ្យរង្វាន់និងប្រទានពរដល់ យ៉ាបេស ហ្គីលៀត។ លើសពីនេះទៀត ទ្រង់បានស្វែងរកព្រះពរដែលបានផ្តោតលើព្រះគុណនិងសេចក្តីពិត។ ព្រះពរពិតគួរតែបង្ហាញដោយព្រះគុណនិងសេចក្តីពិត ដោយការដើរតាមការចាក់ប្រេងតាំង។ វាត្រូវបានសង្វេបមកដោយសេចក្តីស្រឡាញ់និងការយកគម្រូតាមរូបឆ្លុះរបស់ព្រះ។ ព្រះពរពិតចង្អុលទៅកាន់ការយកគម្រូតាមរូបឆ្លុះរបស់ព្រះ ហើយការផ្សេងទៀតគ្រាន់តែជាព្រះពរ

បន្ទាប់បន្សំប៉ុណ្ណោះ។ អ្នកបរិសុទ្ធគួរតែរីករាយនឹងព្រះពរទាំងអស់ដែលចេញមកពីព្រះគ្រីស្ទ (យ៉ូហាន 1:14)។

**4. ទស្សនៈរបស់មនុស្សដែលពិការ (2 សាំយ៉ូអែល 2:12-32)**

តាមរយៈការមើលពីការទាស់គ្នារវាងការគ្រប់គ្រងរបស់ស្តេចដាវីឌនិងស្តេចសូល តើយើងអាចរកឃើញថាទស្សនៈរបស់មនុស្សមានភាពល្ងីល្ងើបែបណា?

ទីមួយ សេចក្តីសុចរិតរបស់ព្រះនឹងត្រូវបានបង្កើតមកនៅក្នុងភាពច្របូកច្របល់។ ព្រះអម្ចាស់បានបង្កើតរាជ្យរបស់ស្តេចដាវីឌឱ្យទទួលបានជ័យជម្នះ។ ដូចដែលភាពជាស្តេចរបស់ព្រះយេស៊ូវត្រូវបានបង្ហាញមកនៅក្នុងភាពច្របូកច្របល់នៃព្យុះ នោះអាណាចក្រនឹងត្រូវបានបង្កើតមកជាប្រាកដនៅក្នុងការនោះ។

ទីពីរ តាមរយៈការឈ្លោះប្រកែកជាមួយគ្នា នោះសេចក្តីសុចរិតនិងសេចក្តីមេត្តានៃនគររបស់ព្រះត្រូវបានបង្ហាញមក។ អាសាហែលបានរត់ទៅសម្លាប់អាប់នើ ប៉ុន្តែគាត់បែជាត្រូវបានគេសម្លាប់វិញ។ នៅពេលដែលព្រះអម្ចាស់បានបញ្ឈប់ដៃរបស់ទ្រង់នៅក្នុងការដឹកនាំពួកគេ គេនឹងត្រូវវិនាសបើទោះជាគេមានជំនាញយ៉ាងពូកែឥតខ្ចោះក៏ដោយ។ អាណាចក្ររបស់ព្រះនឹងត្រូវបានបង្កើតមកដោយការស្តាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះដោយបន្ទាបខ្លួន
(សុភាសិត 3:5-6)។

**5.ចូរយកមីផែលមក(2សាំយ៉ូអែល3:1-16)**

សេចក្តីពិតដែលគោរពតាមលំដាប់លំដោយដែលបានបង្កើតនៃក្រុមគ្រួសារនៅតែមានជីវិតនៅក្នុងគ្រប់សម័យទាំងអស់។ ប្រសិនបើមនុស្សបដិសេធនឹងសេចក្តីពិតនេះ ព្រះអម្ចាស់នឹងដាក់ទោសពួកគេជាប្រាកដ។ តើអត្ថបទបង្ហាញសេចក្តីពិតដូចនេះមកកាន់យើងយ៉ាងដូចម្តេច?

ទីមួយ ពីព្រោះអែបនើបានធ្វើខុសដោយការកំផឹតជាមួយប្រពន្ធរបស់សូល នោះគាត់ត្រូវបានសម្លាប់ដោយយ៉ូអាប់ (27)។ បើទោះជាគាត់បានជួយបង្កើតរាជ្យរបស់ស្តេចដាវីឌឡើងក៏ដោយ អំពើបាបជាសេចក្តីលោភលន់របស់គាត់និងសេចក្តីកំផិតរបស់គាត់មិនត្រូវបានអត់ទោសពីព្រះនោះទេ។ ព្រះជាម្ចាស់ជាព្រះដែលមានសេចក្តីសុចរិតអស់កល្បជានិច្ច។

ទីពីរ ហេតុដែលគាត់ជួបសេចក្តីល្បួងជាច្រើន គឺដោយសារគាត់មានការប្រឆាំងនៅក្នុងជីវិតគ្រួសារ (1-5)។ វាជាអន្ទាក់មួយយ៉ាងខ្លាំងសម្រាប់គាត់មិនឱ្យដើរតាមគោលការណ៍នៃការបង្កបង្កើតយ អាពាហ៍ពិពាហ៍តែមួយ។ ដូច្នេះដាវីឌបានហៅមីឆែលមកកាន់គាត់វិញដោយអែបនើ បើទោះជាមីឆែលបានមើលងាយដល់សេចក្តីស្រឡាញ់ដ៏ធំរបស់នាងក៏ដោយ (13)។ សេចក្តីស្រឡាញ់ដំបូងរបស់យើងទៅកាន់ព្រះអម្ចាស់មិនអាចផ្លាស់ប្រែបានទេ។ ចូរយើងឆ្លើយតបទៅកាន់សេចក្តីស្រឡាញ់ដំបូង។

### 6. ដាវីឌជាអ្នកដែលស្អប់អំពើបាប (2 សាំយ៉ូអែល 3:17-39)

ដោយការនារទេសរបស់អែបនើចេញពីក្រុមគ្រួសាររបស់សូល បើទោះជារាជរបស់ស្តេចដាវីឌបានលូតលាស់ឡើងខ្លាំងក៏ដោយ បញ្ហាជាច្រើនបានកើតឡើងនៅក្នុងជាតិសាសន៍។ នៅពេលដែលយ៉ូអាប់បានសម្លាប់អែបនើដោយដោយអាក្រក់ បើទោះជាគាត់មិនមានអាវុធក៏ដោយ ក៏មានគ្រោះមួយទៀតបានធ្លាក់មកលើការគ្រងរាជ្យរបស់ស្តេច។ តើស្តេចដាវីឌឆ្លើយតបទៅនឹងបញ្ហាទាំងនោះដោយរបៀបណា?

ទីមួយ ទ្រង់បានស្អប់ដល់អំពើបាប ទ្រង់បានស្តីបន្ទោសដល់យ៉ូអាប់យ៉ាងខ្លាំង (28-29, 39)។

ទីពីរ ទ្រង់បានដេញតាមសេចក្តីសុចរិតរបស់នគររបស់ព្រះ។ ទ្រង់ផ្ទាល់បានទួញសោកលើការស្លាប់របស់អែបនើ ហើយបានធ្វើបុណ្យសព្វឱ្យផងដែរ។ បំណងរបស់ស្តេចដាវីឌទៅកាន់ព្រឹត្តិការណ៍ទាំងពីរនេះ៖ ការស្លាប់របស់សូលនិងការស្លាប់របស់អែបនើ បញ្ជាក់ពីគោលបំណងចម្បងដើម្បីបង្កើតអាណាចក្ររបស់ព្រះ ដោយការត្រឡប់បំណងរបស់ប្រជារាស្ត្រទៅ

ក្នុងសេចក្តីច្របូកច្របល់ (36)។ ដាវីឌពិតជាបានស្វែងរកទីមួយនូវនគរនិងសេចក្តីសុចរិតរបស់ព្រះ។ ស្តេចដាវីឌនៅក្នុងសញ្ញាចាស់ មិនបានផ្តោតទៅលើការបង្កើតអាណាចក្ររបស់ខ្លួនផ្ទាល់ តែដើម្បីនឹងបង្កើតអាណាចក្រដែលនៅអស់កល្បនៅលើផែនដីវិញ។ មានតែព្រះគ្រីស្ទទេដែលអាចបង្កើតអាណាចក្រនោះបាន។ យើងគួរតែដើរតាមសេចក្តីសុចរិតរបស់ព្រះ ដោយការចាកចេញពីគ្រប់ទម្រង់របស់អំពើបាប។

**7. ខ្លឹមនៃសេចក្តីជំនឿដែលមានសេចក្តីកោតខ្លាច (2 សាំយ៉ូអែល 4:1-12)**

យើងមើលឃើញសេចក្តីជំនឿដែលមានការកោតខ្លាចរបស់ដាវីឌ ដោយសារអាកប្បកិរិយារបស់ទ្រង់ទៅកាន់មនុស្សពីរនាក់ដែលបាននាំយកក្បាលរបស់ស្តេចសូលនិងអ៊ីសបូសេតមក។

ទីមួយ ទ្រង់បានគោរពដល់ការចាក់ប្រេងតាំងរបស់សូល (11)។ ការចាក់ប្រេងតាំងដែលចង្អុលទៅកាន់ដំណែងពីររបស់សញ្ញាចាស់ (ស្តេច ហោរា និងសង្ឃ) មានន័យថាព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ចិត្តដែលបន្ទាបចុះនៃការស្តាប់បង្គាប់ជាទម្រង់នៃសេចក្តីជំនឿដែលមានការកោតខ្លាច។

ទីពីរ ទ្រង់ស្រឡាញ់សេចក្តីសុចរិតរបស់ព្រះអម្ចាស់។ សេចក្តីជំនឿដែលមានការកោតខ្លាចដោយស្មោះអាចបង្កើតសេចក្តីសុចរិត ដោយការដើរតាមព្រះវិញ្ញាណបរិសុទ្ធ ពីព្រោះទ្រង់បានឃើញភាពពិតនៃអាណាចក្ររបស់ព្រះ។ ការដេញតាមព្រះវិញ្ញាណបរិសុទ្ធ និងការស្វែងរកសេចក្តីសុចរិតជាព្រះពរមួយ រាប់បញ្ចូលទាំងការលំបាករបស់យើងនៅក្នុងវិបត្តិទាំងអស់។ នៅពេលដែលយើងថ្វាយខ្លួនយើងទៅដល់ព្រះអម្ចាស់ ទ្រង់នឹងត្រូវបានដំកើងឡើង។ ចូរយើងរក្សាសេចក្តីគោរពកោតខ្លាចដល់ព្រះពិតប្រាកដដែលព្រះទ្រង់ទទួល។

**8.កិច្ចការដែលព្រះទ្រង់សម្រេចបំពេញ(2សាំយ៉ូអែល5:1-10)**

បើទោះជាសេចក្តីស្មោះត្រង់របស់ព្រះបានបង្ហាញមកដោយការធ្វើជាស្តេចក៏ដោយ តែវាជាបល្ល័ង្កនៃសភាពដែលភ្លាមៗ។ តើជាមូលហេតុអ្វី?

ទីមួយ គោលបំណងរបស់ដាវីឌ មិនធ្វើជាស្តេចរបស់អ៊ីស្រាអែលទេ ប៉ុន្តែដើម្បីបង្កើតអាណាចក្ររបស់ព្រះវិញ។ និយាយម្យ៉ាងទៀតថា ទ្រង់ចង់រីករាយនឹងសិរីល្អរបស់ព្រះគ្រីស្ទដែលជាប្រភពនៃជ័យជម្នះពិតប្រាកដ។ ការរីករាយនឹងសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទ ត្រូវតែជាព្រះពរដ៏ពិត។ ការយកគម្រូតាមព្រះបន្ទូលរបស់ព្រះជាព្រះពរដ៏ពិត ដូចអ្នកសរសេរទំនុកដំកើងបានសារភាពថា "មានតែព្រះជាម្ចាស់ទេដែលជាព្រះពរដល់ខ្ញុំ"។

ទីពីរ ព្រះអម្ចាស់ដែលទ្រង់ចម្រើនកម្លាំងដល់កិច្ចការរបស់ស្តេចដាវីឌ ទ្រង់បានធ្វើការជាបន្តបន្ទាប់ដោយព្រះអេម៉ាញូអែល និងទទួលបានព្រះពរទ្វេរទាំងអស់។ ការនៅជាមួយនឹងព្រះអម្ចាស់ធ្វើឱ្យយើងកាន់តែខ្លាំងថែមទៀត។ នៅក្នុងដំណាក់កាលនៃសេចក្តីសង្គ្រោះរបស់គ្រីស្ទាននេះ ដែលមាន ការរាប់ជាសុចរិត ការបន្សុត ការលើកដំកើង នោះព្រះអម្ចាស់បានផ្តល់ព្រះពរលើអស់ទាំងព្រះពរមក (រ៉ូម 8:29-30)។ ចូរយើងរីករាយនឹងព្រះពររបស់ព្រះអេម៉ាញូអែលដែលជាអ្នកចូលរួមនៅក្នុងព្រះពរនេះ។

**9.ព្រះគ្រីស្ទជាស្តេច(2សាំយ៉ូអែល5:11-25)**

ស្តេចដាវីឌដែលត្រូវបានស្គាល់ថាជាស្តេចដែលបង្រួបបង្រួមពួកអ៊ីស្រាអែល ដោយបានផ្លាស់រាជធានីមកយេរូសាឡិមវិញ ដែលមិនទាន់មានស្ថេរភាពនៅក្នុងជាតិសាសន៍របស់ទ្រង់នៅឡើយ។ បើទោះជាដាវីឌមានកូន11នាក់ជាមួយនឹងប្រពន្ធនិងស្នំរបស់ទ្រង់ក៏ដោយ តែទ្រង់បានស្គាល់ពីផ្លូវរបស់ស្តេចយ៉ាងច្បាស់។ វាជាការស្តាប់បង្គាប់ទៅកាន់ព្រះអម្ចាស់។ ទ្រង់បានស្តាប់បង្គាប់ព្រះអម្ចាស់ដោយបានសួរគ្រប់យ៉ាងទៅកាន់ព្រះ។ តើយើងរកឃើញអ្វីនៅទីនេះ?

ទីមួយ ព្រះអម្ចាស់នៅតែជាស្តេច។ ទ្រង់ផ្ទាល់ជាអ្នកគ្រប់គ្រងលើពួកអ៊ីស្រាអែល ប៉ុន្តែទ្រង់

បានសម្រេចគោលបំណងរបស់ទ្រង់ដោយស្ដេចជាមនុស្ស។ មានតែទ្រង់ទេដែលជាអ្នកចម្បាំង ដែលវាយទាស់នឹងសត្រូវ។

ទីពីរ ព្រះគ្រីស្ទជាស្ដេច។ នៅក្នុងទំនុកដំកើងរបស់ស្ដេចដាវីឌ យើងអាចរកឃើញថាគោលបំណងដែលទ្រង់ច្រៀងថាជាថ្មដា ជាបន្ទាយ ជាទីជ្រកកោន ជាអំណាចរបស់ទ្រង់ និងជាប៉មរបស់ទ្រង់ នោះជាព្រះគ្រីស្ទនៅក្នុងសញ្ញាថ្មី។ ទ្រង់ប្រាកដថាមានតែស្ដេចមួយអង្គគត់ជាព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់នឹងយាងមកក្នុងផែនដី។ មានតែព្រះគ្រីស្ទទេដែលជាស្ដេច ប៉ុន្តែអ្នកបរិសុទ្ធជាអ្នកបម្រើរបស់ទ្រង់។ មានតែព្រះគ្រីស្ទទេជាអ្នកសម្រេចសេចក្ដីសង្គ្រោះរបស់ទ្រង់ដោយសារឈើឆ្កាងរបស់ទ្រង់ ប៉ុន្តែយើងត្រូវបានសង្គ្រោះចេញពីអំពើបាបដ៏អាក្រក់ដោយការជឿដល់ទ្រង់។

**10. ការស្លាប់របស់អ៊ូសា (2 សាំយ៉ូអែល 6:1-11)**

អាណាចក្ររបស់ព្រះតាមរយៈការគ្រប់គ្រងរបស់ស្ដេចដែលបង្រួបបង្រួមរបស់ស្ដេចដាវីឌត្រូវបានរៀបចំ ដោយការនាំយកហិបសញ្ញាទៅកាន់ក្រុងយេរូសាឡិម។ នៅក្នុងដំណាក់កាលនោះតើការស្លាប់របស់អ៊ូសាមានន័យយ៉ាងណា?

ទីមួយ ស្ដេចដាវីឌភ័យខ្លាចចំពោះព្រះអម្ចាស់ ពីព្រោះអ៊ូសាបានស្លាប់ដោយបានប៉ះហិបសញ្ញាដោយផ្ទាល់ដោយមានចេតនា។ កាលដែលគាត់បានកើតមកនៅក្នុងគ្រួសារជាសង្ឃនោះគាត់បានរៀនហើយស្គាល់ពីវិធីសាស្រ្តនៅក្នុងការដឹកជញ្ជូនហិបសញ្ញារបស់ព្រះអម្ចាស់បានយ៉ាងល្អ។ ដូច្នេះទង្វើរបស់គាត់ជាទង្វើមួយដែលមានចេតនានៅក្នុងជីវិតរបស់គាត់។ ប្រសិនបើគាត់ទទួលបានការដាក់ទោសមកពីព្រះដោយការប្រព្រឹត្តខុសនៅក្នុងព្រះវិហារ ជារោងឧបោសថ និងហិបសញ្ញា ដែលជាសញ្ញានៃបល្ល័ង្ករបស់ព្រះ តើទង្វើដែលខុសឆ្គងទៅកាន់ព្រះគម្ពីរ ព្រះវិញ្ញាណបរិសុទ្ធ ដំណឹងល្អ និងការថ្វាយបង្គំមានកំហុសធ្ងន់ប៉ុណ្ណា? ក្រុមជំនុំកូរិនថូសត្រូវបានដាក់ទោសដោយព្រះអម្ចាស់ ពីព្រោះដោយសារការដែលពួកគេធ្វើពិធី

លៀងព្រះអម្ចាស់ ដែលទទួលបានការធ្លាក់ខ្សោយ ជម្ងឺ និងការស្លាប់ (1 កូរិនថូស 11:30)។ ទីពីរ ព្រះពរដែលមកលើអូបិតអេដុមបានផ្ទុយពីបណ្តាសារបស់អ៊ូសា។ ព្រះពររបស់ព្រះអម្ចាស់មកដល់អ្នកគ្រប់គ្នាដែលស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលជាគ្រឹះនៃគ្រប់អស់ទាំងព្រះពរ។ ព្រះគុណចាប់ផ្តើមជាមួយបំណងប្រាថ្នាដែលឆេះឆួល ហើយដែលសំខាន់ជាងនេះទៅទៀតនោះ ព្រះគុណនឹងត្រូវបានបានបន្ថែមមកដោយការស្តាប់បង្គាប់។

### 11. ការប្រារព្ធពិធីថ្វាយបង្គំ (2 សាំយ៉ូអែល 6:12-23)

ខ 21 មានបន្ទូលថា "តែដាវីឌមានបន្ទូលតបថា នោះគឺនៅចំពោះព្រះយេហូវ៉ាទេ ជាព្រះដែលបានរើសអញជាជាងបិតាឯង និងវង្សានុវង្សរបស់ឯងទាំងអស់គ្នាដែរ ដើម្បីនឹងតាំងអញឡើងជាស្តេចលើសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ព្រះយេហូវ៉ា ហេតុដូច្នេះបានជាអញនឹងលេងសប្បាយនៅចំពោះព្រះយេហូវ៉ា។" (2 សាំយ៉ូអែល 6:21)។ អត្ថបទនេះចង្អុលទៅកាន់លក្ខណៈពិសេសនៃការថ្វាយបង្គំ។ ដាវីឌជាអ្នកដែលបានឃើញថាហិបសញ្ញាបានចូលមកដល់ក្រុងយេរូសាឡិម ទ្រង់បានរាំដោយអំណរ ពីព្រោះទ្រង់បានយល់ពីអត្ថន័យពិតប្រាកដនៃការថ្វាយបង្គំ។ ដូច្នេះការថ្វាយបង្គំរបស់ស្តេចដាវីឌត្រូវបានថ្វាយទៅកាន់ព្រះ បើទោះជាគាត់ហាក់បីដូចជាទទួលបានការសើចចំអកពីមនុស្សក៏ដោយ ហើយមីកែលបានទទួលបានការដាក់ទោសមកពីព្រះ (23)។ ជាការធម្មតាទេនៅក្នុងការបង្ហាញពីធាតុនៃអំណរនៅក្នុងការថ្វាយបង្គំដោយវិញ្ញាណនិងការថ្វាយបង្គំពិត។ ការថ្វាយបង្គំពិតរាប់បញ្ចូលទាំងការថ្វាយបង្គំដោយលត់ជង្គង់ចុះនៅចំពោះព្រះ និងពិធីសរសើរដំកើងនិងរាំកញ្ឆេញដូចជាការឆ្លើយតបខាងអារម្មណ៍ដោយចេញពីការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ លើសពីនេះទៀត ការធ្វើនូវសេចក្តីសប្បុរសនិងការធ្វើទាន គួរតែដើរតាមការទាំងនេះនៅក្នុងជីវិតរបស់ពួកគេ (ហេព្រើរ 13:16)។ ការធ្វើកម្មវិធីដោយគ្មានការថ្វាយបង្គំហាក់ដូចជាទង្វើរបស់អ៊ូសាដែរ។ ការថ្វាយបង្គំមិនមែនអាចរៀនបានដោយការធ្វើកម្មវិធីឡើយ តែដោយការថ្វាយបង្គំវិញ ដូចជា

មានដើមឈើហើយទើបមានផលផ្លែតាមក្រោយ។

**ខ. ព្រះពរដែលស្តេចដាវីឌចង់បាន (2 សាំយ៉ូអែល 7:1-29)**

ខ 27 បង្ហាញថាសេចក្តីជំនឿរបស់ដាវីឌបានបង្ហាញពីការចង់ចាំរបស់ទ្រង់ពីព្រះគុណរបស់ព្រះ ដែលទ្រង់បានអនុញ្ញាតមកដល់ទ្រង់ ដោយការអរគុណដល់ព្រះនិងការថ្វាយបង្គំទ្រង់ដោយអំណរ។ តើវាជាអ្វីទៅ?

ទីមួយ ទ្រង់ចង់សង់ព្រះវិហាររបស់ព្រះអម្ចាស់ដោយប្រៀបធៀបដំណាក់តង់របស់ព្រះទៅនឹងវាំងរបស់ខ្លួនដែលត្រូវបានសង់ដោយឈើគគី។ ទ្រង់បានដឹងជាប្រាកដថាមានតែព្រះអម្ចាស់ទេដែលជាស្តេច ហើយរាស្ត្ររបស់ទ្រង់គួរតែរស់នៅដោយការស្តាប់បង្គាប់បន្ទូលរបស់ទ្រង់។ ព្រះអម្ចាស់ទ្រង់បានសព្វព្រះហឫទ័យ។

ទីពីរ ទ្រង់គួរតែស្វែងរកព្រះពរដែលនៅអស់កល្បជានិច្ច ដែលសំដៅលើសេចក្តីសង្គ្រោះនៃការយាងមករបស់ព្រះគ្រីស្ទនៅពេលអនាគត។ ទ្រង់មិនបានស្វែងរកឱ្យបានតែព្រះពរឱ្យបានតែគ្រួសារ ឬប្រជាជាតិមួយឡើយ តែជាព្រះពរដែលនឹងចេញទៅដល់គ្រប់ជាតិសាសន៍ទាំងអស់វិញ (លោកុប្បត្តិ 12:3)។ ស្តេចដាវីឌបានភ្លក់ភាពបរិបូរណ៍នៃសេចក្តីសង្គ្រោះនៅក្នុងព្រះគ្រីស្ទ។ សាវ័កប៉ូលបានប្រកាសថា ក្រុមជំនុំនៅក្នុងព្រះគ្រីស្ទត្រូវបានទទួលជាមួយព្រះពរ (អេភេសូ 1:3)។ យើងដែលទទួលបានព្រះពរដូចគ្នាគួរតែរីករាយនឹងព្រះពរនៅក្នុងព្រះគ្រីស្ទយេស៊ូវដែរ។

**1.និម្មិតរបស់ស្តេចដាវីឌ (2សាំយ៉ូអែល8:1-18)**

នៅក្នុងអត្ថបទ យើងរកឃើញពីនិម្មិតរបស់ស្តេចដាវីឌ។

ទីមួយ ទ្រង់បានរស់នៅដោយខ្លួនឯងយ៉ាងស្មោះត្រង់។ ស្តេចដាវីឌបានថ្វាយខ្លួនរបស់ទ្រង់ទៅកាន់ដែលនៅខាងក្នុងនិងខាងក្រៅ ដើម្បីរៀបចំចាត់ចែងប្រជាជាតិឱ្យបានល្អ។ ការងារ

សត្រូវខាងក្រៅរបស់ដែលចេញមកពីព្រះ។ គ្រប់ជ័យជម្នះជារបស់ខ្ញុំនៅក្នុងដំណឹងល្អរបស់ព្រះគ្រីស្ទ។ គ្រប់កន្លែងដែលខ្ញុំស្នាក់នៅ និងគ្រប់កន្លែងដែលខ្ញុំដើរទៅនឹងក្លាយជារបស់ខ្ញុំពិតនៅក្នុងព្រះគ្រីស្ទ។ មានតែព្រះទេដែលអាចកាន់កាប់គ្រប់ការទាំងអស់ដោយចេស្តានៃអេម៉ាញូអែល។

ទីពីរ ស្តេចដាវីឌបានរៀបចំប្រជាជាតិ ប៉ុន្តែទ្រង់ក៏បានបង្កើតសេចក្តីយុត្តិធម៌នៃអាណាចក្ររបស់ព្រះផងដែរ (ម៉ាថាយ 6:33)។ បន្ទាប់ពីទ្រង់បានគ្រប់គ្រងលើសត្រូវមក ទ្រង់បានបង្កើតអាណាចក្ររបស់ព្រះហើយបានផ្តោតលើអាណាចក្ររបស់ព្រះដើម្បីថ្វាយសិរីល្អដល់ព្រះអម្ចាស់។ គ្រីស្ទានគួរតែបង្កើតសេចក្តីសុចរិតរបស់ព្រះនៅក្នុងជីវិតដែលសេសសល់របស់ខ្លួនបន្ទាប់ពីគេទទួលបានសេចក្តីសង្គ្រោះចេញពីបាបរបស់គេ។ គ្រប់ពេល គ្រប់កន្លែង គេគួរតែដើរតាមនគរនិងសេចក្តីសុចរិតជានិច្ច(ម៉ាថាយ6:33)។

**2. សេចក្តីសុចរិតនៃនគររបស់ព្រះ (2 សាំយ៉ូអែល 9:1-13)**

អត្ថបទក៏បង្ហាញថា ស្តេចដាវីឌបានបង្កើតសេចក្តីសុចរិតនៃនគររបស់ព្រះដែរ។

ទីមួយ វាត្រូវបានបង្ហាញមកតាមរយៈចិត្តអាណិតអាសូរនិងចិត្តមេត្តា។ ការអាណិតអាសូរដរបស់ដាវីឌទៅកាន់មេភីបូសេត ជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់ជាព្រះវិញ្ញាណរបស់ព្រះអម្ចាស់។ វាជារូបភាពនៃសេចក្តីស្រឡាញ់និងការថើបនៃសេចក្តីសុចរិត។ ឥរិយាបថពេញដោយសេចក្តីមេត្តារបស់ទ្រង់ដែលបានអនុញ្ញាតឱ្យចៅរបស់សត្រូវរបស់ទ្រង់មកអង្គុយនៅតុរបស់ទ្រង់ ការនេះបានរំលឹកយើងពីព្រះគុណរបស់ព្រះគ្រីស្ទ។ ប្រសិនបើខ្ញុំបើកទ្វារចិត្តរបស់ខ្ញុំបន្ទាប់ពីបានឮសម្លេងរបស់ទ្រង់ នោះទ្រង់នឹងចូលមកក្នុងចិត្តរបស់ខ្ញុំ ហើយហូបនៅតុជប់លៀងយ៉ាងរីករាយជាមួយគ្នា (វិវរណៈ 3:20)។ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ យើងគួរតែខិតចូលបល្ល័ង្កនេះដើម្បីនឹងរីករាយជាមួយសេចក្តីស្រឡាញ់និងសេចក្តីពិត។

ទីពីរ បំណងដែលមុតមាំរបស់ទ្រង់នៅក្នុងការបង្កើតសេចក្តីសុចរិតមិនដែលផ្លាស់ប្រែឡើយ។

ស្ដេចដាវីឌបានប្ដេជ្ញាខ្លួនរបស់ទ្រង់ដើម្បីនឹងបង្កើតនិងសេចក្ដីសុចរិតនិងយុត្តិធម៌នៅចំពោះព្រះជានិច្ច។ គ្រីស្ទានដែលទទួលបានសេចក្ដីសង្គ្រោះគួរតែផ្ដោតលើការបង្កើតផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះព្រះវិញ្ញាណបានមកកាន់យើង ហើយបានផ្ដល់ព្រះបន្ទូលរបស់ព្រះជានំប៉័ងខាងវិញ្ញាណរបស់យើង (ម៉ាថាយ 4:4, ចោទិយកថា8:3)។

**3.វិធីសាស្ត្ររបស់ស្ដេចដាវីឌ(2សាំយ៉ូអែល10:1-19)**

តើស្ដេចដាវីឌបានយកឈ្នះល្បិចកលរបស់សត្រូវរបស់ទ្រង់ដោយរបៀបណា?

ទីមួយ ទ្រង់មិនត្រូវបានគ្រប់គ្រងដោយល្បិចកលរបស់សត្រូវទ្រង់នោះឡើយ។ ការកាត់ពុកចង្ការបស់ពួកគេនិងឆូតបបូរមាត់របស់ពួកគេ ជាការដែលប្រាប់ដល់គេឱ្យដឹងថាជាការប្រកាសសង្គ្រាមទាស់នឹងពួកគេ។ ទង្វើដ៏អាក្រក់របស់អាម៉ុនដែលបានឆ្លើយតបទៅនឹងព្រះគុណដោយគួរឱ្យអាម៉ាស់ ដែលធ្វើឱ្យស្ដេចដាវីឌសេចក្ដីសុចរិតរបស់ព្រះ។ នៅពេលដែលអ្នកជឿធ្វើសេចក្ដីសប្បុរសទៅកាន់លោកិយ នោះពួកគេនឹងរំពឹងចង់បានការដែលល្អតបស្នងហើយ។ ប៉ុន្តែការបៀតបៀនដោយគ្មានហេតុផលបានសងមកយើងវិញនោះ យើងត្រូវតែរក្សានៅក្នុងបន្ទាត់នៃសេចក្ដីសុចរិត។

ទីពីរ ទ្រង់បង្ហាញពីការការពារខ្លួនឯងនដើម្បីបង្កើតសេចក្ដីសុចរិត។ មុនពេលដែលពួកគេធ្វើការវាយប្រហារដោយគ្មានហេតុផល ការដើរតាមសេចក្ដីសុចរិតពិបាកណាស់។ ប៉ុន្តែនៅក្នុងចំណោមការច្របូកច្របល់បែបនេះ នោះយើងអាចត្រូវបានដឹកនាំឱ្យទាសចេញពីផ្លូវសុចរិតបាន។ ចូរយើងស្វែងប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ។

**4. របៀបនៃការស្ដារឡើងវិញ (2 សាំយ៉ូអែល 12:1-14)**

សេចក្ដីល្បួងតែងតែលាក់ខ្លួននៅក្នុងផ្លូវរបស់ពួកបរិសុទ្ធជានិច្ច។ តើដាវីឌបានស្ដារឡើងវីញដោយរបៀបណានៅក្នុងសេចក្ដីពុករលួយ?

ទីមួយ សេចក្តីល្បួងបានចូលមកកាន់យើងយ៉ាងខ្លាំងថែមទៀតនៅក្នុងកាលដែលមានជ័យជម្នះ ជាជាងពេលដែលមានទុក្ខវេទនាដ៏គ្រោះថ្នាក់ទៅទៀត។ នៅពេលដែលទ្រង់បានឃើញបាតសេបាកំពុងងូតទឹក បំណងប្រាថ្នារបស់ទ្រង់បានឆេះឆួលឡើងនៅក្នុងចិត្តរបស់ទ្រង់។ បើទោះជាគាត់បានលាក់អំពើបាបរបស់ទ្រង់នៅចំពោះព្រះដោយប្រើភាពជាស្តេចរបស់ទ្រង់ក៏ដោយ រូបភាពនៃសេចក្តីគោរពកោតខ្លាចដល់ព្រះនិងវិធីសាស្ត្រទូទៅ នោះព្រះអម្ចាស់បានបង្ហាញនូវអំពើបាបដ៏អាក្រក់របស់ទ្រង់មក។

ទីពីរ ទ្រង់ត្រូវបានព្រះទ្រង់អត់ទោសបាបឱ្យ នៅពេលដែលទ្រង់បានស្តាប់ទៅកាន់សម្លេងស្តីបន្ទោសរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយទ្រង់បានលន់តួបាបរបស់ទ្រង់ភ្លាម។ នៅក្នុងកាលដែលធ្វើបាប នោះព្រះអម្ចាស់បានផ្តល់សេចក្តីមេត្តាយ៉ាងអស្ចារ្យទៅកាន់ដាវីឌ ហើយបានស្តីបន្ទោសទ្រង់ជាមួយការស្តីបន្ទោសយ៉ាងខ្លាំងតាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ យោងតាមសេចក្តីវេទនារបស់ទ្រង់ខាងវិញ្ញាណនិងការសារភាពរបស់ទ្រង់ នោះព្រះអម្ចាស់បានបង្ហាញសភាពដ៏វេទនារបស់ទ្រង់ដោយមានសេចក្តីកោតខ្លាចទៅចំពោះព្រះអម្ចាស់ មានអារម្មណ៍ថាមានបន្ទុកនិងការបែកបាក់នៅក្នុងខ្លួនរបស់ទ្រង់តាមរយៈការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះស្តេចដាវីឌអាចលន់តួបាបភ្លាមៗនៅពេលដែលទ្រង់ទទួលបានការស្តីបន្ទោសពីហោរាណាថាន។ ប្រសិទ្ធិភាពរបស់ឈើឆ្កាងបានធ្វើឱ្យទ្រង់ចូលទៅដល់ការអត់ទោសពិតនៅពេលដែលទ្រង់បានលន់តួបាបទៅកាន់ព្រះ (1 យ៉ូហាន 1:9)។ ការលន់តួបាបពិតប្រាកដនឹងមាននៅចំពោះព្រះ។

**5.ប្រាជ្ញាដែលប្រើសេចក្តីសប្បុរសចេញពីការអាក្រក់(2សាំយ៉ូអែល15:1-37)**

ប្រាជ្ញាដែលបានផ្លាស់ប្រែមនុស្សទុច្ចរិត (12)ចេញមកពីចិត្តនៃការកោតខ្លាចដល់ព្រះអម្ចាស់។ ពីដើមដែលយ៉ូសែបមានការបៀតបៀនបែបនេះនៅក្នុងជីវិតរបស់គាត់ ហើយការបៀតបៀននេះបានកើតឡើងដល់ដាវីឌម្តងទៀត។ ទ្រង់អាចស្តាប់ទៅកាន់សម្លេងរបស់ព្រះនៅក្នុងប

ណ្តាសារបស់ស៊ីមីទៅកាន់ទ្រង់ដែលទ្រង់បានរត់គេចខ្លួនហើយបានលាក់ខ្លួនទាំងគិតពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ (2 សាំយ៉ូអែល 16:5-14).

ទីមួយ ទ្រង់បានដឹងថាព្រះអម្ចាស់កំពុងទតមើលមកទ្រង់។ ទ្រង់ជឿថាព្រះអម្ចាស់អនុញ្ញាតការចំអកមកដើម្បីបង្វឹកដល់ទ្រង់។ ដូច្នេះទ្រង់អាចយកឈ្នះសេចក្តីល្បួងពីអ្នកដែលដើរតាមទ្រង់ដែលបានជម្រុញទ្រង់ឱ្យសម្លាប់ស៊ីមីដោយបានជេរទ្រង់។ ពីព្រោះដាវីឌអាចមើលឃើញព្រះហស្តដ៏កំបាំងរបស់ព្រះ នោះទ្រង់អាចយកឈ្នះបំណងប្រាថ្នាខាងសាច់ឈាម។ អ្នកដែលមើលឃើញថាព្រះអម្ចាស់បានសងថ្លៃបាបរបស់គេ នោះនឹងបន្តនៅក្នុងទីដែលលន់តួបាបហើយគេក៏ឃើញបល្ល័ង្កនៃព្រះហស្តដែលព្យាបាលរបស់ព្រះដែរ ពីព្រោះគាត់អាចមើលឃើញថាព្រះទ្រង់ស្គាល់ពីទុក្ខលំបាករបស់គេ ហើយគេអាចស្តារឡើងវិញទៅកាន់ថ្ងៃនៃការចម្រុងចម្រើនវិញដោយសារព្រះអម្ចាស់។ បើទោះជាទ្រង់ស្គាល់ពីការស្តារឡើងវិញនៃសេចក្តីស្រឡាញ់ តែស្តេចដាវីឌមិនបាននិយាយដោយសេចក្តីឆ្មើងឆ្មៃឡើយ ប៉ុន្តែដោយការបន្ទាបខ្លួនជាមួយសេចក្តីកោតខ្លាចនិងសេចក្តីស្រឡាញ់ដល់ព្រះអម្ចាស់វិញ។

**6. ទីជ្រកកោន (2 សាំយ៉ូអែល 17:1-14)**

បើទោះជាល្បិចកលយ៉ាងទុច្ចរិតត្រូវបានបង្ហាញមកគ្រប់គ្រងលើលោកិយនេះក៏ដោយ តែសេចក្តីសុចរិតរបស់ព្រះអាចបង្កើតនៅអស់កល្បនៅក្នុងផែនដី។ បើទោះជាការបះបោររបស់អាប់សាឡុមនិងល្បិចដ៏អាក្រក់របស់អាហីថូផែលហាក់ដូចជាបំផ្លាញដល់ស្តេចដាវីឌក៏ដោយ ប៉ុន្តែព្រះអម្ចាស់បានធ្វើការនៅក្នុងការនោះ។ ទង្វើរបស់អាប់សាឡុមដែលបានជ្រើសរើសយកល្បិចកលរបស់ហ៊ូសាយហើយបានបដិសេធល្បិចកលរបស់អាហីថូផែល នោះជាព្រះហស្តរបស់ព្រះអម្ចាស់ជាអ្នកកំណត់ (14)។ របៀបដែលមានហេតុផលមិនមែនជាផ្លូវតែមួយដើម្បីនឹងដោះស្រាយគ្រប់បញ្ហានោះទេ។ មានតែព្រះអម្ចាស់ទេដែលទ្រង់បង្កើតការណានោះការនោះនឹងមានការចម្រុងចម្រើនឡើង។ ប្រសិនបើព្រះអម្ចាស់មិនសង់ផ្ទះនោះទេ វានឹងនៅទទេ

រ ហើយប្រសិនបើព្រះអម្ចាស់មិនការពារផ្ទះនោះទេ អ្នកយាមដែលភ្ញាក់ដឹងខ្លួនក៏មិនមានប្រយោជន៍ដែរ។ នៅក្នុងចំណោមនៃការលំបាកសព្វថ្ងៃ យើងគួរតែកាន់ខ្ជាប់ទៅនឹងព្រះហឫទ័យរបស់ព្រះជាចម្បង។ គោលការណ៍នៃការស្វែងរកនគរនិងសេចក្តីសុចរិតរបស់ព្រះជាទីមួយ ហើយគ្រប់យ៉ាងនឹងត្រូវបានផ្តល់មក ដោយព្រះអម្ចាស់ទ្រង់នៅតែដដែល។ ចេញពីការតូចតាច នោះយើងអាចទុកចិត្តទ្រង់ហើយរីករាយនឹងព្រះគុណរបស់ទ្រង់បាន។

**7.រូបភាពពិតនៃព្រះពររបស់អ្នកជឿ(2សាំយ៉ូអែល22:1-20)**

នៅក្នុងអត្ថបទនេះបង្ហាញភស្តុតាងថា ស្តេចដាវីឌបានមើលឃើញព្រះមេស៊ី ដែលទ្រង់នឹងយាងមកនៅពេលអនាគត ហើយទ្រង់បានជឿដល់ទ្រង់ជាព្រះសង្គ្រោះតែមួយនៅឆ្នាំ 1200 មុនគ.ស។

ទីមួយ ទ្រង់មានសេចក្តីជំនឿដូចគ្នានៃការកោតខ្លាចដល់ព្រះអម្ចាស់ដូចដែលអ័ប្រាហាំនិងប៉ូលមាន។ នៅទីនេះ ថ្មដា បន្ទាយ និងទីជ្រកកោនរបស់ខ្ញុំមានតែនៅក្នុងព្រះយេស៊ូវតែមួយប៉ុណ្ណោះ។ ទ្រង់បានទទួលសេចក្តីជំនឿលើផ្លូវ សេចក្តីពិត ហើយនឹងជីវិត (យ៉ូហាន14:6)។ទាំងសញ្ញាចាស់នឹងសញ្ញាថ្មីបង្ហាញថាសេចក្តីជំនឿលើព្រះយេស៊ូវតែមួយប៉ុណ្ណោះ ជាសេចក្តីសង្គ្រោះនិងជាអំណឹងល្អ។

ទីពីរ ស្តេចដាវីឌបានរត់ទៅកាន់ទីជ្រកកោននៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយបានដើរតាមដោយសំងាត់។ ដាវីឌបានជួយនឹងសេចក្តីលំបាកវេទនានៅក្នុងជីវិតរបស់ទ្រង់ ប៉ុន្តែបានរត់ទៅកាន់ទីជ្រកកោនដែលជាព្រះបន្ទូលរបស់ព្រះហើយបានដើរតាមដោយសម្ងាត់។ ជាលទ្ធផល ទ្រង់បានរត់ទៅកាន់ទីខ្ពស់ៗនៅក្នុងពេលដែលមានទុក្ខវេទនាដូចជាជើងរបស់ក្តាន់ញី។ ព្រះគុណនៃការយកឈ្នះចេញមកពីសេចក្តីជំនឿ ដែលជឿតែលើព្រះយេស៊ូវនិងព្រះបន្ទូលរបស់ទ្រង់។វាជាព្រះពរពិតដែលអ្នកជឿអាចទទួលបាន។

**8. ផ្លូវនៃប្រភពនៃព្រះពរ (2 សាំយ៉ូអែល 22:21-28)**

តើស្តេចដាវីឌបានយកឈ្នះលើសេចក្តីទុក្ខវេទនានៅក្នុងជីវិតរបស់ទ្រង់បានដោយរបៀបណា?

ទីមួយ ទ្រង់បានពួននៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់។ នៅពេលដែលទ្រង់ជួបសេចក្តីទុក្ខវេទនា ទ្រង់បានដើរតាមសេចក្តីសុចរិត ហើយទ្រង់មិនធ្វើការអាក្រក់ឡើយព្រមទាំងគេចចេញពីការអាក្រក់ទៀត។ អ្នកដែលពួននៅក្នុងទីជ្រកកោននៃព្រះគម្ពីរជាមនុស្សដែលមានប្រាជ្ញា នៅពេលដែលយើងនៅជាប់នឹងព្រះគម្ពីរដូចជាដង្កូវដែលនៅជាប់រូបកាយ (ទំនុកដំកើង 1:3)។

ទីពីរ ព្រះអម្ចាស់បានសងការនោះជំនួសទ្រង់។ ព្រះអម្ចាស់បានសងដោយព្រះគុណរបស់ទ្រង់ទៅកាន់អ្នកដែលផ្តល់សេចក្តីមេត្តា ការបំពេញរបស់ទ្រង់ទៅកាន់អ្នកដែលផ្តល់ភាពល្អឥតខ្ចោះនិងការសំអាតខ្លួនជាបរិសុទ្ធ ប៉ុន្តែការប្រៀនប្រដៅរបស់ទ្រង់ទៅកាន់អ្នកដែលបោកបញ្ឆោត។ ទៅកាន់អ្នកដែលបន្ទាបខ្លួន ព្រះអម្ចាស់ផ្តល់សេចក្តីសង្គ្រោះរបស់ទ្រង់ដល់គេ ប៉ុន្តែទៅកាន់អ្នកដែលឆ្មើងឆ្មៃ ទ្រង់ផ្តល់ជាសេចក្តីវេទនាវិញ។ សព្វថ្ងៃនេះ យើងត្រូវតែត្រឡប់ទៅកាន់ដំណឹងល្អដើម ហើយភ្ជាប់ទៅនឹងគោលលិទ្ធិដែលត្រឹមត្រូវ ដើម្បីមើលឃើញពិភពខាងវិញ្ញាណនៅក្នុងការនោះ។ ជាជារបៀបដែលត្រូវបានស្តារឡើងវិញ។

**គ. ការតាំងសញ្ញាអស់កល្ប (2សាំយ៉ូអែល 23:1-7)**

តើការតាំងសញ្ញាអស់កល្បរបស់ដាវីឌរាប់បញ្ចូលខ្លឹមសារអ្វីខ្លះ? ខ 4 បង្ហាញការសន្យាប្ញូនដោយប្រើការប្រៀបធៀបបីះព្រះអាទិត្យជះពន្លឺនាងពេលថ្ងៃលិច ពន្លឺនាពេលព្រឹកដែលគ្មានពពក និងភាពភ្លឺចែងចាំងមកលើស្មៅដែលលាស់បន្ទាប់ពីភ្លៀងរួច។ គ្រប់យ៉ាងមានទំនាក់ទំនងទៅនឹងពន្លឺ។ ពិតណាស់ ដាវីឌបានរស់នៅក្នុងសង្ឃឹមនិងភាពស្កប់ស្កល់ដ៏រស់ នៅក្នុងទុក្ខលំបាកជាបរិបូរនិងថ្មី។ ទ្រង់បានមានបទពិសោធន៍ការល្អៗតាមរយ:បញ្ហាជាច្រើន ហើយ

ទ្រង់ត្រូវបានការពារដោយព្រះអម្ចាស់នៅក្នុងគ្រោះនៃសេចក្តីស្លាប់។ ទីជ្រកកោនរបស់ទ្រង់ជាព្រះអម្ចាស់និងព្រះបន្ទូលរបស់ទ្រង់។ ទ្រង់ប្រាកដថាការយកគំរូតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់ទ្រង់ជាការដែលមានពរ។ សេចក្តីសន្យារបស់ព្រះជាព្រះពររបស់គ្រីស្ទានដែលព្រះបានសន្យានៅក្នុងព្រះគ្រីស្ទ។ ពីព្រោះព្រះគ្រីស្ទជាពន្លឺ គ្រីស្ទានដែលនៅជាប់នឹងព្រះគ្រីស្ទអាចរីករាយនឹងពន្លឺដ៏អស្ចារ្យនេះបាន។

**1. ដង្វាយស្រាទំពាំងបាយជូរដែលបានចាក់ថ្វាយដល់ព្រះជាម្ចាស់ (2 សាំយ៉ូអែល 23:13-35)**

ដូចដែលប៉ូលបានធ្វើ នៅពេលដែលយើងថ្វាយខ្លួនទៅកាន់ព្រះទុកជាដង្វាយសម្រាប់ផឹក នោះព្រះហប្ញទ័យរបស់ព្រះអម្ចាស់នឹងត្រូវបានសម្រេច។ អត្ថបទបង្ហាញដង្វាយច្រួចទៅកាន់ព្រះពីរ។

ទីមួយ ដង្វាយច្រួចរបស់អ្នកចម្បាំងបីនាក់ដែលបានថ្វាយទៅកាន់ព្រះអម្ចាស់។ នេះជាដង្វាយច្រួចរបស់អ្នកចម្បាំងរបស់ដាវីឌ (យ៉ូសែបបាសេបេត អេលីសា និងសាំម៉ា) ជាអ្នកដែលបានយកទឹកនៅអណ្តូងបេថ្លេហិមដោយបានចូលទៅតាមរយៈរបាំងដែលជាសត្រូវរបស់ដាវីឌ ជាមនុស្សរបស់ព្រះអម្ចាស់ ដែលជាពន្លឺរបស់អ៊ីស្រាអែល។ វាជាដង្វាយច្រួចដល់ព្រះអម្ចាស់។ ដង្វាយដែលពួកគេបានថ្វាយនៅពេលនោះអាចបង្កើតអាណាចក្ររបស់ព្រះ។

ទីពីរ ដង្វាយរបស់ដាវីឌបានថ្វាយទៅកាន់ព្រះអម្ចាស់។ ដង្វាយដ៏ស្រស់ស្អាតរបស់ដាវីឌជាដង្វាយច្រួចដោយការចាក់ទឹកនៅលើដី ហើយជាដង្វាយដែលត្រូវបានលើកឡើងទៅកាន់ព្រះអម្ចាស់។ ការដើរតាមព្រះអម្ចាស់ដោយបន្ទាបខ្លួននោះមានតម្លៃណាស់ ដែលថ្វាយគ្រប់ការទាំងអស់ទៅដល់ព្រះអម្ចាស់។ ព្រះអម្ចាស់ទ្រង់រងចាំចិត្តដែលខ្វេចខ្ទាំដូច្នេះ។ចិត្តរបស់ទ្រង់មានការប៉ះពាល់មកពីព្រះអម្ចាស់។ វាជាហេតុផលចម្បង ហេតុដែលចិត្តរបស់ទ្រង់ចង់សង់ព្រះវិហារត្រូវបានប្តូរទៅជាចិត្តដែលមានសេចក្តីឆ្មើងឆ្មៃទៅវិញ។ ទោះជាយ៉ាងណា នៅពេលដែលទ្រង់បានមើលឃើញសភាពដ៏អាក្រក់របស់ទ្រង់ភ្លាម នោះទ្រង់បានលន់តួអំពើបាបជា

ប្រញាប់ ហើយបានស្វែងរកការអត់ទោសមកពីព្រះ។ បន្ទាប់មកស្តេចដាវីឌបានសារភាពថា "តើគួរឱ្យទូលបង្គំជឹកឈាមរបស់មនុស្សដែលទៅទាំងប្រថុយជីវិតដូច្នេះឬអី?" (17)។ ការលន់តួអំពើបាបជាវិធីដើម្បីបញ្ឈប់ការស្រេកឃ្លាន។ វាមិនមែនជាការល្អទេដែលតោងទៅកាន់តែប្រយោជន៍របស់ខ្លួន។ ការទទួលស្គាល់សេចក្តីជំនឿរបស់ដាវីឌចេញមកពីចិត្តនៃការលន់តួបាប។

ទីបី សេចក្តីមេត្តារបស់ព្រះអម្ចាស់ នៅពេលដែលយើងលន់តួបាបទៅព្រះអម្ចាស់ សេចក្តីមេត្តារបស់ទ្រង់នឹងផ្តល់មក។ នៅពេលដែលយើងលន់តួបាបពិតប្រាកដ នោះយើងនឹងប្រាកដថាដោយសារព្រះគុណរបស់ព្រះ។ គន្លឹះចម្បងដើម្បីដោះស្រាយបញ្ហាត្រូវតែជាសេចក្តីមេត្តារបស់ព្រះ។ នៅពេលមានសេចក្តីអត់ឃ្លានមកដល់យើង នោះយើងគួរតែលត់ជង្គង់ចុះនៅចំពោះព្រះហើយលន់តួបាបទៅចំពោះទ្រង់។ បន្ទាប់មកព្រះអម្ចាស់នឹងផ្តល់ព្រះគុណយ៉ាងអស្ចារ្យមកដល់យើង។ ការសារភាព "វាយទូលបង្គំមក"។បង្កើតកិច្ចការថ្មីនៅក្នុងជីវិតរបស់យើង។

**3. ដង្វាយដែលត្រូវបានទទួលយក (2 សាំយ៉ូអែល 24:18-25)**

នៅពេលដែលស្តេចដាវីឌជួបសេចក្តីអត់ឃ្លាន តើទ្រង់បានថ្វាយដង្វាយដែលព្រះទ្រង់ទទួលយកដោយរបៀបណា?

ទីមួយ ទ្រង់បានដើរតាមសេចក្តីសុចរិត។ បើទោះជាទ្រង់បានទទួលជំនួយខ្លះៗដោយមិនបានបង់ថ្លៃក៏ដោយ ទ្រង់បានទិញវាដោយបានបង់ថ្លៃដែលសាកសមទៅកាន់ម្ចាស់គេ ពីព្រោះទ្រង់មានចិត្តដើរតាមសេចក្តីសុចរិតរបស់ព្រះអម្ចាស់។ បន្ទាប់ពីបង់ថ្លៃសមរម្យទៅដល់ម្ចាស់រួចមក ទ្រង់បានបង្កើតអាសនាសម្រាប់ព្រះអម្ចាស់។ ព្រះគ្រីស្ទជាកូនចៀមរបស់ព្រះដែលបានបង់បំណុលបាបរបស់យើង ជាដង្វាយដែលធ្វើឱ្យព្រះអម្ចាស់ស្តាប់ស្តល់មកលើសេចក្តីសុចរិតរបស់យើង។ យើងបានទទួលសេចក្តីមេត្តារបស់ទ្រង់ដើម្បីថ្វាយដង្វាយដែលសុចរិត

ទៅកាន់ព្រះដោយសេចក្តីជំនឿ។

ទីពីរ ដាវីឌបានថ្វាយដង្វាយសន្តិភាពនិងដង្វាយដុតតៅកាន់ព្រះជាម្ចាស់។ មានតែដង្វាយលោះបាបនៃការសុគតរបស់ព្រះគ្រីស្ទទេ ដែលអាចដោះគ្រប់ទាំងសេចក្តីអត់ឃ្លានបានពីព្រោះដោយសារឥទ្ធិពលរបស់ទ្រង់។ ការអធិស្ឋានរបស់ស្តេចដាវីឌសម្រាប់រាស្ត្ររបស់ទ្រង់ផ្ទាល់នោះជាយញ្ញបូជា។ នៅពេលដែលការអធិស្ឋានឡើងទៅដល់ព្រះ នោះការអត់ឃ្លានត្រូវបានបញ្ឈប់។ ការទូលអង្វរពិតប្រាកដរបស់ពួកបរិសុទ្ធនឹងនាំមកនូវឥទ្ធិពលយ៉ាងអស្ចារ្យមកដល់យើង។

## សរុបសេចក្តី

អាណាចក្ររបស់មនុស្សរបស់ស្តេចសូលត្រូវបានបំផ្លាញដោយព្រះដែលមានគ្រប់អំណាចចេស្តា ពីព្រោះដោយសារសកម្មភាពនៃការធ្វើតាមចិត្តខ្លួនរបស់អ័ដាម ជាមនុស្សដំបូង បានធ្វើនៅក្នុងសួនអេដែន។ ប៉ុន្តែការគ្រងរាជ្យរបស់ស្តេចដាវីឌបានបង្ហាញពីពន្លឺនៃសង្ឃឹមទៅលើលំនាំនៃសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទវិញ។ ដូច្នេះ ការគ្រងរាជ្យរបស់ដាវីឌ ជាគំរូដំបូងនៃអាណាចក្ររបស់ព្រះ ដែលជា ភាពជាស្តេចដែលត្រូវបង្ហាញដោយភ្នាក់ងារនៃការគ្រប់គ្រងរបស់មនុស្ស។បើទោះជាអាណាចក្ររបស់ព្រះដំបូងឡើយបានបង្ហាញមកដោយព្រះអម្ចាស់ នៅក្នុងសម័យនិក្ខមនំក៏ដោយ តែនៅក្នុងសម័យនៃវាលរហោស្ថាននិងនៅក្នុងថ្ងៃដែលតាំងនៅក្នុងស្រុកកាណាន ជាពិសេសអាកប្បកិរិយារបស់គេដែលពឹងលើលំហូរនៃសេចក្តីប្រោសលោះ ជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ប៉ុន្តែរូបតំណាងមានច្រើនប្រភេទ។ អាណាចក្ររបស់ព្រះរបស់ដាវីឌមានទំនាក់ទំនងទៅនឹងអាណាចក្រនៅក្នុងសញ្ញាថ្មីយ៉ាងខ្លាំង ដោយសារមានការស្រដៀងគ្នា។ ដូច្នេះ មានន័យដែលពិសោធន៍ពីលំហូរនៃកណ្ឌគម្ពីរ 2សាំយ៉ូអែលដើម្បីឱ្យយល់ពីអាណាចក្ររបស់ព្រះ។ ស្តេចដាវីឌជាតំណាងឱ្យព្រះយេស៊ូវ ដែលបានធ្វើជាស្តេចនៅក្នុងព្រះគុណនៃសញ្ញាថ្មី។ ទ្រង់

បានរីករាយនឹងព្រះគុណរបស់សេចក្តីប្រោសលោះ ហើយបានបង្ហាញពីគោលការណ៍នៃការប្រោសលោះនៅក្នុងលោកិយបើទោះជាទ្រង់រស់នៅមុនពេលដែលព្រះគ្រីស្ទយកកំណើតជាមនុស្សក៏ដោយ។ ហេតុនៃការលំបាកជាបញ្ហាតែមួយនោះជាបំណងប្រាថ្នាបាបរបស់គេ។ តាមរយៈបទពិសោធន៍ខាងវិញ្ញាណ នោះយើងរៀនពីជីវិតដែលត្រូវបានដឹកនាំទៅកាន់ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

## II. ពង្សាវតារក្សត្រទី១

### សេចក្តីផ្តើម

កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះអម្ចាស់បានចាក់បង្ហូរមកលើសាឡូម៉ូន បង្ហាញពីប្រាជ្ញានៃការពិចារណា ការយល់ពីព្រះគុណទូទៅ និងប្រាជ្ញានៃជីវិតនៅក្នុងសហគមន៍តាមរយៈសុភាសិត និងសាស្តា។ បើទោះជាមនុស្សបានប្រកែកអំពីប្រភពនាំប្រាជ្ញាក៏ដោយ តែព្រះយេស៊ូវគ្រីស្ទបានទទួលស្គាល់ប្រាជ្ញារបស់សាឡូម៉ូន ហើយបានប្រកាសថាប្រាជ្ញាបានសម្រេចនៅក្នុងព្រះយេស៊ូវផ្ទាល់។ ព្រះយេស៊ូវគ្រីស្ទប្រសើរជាសាឡូម៉ូន។ តើភស្តុតាងអ្វីដែលបញ្ជាក់ថាសាឡូម៉ូនបានទទួលព្រះវិញ្ញាណបរិសុទ្ធនោះ?

ទីមួយ ទ្រង់បានថ្វាយដង្វាយដុតចំនួន1000នៅលើអាសនាហ្គីបុន។ ដង្វាយដុត1000នៅទីខ្ពស់នៅហ្គីបុន មានន័យថាជាដង្វាយដុតដែលថ្វាយនៅលើអាសនាជាច្រើនដង។ វាមានន័យថា ទ្រង់បានថ្វាយដង្វាយល្អបំផុតទៅកាន់ព្រះដែលមានព្រះជន្មរស់។ វាមានន័យថាទ្រង់បានថ្វាយដង្វាយពិតនៅក្នុងវិញ្ញាណនិងសេចក្តីពិតដោយស្មោះត្រង់ ដោយផ្តោតលើសិរីល្អដល់ព្រះជាម្ចាស់គ្រប់ជ្រុងជ្រោយ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តដែលផ្តោតលើការថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ព្រះអម្ចាស់បានទតមើលទៅកាន់ការថ្វាយបង្គំពិតប្រាកដ។ ព្រះវិហារ រោងឧបោសថ និងអាសនាមានន័យថាជាសញ្ញានៃការថ្វាយបង្គំ។

នៅក្នុងសញ្ញាថ្មី ការដែលព្រះអម្ចាស់បានសំអាតព្រះវិហារមានន័យថា ជាការថ្វាយបង្គំពិតជាការដែលទ្រង់ចង់បាន។ យើងត្រូវតែដេញតាមអ្នកថ្វាយបង្គំ ឬតាមចោរប្លន់ ផ្ទះនៃការអធិស្ឋាន ឬជាផ្ទះរបស់ចោរប្លន់។ ទំនាស់រវាងបំណងប្រាថ្នាខាងសាច់ឈាមនិងខាងវិញ្ញាណនៅតែបន្តនៅក្នុងលោកិយនៅក្នុងជីវិតរបស់យើង។ បន្ទាប់ពីយើងបានសង្គ្រោះ នោះយើងត្រូវតែថ្វាយយញ្ញបូជារស់ទៅកាន់ព្រះជារៀងរាល់ថ្ងៃ (រ៉ូម 12:1-3)។ យើងបានយល់ពីគោលបំណងនៃការថ្វាយបង្គំ ក៏ដូចជាយញ្ញបូជាដ៏ល្អបំផុតទៅកាន់ព្រះហើយ។ សាឡូម៉ូនបានទទួលឥទ្ធិពលដោយការបង្រៀនពីសេចក្តីគោរពកោតខ្លាចដល់ព្រះរបស់ដាវីឌ។ ទ្រង់បានរៀនពីភាពស្មោះត្រង់ ត្រង់ និងសុចរិតចេញពីដាវីឌ។

ទីពីរ ទ្រង់បង្ហាញពីសេចក្តីសុចរិតរបស់ព្រះ (11) (16-28)។ បន្ទាប់ពីសាឡូម៉ូនបានថ្វាយដង្វាយដុតទៅកាន់ព្រះរួច ទ្រង់បានឃើញព្រះអម្ចាស់ដែលបានសួរពីបំណងរបស់ទ្រង់នៅក្នុងសុបិនរបស់ទ្រង់។ បន្ទាប់មកទ្រង់ចង់បានប្រាជ្ញា ដែលដឹងរវាងការល្អនិងការអាក្រក់សម្រាប់អាណាចក្ររបស់ព្រះ។

ទីបី ទ្រង់ទទួលបានការយល់ដឹងដែលជាព្រះគុណទូទៅ (4:29-34)។ អំណោយរបស់ព្រះវិញ្ញាណបរិសុទ្ធដែលសាឡូម៉ូនទទួលបាន បង្ហាញពីការស្គាល់ព្រះគុណទូទៅរបស់ព្រះ។ ទ្រង់មានបន្ទូលជាសុភាសិតចំនួន 3000 ចម្រៀង 1500 ចំណេះដឹងអំពីសត្វនិងរុក្ខជាតិ។ នៅពេលដែលទ្រង់ត្រឡប់ទៅកាន់ព្រះគម្ពីរ នោះការបើកសម្តែងពិសេស ទទួលបានប្រាជ្ញានៃព្រះគុណទូទៅដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ យើងដែលទទួលមួយអង្គដែលប្រសើរជាសាឡូម៉ូនមានប្រភពនៃប្រាជ្ញានោះ។

អត្ថបទចង់ផ្តោតទៅលើសាឡូម៉ូនជាតំណាងរបស់ព្រះគ្រីស្ទ ដែលជាប្រភពនៃរូបឆ្លុះរបស់ព្រះមានសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ដោយយោងតាមលំដាប់លំដោយដូចតទៅ - 1) ទ្រង់បានថ្វាយដង្វាយដុត1000នៅលើអាសនាហ្គីបុន 2) ទ្រង់ស្វែងរកសេចក្តីសុចរិតរបស់ព្រះជាទីមួយ 3) ទ្រង់បានយល់ពីព្រះគុណទូទៅដោយប្រាជ្ញារបស់ព្រះវិញ្ញាណ

បរិសុទ្ធ (4:29-34) ហើយ 4) ការណែនាំរបស់រាជ្យស្តេចដាវីឌកុំឱ្យបាត់រូបឆ្លុះរបស់ព្រះ។

**1. រូបឆ្លុះរបស់ព្រះបង្ហាញមកដោយយញ្ញបូជារស់ (1:1-3:28)**

សេចក្តីគោរពកោតខ្លាចដំបូងរបស់សាឡូម៉ូនជាជីវិតនៃយញ្ញបូជារស់ដែលមានឥទ្ធិពលខាងវិញ្ញាណពីស្តេចដាវីឌ។ វាជាគោលបំណងស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ហើយក៏ជាវិធីសាស្រ្តសម្រេចបំពេញគោលបំណង ដូចជា សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ ដូច្នេះការគ្រប់គ្រងរបស់ស្តេចសាឡូម៉ូនបានដើរតាមលំនាំតែមួយនៃការគ្រប់គ្រងរបស់ដាវីឌ ពីព្រោះព្រះអម្ចាស់បានធ្វើការដើម្បីសម្រេចការតាំងសញ្ញារបស់ដាវីឌនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។ តើភស្តុតាងរបស់ពួកគេនៅឯណា? 1 ពង្សាវតារក្សត្រ 1:1- 11:27 បង្ហាញពីធាតុគ្រឹះនៃការចម្រុងចម្រើនដែលព្រះផ្តល់មកយើង។ ប៉ុន្តែនៅផ្ទុយពីជីវិតរស់នៅជាដង្វាយរស់ទៅកាន់ព្រះ យញ្ញបូជាដែលជ្រុលហួសទៅកាន់ខ្លួនឯង ជាបំណងប្រាថ្នាបាបដែលបង្ហាញនៅក្នុងប្រវត្តិសាស្រ្ត 1 ពង្សាវតារក្សត្រ ដែលជាប្រវត្តិដែលបានអណ្តែតទៅបាត់។ យ៉ាងណាក៏ដោយ វាមិនអាចបំបែកលំនាំនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះទេ។ ពិតណាស់និម្មិតរូបរបស់សាឡូម៉ូនបង្ហាញពីឧទាហរណ៍នៃយញ្ញបូជារស់របស់មនុស្សដែលនៅក្នុងការតាំងសញ្ញាថ្មី (រ៉ូម 12:1-2)។ ប៉ុន្តែបន្ទាប់ពីការគ្រប់គ្រងរបស់សាឡូម៉ូនបានបំបែកធាតុជាពីរច្បាស់តាមលំនាំនៃប្រវត្តិសាស្រ្តរបស់អ៊ីស្រាអែល។

**2.ចូរស្វែងរកប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ!(1ពង្សាវតារក្សត្រ1:11-27)**

ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះចាប់ផ្តើមជាមួយប្រាជ្ញា និងចំណេះដឹងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ 1ពង្សាវតារក្សត្របង្ហាញពីកិច្ចការនៃប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងមនុស្សម្នាក់គឺសាឡូម៉ូននិងខ្សែរាជវង្សរបស់ទ្រង់។ ប្រាជ្ញាមានទំនាក់ទំនងទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅក្នុង 1 ពង្សាវតារក្សត្រ 1:11-27 យើងអាចរកឃើញលំនាំទីមួយនៃប្រា

ជ្ញា។ តើហោរាណាថាន និងនាងបាតសេបាបានយកឈ្នះលើបញ្ហានៃការបះបោរដែលត្រូវបានបញ្ចប់នៅក្នុងកិច្ចការដែលបរាជ័យដោយរបៀបណា? ទីមួយ ពួកគេបានដើរតាមប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ (13)។ ហោរាណាថានដែលបានធ្វើជាអ្នកព្រឹក្សាដល់ស្តេចដាវីឌបានទាស់នឹងបំណងរបស់មនុស្ស ប៉ុន្តែបានដើរតាមបំណងរបស់ព្រះជាម្ចាស់វិញ។ នៅពេលយើងស្វែងរកនគរនិងសេចក្តីសុចរិតរបស់ទ្រង់ នឹងមានផ្លូវបើកចំហរ ពីព្រោះព្រះវិញ្ញាណបរិសុទ្ធធ្វើការសម្រេចបំណងរបស់ព្រះអម្ចាស់។ វាជាប្រាជ្ញាពិតដែលជ្រើសយកការមួយនេះឬការមួយនោះដោយការដើរតាមបំណងរបស់ព្រះជាម្ចាស់ ហើយសារភាពថាខ្ញុំនឹងមិនដើរតាមបំណងរបស់ខ្ញុំឡើយ ប៉ុន្តែតាមបំណងរបស់ទ្រង់វិញ (យ៉ាកុប 4:15)។ ទីពីរ ពួកគេបានអះអាងពីសេចក្តីសន្យារបស់ព្រះជាម្ចាស់។ ប្រាជ្ញាខាងវិញ្ញាណជាផលផ្លែដែលនឹងរីកចេញមកពីប្រាជ្ញារបស់ព្រះ។ បាតសេបាត្រូវបានប្រើដោយព្រះនៅក្នុងការដើរតាមការសន្យារបស់ព្រះជាម្ចាស់។ ប្រាជ្ញារបស់ព្រះវិញ្ញាណជាចិត្តដែលបន្ទាបចុះហើយធ្វើតាមបំណងរបស់ព្រះអម្ចាស់វិញ។ .

**3. ហេតុផលយើងគួរតែបន្ទាបខ្លួន (1 ពង្សាវតារក្សត្រ 1:1-10)**

តាមរយៈការបះបោររបស់អាដូនីយ៉ា នោះយើងបានរៀនពីសារៈសំខាន់នៃការបន្ទាបខ្លួនដែលជាធាតុនៃ (5)។ ហេតុអ្វីបានជាការបន្ទាបខ្លួនសំខាន់នៅក្នុងជីវិតរបស់យើង?

ទីមួយ មនុស្សត្រូវបានបង្កើតជាពិសេសជាអ្នកដែលត្រូវមានការបន្ទាបខ្លួន។ មនុស្សដែលចេញមកពីដី ហើយគួរតែត្រឡប់ទៅដីវិញយ៉ាងណាត្រូវតែបន្ទាបខ្លួន។ ដូចស្តេចដាវីឌបានថ្វាយខ្លួនរបស់ទ្រង់ទៅព្រះអម្ចាស់ហើយបានទ្រង់បានផ្ទាល់ទៅជាបន្ទាបខ្លួន បើទោះជាទ្រង់ខ្លាំងនៅក្នុងអង្គទ្រង់ក៏ដោយ ជាមនុស្សដែលគ្មានធនធាននៅក្នុងខ្លួនឯង។

ទីពីរ ព្រះគុណរបស់ព្រះនឹងមកលើយើង នៅពេលដែលយើងបន្ទាបខ្លួន។ សេចក្តីអំនួតរបស់គាត់ជាឧបករណ៍ចម្បងដែលសាតាំងប្រើ ដូចជាអ័ដាមត្រូវបានល្បួងដោយសត្វពស់ ហើយនី

ម៉ូរ៉ុឌត្រូវបានល្បួងដោយសារអំនួត ដែលបានដឹកនាំឱ្យសាងសង់ប៉មពីសាតាំងមក។ បើទោះជាគាត់ជាសមាជិកគ្រួសារដែលមានសេចក្តីកោតខ្លាចដល់ព្រះក៏ដោយ នៅតែមានសេចក្តីអំនួតដែលបានរីកឡើង គាត់គួរតែដើរតាមច្បាប់នៃការបន្ទាបខ្លួន។

ទីបី ដោយសារភ្នែកខាងវិញ្ញាណរបស់គាត់បានបើកឡើង នោះគាត់អាចមើលឃើញរបស់ផ្សេងៗបានត្រឹមត្រូវ។ មនុស្សដែលចូលទៅក្នុងការបះបោររបស់អាដូនីយ៉ាជាមនុស្សដែលលោភលន់។ ដោយសាររូបភាពនៃសេចក្តីគោរពកោតខ្លាចដល់ព្រះទេដែលអាចវែកញែកបញ្ហានេះឱ្យបានច្បាស់ពិតប្រាកដ។ នៅពេលដែលយើងបន្ទាបខ្លួន ដោយនៅពន្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះយើងនឹងអាចស្គាល់ផ្លូវនៃសេចក្តីពិតបាន។

**4. ចូរយើងធ្វើការជាប្រាជ្ញារបស់ព្រះអម្ចាស់ (1 ពង្សាវតារក្សត្រ 3:16-28)**

សាឡូម៉ូនដែលមានប្រាជ្ញារបស់ព្រះ បានបង្កើតអំណាចរបស់ព្រះ ហើយដោះស្រាយបញ្ហារបស់ប្រជាជនរបស់ទ្រង់ (28)។ តើប្រាជ្ញាជាអ្វី? ទីមួយ វាជាប្រាជ្ញាដើម្បីស្គាល់ការល្អនិងអាក្រក់។ ដូចជាញត្តិរបស់មនុស្សពីរនាក់ត្រូវបានដោះស្រាយដោយការប្រើឥរិយាបថនៃសេចក្តីស្រឡាញ់ ព្រោះយើងដឹងថាសេចក្តីស្រឡាញ់របស់ព្រះ នោះយើងមានប្រាជ្ញាដើម្បីស្វែងយល់រវាងភាពល្អនិងអាក្រក់។ ទីពីរ វាត្រូវបានបង្ហាញជាចិត្តដែលកោតខ្លាច។ នៅក្នុងខ 28 ការកោតខ្លាចគឺជាគ្រឹះនៃប្រាជ្ញានិងចំណេះដឹង។ នៅពេលអំណោយនឹងត្រូវបានបង្ហាញខ្លួនធម្មតាដែលសិរីរុងរឿងនិងការកោតខ្លាចនឹងកើតឡើងនៅក្នុងចិត្តដែរ។

ដូច្នេះក្រុមជំនុំបុរាណបានតែងតាំងអ្នកបម្រើដែលពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធនិងចំណេះដឹង។ ទីបី វាគឺជាប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ។ បន្ទាប់ពីទ្រង់បានថ្វាយតង្វាយដុតរាប់ពាន់ថ្វាយព្រះអម្ចាស់គាត់មិនបានទទួលជំនាញខាងរដ្ឋបាលនិងអំណាចទេ តែជាប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ។ វាជាប្រាជ្ញារបស់ព្រះវិញ្ញាណដែលបំភ្លឺចិត្តដោយអំណាចនៃព្រះវិញ្ញាណ។ ចូរជំនះគ្រប់ស្ថានការណ៍បច្ចុប្បន្នរបស់យើងដោយប្រាជ្ញានៃព្រះវិញ្ញាណបរិសុទ្ធ។

**5.ពិធីឡើងគ្រងរាជ្យរបស់ស្តេចសាឡូម៉ូន (1ពង្សាវតារក្សត្រ1:28-37)**

តើយើងរៀនអ្វីខ្លះអំពីប្រាជ្ញារបស់ព្រះ តាមរយៈការឡើងគ្រងរាជ្យរបស់សាឡូម៉ូននៅពេលមានភាពច្របូកច្របល់?

ទីមួយ យើងត្រូវជឿលើព្រះដែលបានជួយសង្គ្រោះពីទុក្ខវេទនាទាំងអស់។ នៅក្នុង ខ 20 ព្រះអម្ចាស់ដែលដាវីឌបានលះបង់ដើម្បីជួយពួកគេអោយរួចផុតពីទុក្ខវេទនាទាំងអស់។ យើងត្រូវថើបព្រះហស្តរបស់ព្រះអម្ចាស់ដែលអាចជួយសង្គ្រោះយើងអោយរួចផុតពីការរងទុក្ខពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល (1កូរិនថូស 1:10) ។

ទីពីរ ទ្រង់គឺជាព្រះដែលបានផ្លាស់ប្តូរការបះបោររបស់អាដូនីយ៉ាទៅជារឿងល្អ។ អ្នកដែលស្រឡាញ់ព្រះជាម្ចាស់នឹងទទួលបានលទ្ធផលល្អ ដោយព្រះជាម្ចាស់ព្រះអម្ចាស់បានធ្វើការគ្រប់យ៉ាងសម្រាប់ការនោះ។នេះជាប្រាជ្ញាដែលយើងមានអាកប្បកិរិយាវិជ្ជមានក្នុងការសម្រេចបំណងប្រាថ្នារបស់ព្រះ។ទីបីព្រះបានធ្វើឱ្យពួកគេធ្វើការចាក់ប្រេងតាំងនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះជាម្ចាស់ផ្ទាល់បានធ្វើការជាមួយវិធីសាស្ត្ររបស់ទ្រង់។ ពួកបរិសុទ្ធគឺជាអ្នកដែលធ្វើការងារបំរើព្រះជាម្ចាស់ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ (កិច្ចការ 1: 8)។

**6. ស្តេចដែលព្រះអម្ចាស់បានបង្កើត (1 ពង្សាវតារក្សត្រ 1:40-53)**

ប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញនៅក្នុងការយកព្រះជាស្តេចនៅក្នុងការគ្រប់គ្រងរបស់ស្តេចជាមនុស្ស ដូចជានិម្មិតរូបនៃស្តេចពិតប្រាកដ។ ដូច្នេះគោលបំណងនៃ1ពង្សាវតារក្សត្រ មិនមែនជាការប្រកាសភាពជាស្តេចទៅកាន់លោកិយឡើយ តែជាការបង្ហាញពីការបង្កើតអាណាចក្ររបស់ព្រះវិញ។ អាណាចក្រមានធាតុពីរ។

ទីមួយ មនុស្សដែលមានផលផ្លែរបស់ព្រះដែលទ្រង់ជាស្តេចត្រូវបានបង្ហាញមក (45)។ ហោរាណាថានត្រូវបានព្រះទ្រង់ប្រើជាវង្សានុវង្សរបស់ស្តេចដាវីឌឱ្យបានបង្កើតមក ហើយចិត្តរបស់ប៊ីនេហាសប្រាថ្នាចង់បានតែព្រះអម្ចាស់ ហើយសាឡូម៉ូនមានសេចក្តីជំនឿដែលកោតខ្លាច

ដល់ព្រះ ដែលរងចាំនគររបស់ព្រះដោយស្ងៀមស្ងាត់។ ពួកគេជាអ្នកបម្រើដែលស្មោះត្រង់ ដូចដែលស្តេចដាវីឌដែលសាកសមទៅនឹងបំណងរបស់ព្រះអម្ចាស់យ៉ាងឥតខ្ចោះ។

ទីពីរ មនុស្សបះបោរបានលេចមក (50)។ អាប៊ីដាល យ៉ូអាប់ និងអាដូនីយ៉ា ត្រូវបានដាក់បញ្ចូលនៅក្នុងក្រុមដែលបះបោរទាស់នឹងបំណងរបស់ព្រះអម្ចាស់ ដោយអាងលើសេចក្តីពុករលួយខាងសាច់ឈាម។ លទ្ធផលបានមកជាខ្សោយហើយស្លាប់។(ម៉ាថាយ16:16)

**7.អាថ៌កំបាំងនៃភាពចម្រុងចម្រើន(1ពង្សាវតារក្សត្រ2:1-12)**

គ្រីស្ទានត្រូវការផ្លូវដែលដាវីឌបានចង្អុលបង្ហាញទៅកាន់សាឡូម៉ូនមុនដែលទ្រង់ចាកចេញពីលោកិយនេះទៅកាន់ស្ថានសួគ៌។

ទីមួយ យើងត្រូវតែដើរតាមស្តង់ដារបស់ព្រះបន្ទូល។ ដូចដែលម៉ូសេបានប្រាប់អំពីផ្លូវនៃការចម្រុងចម្រើន នោះជាការរក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាផ្លូវទៅកាន់គ្រប់ទាំងព្រះពរ (យ៉ូស្វេ1:8)។ ស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះជានិច្ច ជាអាថ៌កំបាំងទទួលបានជោគជ័យ។ ក្រៅពីការនេះ ការក្រៅពីនេះសុទ្ធតែបោកបញ្ឆោត។

ទីពីរ យើងត្រូវតែដើរតាមការនោះឱ្យអស់ពីចិត្ត។ នៅពេលដែលយើងធ្វើតាមបញ្ញាត្តិទីមួយអស់ពីចិត្តរបស់យើង អាកប្បកិរិយារបស់យើងនិងជីវិតរបស់យើង នោះយើងនឹងអាចទៅកាន់ទីដែលមានជ័យជម្នះ (4)។ នៅទីនេះ ព្រះអម្ចាស់ក៏បានទាមទារយញ្ញបូជារស់របស់យើងទៅកាន់ព្រះដែរ (រ៉ូម 12:1-2)។

ទីបី យើងត្រូវតែដើរតាមផ្លូវដោយចេញពីចិត្តដែលស្មុគ្រស្មោះ។ បាស៊ីលដែលបានកំសាន្តដល់អារៀលបានទទួលព្រះគុណរបស់ព្រះអម្ចាស់ ប៉ុន្តែយ៉ូអាប់និងស៊ីម៉ីត្រូវទទួលបានការដាក់ទោសពីព្រះវិញ ពីព្រោះការដែលមានចិត្តដែលធ្វើដោយស្មុគ្រស្មោះ។ ចូរយើងចុះចូលពេញពីចិត្តរបស់យើង ចង់បានការចាក់ប្រេងតាំងពីព្រះអម្ចាស់នៅក្នុងចិត្តរបស់យើងវិញ (1 ពេត្រុស 1:8)។

**8.គំនិតខាងរូបកាយ (1ពង្សាវតារក្សត្រ2:13-25)**

អត្ថបទបង្ហាញពីគ្រោះថ្នាក់របស់សាច់ឈាមមកដល់យើង ដោយការសម្រេចចិត្តយ៉ាងមុតមាំរបស់សាឡូម៉ូនទៅកាន់សំណូមពរខុសឆ្គងរបស់អាដូនីយ៉ា។ តើជាការអ្វីទៅ?

ទីមួយ អាដូនីយ៉ាបានដកចេញសេចក្តីជំនឿដែលមានការកោតខ្លាចចេញ ពីព្រោះដោយសារការដើរតាមលទ្ធផលនៃគំនិតខាងរូបកាយ (21)។ ប្រសិនបើសេចក្តីជំនឿត្រូវបានបំផ្លាញ យើងមិនអាចជួយការដើរតាមផ្លូវនៃសេចក្តីពុករលួយបានឡើយ ពីព្រោះស្តង់ដារនៃគោលការណ៍និងតម្លៃនឹងក្លាយទៅជាស្ទាក់ស្ទើរ។

ទីពីរ គំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធត្រូវបានបង្ហាញដោយការគិតរបស់សាឡូម៉ូន (23)។ សេចក្តីជំនឿមានតម្លៃជាងភាពជាស្តេចនិងជីវិតទៅទៀត ទ្រង់បានដោះស្រាយបញ្ហាដោយការវែកញែកខាងវិញ្ញាណ ដោយសារគំនិតខាងសាច់ឈាមបានក្លាយជាសេចក្តីស្លាប់តែគំនិតខាងវិញ្ញាណជាជីវិតវិញ។យើងត្រូវតែរស់នៅជាអ្នកបម្រើដែលស្មោះត្រង់របស់ព្រះ ដោយការពិចារណាព្រះបន្ទូលរបស់ព្រះនិងសម្លេងរបស់ទ្រង់នៅក្នុងចិត្តរបស់យើងនៅក្នុងស្ថានភាពជាច្រើន។ ជាពិសេស ដោយការពិចារណាការដែលពេញដោយល្បិចកល្ប ដែលងាយនឹងល្បួងដោយអារម្មណ៍និងការខ្វល់ខ្វាយរបស់មនុស្ស យើងត្រូវដេញតាមផ្លូវរបស់ព្រះវិញ្ញាណបរិសុទ្ធនៅដំណាក់របស់ព្រះអម្ចាស់។

**9.សេចក្តីគ្រេកគ្រអាលរបស់សាច់ឈាម (1ពង្សាវតារក្សត្រ2:26-35)**

យើងរៀនថាការមកដោយបើកសម្តែងនឹងជាសេចក្តីស្លាប់ ដោយការធ្វើទៅកាន់យ៉ូអាប់និងអាបីដាល់របស់សាឡូម៉ូន។

ទីមួយ អាបីដាល់ជាអ្នកបះបោរនៅក្នុងលោកិយ (26-27)។ ពួកគេមិនបានដើរតាមព្រះបន្ទូលរបស់ព្រះ សេចក្តីសន្យា និងលំនាំនៃសេចក្តីជំនឿដែលកោតខ្លាចដល់ព្រះទេ។ ជាលទ្ធផល

ពួកគេត្រូវបានបំបរបង់ដោយព្រះអម្ចាស់។
ទីពីរ បើទោះជាយ៉ូអាប់ជាអ្នកចម្បាំងដ៏ពូកែដែលជួយដាវីឌក៏ដោយ តែគាត់មិនអាចគេចផុតពីបំណងប្រាថ្នាខាងសាច់ឈាមដែលស្វែងរកការលោភលន់និងកិត្តិយស (28-29)។ ពីព្រោះគាត់បានពឹងលើដាវនៅគ្រប់ផ្លូវនិងវិធីសាស្រ្តទាំងអស់ គាត់បានយកឈាមមនុស្សមានបានសាមញ្ញៗ។ គ្រប់ទាំងព្រះពរនឹងទៅតាមអ្នកដែលស្វែងរកនគរនិងសេចក្តីសុចរិតរបស់ព្រះជាទីមួយ។ តណ្ហារបស់សាច់ឈាមជាសេចក្តីស្លាប់ប៉ុន្តែផ្លូវនៃព្រះវិញ្ញាណបរិសុទ្ធជាជីវិតពេញបរិបូរណ៍វិញ។

**10.ការលន់តួបាបដ៏ពិតប្រាកដ(1ពង្សាវតារក្សត្រ2:36-46)**

ទីមួយ អត្ថបទបានបង្ហាញថាស៊ីម៉ីដែលបានដាក់បណ្តាសាដាវីឌ បានដើរតម្រង់ជួរដើម្បីស្វែងរកអ្នកបំរើដែលវង្វេងបាត់។ យើងអាចរៀនពីសារៈសំខាន់នៃការប្រែចិត្តនៅទីនេះ។ តើការប្រែចិត្តពិតគឺជាអ្វី? ដំបូងខ្ញុំត្រូវការបំណងចិត្តបរិសុទ្ធ។ មើលទៅកាន់ទង្វើរបស់ស៊ីម៉ីដែលមិនអាចគេចផុតពីប្រភេទនៃការលោភលន់បានទេ។ គាត់ជាមនុស្សមិនធម្មតា ដែលជាអ្នកស្វែងរកឱកាសសម្រាប់សេចក្តីប្រាថ្នាខាងសាច់ឈាមរបស់គាត់ (38-39)។ គាត់មានចរិតលក្ខណៈនៃការញៀនល្បែង។
ទីពីរ វាត្រូវការការប្រែចិត្តទាំងស្រុង។ ការប្រែចិត្តរបស់គាត់មិនអាចផ្លាស់ប្តូរទៅរកការផ្លាស់ប្តូរជីវិតបានទេ។ ដាវីឌដឹងពីរឿងបែបនេះនៅក្នុងជីវិតរបស់គាត់ (43-44)។ ទោះបីជាគាត់បានជួបនឹងបញ្ហាផ្សេងទៀតក៏ដោយ ក៏គាត់ត្រូវបានសំលាប់ដោយដៃដ៏មើលមិនឃើញរបស់ព្រះ។ នៅពេលយើងធ្វើតាមការប្រែចិត្តដ៏ពិតដែលប៉ុលបានធ្វើនៅក្នុងជីវិតរបស់គាត់ដែលបានស្លាប់រាល់ថ្ងៃក្នុងជីវិតរបស់គាត់ ដើម្បីទទួលបានភាពរុងរឿងនៃជីវិតរបស់ខ្ញុំដូចជាដើមឈើនៅក្បែរមាត់ទន្លេអាចផ្តល់ផលផ្លែជាច្រើន។

## ក ការដេញតាមសេចក្តីសុចរិតរបស់ព្រះជាម្ចាស់

ជីវិតនៃយញ្ញបូជារស់ទៅកាន់ព្រះគួរតែបានបង្ហាញមកពីព្រះដែលទ្រង់ចាក់បង្ហូរមកនូវសេចក្តីសុចរិត។ វាមិនត្រូវបានកំណត់នៅក្នុងជំហរច្បាប់ទេ។ លើសពីនេះទៅទៀតវាត្រូវដើរទៅរកទីតាំងពិតនៃសេចក្តីសុចរិត។ ព្រះបាទសាឡូម៉ូនមុនអំពើពុករលួយ បានស្វែងរកភាពសុចរិតក្នុងរបបរាជានិយម។ ដូច្នេះសាឡូម៉ូនផ្តោតលើភាពសុចរិតមុនពេលគាត់ត្រូវបានបំផ្លាញដោយបំណងប្រាថ្នាខាងលោកិយដើម្បីបង្ហាញពីគោលការណ៍នៃនគររបស់ព្រះជាម្ចាស់។ នៅផ្នែកនៃជីវិតរបស់សាឡូម៉ូនការស្វែងរករបស់គាត់បានបង្ហាញពីចរិតលក្ខណៈនៃនគររបស់ព្រះ។ ព្រះវិហារសកលនៅស្ថានសួគ៌ ដែលមានសេចក្តីសុចរិត សេចក្តីមេត្តាករុណា និងភាពស្មោះត្រង់។ យើងនឹងរៀនទៅលើធាតុដែលបានបង្ហាញនៅក្នុងខ 4:20-9:28 នៅទីនេះ។

### 1. ស្រមោលនៃនគររបស់ព្រះជាម្ចាស់ (1 ពង្សាវតារក្សត្រ 4:20-34)

ការគ្រប់គ្រងរបស់សាឡូម៉ូនជាស្រមោលនៃអាណាចក្ររបស់ព្រះ។ តើអាណាចក្ររបស់ព្រះមានលក្ខណៈដូចម្តេច?

ទីមួយ អំណាចត្រូវបានបង្កើតមកដោយសារព្រះអម្ចាស់ (20-23)។ អ្វីដែលគ្រប់ជាតិសាសន៍បានថ្វាយសួយសាមក បញ្ជាក់ពីការសម្រេចបំពេញការតាំងសញ្ញារបស់អ័ប្រាហាំ។ ក្រុមជំនុំដែលមានចេស្តាខាងវិញ្ញាណគ្រប់គ្រងលើផែនដីទាំងមូលដោយចេស្តានៃឥទ្ធិឫទ្ធិរបស់ស្ថានសួគ៌និងផែនដី។ ដូច្នេះ យើងត្រូវអះអាងការដឹងពីឥទ្ធិឫទ្ធិនេះ។

ទីពីរ ជីវិតដែលពេញដោយសេចក្តីសុខសាន្ត ត្រូវបានផ្តល់មកដល់មនុស្ស (24-25)។ ការគ្រប់គ្រងរបស់សាឡូម៉ូនបានផ្តល់ដល់រាស្ត្ររបស់ទ្រង់ ដែលប្រាប់ពីសេចក្តីសុខសាន្តនៃការអត់ទោសបាបដែលបានផ្តល់មក ដោយការសងថ្លៃលោះដោយការសុគតរបស់ព្រះគ្រីស្ទ។

ទីបី សីលធម៌ត្រូវបានបង្កើតដោយសារប្រាជ្ញា (29-34)។ វាជានិម្មិតសញ្ញាដែល គ្រប់ស្តេចទាំងអស់បានមកសាឡូម៉ូនដើម្បីស្តាប់ទៅកាន់ពាក្យប្រាជ្ញាទៅកាន់ពួកអ៊ីស្រាអែល ពីព្រោះ

គ្រប់រាស្ត្រដែលបានជ្រើសរើសនៅក្នុងលោកិយនឹងមកកាន់ព្រះយេស៊ូវដើម្បីនឹងស្ដាប់ដំណឹងល្អនៃសេចក្ដីសង្គ្រោះ។ យើងត្រូវតែនៅជាប់ជាមួយព្រះយេស៊ូវគ្រីស្ទដែលទ្រង់មានឥទ្ធិឫទ្ធិ សេចក្ដីសុខសាន្ដ និងប្រាជ្ញាប្រសើរសាឡូម៉ូនផង។

**2.សាឡូម៉ូនស្មោះត្រង់(1ពង្សាវតារក្សត្រ5:1-18)**

អត្ថបទដែលរៀបរាប់ពីការរក្សាការតាំងសញ្ញាព្រះគុណដោយស្មោះត្រង់ដែលបានផ្ដល់មកដាវីឌនិងពូជពង្សរបស់ទ្រង់ ដែលបង្រៀនពីអត្ថន័យសំខាន់នៃរោងឧបោសថនៅក្នុងជីវិតរបស់យើង។

ទីពីរ ទ្រង់ផ្តោតលើភាពស្មោះត្រង់។ ភាពស្មោះត្រង់របស់យ៉ូដាមនៅក្នុងខ 34 ជាផលផ្លែដែលឪពុករបស់ទ្រង់អ៊ូហាសៀត្រូវទទួលបានការប្រដៅ។ យ៉ូដាមដែលជាអ្នកសាងសង់អាសនារបស់ព្រះយេហូវ៉ា ជាមនុស្សមិនស្មោះត្រង់រហូតដល់ទីបំផុត។ សេចក្តីស្មោះត្រង់ជាសេចក្តីស្មោះត្រង់នៃព្រះបន្ទូលរបស់ព្រះ។ ជាការដែលមានតម្លៃដែលយើងរស់នៅក្នុងជីវិតដែលមានព្រះបន្ទូលជាចំណុចកណ្តាល។ ទីបី ព្រះអម្ចាស់ផ្តោតទៅលើពេលវេលា។ ជាចុងក្រោយ ព្រះអម្ចាស់បានធ្វើការ។ វាមានន័យថាព្រះអម្ចាស់បានសម្រេចនោះជាផែនការនៅក្នុងពេលវាលាកំណត់របស់ទ្រង់។ ពេលវេលាដែលមានការផ្លាស់ប្រែនាពេលរបស់ណូអេ ពេលនៃការផ្លាស់ប្រែរបស់ក្រុមជំនុំនៅអាន់ទីយ៉ុក និងការត្រឡប់មកវិញនៅក្នុងគ្រាចុងក្រោយ។ យើងគួរតែសន្សំពេលនៅក្នុងពេលដ៏អាក្រក់សព្វថ្ងៃនេះ។

## 8.ការសម្លឹងមើលការការលោក់កំបាំងSyncretic(ពង្សាវតារក្សត្រទី2, 17:24-41)

ភាពបរិសុទ្ធរបស់សាសនាជាគោលដៅរបស់សាតាំងវាយប្រហារជានិច្ច។
ទីមួយ លក្ខខណ្ឌដែលសាកសមនៃទីកន្លែង និងព្រះក្លែងក្លាយត្រូវបានបង្កើតឡើង ហើយស្តេចរបស់អាស៊ីរីបានបញ្ជាថា គ្រប់ជាតិសាសន៍ទាំងអស់គួរតែគោរពសាសនារបស់ទ្រង់ ដែលជាគោលការរបស់ស្តេចបញ្ជាមកឱ្យបែកចេញពីភាពបរិសុទ្ធ (29-33)។ ទ្រង់បានអនុញ្ញាតឱ្យគ្រប់ជាតិសាសន៍បម្រើព្រះក្លែងក្លាយនិងផ្លាស់ប្តូរសេចក្តីជំនឿលើព្រះយេហូវ៉ារបស់ពួកគេ។
គោលការណ៍នេះត្រូវបានបន្តបន្ទាប់ពីពួកខាងជើងនិងខាងត្បូងត្រូវបានបំបែក ហើយបានបង្កើតគម្ពីរទាំងប្រាំរបស់ម៉ូសេរបស់ពួកសាម៉ារី ហើយត្រូវបានធ្លាក់នៅក្នុងភាពងងឹតខាងវិញ្ញាណ។
ទីពីរ ការនេះបានធ្វើឱ្យគេឃ្លាតចេញពីព្រះសៃនឆ្ងាយ (35-37)។ ប្រៀបបីដូចជាបាតដែលមិនទាន់បានដុសដុល នោះដំហានបន្ទាប់នឹងមិនត្រឹមត្រូវឡើយ បើទោះជានៅមុនព្រះយេស៊ូវបានយាងមកទីនេះក៏ដោយ ក៏គ្មានសង្ឃឹមដែរ។ ប៉ុន្តែកាលដែលដំណឹងល្អត្រូវបានប្រកាសទៅកាន់ពួកគេ កិច្ចការថ្មីបានចាប់ផ្តើមឡើង។ យើងត្រូវចាត់ទុកពេលនោះជាពេលដែលចាកចេញពីសេចក្តីពិត។ ចូរយើងមានសេរីភាពចេញពី sycrestism.

**9. ផ្លូវដែលឈ្នះលើសត្រូវ (ពង្សាវតារក្សត្រទី2, 18:17-37)**

តើរាបសាខេបានយកឈ្នះលើការនេះដោយរបៀបណា?

ទីមួយ ទ្រង់បានពឹងលើសេចក្តីមេត្តារបស់ព្រះអម្ចាស់។ បើទោះជាអ្នកដែលផ្លាស់ប្រែរ័យក្មេងក៏ដោយ ទ្រង់បានយោគយល់ដល់អាស៊ីរី ហើយបានប្រគល់ទ្រព្យសម្បត្តិដែលបរិសុទ្ធ ហើយចុងក្រោយស្តេចនឹងត្រូវបរាជ័យ។ ស្តេចអាស៊ីរីបានចំអកដល់ហេសេគាដើម្បីទទួលបានឯកសារដោយការល្បួងដល់រាបសាខេ។ បើទោះជាហេសេគាមានភាពទន់ខ្សោយក៏ដោយ។ បន្ទាប់មកព្រះអម្ចាស់បានទទួលយកការអង្វរកររបស់ទ្រង់ ហើយបានផ្តល់ការដ៏អស្ចារ្យដល់ទ្រង់ដោយសារការអាសូររបស់ព្រះអម្ចាស់ ដែលទ្រង់ស្តាប់ឮសេចក្តីអធិស្ឋានរបស់ទ្រង់ ទ្រង់បានសង្គ្រោះពួកគេចេញពីសត្រូវ។

ទីពីរ ទ្រង់បានយកឈ្នះពួកគេដោយការអង្វរករ។ ទ្រង់បានយកលិខិតដែលអាសាខេដែលចំអកមកទ្រង់មកទីបរិសុទ្ធ។ អ្នកដែលស្វែងរកពិតប្រាកដបង្ហាញពីបញ្ហានេះទៅកាន់ព្រះដោយស្មោះដល់ទ្រង់។ យើងគួរតែរៀនអធិស្ឋានដូចជាស្តេចហេសេគាបានធ្វើ។

**10.ការផ្លាស់ប្រែរបស់ស្តេចហេសគា (ពង្សាវតារក្សត្រទី2, 18:1-16)**

តើការកែទម្រង់អ្វីដែលស្តេចហេសេគាអាយុ25ឆ្នាំបានធ្វើក្នុងនាមជាស្តេចរបស់អ៊ីស្រាអែល?

ទីមួយ ទ្រង់បានបំផ្លាញរូបព្រះក្លែងក្លាយ (4)។ ដោយសារទ្រង់ធ្វើការនេះនៅចំពោះព្រះអម្ចាស់ ដែលទ្រង់បានលុបបំបាត់ព្រះរបស់សាសន៍ដទៃ ហើយបានបំផ្លាញព្រះក្លែងក្លាយដែលចេញមកពីពស់លង្ហិនរបស់ម៉ូសេ។ ការកែទម្រង់បានចាប់ផ្តើមពីការស្តារឡើងវិញនូវបទបញ្ញាត្តិទីមួយនៅចំពោះព្រះ។

ទីពីរ ទ្រង់បានកាន់តាមក្រិត្យវិន័យរបស់ម៉ូសេដោយផ្ទាល់។ ការកែទម្រង់ពិតប្រាកដមិនដែលឈប់បំផ្លាញរូបព្រះក្លែងក្លាយឡើយ ប៉ុន្តែបានត្រលប់ទៅកាន់ព្រះអម្ចាស់និងព្រះបន្ទូលរបស់ទ្រង់ដោយវិជ្ជមានវិញ។ ការដែលនៅជាប់នឹងព្រះបន្ទូលរបស់ព្រះ ជាការចាប់ផ្តើមនៃការកែទម្រង់និងការលូតលាស់។

ទីបី ពេលដែលគេមិនព្រមស្តាប់តាមក្រឹត្យវិន័យ នោះការវេទនានឹងមកលើគេ (12)។ ការ

ចម្រុងចម្រើនពិតប្រាកដមិនមែនជាទុក្ខវេទនានោះទេ ប៉ុន្តែជាការភ្លក់រសជាតិនៃព្រះគុណរបស់ព្រះ ដែលធ្វើការនៅក្នុងពេលមានទុក្ខលំបាកនោះ (9-11)។ នៅពេលដែលក្រុមជំនុំបច្ចុប្បន្នដើរតាមគោលការណ៍នៃការកែទម្រង់នោះគេនឹងអាចរីករាយនូវព្រះគុណដែលចម្រុងចម្រើន។

**11.អំណាចនៃការអធិស្ឋាន(ពង្សាវតារក្សត្រទី2, 19:20-37)**

តើការអធិស្ឋានដោយយំរបស់ហេសេគាត្រូវបានទទួលយកដោយព្រះអម្ចាស់យ៉ាងដូចម្ដេច? ទីមួយ ព្រះអម្ចាស់បានឮការអធិស្ឋានរបស់គាត់។ ព្រះអម្ចាស់ដែលបានស្ដាប់ទៅកាន់ពាក្យដៀលចំអករបស់រាសាខេ ទ្រង់ក៏បានស្ដាប់ទៅកាន់ការអង្វររបស់ស្ដេចហេសេគា (20)។ ដូច្នេះព្រះអម្ចាស់បានបង្រៀនយើងថា កាលដែលយើងអធិស្ឋានទៅកាន់ព្រះអម្ចាស់ យើងមិនចាំបាច់បើកមាត់របស់យើងដោយគ្មានការប្រុងប្រយត្ននោះឡើង (cc.5:1-2)។ យើងត្រូវតែឈរវឹងមាំនៅលើចិត្តដែលយកព្រះអម្ចាស់ជាកណ្ដាលជាជាងការនិយាយរបស់យើង ពីព្រោះការអធិស្ឋានជាដង្វាយដែលព្រះអម្ចាស់គួរតែទទួល។

ទីពីរ តើការឆ្លើយតបរបស់ព្រះមកគាត់បង្ហាញពីអ្វី? អាការៈបានលេចឡើងមក (29)។ យោងតាមការសន្យានៃការថែរក្សាយ៉ាងពេញលេញ (34)។ អាស៊ីរ៉ីត្រូវបានបំផ្លាញដោយអំណាចចេស្ដារដ៏អស្ចារ្យ (35)។ ហើយស្ថានភាពនេះនឹងត្រូវបានសម្រេចដោយឈើឆ្កាងរបស់ព្រះគ្រីស្ទដែលជាចំនុចកំពូលនៃសេចក្ដីប្រោសលោះ (31)។ ចូរយើងបង្កើតបំណងរបស់ព្រះអម្ចាស់ដោយការថ្វាយដង្វាយជាការអធិស្ឋានពិតប្រាកដទៅកាន់ព្រះអម្ចាស់នៅក្នុងសេចក្ដីវេទនា។

**12.ការអធិស្ឋានស្មោះត្រង់ (ពង្សាវតារក្សត្រទី2, 20:1-11)**

តើព្រឹត្តិការណ៍អស្ចារ្យអ្វីដែលបង្ហាញមកនៅក្នុងជីវិតរបស់ហេសេគា?

ទីមួយ សេចក្ដីទុក្ខលំបាកដែលព្រះទ្រង់អនុញ្ញាតមកដល់ទ្រង់។ ដោយសារព្រឹត្តិការណ៍នោះស្ថិតនៅក្នុងព្រះហស្ដរបស់ព្រះដ៏មានអំណាចចេស្ដា នោះអ្នកបរិសុទ្ធនឹងទទួលបានការហ្វឹកហាត់នៅក្នុងវត្តមានរបស់ព្រះអម្ចាស់។ ការកែទម្រង់របស់ជាតិសាសន៍និងការវាយលុករបស់អាស៊ីរ៉ីជាការមួយដ៏ធំ ក៏ប៉ុន្តែជម្ងឺផ្ទាល់ខ្លួនជាការមួយដ៏ធំជាងទៅទៀត។ បន្ទាប់ពីយើងបាន

បកស្រាយពីបញ្ហាបច្ចុប្បន្នរបស់យើងរួចមក យើងគួរតែថ្វាយការនោះដល់ព្រះអម្ចាស់ដោះស្រាយ។

ទីពីរ ទ្រង់បានជឿថាមានតែព្រះអម្ចាស់ទេជាអ្នកដោះស្រាយបញ្ហារបស់គាត់។ នៅពេលដែលទ្រង់បានទូលអង្វរដើម្បីបានរស់នៅ ហើយបានសម្រេចចិត្តថាទ្រង់នឹងអធិស្ឋានដោយស្មោះត្រង់ទៅកាន់ព្រះអម្ចាស់ ហើយរស់នៅចំពោះព្រះដោយការបន្ទាបខ្លួនពេញមួយជីវិតរបស់ទ្រង់ ដោយចង់ចាំសេចក្តីសប្បុរសរបស់ព្រះនៅអតីតកាល និងសេចក្តីមេត្តារបស់ទ្រង់ (3)។ បន្ទាប់មកព្រះអម្ចាស់បានស្តាប់ទៅកាន់ការទូលអង្វររបស់ទ្រង់ ហើយបានពន្យាជីវិតរបស់ទ្រង់15ឆ្នាំថែមទៀត។ចូរយើងស្រែករកព្រះជាម្ចាស់នៅក្នុងគ្រាដែលមានទុក្ខលំបាក។

**13.បន្ទាប់ពីយើងបានទទួលព្រះគុណរបស់ព្រះអម្ចាស់(ពង្សាវតារក្សត្រទី2, 20:12-21)**

តើអត្ថបទបង្រៀនពីការចាត់ចែងព្រះគុណរបស់ព្រះនោះជាការសំខាន់ជាការទទួលយក?

ទីមួយ គាត់បានបរាជ័យដោយស្តាប់ទៅកាន់សម្រែកមួយចំនួន (12)។ នៅពេលដែលទ្រង់បានជាសះស្បើយពីជម្ងឺមហារីកស្បែករបស់ទ្រង់ ទ្រង់បានទទួលអំណោយជាច្រើនចេញពីមនុស្សជាច្រើន។ បន្ទាប់មកទ្រង់បានបើកទ្វារឃ្លាំងដើម្បីនឹងបង្ហាញពីអំណួតរបស់ទ្រង់។ ដោយសារអំពើបាបបានចាប់ផ្តើមជាមួយសេចក្តីអួតរបស់ទ្រង់ ព្រះអម្ចាស់បានព្រមានដល់ទ្រង់ថា ការកោតសរសើររបស់មនុស្សជាការដែលគួរស្អប់ដោយព្រះអម្ចាស់ (លូកា 6:26)។

ទីពីរ ទ្រង់បានទាមទាររកការស្បថស្បែ។ ខ 16-20 បង្ហាញថាទ្រង់បានបាត់បង់សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់។ បើទោះជាទ្រង់បានរីករាយនឹងសេចក្តីសុខសាន្តនិងភាពបរិបូរយ៉ាងខ្ជាប់ខ្ជួនក៏ដោយ កូនប្រុសរបស់ទ្រង់ ម៉ាណាសេ ត្រូវបានដាក់ទោសដោយព្រះអម្ចាស់យ៉ាងធ្ងន់ធ្ងរ។ ជាការសំខាន់ណាស់នៅក្នុងការទទួលការហ្វឹកហាត់ខាងសេចក្តីជំនឿនៅក្នុងការគ្រប់គ្រងព្រះគុណរបស់ព្រះអម្ចាស់នៅក្នុងព្រះគ្រីស្ទ។

**14.អំពើរបាបរបស់ម៉ាណាសេ (ពង្សាវតារក្សត្រទី2, 21:1-26)**

ម៉ាណាសេបានហាមការកែទម្រង់ខាងសាសនាដោយចាប់ផ្តើមពីឪពុករបស់ទ្រង់ហេសេគា ហើយបានត្រឡប់ទៅកាន់ទីដើមដែលជាការថ្វាយបង្គំព្រះក្លែងក្លាយ។

ទីមួយ ទ្រង់បានដើរតាមការថ្វាយបង្គំព្រះក្លែងក្លាយរបស់អ័ហាប (3)។ ទ្រង់មិនបានដើរតាមចំណុចល្អរបស់ឪពុករបស់ទ្រង់ទេ ប៉ុន្តែបានត្រឡប់រកអំពើបាបរបស់ស្តេចអ័ហាបវិញ។ ការចាត់ចែងការស្មងតំណែងជាការសំខាន់ជាងការគ្រប់គ្រងទៅទៀត។ បើទោះជានៅក្នុងពេលមានសន្តិភាពក៏ដោយ ប្រសិនបើទំនាក់ទំនងជាមួយព្រះអម្ចាស់ត្រូវបំផ្លាញ នោះការអន្តរាយដ៏ធំនឹងមកកាន់យើង។

ទីពីរ ត្រង់បានបំផ្លាញក្រឹត្យវិន័យនៃតួរនាទីស្តេចចោល។ ទ្រង់បានធ្លាក់ចុះនៅក្នុងការបំផ្លាញសាសនា ដោយការមើលងាយគ្រប់ទាំងស្តង់ដារនិងកម្រិតនៃសេចក្តីជំនឿដ៏ត្រឹមត្រូវរបស់ទ្រង់។

ទីបី ទ្រង់បានធ្លាក់ចុះទៅកាន់សភាពដែលជ្រុលហួសនៃការបំផ្លាញសង្គម (10-11)។ ដោយសារការមិនគោរពកោតខ្លាចដល់ព្រះបានបង្កើតមកនូវសេចក្តីទុច្ចរិត ដែលអ្នកដឹកនាំរបស់យូដាបានធ្លាក់ចុះទៅក្នុងការវិនាសយ៉ាងធ្ងន់ (16)។ នៅក្នុងពេលមានសន្តិភាពដោយការសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះយើងត្រូវតែទទួលបានការការពារចេញពីបាបរបស់យើងហើយរីករាយនឹងព្រះគុណដ៏បរិបូរណ៍។

**15. ការផ្លាស់ប្រែដែលលម្អិត (ពង្សាវតារក្សត្រទី2, 23:1-20)**

តើការកែទម្រង់អ្វីដែលអម្ចាស់បានគ្រប់គ្រងទាំងនៅពេលធ្លាក់ចុះនិងការងើបឡើងនៅក្នុងប្រវត្តិសាស្ត្រ?

ទីមួយ ទ្រង់បានដកគ្រប់ទាំងព្រះក្លែងក្លាយនិងទីថ្វាយបង្គំរបស់វាចេញ។ មានព្រះបាល អាសេរ៉ា ថ្ងៃនិងខែ ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ ផ្កាយទាំង12 ព្រះម៉ូឡុក ព្រះសាថារូថ (ស៊ីដូន), ហេ្គមូស (ម៉ូអាប់) មីលកុន (អាម៉ូន) និងទីខ្ពស់ៗនិងផ្ទះរបស់គេ។ វាមានន័យថាសេចក្តីល្បួងដែលនាំឱ្យចាកចេញពីព្រះអម្ចាស់ត្រូវបានដកចេញ។

ទីពីរ ទ្រង់បានបង្កើតអាសនា។ ទ្រង់ដឹងថាការកែទម្រង់ពិតជាការត្រឡប់ទៅរកព្រះបន្ទូលរបស់ព្រះអម្ចាស់ដោយការបង្កើតទីបរិសុទ្ធជាថ្មី ហើយបង្រៀនព្រះបន្ទូលរបស់ព្រះទៅកាន់មនុស្ស។ ការបកប្រែគម្ពីរនៅក្នុងប្រវត្តិសាស្ត្រនិងការបង្រៀនដល់អ្នកផ្សេងដើម្បីអនុវត្តតាមនៅក្នុងជីវិត។

16. **ចូរយើងវាយទាស់នឹងអំពើបាប** (**ពង្សាវតារក្សត្រទី2, 23:31-24:7)**

អំពើបាបជាសកម្មភាពទាំងឡាយដែលទាសចេញនិងរំលងពី និងការដែលខ្វះមិនដល់ចំណុចកណ្ដាលដែលជាបំណងព្រះហឫទ័យរបស់ព្រះ។ ការគ្រប់គ្រងរបស់អេលាគីមនិងយ៉ូសៀបានធ្វើឱ្យយើងដឹងពីការដ៏អាក្រក់របស់អំពើបាប។

ទីមួយ តើអំពើបាបអាក្រក់ប៉ុណ្ណា? ពីព្រោះអំពើបាបរបស់ម៉ាណាសេបានធ្វើឱ្យកំហឹងរបស់ព្រះបានកើនឡើង នោះវាបានលុបបំបាត់នូវការកែទម្រង់របស់យ៉ូសៀ ហើយវាបានធ្វើឱ្យមានការឈ្លានពានមកពីអេស៊ីបនិងបាប៊ីឡូន (1-4, 32)។ អំពើបាបជាការដែលគួរឱ្យខ្លាច។

ទីពីរ តើយើងប្រឆាំងនឹងអំពើបាបដោយរបៀបណា? ជាការសំខាន់នៅក្នុងការដកព្រះក្លែងក្លាយចេញ ប៉ុន្តែការដែលសំខាន់ជាងនោះគឺជាការរក្សាពិធីបុណ្យរំលងរបស់អ៊ីស្រាអែល។ យើងត្រូវតែប្រយត្ននឹងអាកប្បកិរិយាពីសេចក្ដីពុករលួយខាងសាច់ឈាមនៅក្នុងខាងក្នុងចិត្តរបស់យើងនៅពេលដែលផ្ការីកលេចមក។ អ្នកដែលដើរតាមទស្សនៈរបស់សាវ័កប៉ូល "ខ្ញុំស្លាប់រាល់តែថ្ងៃ" ដែលគាត់ជាអ្នកដែលមានជ័យជម្នះ។ នៅពេលដែលយើងព្យាយាមវាយទាស់នឹងអំពើបាបខាងសាច់ឈាមជាជាងលោកិយនិងសាតាំង(លូកា9:23)។ចូរយើងធ្វើតាមវិធីនេះ

17.**ការអាក្រក់របស់សេដេគា**(**ពង្សាវតារក្សត្រទី2,24:8-25:7)**

យើងអាចរៀនពីសារៈសំខាន់នៃព្រះបន្ទូលរបស់ព្រះតាមរយៈការវិនាសរបស់យូដា។

ទីមួយ លទ្ធផលនៃការមិនស្ដាប់បង្គាប់ – សេដេគាបានបាត់បង់ភ្នែកទាំងសងរបស់ទ្រង់ ហើយត្រូវបានចាប់ខ្លួនទៅកាន់បាប៊ីឡូន ដោយសារការចាកចេញពីព្រះអម្ចាស់ (19)។ អ្នកដែលនៅជាប់នឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាអ្នកដែលមានពរពិត (យ៉ូហាន 1:7)។ យើងត្រូវតែមើលទៅកាន់សេចក្ដីអាក្រក់របស់សេដេគា ហើយត្រូវត្រឡប់តៅកាន់ការស្ដាប់បង្គាប់វិញ។

ទីពីរ យើងត្រូវតែដាក់ជីវិតរបស់យើងនៅលើព្រះបន្ទូលរបស់ព្រះអម្ចាស់។ ខ 13 បានប្រកាស

ថា គ្រប់ការទាំងអស់គួរតែបានសម្រេចជាព្រះបន្ទូលរបស់ព្រះ។ យើងមិនបានរស់នៅជារបស់ដែលមើលឃើញនោះទេ ប៉ុន្តែរស់នៅក្នុងអាណាចក្រព្រះដែលមើលមិនឃើញវិញ ហើយសេចក្តីសុចរិតដោយការដើរតាមតម្លៃរបស់នគររបស់ព្រះ តាមរយៈការបើកសម្តែងនៃបទគម្ពីរ។ដូចដែលសាវ័កប៉ូលបានធ្វើ នៅពេលដែលយើងចុះចូលនឹងព្រះអម្ចាស់និងព្រះបន្ទូលទ្រង់ (កិច្ចការ 20:23)។ ជាចុងក្រោយ យើងអាចសារភាពថា ខ្ញុំបានបញ្ចប់ផ្លូវដែលខ្ញុំគួរតែរត់(ធីម៉ូថេទី24:7)។

**18.លទ្ធផលនៃអំពើបាប(ពង្សាវតារក្សត្រទី2, 25:8-30)**

ព្រះអម្ចាស់បានអនុញ្ញាតឱ្យមានការច្របូកច្របល់ ដែលព្រះវិហារនិងវាំងត្រូវបានដុតចោល ហើយសម្ភារៈរបស់ទីបរិសុទ្ធត្រូវបានរឹបអូសដោយការលុកលុយរបស់បាប៊ីឡូន។ ចេញពីសភាពនេះដែលត្រូវបានបាត់បង់រសជាតិប្រៃ នោះយើងអាចរៀនការពីរយ៉ាង។

ទីមួយ ដោយសារការមិនស្តាប់បង្គាប់ព្រះ ពួកគេត្រូវបានចាប់ខ្លួននៅក្នុងការច្របូកច្របល់យ៉ាងអាម៉ាស់ (12, 21-25)។ ប្រព័ន្ធនៃការច្របូកច្របល់ដែលអ៊ីស្មាអែលបានសម្លាប់គេដាលា ហើយបានរត់ទៅអេស៊ីប បង្ហាញពីការមិនស្តាប់បង្គាប់នាំមកនូវបញ្ហាដល់ពួកគេ។

ទីពីរ យើងអាចឃើញថាព្រះអម្ចាស់បានផ្តល់សេចក្តីសុខសាន្តដល់ពួកគេ។ យេហូយ៉ាគីន ដែលជាស្តេចត្រូវបានបាត់បង់សញ្ជាតិខ្លួន ដែលត្រូវបានជាស្តេចអស់រយៈពេល 37ឆ្នាំ (27-28)។ នៅពេលដែលត្រួយមួយលេចមក ព្រះហស្ថរបស់ព្រះអម្ចាស់បានធ្វើការនៅក្នុងទឹកដីរបស់សាសន៍ដទៃ ដោយការរក្សាសេចក្តីសន្យារបស់ព្រះជាបន្ត។ បើទោះជាលោកិយបានធ្លាក់ចុះទៅក្នុងភាពច្របូកច្របល់និងងងឹតក៏ដោយ តែសេចក្តីសន្យារបស់ព្រះអម្ចាស់នឹងត្រូវបានបង្កើតឡើងនៅក្នុងលោកិយ។

**IV. របាក្សត្រទី 1**

**សេចក្តីផ្តើម**

ការអធិស្ឋានរបស់យ៉ាបេស (4:8-10) បានក្លាយជាចំណងជើងមួយដែលគួរឱ្យចាប់អារម្មណ៍

នៅក្នុងពេលបច្ចុប្បន្ននៅក្នុងពិភពរបស់គ្រីស្ទានពេលនេះ។ លោក Wilkerson ដែលជាគ្រូគង្វាលនៅក្នុងរដ្ឋ Chicagoនៅសហរដ្ឋអាមេរិកបានសរសេរសៀវភៅតូចមួយ *"សេចក្តីអធិស្ឋានរបស់យ៉ាបេស"* ហើយបានបោះពុម្ពទៅកាន់គ្រីស្ទាននៅលើពិភពលោក។ ខ្លឹមសារផ្ទុកទៅដោយការដែលសមហេតុផល ទ្រឹស្តីនៃភាពចម្រុងចម្រើននិងសម្ភារៈនិយម។ វាមានសំដៅធ្វើឱ្យគ្រីស្ទានដេញតាមរបស់របរខាងក្រៅនិងមានទំនោរទៅកាន់ពេលបច្ចុប្បន្ន ទាំងនោះមាន ៖ ការគិតវិជ្ជមាន ការដែលគិតថាអាចធ្វើបាបជាដើម។ ខ្ញុំចង់ចាំថាខ្ញុំបានអនុវត្តការអធិស្ឋានរបស់គាត់ (ការព្យាបាលជម្ងឺ ការរកលុយ ទ្រព្យសម្បត្តិ កិត្តិយសជាដើម) ដូចដែលយ៉ាបេសអធិស្ឋានជារៀងរាល់ថ្ងៃ។ ជាចុងក្រោយព្រះអម្ចាស់បានឆ្លើយតបមកគាត់។ ដូច្នេះគាត់បានអះអាងថាអ្នកណាដែលដើរតាមគោលការណ៍នៃការអធិស្ឋានរបស់យ៉ាបេសនឹងទទួលបានជោគជ័យ ចម្រុងចម្រើន និងមានសុខភាពដ៏អស្ចារ្យ និងទ្រព្យសម្បត្តិជាច្រើនជាដើម។ តើអ្នកគិតយ៉ាងណាដែរពីការនេះ? តើព្រះគម្ពីរពិតជាបានបង្រៀនថានឹងរក្សាយើងខាងសុខភាពខាងរូបកាយ កេរ្តិ៍ឈ្មោះដែលគេគោរព និងទំនាក់ទំនងដែលល្អបំផុត? តើយ៉ាបេសដើរតាមការយល់បែបនោះនៅក្នុងជីវិតរបស់គាត់ឬទេ? មិនមែនឡើយ ការអធិស្ឋានរបស់យ៉ាបេសជាការផ្តោតលើព្រះអម្ចាស់ជាចំណុចកណ្តាលនៃការអធិស្ឋានរបស់ព្រះ ដូចជាការអធិស្ឋានរបស់អាគើដែរ (សុភាសិត 30:7-8) និងការអធិស្ឋានរបស់ព្រះអម្ចាស់។

ជាទូទៅយ៉ាបេសដែលឈ្មោះនេះមានន័យថា "ការឈឺចាប់" បានលេចមកនៅតែនៅក្នុង របាក្សត្រទី1 4:9-10។ ជាពិសេសសៀវភៅទីមួយនៃរបាក្សត្ររៀបរាប់ពីព្រឹត្តិការណ៍ប្រវិត្តសាស្រ្តចាប់ពីរាជរបស់ស្តេចសូលនិងការវិនាសរបស់អ៊ីស្រាអែលទាំងនោះមាន សូល ដាវីឌ សាឡូម៉ូន និងយេរូបោមដែលជាអ្នកបំបែកអ៊ីស្រាអែលជាពីរផ្នែក ខាងជើងជាអ៊ីស្រាអែលនិងខាងត្បូងជាយូដា។ អ្នកនិពន្ធបានសរសេរពីប្រវត្តិរបស់យ៉ាបេសនៅក្នុងជំពូកទី 4 ហើយបានបង្ហាញពីរូបភាពននៅក្នុងរាជស្តេចដាវីឌ។ ខ 8-9 បង្ហាញពីប្រវត្តិរបស់យ៉ាបេស ហើយខ 10 បានបិទជាមួយព្រឹត្តិការណ៍អស្ចារ្យមួយនៅក្នុងជីវិតរបស់គាត់ ដើម្បីឱ្យអ្នកអានអាចផ្តោតលើសារៈសំខាន់នៃសេចក្តីជំនឿរបស់គាត់ដែលមានសេចក្តីកោតខ្លាចដល់ព្រះអម្ចាស់។

**ទីមួយ តើយ៉ាបេសជានរណា? (8-9) –** Keil បានគិតថាគាត់ជាមនុស្សម្នាក់ដែលដែលគេឱ្យតម្លៃ ពីព្រោះជាឈ្មោះមួយនៅក្នុងយូដា (2:55) ដោយផ្អែកលើឈ្មោះរបស់គាត់ ហើយ

គាត់បានពន្យល់ថាយ៉ាបេសជាម្នាក់នៅក្នុងចំណោមកូនៗរបស់ ខូស (អានុប សូប៊ីបា និងអាហាហេល 4:8 "ខូសជាឪពុករបស់អានុប សូប៊ីបា និងកុលសម្ព័ន្ធហារុម") ម្ដាយរបស់គាត់ហាក់បីដូចជាមិនទទួលបានការគោរពអ្វីឡើយ ហើយអាចជាមានទុក្ខលំបាកជាច្រើននៅក្នុងជីវិតរបស់នាង។ ប្រៀបបីដូចជាឈ្មោះរបស់ស៊ីម៉ូននិងលេវីដែរ ដែលបង្ហាញពីការលំបាកនៅក្នុងចិត្តដែល លេអានិងរ៉ាឆែលបានគិតនៅក្នុងទំនាក់ទំនងជាមួយយ៉ាកុប។ នៅទីនេះមនុស្សគួរឱ្យគោរពមានន័យថាជាម្នាក់ដែលមានសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់ និងប្រាជ្ញារបស់ព្រះអម្ចាស់ដែលគាត់មានពិសោធន៍នៅក្នុងសេចក្ដីទុក្ខលំបាកនាងពេលបច្ចុប្បន្ន។ (សុភាសិត 3:8-*9* នោះនឹងបានជាសេចក្ដីសុខស្រួលដល់សរសៃឯង ហើយជាធាតុសើមដល់ឆ្អឹងឯង។ ចូរថ្វាយកិត្តិនាមដល់ព្រះយេហូវ៉ា ដោយទ្រព្យសម្បត្តិ ហើយនឹងផលដំបូង ពីសេចក្ដីចម្រើនរបស់ឯងទាំងអំបាលម៉ានចុះ។)

នៅទីនេះ យើងឃើញឧទាហរណ៍នៃជំនឿដែលមានការកោតខ្លាចដល់ព្រះរបស់យ៉ាបេសដែលនៅក្នុងសេចក្ដីទុក្ខលំបាកជាខ្លាំង។ មនុស្សជាច្រើនតែងរអ៊ូរទាំពីជីវិតបច្ចុប្បន្នរបស់គេ សេចក្ដីទុក្ខលំបាករបស់គេ គ្រួសាររបស់គេ សញ្ជាតិរបស់គេ ហើយនឹងព្រះ ពីព្រោះដោយសារសេចក្ដីទុក្ខលំបាកនាពេលបច្ចុប្បន្នរបស់គេ។ ហើយពួកគេមានការបាក់ខកចិត្តដោយបញ្ហាមួយចំនួន សុខភាព ទ្រព្យសម្បត្តិ គ្រួសារ និងការវេទនាដដែលៗ។ នៅក្នុងជីវិតគ្រីស្ទានរបស់ពួកយើង យើងបានជួបបញ្ហាលំបាកជាច្រើន ហើយបន្ទាប់មកយើងអាចចង់ចាំពីព្រះគុណរបស់ព្រះអម្ចាស់នៅក្នុងយ៉ាបេស ដែលជាអ្នកមានទុក្ខលំបាកម្នាក់។ បើទោះជាគាត់បានរស់នៅក្នុងលក្ខខណ្ឌដ៏អាក្រក់ក៏ដោយ ជីវិតរបស់គាត់ខុសពីអ្នកដែលមានជីវិតដែលល្អ។ តើមានន័យយ៉ាងណាដែរ? ដូចអ្វីដែលប៉ូលបានសង្កត់ធ្ងន់មកយើងថា យើងអាចធ្វើគ្រប់ការទាំងអស់បាននៅក្នុងព្រះគ្រីស្ទយេស៊ូវ នៅក្នុងការអត់ឃ្លាន និងនៅក្នុងភាពបរិបូរណ៍។ តើអ្នកជឿលើការនេះឬទេ? ជាពិសេសនៅពេលដែលយើងសញ្ជឹងគិតជីវិតរបស់គាត់ យើងគិតពីទុក្ខលំបាករបស់ព្រះយេស៊ូវគ្រីស្ទ ព្រះអម្ចាស់របស់យើង។ ហេតុអ្វី? ព្រះយេស៊ូវគ្រីស្ទបានយាងមកនៅក្នុងលក្ខខណ្ឌមួយដែលអាក្រក់នៅក្នុងលោកិយ៍ ប៉ុន្តែទ្រង់បានសម្រេចការប្រោសលោះសម្រាប់យើងដោយការសុគតរបស់ទ្រង់និងការរស់ឡើងវិញ។ ដូច្នេះយើងគួរតែមើលទៅព្រះគ្រីស្ទតាមរយៈជីវិតរបស់យ៉ាបេស។

**ទីពីរ តើអ្វីទៅជាព្រះពរដ៏មានកិត្តិយសរបស់គាត់? -** យើងអាចរកឃើញចំណុចជើងបីនៅក្នុងការអធិស្ឋានរបស់គាត់។" "ឱបើទ្រង់នឹងប្រទានពរមកទូលបង្គំទៅអេះ ព្រមទាំងវាតព្រំដែនរបស់ទូលបង្គំឱ្យទូលាយឡើង ហើយឱ្យព្រះហស្តទ្រង់បាននៅជាមួយនឹងទូលបង្គំ ដើម្បីនឹងរក្សាទូលបង្គំ មិនឱ្យប្រព្រឹត្តអាក្រក់ឡើយ ប្រយោជន៍មិនឱ្យទូលបង្គំកើតចិត្តព្រួយ" (10)។ ការអធិស្ឋានទីមួយជាព្រះពរដែលត្រូវបានពង្រីកឡើង "ឱបើទ្រង់នឹងប្រទានពរមកទូលបង្គំទៅអេះ ព្រមទាំងវាតព្រំដែនរបស់ទូលបង្គំឱ្យទូលាយឡើង– គាត់បានសុំឱ្យទឹកដីរបស់គាត់បានធំឡើងដោយសារព្រះអម្ចាស់។ ដូចដែលយ៉ូសែបបានទទួលទឹកដីយ៉ាងធំកាលដែលដើមទំពាំងបាយជូរបានវាឡើងលើជញ្ជាំង គាត់ចង់បានទឹកដីដែលជោគជ័យនិងចម្រុងចម្រើន។ ព្រះពររបស់អ័ប្រាហាំរាប់បញ្ចូលទាំងព្រះពរនេះដែរ។ ដូចដែលយើងបានដឹងហើយថាអ័ប្រាហាំមានទ្រព្យសម្បត្តិជាច្រើន ស្តេចដាវីឌមានភាពជាស្តេច ហើយសាឡូម៉ូនមានជាបរិបូរណ៍ (ប្រាជ្ញា និងសម្ភារ:) បើទោះជាសាវ័កប៉ូលមិនមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងសុខភាពក៏ដោយ គាត់បានអះអាងថាគាត់អាចធ្វើគ្រប់ការទាំងអស់បាននៅក្នុងជីវិតរបស់កាត់សម្រាប់ព្រះគ្រីស្ទ។ តើអ្វីទៅជាអាថ៌កំបាំងរបស់គាត់? វាជាការនៅជាប់នឹងព្រះគ្រីស្ទ។

ដូច្នេះយើងត្រូវការសូមការដែលចាំបាច់នាពេលបច្ចុប្បន្ននេះទៅកាន់ព្រះ ហើយតាមបំណងរបស់ទ្រង់។ យើងត្រូវសុំដល់ព្រះនូវប្រាជ្ញា ជំនាញ លុយ និងសុខភាពដើម្បីថ្វាយសិរីល្អដល់ព្រះអម្ចាស់។ យើងត្រូវអនុវត្តគោលការណ៍នេះនៅក្នុងការត្រាស់ហៅរបស់យើង ការផ្សាយដំណឹងល្អនៅក្នុងប្រទេសយើង គ្រួសារយើង និងភូមិរបស់យើង ដោយការស្វែងរកព្រះគុណោរបស់ព្រះជាម្ចាស់ជាមួយមាត់បើកធំ។ ហេតុអ្វី? ព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងចិត្តរបស់យើងតាមរយ:ប្រាថ្នាដែលបរិសុទ្ធ (ភីលីព 2:12-13)។ បានជាឱពួកស្ងួនភ្ងាអើយ ចូរបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា ដោយកោតខ្លាច ហើយញាប់ញ័រចុះ ដូចជាបានស្តាប់បង្គាប់ខ្ញុំជាដរាបរៀងមកដែរ មិនមែនតែកាលខ្ញុំនៅជាមួយនោះទេ សូម្បីឥឡូវនេះដែលខ្ញុំមិននៅជាមួយ នោះក៏ចូរខំប្រឹងលើសទៅទៀតផង។ ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នាឱ្យមានទាំងចំណង់ចង់ធ្វើ ហើយឱ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ។

តើអ្វីទៅជាក្តីស្រម៉ៃរបស់អ្នក? តើអ្វីទៅជានិម្មិតរបស់អ្នក? តើអ្វីទៅជាគោលបំណងសម្រាប់ព័ន្ធកិច្ចរបស់អ្នក?ដោយមិនមាននិម្មិតសម្រាប់ព្រះគ្រីស្ទ នោះអ្នកនឹងត្រូវវិនាស។ យើងត្រូវតែ

ត្រួតពិនិត្យនិម្មិតរបស់យើង វិញ្ញាណរបស់យើងនៅក្នុងចិត្ត។ ខ្ញុំជម្រុញថាអ្នកគួរតែមានក្តីស្រម៉ៃដូចតទៅ ប្រាជ្ញាដ៏អស្ចារ្យនៅក្នុងការប្រកាសដំណឹងល្អនៅកម្ពុជា ជាគំរូដ៏ល្អនៅក្នុងការគោរពកោតខ្លាចដល់ព្រះនៅក្នុងក្រុមជំនុំ និងវិធីសាស្ត្រនៅក្នុងការផ្សាយដំណឹងល្អនៅក្នុងការបំបែកសាសនាជាច្រើននៅក្នុងប្រទេសកម្ពុជា។

ការអធិស្ឋានទីពីរជាព្រះពរដែលបានផ្តល់មកពីទុក្ខលំបាក់ដែលគាត់កំពុងមាន–"ដើម្បីនឹងរក្សាទូលបង្គំ មិនឱ្យប្រព្រឹត្តអាក្រក់ឡើយ ប្រយោជន៍មិនឱ្យទូលបង្គំកើតចិត្តព្រួយ" គាត់អាចជាជួបសេចក្តីទុក្ខវេទនាមួយចំនួនខាងសុខភាព បញ្ហាលុយកាក់ បញ្ហាទំនាក់ទំនង និងបញ្ហាកូនៗរបស់គាត់ជាដើម។ ពួកគេនិយាយថា "ប្រសិនបើអ្នកទទួលបានការដែលខ្លួនពេញចិត្តនោះត្រូវតែសរសើរដល់ព្រះអម្ចាស់ ប៉ុន្តែបើអ្នកមានទុក្ខលំបាកវិញ នោះគួរតែអធិស្ឋានដល់ទ្រង់" ព្រះអម្ចាស់នឹងឆ្លើយតបនូវការយ៉ាងអស្ចារ្យដល់អ្នក។"

យ៉ាកុប 1: 5-6 មានបន្ទូលថា "តែបើអ្នកណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឱ្យ តែត្រូវឱ្យអ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ដ្បិតអ្នកណាដែលសង្ស័យ នោះប្រៀបដូចជារលកសមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំងរំពើកចុះឡើង។" ប្រសិនបើយើងមានការលំបាកនៅពេលនេះ ការឈឺចាប់នៅក្នុងជីវិតរបស់យើង នោះយើងអាចសូមការនោះដល់ព្រះជាម្ចាស់ ដូចជាយ៉ាបេសបានសូមដែរ។ ពីឆ្នាំមុខខ្ញុំបានធ្លាក់ចុះនៅក្នុងបញ្ហានៅក្នុងជីវិតរបស់ខ្ញុំ។ បន្ទាប់មកខ្ញុំបានចង់ចាំទុក្ខលំបាក ការឈឺចាប់នៅក្នុងចិត្តរបស់ខ្ញុំនិងនៅក្នុងក្រុមគ្រួសាររបស់ខ្ញុំ។ ខ្ញុំមានការលំបាកអស់រយៈពេលពីរឆ្នាំ។ ជាក់ស្តែងពេលនេះខ្ញុំអាចសារភាពថាព្រះអម្ចាស់បានផ្តល់ព្រះគុណរបស់ទ្រង់ដល់ខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំ។ ខ្ញុំប្រាកដថាព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់យើងជាប្រាកដ ហើយបានផ្គត់ផ្គង់ព្រះគុណដ៏អស្ចារ្យដល់យើងតាមពេលកំណត់។ ប្រសិនបើអ្នកមានបញ្ហាដែលមិនអាចទៅរួចនៅក្នុងជីវិតពេលនេះ ចូរសូមពីការនោះ ចូរស្វែងរក និងគោះទ្វារផង។ ព្រះអម្ចាស់បានរៀបចំព្រះគុណយ៉ាងអស្ចារ្យដល់យើង។ ព្រះអម្ចាស់នឹងឆ្លើយតបដោយព្រះគុណដ៏អស្ចារ្យដល់យើង។ បើទោះជាអ្នកមិនអាចមើលឃើញការនោះ ហើយអ្នកមិនអាចស្តាប់ទៅកាន់ដ៏អស្ចារ្យបានក៏ដោយ តែចូរជឿថាព្រះអម្ចាស់កំពុងរង់ចាំស្តាប់ការអធិស្ឋានរបស់អ្នក។

ការអធិស្ឋានទីបីជាព្រះពរដែលរីករាយនៅក្នុងសេចក្ដីសុខសាន្តនៅក្នុងព្រលឹង - "ហើយព្រះហស្តទ្រង់នឹងនៅជាមួយនឹងទូលបង្គំ" ស្នូលនៃគ្រប់បញ្ហាទាំងអស់ជាបញ្ហារបស់ព្រលឹងរបស់យើង។ យើងត្រូវតែស្វែងរកដើម្បីធ្វើឱ្យព្រលឹងរបស់យើងបានល្អ។ យ៉ូហានទី3 1:2 មានបន្ទូលថា "អ្នកស្ងួនភ្ងាអើយ ខ្ញុំប្រាថ្នាចង់ឱ្យអ្នកបានចំរើនឡើងគ្រប់ជំពូក ហើយឱ្យបានសុខសប្បាយខាងរូបសាច់ ដូចជាព្រលឹងអ្នកបានចម្រើនឡើងដែរ"។ អត្ថបទនេះបានផ្ដោតលើការរស់នៅល្អខាងព្រលឹង។ តើមានន័យដូចម្ដេច? តើការរស់នៅល្អខាងព្រលឹងជាអ្វី? និយាយដោយខ្លី វាជាភាពពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធនៅក្នុងព្រលឹងរបស់យើង។ នៅពេលដែលយើងពេញដោយព្រះវិញ្ញាណបរិសុទ្ធ នោះព្រលឹងរបស់យើងនឹងបានល្អឡើង។ (អេភេសូ 5:18) "កុំឱ្យស្រវឹងស្រា ដែលនាំឱ្យព្រើលចិត្តឡើយ តែចូរឱ្យមានពេញដោយព្រះវិញ្ញាណវិញ។" វាជាប្រភពនៃព្រះពររបស់យើង។ ដូច្នេះយើងគួរតែស្រេកឃ្លានសម្រាប់ការនោះគ្រប់ពេលនៅក្នុងជីវិតយើងនេះ ដូចជាអេលីសេបានធ្វើនៅក្នុងសញ្ញាចាស់។ យោងតាមពង្សាវតារក្សត្រទី 2 2: ហេតុអ្វីបានជាអេលីយ៉ាស្វែងរកចំណែកនៃការបើកសម្ដែងពីអេលីយ៉ា? និយាយដោយខ្លី គឺដើម្បីនឹងរក្សាគោលលិទ្ធិដ៏ត្រឹមត្រូវរបស់គាត់នៅក្នុងពេលមានទុក្ខលំបាក គាត់បានសូមព្រះគុណដ៏អស្ចារ្យនៅក្នុងជីវិតរបស់គាត។ ចូរក្រលេកមើលបំណងរបស់គាត់និងការស៊ូទ្រាំរបស់កាត់ដើម្បីទទួលបានព្រះគុណមកពីព្រះ។ តើអ្នកចង់បានអ្វី? គាត់បានឆ្លើយថាខ្ញុំត្រូវការចំណែកទ្វេរដងនៃការបើកសម្ដែងរបស់អ្នក។ ខ្ញុំគិតថាយើងត្រូវតែយល់ហេតុផលបីយ៉ាង នៅក្នុងការស្វែងរកភាពពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធដើម្បីនឹងទ្រទ្រង់ដល់សេចក្ដីជំនឿដែលត្រឹមត្រូវនៅក្នុងពេលដែលមានទុក្ខលំបាក។ ហើយយើងត្រូវការសុខភាពតាមរយៈព្រះគុណទូទៅ។ ហើយយើងត្រូវតែថ្វាយខ្លួនដើម្បីនឹងធ្វើតាមការត្រាស់ហៅរបស់ព្រះអម្ចាស់។ អ្នកដែលនៅក្នុងព្រះបន្ទូលរបស់ព្រះគួរតែជាអ្នកដែលអធិស្ឋាន។ ជាការពិតណាស់ សភាពនៃការអធិស្ឋាននៅក្នុងព្រលឹងគឺជាព្រះពរ។ ដូច្នេះព្រះអម្ចាស់បានថវាយតម្លៃការអធិស្ឋានរបស់យ៉ាបេសថាជាមនុស្សដែលមានគេគោរព ពីព្រោះព្រលឹងរបស់គាត់បង្ហាញពីរូបឆ្លុះយ៉ាងស្រស្អាត់របស់ព្រះអម្ចាស់ ជាសេចក្ដីសុចរិត សេចក្ដីមេត្តា និងភាពបរិសុទ្ធ។

**ទីបី តើព្រះអម្ចាស់បានឆ្លើយតបទៅនឹងយ៉ាបេសដោយរបៀបណា? -** ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលដោយសាមញ្ញថា "*ហើយព្រះអម្ចាស់បានផ្តល់អ្វីៗដែលគាត់បានសូម* "។ ព្រះអម្ចាស់របស់អ៊ីស្រាអែលបានអនុញ្ញាតអ្វីៗដែលគាត់បានសូម។ អ្វីដែលសំខាន់ដែលគាត់មិនបានក្លាយជាមនុស្សខាងវប្បធម៌ មនុស្សដែលស្រឡាញ់លុយ និងមនុស្សតាមសុខភាពឡើយ ប៉ុន្តែជាមនុស្សដែលពេញដោយការអធិស្ឋាន។ គាត់ស្គាល់ពីពិភពនៃការអធិស្ឋានបានយ៉ាងល្អ។ ហើយគាត់បានប្រាកដថាព្រះពរដ៏សំខាន់បំផុតជាទំនាក់ទំនងដ៏រស់ជាមួយព្រះអម្ចាស់នៅក្នុងជីវិតអស់កល្បជានិច្ច។ គាត់បានដេញតាមគម្រូនៃការអធិស្ឋានរបស់យ៉ាកុបនៅបេិតអែល។ កាលដែលព្រះពររបស់ព្រះបានឆ្លើយតបដល់យ៉ាកុប នោះយ៉ាបេសក៏បានទទួលព្រះគុណដ៏អស្ចារ្យ ការចម្រុងចម្រើន និងសុខភាពរូបរាងកាយ ព្រះទាំងមានសុខភាពល្អខាងព្រលឹងផងដែរ។ នេះជាបុរសដែលពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយក៏ជាបុរសដែលពេញដោយព្រះបន្ទូលដែរ ហើយជាបុរសដែលត្រូវបានស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងជីវិតបច្ចុប្បន្នរបស់គាត់។

**ក បញ្ជីពង្សានុវង្ស (1:-9:)**

**1. ម្នាក់ដែលគ្រប់គ្រងនៅលើពិភពលោក (របាក្សត្រទី1, 1:1-54)**

របាក្សត្រទី1 1:-9: សម្គាល់ពីបញ្ជីពង្សានុវង្សនិងជំពូក 10: - ទីបញ្ចប់នៃប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលពីស្តេចសូមមកដល់ដាវិឌ។ ជំពូក1 បាននិយាយពីលំហូរនៃប្រវត្តិសាស្ត្ររបស់មនុស្សតាំងពីលោកអាដាម។ ហើយបានបង្ហាញពីចេស្តាគ្រប់គ្រងរបស់ព្រះអម្ចាស់ដែលបានដឹកនាំរាស្ត្រនៃការតាំងសញ្ញា។

ទីមួយ វាត្រូវបានបង្ហាញដោយការដឹកនាំនៅក្នុងប្រវត្តិសាស្ត្រ។ តើប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលបានលូតលាស់នៅក្នុងព្រះគុណទូទៅយ៉ាងដូចម្តេច? វាបង្ហាញថាវាបានលូតលាស់នៅក្នុងជាតិសាសន៍ខាងសាច់ឈាម។ យ៉ាងណាក៏ដោយការញែករវាងការល្អនិងការអាក្រក់ ត្រូវបានបង្ហាញមកយ៉ាងច្បាស់ កាលដែលគោលការណ៍រវាងពូជល្អនិងពូជអាក្រក់។

ទីពីរ វាត្រូវបានបង្ហាញដោយកិច្ចការរបស់ព្រះអម្ចាស់។ នគរដែលប្រៀបបីដូចជាការលូត

លាស់ចេញពីគ្រាប់ពូជដ៏ល្អិតបន្តិចម្តងៗ ហើយបានគ្របពាសពេញផែនដីដោយអំណាចនៃសេចក្តីសុចរិតនិងសេចក្តីសុខសាន្ត (អេសាយ 9:6)។ ដូច្នេះយើងគួរតែរស់នៅដោយមានបំណងដឹងខ្លួនជានិច្ចពីនគរដែលបានមកដល់រួចហើយ ប៉ុន្តែមិនទាន់នៅឡើយ ពីព្រោះគ្រីស្ទានគួរតែស្វែងរកជីវិតរបស់គេជាមុខសិន។ (ម៉ាថាយ 6:33)

**2.ជីវិតដែលអនុវត្តសេចក្តីប្រោសលោះ (របាក្សត្រទី1, 2:1-17)**

ការកត់ត្រាដ៏ប្លែកដែលនៅក្នុងខ 1-17 បង្ហាញថាបញ្ជីពង្សានុវង្សរបស់យូដា ដែលដោយសារព្រះមេស៊ីនឹងយាងមកតាមរយៈពង្សានុវង្សនេះមកក្នុងផែនដី។ តើការកត់ត្រានេះបង្ហាញពីអ្វីនៃសេចក្តីប្រោសលោះ?

ទីមួយ វាបង្ហាញកិច្ចការដែលព្រះជាកណ្តាលដោយបង្ហាញពីការកាត់ទោសជាការសម្លាប់ដល់អើរ ដែលជាកូនទីមួយរបស់យូដា ដោយសារទង្វើដ៏អាក្រក់របស់គាត់នៅចំពោះព្រះ។ ទង្វើដែលទាស់នឹងការញែកចិត្តនិងឥរិយាបថនៃសេចក្តីប្រោសលោះ ដែលជាថ្នូជំពប់ទាស់នឹងផ្លូវរបស់ព្រះវិញ្ញាណបរិសុទ្ធ។

ទីពីរ ការពង្រាយពូជពង្សរបស់យូដាដែលផ្តោតលើសេចក្តីប្រោសលោះ(4) យើងរៀនថាប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះមិនបានពឹងផ្អែកលើចំណុចល្អរបស់មនុស្សតាមរយៈ ការពង្រាយពូជរបស់ថាម៉ានោះឡើយ។ បើទោះជាស្ត្រីសាសន៍សាម៉ារីនិងមារីម៉ាក់ដាលីនមានអារម្មណ៍មិនល្អដែលធ្លាក់នៅក្នុងសភាពមួយដែលមិនស្អាតក៏ដោយ តែកាលដែលគេរស់នៅតាមសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទ នោះពួកគេត្រូវបានប្រើជាចរន្ទសម្រាប់សេចក្តីប្រោសលោះ។ ចូរយើងផ្តោតជីវិតរបស់យើងនៅលើសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទវិញ។

**3.ពូជពង្សនៃសេចក្តីជំនឿ(របាក្សត្រទី1, 2:18-55)**

តើរូបភាពប្រភេទណាដែលយើងរកឃើញនៅក្នុងពង្សានុវង្ស?

ទីមួយ សេចក្តីជំនឿរបស់ស៊ូសាន (34) - ស៊ូសានដែលជាពូជពង្សរបស់ យេរ៉ាមូល ដែលត្រូវជាកូនប្រុសច្បងរបស់ហាសរូន ដែលមានតែកូនស្រីតែម្នាក់គត់ ហើយបានឱ្យកូនស្រីនោះទៅ

អ្នកបម្រើជនជាតិអេស៊ីបទៅធ្វើជាប្រពន្ធដែលជាលំនាំជាក់លាក់របស់ក្រុមគ្រួសារ។ គ្រួសារនៃសេចក្ដីជំនឿមិនពឹងផ្អែកលើឈាមរបស់មនុស្សនិងកិត្តិយសរបស់ក្រុមគ្រួសារនោះទេ ប៉ុន្តែជាព្រះគុណរបស់ព្រះវិញ។ ប្រសិនបើអំណឹងល្អមានបូកបញ្ចូលទាំងពូជពង្សរបស់គ្រួសារនិងកិត្តិយស នោះវាមិនតាមបទគម្ពីរនោះឡើយ។ កិច្ចការដែលមានព្រះហប្ញទ័យរបស់ព្រះជាកណ្ដាលនោះនឹងស្ថិតស្ថេរអស់កល្ប ពីព្រោះវាជាលក្ខខណ្ឌចម្បងដែលព្រះអម្ចាស់ប្រើ។

ទីពីរ សេចក្ដីជំនឿរបស់កាលេប (55) – កាលេបត្រូវបានព្រះអម្ចាស់ប្រើជាបុរសរបស់ព្រះយ៉ាងមានប្រយោជន៍ គាត់មានប្រពន្ធពីរ (46, 48) ចាប់ពីពង្សានុវង្សនេះកាលេបដែលមានសេចក្ដីជំនឿដែលល្អនៅក្នុងជីវិតរបស់គាត់។ ពួកគេមិនមានចម្ការទំពាំងបាយជូរឬផ្ទះសំបែងដើម្បីនឹងស្នាក់នៅនោះទេ ហើយបានរស់នៅក្នុងទីបរិសុទ្ធហើយមិនបានផឹងស្រាទំពាំងបាយជូរសោះ (Rem 35:5-11)។ ព្រះអម្ចាស់បានប្រើពួកគេដែលមានសេចក្ដីជំនឿពេញដោយការកោតខ្លាចដល់ព្រះអម្ចាស់។ ចូរយើងរស់នៅចំណុចកណ្ដាលនៃព្រះគុណនិងសេចក្ដីពិត។ ដើម្បីក្លាយជាសម្ភារៈរបស់ព្រះបន្ទូលរបស់ព្រះ។

**4.ពូជពង្សរបស់ដាវីឌ (របាក្សត្រទី1, 3:1-24)**

តាមរយៈពូជពង្សរបស់ស្ដេចដាវីឌ យើងអាចរកឃើញព្រះហស្តរបស់ព្រះអម្ចាស់ដែលបានដឹកនាំប្រវត្តិសាស្ត្រ ដោយគ្មានការពាក់ព័ន្ធនឹងចំណុចល្អរបស់មនុស្ស។ ការនេះបានចង្អុលបង្ហាញមកកាន់យើងអ្វីទៅ?

ទីមួយ ដាវីឌមានភាពល្បីល្បាញយ៉ាងខ្លាំង តែជីវិតគ្រួសាររបស់គាត់មានភាពស្មុគស្មាញណាស់។ ព្រះអម្ចាស់បានបង្ហាញពីព្រះគុណនៃសេចក្ដីប្រោសលោះ បោះទោះជាដាវីឌបានធ្លាក់ចុះនៅក្នុងការប្រព្រឹត្តសាហាយស្មន់និងការសម្លាប់ក៏ដោយ។ តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានសម្លឹងមើលកិច្ចការដ៏អស្ចារ្យនៅក្នុងសញ្ញាថ្មី ហើយបានរីករាយនឹងសេចក្ដីពិតនៅក្នុងដំណឹងល្អ។ យើងមានព្រះគុណនៃមការអត់ទោសបាបនៅក្នុងជីវិតរបស់យើង (រ៉ូម 4:7-8)។

ទីពីរ សាឡូម៉ូនក៏ជាស្ដេចដ៏អស្ចារ្យដែលមានប្រាជ្ញា ប៉ុន្តែបានបរាជ័យនៅក្នុងជីវិត

អាពាហ៍ពិពាហ៍ ហើយបានធ្វើឱ្យនគរនិងជាតិសាសន៍ទៅជាគោរពព្រះក្លែងក្លាយ។ ប៉ុន្តែការទាមទាររបស់ទ្រង់នោះជាការថ្វាយខ្លួនរបស់ទ្រង់ដល់ព្រះអម្ចាស់ ហើយស្វែងរកប្រាជ្ញាដែលបញ្ជាក់ថាគាត់មានសេចក្តីជំនឿដែលកោតខ្លាចដល់ព្រះជាម្ចាស់។ ការនេះបង្ហាញពីដំណឹងល្អនៃគម្ពីរសញ្ញាថ្មីដល់យើង ដោយការមើលថាអ្នកដែលគោរពព្រះក្លែងក្លាយត្រលប់មករកព្រះអម្ចាស់។ ការតាំងសញ្ញារបស់ព្រះអម្ចាស់នឹងត្រូវបានសម្រេចដោយមិនមានការយោគយល់ជាមួយមនុស្សសម្រាប់ទ្រង់នោះឡើយ។

**5.ការអធិស្ឋានរបស់យ៉ាបេស(របាក្សត្រទី1, 4:1-23)**

យ៉ាបេសជាបុរសម្នាក់មកពីកុលសម្ព័ន្ធយូដា ជាអ្នកដែលបានបង្ហាញពីគម្រូដ៏មានតម្លៃនៃការអធិស្ឋាន។ រូបភាពនៃការអធិស្ឋានបែបណាដែលគាត់មាន?

ទីមួយ គាត់ស្គាល់ពីអ្នកដែលគាត់អធិស្ឋានទៅយ៉ាងច្បាស់។ បើទោះជាគាត់បានកើតមកនៅក្នុងសភាពមួយដែលពេញដោយសេចក្តីឈឺចាប់ក៏ដោយ គាត់នៅតែអាចដឹងថា គាត់អាចអធិស្ឋានទៅព្រះរបស់អីស្រាអែល។ ដែលទ្រង់ជាព្រះអម្ចាស់របស់សហាគមនិងគាត់ប្រាកដថាព្រះយេហូវ៉ាជាព្រះជាម្ចាស់ផ្ទាល់របស់គាត់ ហើយគាត់បានថ្វាយបញ្ហារបស់គាត់ដល់ព្រះ។ នៅពេលដែលយើងសំណូមពរការអធិស្ឋានរបស់យើងទៅដល់ព្រះអម្ចាស់នៅក្នុងទីលាក់កំបាំង នោះព្រះអម្ចាស់ផ្ទាល់នឹងស្តាប់ការសុំរបស់យើង (9-10)។

ទីពីរ គាត់បានថ្វាយការអធិស្ឋានទៅដល់ព្រះបានយ៉ាងល្អ។ គាត់បានអធិស្ឋានថាទឹកដីរបស់គាត់នឹងបានរីកធំឡើង ហើយការលំបាករបស់គាត់និងការឈឺចាប់នឹងត្រូវរលាយបាត់ទៅ។ បើទោះជាគាត់មិនអាចស្តាប់ឮសំលេងដ៏តូចក៏ដោយ តែគាត់បានអធិស្ឋានការនោះទៅដល់ព្រះអម្ចាស់។ ការអធិស្ឋានដោយសេចក្តីជំនឿនឹងកើតឡើង (ហេព្រើរ 11:6)។

ទីបី ការអធិស្ឋានរបស់គាត់ត្រូវបានឆ្លើយតប ហើយគាត់ទទួលបានកិត្តិយស ពីព្រោះគាត់បានមានជ័យជម្នះនៅក្នុងការទំនាក់ទំនងជាមួយព្រះជាម្ចាស់នៅក្នុងជីវិតរបស់គាត់។ ជាលទ្ធផលព្រះអម្ចាស់បានឆ្លើយតបការសូមរបស់គាត់ជាបរិបូរណ៍។ ម្នាក់ដែលអធិស្ឋានទៅកាន់ព្រះអម្ចាស់ត្រូវតែក្លាយជាអ្នកដែលមានជ័យជម្នះ។

**6.ពង្សានុវង្សរបស់ស៊ីម្ម៉ូន(របាក្សត្រទី1, 4:24-43)**

យោងតាមព្រះគម្ពីរយេរេមា 17:5-8 បុរសដែលទុកចិត្តលើព្រះអម្ចាស់នឹងមានសេចក្ដីចម្រុងចម្រើនយ៉ាងហូរហៀរ ដែលជាដើមឈើដែលបង្កើតផលផ្លែនៅក្បែរផ្លូវទឹក។ តើរូបភាពអ្វីដែលពូជពង្សរបស់ស៊ីម្ម៉ូនមាន?

ទីមួយ បើទោះជាពូជពង្សនោះមានភាពចម្រុងចម្រើនខ្លាំងក៏ដោយ ពួកគេមិនមានមនុស្សដែលអស្ចារ្យឬទឹកដីដែលវិសេសអ្វីឡើយ។ ការខ្ចាត់ខ្ចាយពូជពង្សរបស់ខ្លួនកើតឡើងដោយសារអំពើបាបយ៉ាងឃោឃៅដែលគាត់បានប្រព្រឹត្តជាមួយពួកលេវីនៅក្រុងសិខេម។ នៅក្នុងលោកុប្បត្តិ 49:6-7 យើងរកឃើញថាពួកគេបានវង្វេងនៅក្នុងការស្វែងរកទ្រព្យសម្បត្តិរបស់គេ ហើយបានបណ្ដេញកុលសម្ព័ន្ធហាំចេញពីទឹកដី។ តាមភូមិវិទ្យាពួកគេបានទទួលមរតករបស់យូដា។ ប៉ុន្តែពួកគេមិនមានមនុស្សដែលពិសេសនៅក្នុងកុលសម្ព័ន្ធរបស់ពួកគេ។

ទីពីរ ពួកគេមិនមានផលផ្លែអ្វីសោះ ដោយសារពួកគេបានពឹងលើដាវ។ បើទោះជាពួកគេបានកាន់កាប់លើពួកអាម៉ាលេកក៏ដោយ តែពួកគេបានបាត់បង់ជ័យជំនះខាងវិញ្ញាណពិតប្រាកដ។ យើងត្រូវតែក្លាយជាអ្នកដែលកាន់កាប់ ជាម្នាក់ដែលត្រូវតែទុកចិត្តនឹងព្រះអម្ចាស់និងព្រះបន្ទូលរបស់ទ្រង់។ បំណងព្រះហឫទ័យរបស់ព្រះនឹងនៅអស់កល្បជានិច្ច។

**7. មរតករបស់កូនច្បង (របាក្សត្រទី1, 5:1-17)**

ក្រឹត្យវិន័យសង្កត់ធ្ងន់លើពូជពង្ស។

ទីមួយ កូនច្បងទទួលបានចំណែកមរតកទ្វេរ។ ប៉ុន្តែពូជពង្សរបស់រូបេនត្រូវបានបាត់បង់សិទ្ធិជាកូនច្បង។ អ្នកដែលមើលទៅកាន់ព្រះនេត្ររបស់ព្រះអម្ចាស់ ដែលជាអង្គដែលអាចរាប់ជីវិតប្រចាំថ្ងៃរបស់យើងនឹងជាអ្នកដែលមានពរ។ នៅពេលដែលគាត់នៅម្នាក់ឯងនៅទីនោះ សកម្មភាពអាថ៌កំបាំងរបស់គេនឹងត្រូវពឹងផ្អែកលើរូបភាពនៃជីវិតដែលជោគជ័យរបស់គេ។

ទីពីរ គាត់បានបាត់បង់សិទ្ធិរបស់គាត់ហើយជាពិសេសអាកប្បកិរិយា និងសិទ្ធិអំណាចត្រូវបានផ្ទេរទៅកុលសម្ព័ន្ធយ៉ូសែប។ យូដាបានក្លាយជាអ្នកគ្រប់គ្រងនិងយ៉ូសែបបានក្លាយជារឹងមាំហើយបានទទួលមរតកនៃកូនច្បង។ ដូចជាអេលីសេបានសូមចំណែកទ្វេរដងរបស់អេលីយ៉ា នោះយើងគួរតែមានបំណងចង់បានកិច្ចការរបស់ព្រះខ្លាំងថែមទៀត ដើម្បីឱ្យព្រះប្រើ

យើងយើងគួរតែរស់នៅជាអ្នកបម្រើដំណឹងល្អ។

**8.ជីវិតនៃសេចក្តីជំនឿដែលស្មោះត្រង់(របាក្សត្រទី1, 5:18-26)**

ព្រះអម្ចាស់របស់យើងសព្វព្រះទ័យនឹងមនុស្សដែលអធិស្ឋាន ប៉ុន្តែអ្នកដែលមានសេចក្តីកំផិតខាងវិញ្ញាណនឹងត្រូវទទួលបានការកាត់ទោស។ តើអត្ថបទបានបង្ហាញអ្វីមកកាន់យើង?

ទីមួយ ជីវិតនៃការអធិស្ឋាន - នៅពេលដែលកុលសម្ព័ន្ធបីបានជួបការលំបាក ពួកគេបានអធិស្ឋានទៅកាន់ព្រះ (20)។ បន្ទាប់មកព្រះអម្ចាស់បានជួយពួកគេ ហើយបានធ្វើឱ្យពួកគេឈ្នះលើពួកខ្មាំង។ ការអធិស្ឋានរបស់គេជាចរន្តនៃព្រះគុណដើម្បីចូលទៅជិតព្រះអម្ចាស់បន្តិចម្តងៗនិងការពារចេញពីការសរសើរដែលអាក្រក់ទៅកាន់ព្រះអម្ចាស់ (Calvin)។

ទីពីរ ជីវិតនៃភាពស្មោះត្រង់ បើទោះជាយើងបម្រើដល់ព្រះក្លែងក្លាយក៏ដោយ កាលដែលយើងយកជ័យជម្នះនិងមុខរបរ (25) ព្រះអម្ចាស់នឹងការទោសយើង។ វាជាព្រះពរដែលយើងមិនមានការស្អប់ស្អល់ដោយរបស់ដែលនៅតែមួយរយៈពេល ប៉ុន្តែយើងមានបំណងលូតលាស់នៅក្នុងព្រះគុណបន្តិចម្តងៗ។ ការក្លាយជាមនុស្សត្រូវបានប្រើបណ្តោះអាសន្ន ប៉ុន្តែបរិបូរណ៍មិនមែនជាគោលបំណងរបស់អ្នកបរិសុទ្ធនោះទេ។ យើងត្រូវតែស្មោះត្រង់តៅកាន់ព្រះអម្ចាស់ដូចដានីយ៉ែលបានធ្វើដើម្បីឱ្យព្រះអម្ចាស់ប្រើយើង។ ព្រះពរដ៏អស្ចារ្យត្រូវតែចេញមកពីព្រះអម្ចាស់។

**9.ជីវិតដែលយកការថ្វាយបង្គំជាចំណុចកណ្តាល(របាក្សត្រទី1,6:1-48)**

អត្ថបទបានសង្កត់ធ្ងន់លើការថ្វាយបង្គំជាកណ្តាលរបស់ពួកលេវី។ នៅពេលដែលពួកលេវីបានធ្វើ អាល់ហ្វានិងអូមេហ្គារបស់គ្រីស្ទាននឹងក្លាយជាការថ្វាយបង្គំ។ ដូចជាចាស់ទុំទាំង 24 នាក់នៅក្នុងវិវរណៈ 4:-5: និងស្ត្រីសាសន៍សាម៉ារីដែលបានថ្វាយបង្គំដល់ព្រះជាម្ចាស់ ហើយការថ្វាយបង្គំនេះគួរតែជាចំណុចកណ្តាលនៅក្នុងជីវិតរបស់យើង។ តើយើងអាចថ្វាយការថ្វាយបង្គំពិតប្រាកដដល់ព្រះដោយរបៀបណា?

ទីមួយ យើងគួរតែថ្វាយបង្គំដោយវិញ្ញាណ។ "នៅក្នុងវិញ្ញាណ" មានន័យថាថ្វាយបង្គំដែល

ថ្វាយនៅក្នុងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ គ្រីស្ទានខាងវិញ្ញាណអាចថ្វាយការថ្វាយបង្គំនេះបានទៅកាន់ព្រះអម្ចាស់។

ទីពីរ យើងគួរតែថ្វាយបង្គំនៅក្នុងសេចក្តីពិតទៅកាន់ព្រះអម្ចាស់។ វាជាការថ្វាយបង្គំទៅកាន់ព្រះអម្ចាស់ដោយការដើរតាមការយល់ដឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះការថ្វាយបង្គំរបស់យើងគួរតែនៅក្នុងចំណុចកណ្តាលនៃការបកស្រាយនិងព្រះបន្ទូលនិងការអនុវត្តតាមព្រះបន្ទូល។

ទីបី យើងត្រូវតែថ្វាយបង្គំដោយការសរសើរដែលជាការបង្ហាញនូវសេចក្តីជំនឿ នោះជាការអរព្រះគុណនិងការសរសើរដំកើង។ យើងគួរតែថ្វាយការដែលល្អបំផុតទៅកាន់ព្រះដ៏ខ្ពស់បំផុត។ យើងគួរតែរស់នៅជាគ្រីស្ទានដ៏ពិតដោយការអនុវត្តការថ្វាយបង្គំខាងវិញ្ញាណតាមរយៈការសិក្សាការនោះដោយបន្ទាបខ្លួន។

**10. ជីវិតដែលមានទំនួលខុសត្រូវ (របាក្សត្រទី1, 6:49-81)**

ទីក្រុងសម្រាប់ជ្រកកោនស្ថិតនៅកណ្តាលប្រទេសអ៊ីស្រាអែល ដែលជាស្រមោលរបស់ព្រះគ្រីស្ទ ដែលទ្រង់ជាសេចក្តីពិតនៃទីជ្រកកោន។ គ្រប់គ្រីស្ទានទាំងអស់រស់នៅក្នុងទីជ្រកកោនពិតប្រាកដ។ នៅទីនេះ តើពួកគេបានរៀនអ្វីខ្លះអំពីជីវិតរបស់ពួកគេ?

ទីមួយ គ្រីស្ទានគួរតែរស់នៅក្នុងជីវិតនៃការថ្វាយបង្គំពិតប្រាកដ ដូចជាពួកលេវីដែលបានបម្រើដង្វាយគ្រប់ប្រភេទទាំងអស់សម្រាប់ជាការប្រោសលោះដល់រាស្ត្ររបស់គេ។ ហើយរដ្ឋាភិបាលគួរតែការពារក្រុមជំនុំ ដើម្បីចូលទៅដល់គោលបំណងជោគជ័យជាមនុស្សទូទៅដែលត្រូវតែការពារផ្ទះនិងចម្ការនិងជីវិតរបស់គេ។ គ្រូគង្វាលជាសង្ឃនៃដំណឹងល្អ គួរតែថ្វាយខ្លួនគាត់ផ្សាយដំណឹងល្អនិងមនុស្សធម្មតាគួរតែផ្គត់ផ្គង់ដល់ការរស់នៅរបស់គាត់។

ទីពីរ យើងអាចមើលឃើញព្រះយ៉ាងលម្អិត។ អ្នកបម្រើគួរតែទទួលរង្វាន់ពិតប្រាកដដោយសារការលះបង់របស់គេ ដូចដែលគោដែលធ្វើការនោះត្រូវបើកមាត់ឱ្យស៊ីដែរ។ ចូរយើងសរសើរដល់ព្រះអម្ចាស់ ដែលជាផ្គត់ផ្គងដល់សេចក្តីត្រូវការរបស់យើងជារបស់យ៉ាងបរិបូរណ៍។

**11.គូសសេចក្តីសុបិននៃមរតក(របាក្សត្រទី1, 7:20-40)**

ការកាន់កាប់និងការរំខានដល់មរតករបស់កុលសម្ព័ន្ធទាំងប្រាំមួយត្រូវបានបញ្ចប់ ហើយកុលសម្ព័ន្ធដែលសេសសល់បានធ្វើការប្រមូលជាបន្ត។ ព្រះគុណនៃសេចក្តីសង្រ្គោះ (Mona) ជាការទូទៅ ប៉ុន្តែព្រះគុណនៃអំណោយទាន (gift) ជាការផ្ទាល់ៗខ្លួន ព្រះគម្ពីរបានទទួលស្គាល់រង្វាន់ខុសៗគ្នា។ តើយើងអាចរីករាយនឹងមរតកនៅក្នុងជីវិតរបស់យើងបានយ៉ាងដូចម្តេច?

ទីមួយ យើងគួរតែមានបំណងចង់បានមរតក។ ក្តីស្រម៉ៃរបស់អ្នកសង្កេតទាំងដប់នាក់និងក្តីស្រម៉ៃរបស់កាលេបជាក្តីស្រម៉ៃចង់បានមរតក។ អំណាចនិងអំណោយទានដែលចេញមកពីខាងលើមកលើមនុស្សដែលនៅក្នុងបន្ទាត់ ដោយសារក្រឹត្យវិន័យខាងវិញ្ញាណ។

ទីពីរ យើងត្រូវតែគូរគម្រោងនៃមរតករបស់ពួកគេ។ ដូច្នេះយ៉ូស្វេបានបង្គាប់ថាពួកគេគួរតែយកការកត់ត្រាគម្រោងរបស់ពួកគេចេញពីមរតកនោះមក។ ដូចដែលយើងបានស្គាល់ពីមរតកយ៉ាងលម្អិតនៅក្នុងចិត្តរបស់យើង យើផ្តោតទៅលើភាពពិតជាក់ស្តែងនិងនៅក្នុងចិត្តរបស់យើង។

ទីបី យើងត្រូវតែថ្វាយការនោះនៅចំពោះព្រះអម្ចាស់និងអធិស្ឋានសម្រាប់ការនោះ។ សកម្មភាពនៃការខំានៅចំពោះស៊ីឡូមានន័យថាជាការអធិស្ឋានទៅកាន់ព្រះ។ នៅពេលដែលយើងទទួលបានការពិសោធន៍នៅចំពោះព្រះ នោះយើងអាចធ្វើជាភាជន៍ដែលបរិសុទ្ធនិងស្មោះត្រង់បាន។

**12. សារៈសំខាន់នៃការស្តាប់បង្គាប់ (របាក្សត្រទី1, 8:1-40)**

អនាគតរបស់កុលសម្ព័ន្ធបេនយ៉ាមីនមានទាក់ទងនឹងការស្លាប់របស់រ៉ាជេល។ ទំនាក់ទំនងដ៏សោកសៅរបស់រ៉ាជេលដែលនាងបានស្លាប់នៅក្នុងការដែលបង្កើតបេនយ៉ាមីនបានបង្ហាញដល់ពូជពង្សរបស់ពួកគេ។ ពួកគេមានអ្នកខ្លាំងៗអស្ចារ្យជាច្រើន ប៉ុន្តែពួកគេបានចាកចេញពីបន្ទាត់នៃក្រុមជំនុំនៅសញ្ញាចាស់ ហើយប្រឆាំងនឹងព្រះអម្ចាស់ ហើយក៏ត្រូវបានបំផ្លាញដោយការប្រៀនប្រដៅរបស់ព្រះអម្ចាស់បណ្តោះអាសន្ន។ យ៉ាងណាក៏ដោយអ្នកខ្លាំងពូកែសូលបាន

ចេញមកពីកុលសម្ព័ន្ធនោះ ប៉ុន្តែពួកគេបានបរាជ័យក្លាយទៅជាកុលសម្ព័ន្ធមួយតូច។ តើមេរៀនអ្វីដែលយើងបានរៀនតាមរយៈស្តេចសូលនៅក្នុងអត្ថបទ?
ទីមួយ នៅពេលដែលយើងបន្ទាបខ្លួន ព្រះអម្ចាស់នឹងផ្តល់ព្រះគុណដល់យើង។ ការបន្ទាបខ្លួនរបស់សូលជាភាជន៍នៃព្រះគុណរបស់ព្រះដើម្បីក្លាយជាស្តេចទីមួយរបស់អ៊ីស្រាអែល។
គោលការណ៍ដែលព្រះអម្ចាស់ផ្តល់ព្រះគុណដល់អ្នកដែលបន្ទាបខ្លួននោះមិនអាចផ្លាស់ប្តូរបានឡើយ។
ទីពីរ ការមិនស្តាប់បង្គាប់ម្តងបានធ្វើឱ្យគាត់បរាជ័យដល់ដី។ អ្នកដែលមើលងាយព្រះបន្ទូលរបស់ព្រះនឹងក្លាយជាទាសកររបស់កិត្តិយសនិងការលោភលន់ ហើយនឹងត្រូវឃ្លាតចេញពីព្រះបន្ទូលរបស់ព្រះ។ ជាជាប់លាប់ចូរយើងស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

**ខ.អាណាចក្រដែលរួបរួម(របាក្សត្រទី1:10:-IIChronicles.29:30)**

**1.នគរដែលព្រះវិញ្ញាណបរិសុទ្ធជាអ្នកបង្កើតឡើង(របាក្សត្រទី1, 12:23-40)**
តើអត្ថបទនិយាយពីសេចក្តីពិតអ្វីដែលរាជរបស់ស្តេចសូលបានដកទៅឱ្យស្តេចដាវីឌដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ?
ទីមួយ គ្រប់កុលសម្ព័ន្ធទាំងអស់មានការរួបរួមដោយចិត្ត (33)។ គ្រប់កុលសម្ព័ន្ធទាំងអស់យល់ស្របឱ្យកុលសម្ព័ន្ធយូដាជាកណ្តាលឱ្យដាវីឌសោយរាជ្យជាស្តេចរបស់អ៊ីស្រាអែល ហើយអ្នកខ្លាំងពូកែរបស់ទ្រង់បម្រើជាតិសាសន៍ដោយចិត្តតែមួយ។
ទីពីរ ទ្រង់បានបម្រើដោយចិត្តដែលស្មោះត្រង់ (38)។ ព្រះវិញ្ញាណបានធ្វើឱ្យមនុស្សដែលសេសសល់មានចិត្តតែមួយ។ ទីបី ទ្រង់មានពេញទៅដោយអំណរ (40)។ ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំឱ្យចូលរួមនៅក្នុងពិធីជប់លៀនយ៉ាងមានអំណរ។ នៅមុនពេលព្រះគ្រីស្ទយាងមកលើផែនដី ការនៅក្មេងនៅឡើង ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការរបស់ទ្រង់ដោយសេចក្តីស្រឡាញ់និងសេចក្តីពិត។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការជានិច្ចដើម្បីនឹងសម្រេចបំណាងរបស់ព្រះជាម្ចាស់ដោយអំណរនៃការរួបរួម (អេភេសូ 4:1-3, កិច្ចការ 2:42-47)។ ចូរយើងដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។

**2.ជីវិតដែលមានហិបសញ្ញាជាកណ្តាល(របាក្សត្រទី1, 13:1-14)**

ហេតុអ្វីបានជាការបម្រើហិបសញ្ញាជាការដែលសំខាន់នៅក្នុងពួកអ៊ីស្រាអែលដែលជាសម្គាល់ថាជាអាណាចក្ររបស់ព្រះ?

ទីមួយ វាបញ្ជាក់ថាព្រះអម្ចាស់ជាស្តេចនៃនគររបស់ពួកគេ (2,6)។ ស្តេចដាវីឌដែលជឿថាមានតែស្តេចដែលមើលមិនឃើញប៉ុណ្ណោះដែលជាអង្គុយនៅចន្លោះសេរ៉ាភីមដែលជាស្តេចពិតប្រាកដ នៅក្នុងរាជរបស់ទ្រង់ដែលបានព្យាយាមយកហិបសញ្ញាមកកាន់ហេប្រុនវិញ។

ទីពីរ វាប្រភពនៃអំណាររបស់អ៊ីស្រាអែល (8)។ សេចក្តីពិតដែលទ្រង់មានអំណាងដែលហិបសញ្ញាបានមកដល់យេរូសាឡិម មានន័យថាប្រភពអំណាររបស់ពួកគេជាព្រះបន្ទូលរបស់ព្រះអម្ចាស់(8)។

ទីបី វាប្រភពនៃព្រះពររបស់អ៊ីស្រាអែល។ ការស្លាប់របស់អ៊ូសានៅក្នុងការលដែលកំពុងបញ្ជូនហិបនោះបង្ហាញថា មានតែព្រះអម្ចាស់ប៉ុណ្ណោះដែលជាព្រះពរដោយការត្រឡប់មករកស្តេចកោតខ្លាចដល់ព្រះអម្ចាស់ឡើងវិញ។ ជីវិតដែលមានព្រះបន្ទូលនៅចំណុចកណ្តាលជាព្រះពរដ៏ពិត។ ចូរយើងរីករាយនឹងព្រះពរនេះដោយស្តប់ស្តល់ចុះ។

**3.ភាពជាម្ចាស់របស់ដាវីឌ(របាក្សត្រទី1, 14:1-17)**

ដាវីឌមានលក្ខណៈផ្ទុយពីស្តេចសូល ដែលទ្រង់បានផ្តោតលើភាពជាព្រះអម្ចាស់របស់ព្រះជាម្ចាស់។ តើសេចក្តីជំនឿលើព្រះជាអម្ចាស់របស់ទ្រង់បង្ហាញមកដោយរបៀបណា?

ទីមួយ ទ្រង់ប្រាកដថាព្រះអម្ចាស់នឹងផ្តត់ផ្គង់ភាពជាស្តេចដល់ទ្រង់ មិនមែនដោយសារភាពស្មោះត្រង់របស់គូរកនទ្រង់និងប្រាជ្ញារបស់ទ្រង់ផ្ទាល់នោះទេ (2)។ សេចក្តីជំនឿនៅក្នុងពេលដែលអត់ឃ្លានបានក្លាយជាកម្លាំងថែមទៀតនៅក្នុងភាពចម្រុងចម្រើន។ ទ្រង់ដឹងថាអ្វីដែលទ្រង់មានជាព្រះគុណរបស់ព្រះអម្ចាស់។

ទីពីរ ទ្រង់ស្តាប់បង្គាប់ព្រះដោយសួរដល់ទ្រង់នៅក្នុងកាលវាយជាមួយពួកផាលេស្ទីន (10,14)។ ហើយទ្រង់ក៏បានរក្សាសេចក្តីជំនឿរបស់ទ្រង់ដែលថាការឈ្នះសង្គ្រាមជារបស់ព្រះអម្ចាស់ ដែលទ្រង់បានអះអាងការដែលទ្រង់នៅវ័យជំទង់។ កាលដែលទ្រង់ជួបបញ្ហាមួយ

ចំនួន ទ្រង់បានទុកចិត្តដល់ព្រះអម្ចាស់ថែមទៀតហើយបានដើរតាមព្រះអម្ចាស់។
ទីបី ព្រះអម្ចាស់បានលើកទ្រង់ឡើងនិងអំណាចដល់ទ្រង់ (17)។ ហើយទ្រង់បានទទួលស្គាល់ថាកិត្តិយសរបស់លោកិយ៍និងផលផ្លែរបស់វាជាគោលបំណងដើម្បីថ្វាយសិរីល្អដល់ព្រះអម្ចាស់។ យើងគួរតែរស់នៅក្នុងសេចក្ដីជំនឿដែលយកព្រះជាអម្ចាស់ដូចដាវីឌមានដែរ (លោកុប្បត្តិ 12:3)។

**4.ជីវិតដែលយកព្រះបន្ទូលជាកណ្តាល (របាក្សត្រទី1,15:1-15)**

ដាវីឌបានលាតត្រដាងអំពីជីវិតដែលមានព្រះបន្ទូលជាកណ្តាលដោយការផ្លាស់ប្តូរហិបទៅកាន់ក្រុងយេរូសាឡិមបន្ទាប់ពីទ្រង់បានបង្កើតវិមានរបស់ទ្រង់ ហើយតែងតាំងសង្ឃដែលគ្រប់គ្រងច្បាប់អោយថែរក្សាហិប។

ទីមួយ ហិបសញ្ញាត្រូវបានគេដាក់នៅចំកណ្តាលវិមាន មានន័យថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាគ្រឹះនៃនគររបស់ព្រះអង្គ។ (1) ព្រះវិហារដែលជានិមិត្តរូបនៃអាណាចក្រដាវីឌបានចង្អុលបង្ហាញថាគ្រឹះគឺជាព្រះគម្ពីរ។ ផ្លូវដែលចេញពីព្រះបន្ទូលមិនមែនជាព្រះវិហាររបស់ព្រះអម្ចាស់ទេ។

ទីពីរ ការលើកវានៅលើស្មារបស់សង្ឃលេវីចង្អុលដើម្បីធ្វើតាមព្រះបន្ទូលរបស់ព្រះ(2)។ នៅថ្ងៃផ្សេងទៀតការសោយទិវង្គតរបស់អ៊ូសាដែលជញ្ជូនហិបសញ្ញាបានប្តូរទៅជាទ្រនៅលើស្មារបស់បូជាចារ្យដើម្បីបង្ហាញវិធីសាស្រ្តនៃនគរ គឺព្រះបន្ទូលរបស់ព្រះ។ វិធីសាស្រ្តណាមួយរបស់មនុស្សដែលផ្ទុយនឹងព្រះបន្ទូលរបស់ព្រះ នឹងមិនត្រូវបានទទួលយកនៅចំពោះព្រះឡើយ។

ទីបី ទ្រង់បានសង្កត់ធ្ងន់លើភាពបរិសុទ្ធ (12) ចំណុចកណ្តាលជាព្រះបន្ទូលនេះបានខិតជិតទៅរកភាពបរិសុទ្ធ។ ព្រះបន្ទូលខ្លួនឯងគឺជាសេចក្ដីពិតនិងភាពបរិសុទ្ធ។ (យ៉ូហាន 17: 17) សូមឱ្យយើងរីករាយនឹងព្រះពរនៃការធ្វើឱ្យប្រសើរឡើងនៃភាពមជ្ឈមណ្ឌលរបស់ព្រះបន្ទូល។

**5.ទ្រង់សរសើរដល់ព្រះបន្ទូល (របាក្សត្រទី1,15:6-16:6)**

ការរៀបចំក្រុមចម្រៀងនៅពេលពួកគេស្វាគមន៍ហិបសញ្ញាគឺជាការបង្ហាញការថ្លែងអំណរ

គុណនិងចំណាប់អារម្មណ៍នៅក្នុងដួងចិត្តរបស់ពួកគេ។ នេះគឺជាជីវិតនិងការថ្វាយបង្គំព្រះពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ តើមានលទ្ធផលអ្វី?

ទីមួយ ការសរសើរត្រូវបានកើតឡើងនៅក្នុងនោះដែរ។ (4) ភាពពោរពេញនៃព្រះបន្ទូលរបស់ព្រះនឹងកើតឡើងដោយសារការពោរពេញដោព្រះវិញ្ញាណ ហើយនឹងត្រូវសរសើរតម្កើងទំនុកតម្កើងពីធម្មជាតិ ពីព្រោះព្រះវិញ្ញាណបរិសុទ្ធបានធ្វើឱ្យពួកគេបើកភ្នែករបស់ពួកគេដើម្បីមើលឃើញពិភពនៃសេចក្តីពិត។ ដូច្នេះពួកគេអាចច្រៀងចម្រៀងខាងវិញ្ញាណដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (អេភេសូ 5: 18-19)។

ទីពីរ ការអរព្រះគុណនឹងត្រូវកើតឡើង (1.4) នេះគឺជាផលដែលអាចមើលឃើញពីព្រះពររបស់ព្រះនៅក្នុងព្រះគ្រីស្ទតាមរយៈការបំភ្លឺនៃព្រះវិញ្ញាណបរិសុទ្ធ (អេភេសូរ 1: 3)។ នេះគឺជាការបង្ហាញពីជំនឿពិត។

ទីបី កិច្ចការដែលមានភាពរុងរឿងនឹងត្រូវកើតឡើង (1)។ ការអោយពរដល់អ្នកជិតខាងបានបង្ហាញពីភាពចម្រុងចម្រើនរបស់ពួកគេ។ ហើយហេតុការណ៍ដែលដាវីឌបានប្រទានពរដល់រាស្ត្ររបស់ទ្រង់និងក្រុមគ្រួសាររបស់ទ្រង់ បង្ហាញពីព្រះពរដ៏បរិបូររបស់ទ្រង់។ ទោះយ៉ាងណាក៏ដោយមីឆែលបានបញ្ចប់ការសើចចំអកឱ្យទ្រង់ ព្រោះនាងមិនស្គាល់ពិភពលោក(29)។ចូរយើងស្វែងរកព្រះគុណដ៏បរិបូរណ៍របស់ព្រះ។

**6.ជីវិតដែលមានព្រះជាចំណុចកណ្តាល(របាក្សត្រទី1, 16:7-36)**

នៅក្នុងអត្ថបទដែលអង្គដែលប្រោសលោះ ដែលជាអ្នកផ្គត់ផ្គង់ និងជាអ្នកបញ្ចប់ ដែលព្រះបានបង្ហាញ ឱ្យឃើញយើងជួបព្រះត្រីឯក។ តើយើងគួរអរគុណដល់ទ្រង់អ្វី?

ទីមួយ យើងគួរតែអរគុណាទ្រង់ដោយស្វែងរកព្រះភ័ក្ររបស់ទ្រង់ (11)។ យើងគួរតែថ្លែងអរគុណដល់ទ្រង់ដោយបានឃើញព្រះអម្ចាស់ដែលនឹងផ្តល់ព្រះគុណសេចក្តីសុខសាន្ត និងការការពារដល់យើង។ ទោះបីជាយើងបានប្រព្រឹត្តអំពើបាបក៏ដោយ យើងបានប្រែចិត្តពីអំពើបាបរបស់យើងហើយបានចូលទៅជិតព្រះ ប៉ុន្តែព្រះអម្ចាស់របស់យើងទទួលយកយើងដោយការពេញចិត្ត។

ទីពីរ យើងគួរតែថ្លែងអរគុណដល់ព្រះដោយស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ទ្រង់ (16-

17)។ នៅពេលយើងស្មោះត្រង់ក្នុងទំនាក់ទំនងរវាងឪពុកនិងកូន រវាងស្តេចនិងអ្នកបម្រើ និងរវាងប្តីនិងប្រពន្ធទៅកាន់ព្រះអម្ចាស់យោងតាមការតាំងសញ្ញានៃព្រះគុណ។ នេះគឺជាយញ្ញបូជាដ៏ថ្លៃថ្លាដែលព្រះសព្វព្រះហឫទ័យ។
ទីបី យើងគួរតែថ្លែងអរគុណដោយថ្វាយខ្លួនរបស់យើងចំពោះទ្រង់ (29)។ យើងត្រូវបានកោតសរសើរចំពោះព្រះដោយថ្វាយរូបកាយដល់ព្រះហើយថ្វាយខ្លួនដល់ព្រះអង្គ។ចូរយើងរស់នៅក្នុងជីវិតដែលពោរពេញទៅដោយការអរព្រះគុណ។

**7.ការសរសើរដែលនៅអស់កល្ប(របាក្សត្រទី1, 16:37-43)**

អត្ថបទបង្ហាញពីឧទាហរណ៍នៃការថ្វាយបង្គំពិត ដោយបង្ហាញពីការបញ្ចប់ដោយទទួលយកហឹបនៃសេចក្តីសញ្ញា ហើយចាត់ចែងជាបន្តបន្ទាប់នៅក្នុងការសរសើរដំកើងនិងការថ្លែងការអរគុណ។
ទីមួយ ដើម្បីធ្វើឱ្យពួកគេបម្រើព្រះជានិច្ច (41) ព្រះបានតែងតាំងមនុស្សដែលបានជ្រើសរើសគឺហឹម៉ាន ជេឌូឌុនដើម្បីសរសើរដល់ព្រះអម្ចាស់ដែលលំដាប់លំដោយ។
ទីពីរ ព្រះបានបង្រៀនឱ្យរក្សាកាន់តាមក្រិត្យវិន័យទាំងអស់ (40)។ ពីព្រោះវាជាផ្លូវនៃជីវិត។ ពួកគេបម្រើព្រះដោយមិនលំអៀងចំពោះព្រះ ប៉ុន្តែមានរបៀបរៀបរយដើម្បីបម្រើទ្រង់។ ផ្លូវតូចចង្អៀតគឺរក្សាធ្វើតាមព្រះបន្ទូលរបស់ព្រះ។ មានជីវិត។ ទី4 យើងត្រូវគ្រាប់តាមគំរូរបស់ដាវីឌដែលបានប្រទានពរដល់ក្រុមគ្រួសាររបស់ទ្រង់ (43)។ ជីវិតដើម្បីសរសើរតម្កើងព្រះជាម្ចាស់និងប្រទានពរដល់រាស្ត្រ និងការវិលត្រឡប់ទៅផ្ទះរបស់ទ្រង់វិញនិងប្រទានពរដល់ក្រុមគ្រួសារគឺជាឧទាហរណ៍មួយដែលយើងគួរតែដើរតាម ជីវិតដែលមានប្រព័ន្ធសណ្តាប់ធ្នាប់។ ឧទាហរណ៍នៅក្នុងប្រវត្តិសាស្ត្រដែលពួកបរិសុទ្ធបានប្រតិបត្តិ គឺជាអំណាចដ៏សំខាន់ដើម្បីធ្វើឱ្យថ្ងៃនោះផ្លាស់ប្តូរ។យើងដែលបានទទួលព្រះពរគួរតែធ្វើតាមគំរូរបស់ដាវីឌ។

**8.អាណាចក្រដែលនៅអស់កល្ប(របាក្សត្រទី1, 17:1-15)**

ជំនឿដែលមានព្រះជាកណ្តាលមិនគួរត្រូវបានផ្លាស់ប្តូរនៅក្នុងថ្ងៃលំបាកនិងថ្ងៃដែលរីកចំរើននោះទេ។ ដាវីឌមានសេចក្តីស្រឡាញ់យ៉ាងពេញលេញចំពោះព្រះដោយគិតដូចជាដំណាក់

របស់ព្រះ។ តើវាត្រូវបានបង្ហាញយ៉ាងដូចម្ដេច?
ទីមួយ ទ្រង់ដឹងថាព្រះអម្ចាស់ប្រគល់ខ្លួនឯងនៅពេលទ្រង់លះបង់ខ្លួនឯងចំពោះព្រះ (1-6) ។ ការធានារបស់ប៉ូលថានៅពេលយើងរស់នៅដើម្បីព្រះអម្ចាស់ព្រះអម្ចាស់នឹងទទួលយកសម្រាប់យើង។ ព្រះជាម្ចាស់គឺជាសេចក្ដីសុចរិតដែលទ្រង់គោរពដល់ប្រជាជនដើម្បីគោរពខ្លួនឯងហើយគេបានមើលងាយរាស្ត្រ ដើម្បីនឹងមើលងាយព្រះជាម្ចាស់។
ទីពីរ ទ្រង់បានដឹងថាវាជាព្រះពររបស់ព្រះដែលព្រះអម្ចាស់បានជួយទ្រង់អោយរួចផុតពីស្ថានភាពវេទនា ដែលចេញពីជីឥដ្ឋ (7-8)។ ទ្រង់បានសន្យាថាព្រះនឹងគង់នៅជាមួយអ្នកហើយខ្ញុំនឹងដេញខ្មាំងសត្រូវទាំងអស់ចេញ ហើយទ្រង់នឹងអនុញ្ញាតឱ្យមានជ័យជំនះ។
ទីបី ការសន្យាថាព្រះនឹងបង្កើតព្រះវិហាររបស់ព្រះចង្អុលបង្ហាញក្រុមជំនុំដែលជាដំណាក់របស់ព្រះ (12-14)។ ផ្ទះនេះជាផ្ទះអស់កល្បជានិច្ចដែលបង្ហាញពីសេចក្ដីសញ្ញានៃព្រះគុណដែលចង្អុលបង្ហាញថាព្រះជាឪពុករបស់គេហើយពួកគេជាកូនរបស់ព្រះ។ ទោះបីគ្រួសាររបស់ដាវីឌពូកែជាងគេនៅលើពិភពលោកក៏ដោយ ក៏វាអាចប្រៀបធៀបនឹងភាពរុងរឿងរបស់ក្រុមជំនុំដែរ។ចូរយើងស្មោះត្រង់នៅក្នុងដំណាក់របស់ស្ដេចពិតគឺដែលជាព្រះគ្រីស្ទ។

**9.ការធានាអះអាងរបស់ស្ដេចដាវីឌ(របាក្សត្រទី1,17:16-27)**

ការរីករាយរបស់អ័ប្រាហាំគឺជាអំណររបស់ដាវីឌដែរ។ តើសេចក្ដីអធិស្ឋានរបស់ដាវីឌបង្ហាញពីអ្វីដែលធ្វើឱ្យទ្រង់រីករាយ?
ទីមួយ ទ្រង់បានដឹងថាអ្វីៗទាំងអស់ត្រូវបានសម្រេចដោយព្រះគុណ។ ទ្រង់ដឹងថាព្រះបានលើកទ្រង់ឡើងជាមនុស្សមានកិត្តិយស ហើយបានធ្វើឱ្យក្លាយជាម្ចាស់នៅអ៊ីស្រាអែល។ ការស្គាល់ព្រះគុណបានគ្រប់គ្រងលើចិត្តរបស់ទ្រង់ដូចប៉ុលដែរ។
ទីពីរ ព្រះអង្គសព្វព្រះហឫទ័យនឹងអ្វីៗទាំងអស់ដែលស្ថិតនៅក្នុងព្រះរាជ្យអស់កល្បជានិច្ច។ ការពង្រឹងប្រទេសនៅខ 24 គឺជាប្រភេទនៃនគររបស់ព្រះគ្រីស្ទ ដែលចង្អុលបង្ហាញថាព្រះគ្រីស្ទគឺជាស្ដេចនៃនគរនោះ។
ទីបី ទ្រង់បានដឹងថាអ្នកឈ្លានពាននគរព្រះត្រូវបានប្រទានពរ។ គ្រីស្ទានគឺជាអ្នកដែលផឹកទឹក

ដែលនៅអស់កល្បជានិច្ច ហើយគេស្វែងរកកំណាប់នៃប្រាជ្ញានិងចំណេះដឹងជាខ្លាំង។ បញ្ហារបស់ក្រុមជំនុំនឹងត្រូវបានព្យាបាលដោយព្រះវិញ្ញាណបរិសុទ្ធ។ យើងគួរតែមានស្មារតីដឹងគុណដូចដាវីឌដែរ។

**10.ជ័យជម្នះរបស់ស្តេចដាវីឌ(របាក្សត្រទី1,18:1-17)**

យើងគួរតែយល់ថារាជវង្សរបស់ដាវីឌ បានចង្អុលបង្ហាញជ័យជំនះនៃនគររបស់ព្រះ ពីព្រោះរជ្ជកាលរបស់ទ្រង់គឺជាប្រភេទនៃអាណាចក្ររបស់ព្រះ។ តើអត្ថបទបង្ហាញពីជ័យជំនះយ៉ាងដូចម្តេច?

ទីមួយ ជ័យជំនះទាំងអស់ជារបស់ដាវីឌ ព្រះបានធ្វើឱ្យដាវីឌឈ្នះនៅគ្រប់កន្លែងដែលទ្រង់ទៅ។ យើងដែលស្ថិតនៅជាប់នឹងព្រះគ្រិស្តគួរតែទទួលជ័យជំនះជាដរាប។

ទីពីរ ព្រះអង្គបានបង្កើតអាណាចក្រដែលយុត្តិធម៌។ គោលដៅដែលគ្រីស្ទានប្រយុទ្ធ គឺដើម្បីបង្កើតនគរយុត្តិធម៌ មានសេចក្តីមេត្តាករុណានិងមេត្តាធម៌។ និយាយម៉្យាងទៀត វាគឺជាអាណាចក្រដែលបានបំពេញដោយរូបឆ្លុះរបស់ព្រះ។ ឈើឆ្កាងនៃការសោយទិវង្គតរបស់ព្រះគ្រីស្ទបានសម្អាតអំពើបាបទាំងអស់របស់រាស្ត្រទ្រង់ ហើយត្រូវបានទទួលថាជាមនុស្សសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ដែលជាលក្ខណៈរបស់ព្រះ (ម៉ាថាយ 23:23) នៅក្នុងរាស្ត្ររបស់ពួកគេ។

**11. ចរន្តនៃព្រះគុណ (របាក្សត្រទី1, 19:1-5)**

ព្រះគុណរបស់ព្រះជាម្ចាស់តាមរយៈដាវីឌគឺដើម្បីប្រកាសអំពីអាណាចក្ររបស់ព្រះនៅក្នុងពិភពលោក។

ទីមួយ លក្ខណៈវិនិច្ឆ័យ - ការសន្យាតែមួយដែលអ័ប្រាហាំបានទទួលពីព្រះដើម្បីឱ្យពិភពលោក ទទួលបានព្រះពរពីព្រះតាមរយៈព្រះគ្រីស្ទនៅក្នុងពិភពលោក ដែលជាសញ្ញាដំបូងនៃសេចក្តីសញ្ញានៃព្រះគុណ។ (លោកុប្បត្តិ 12: 1-2) ការសន្យានេះត្រូវបានបន្តនៅសម័យដាវីឌទីបំផុតវាត្រូវបានលេចចេញកាន់តែច្បាស់នៅក្នុងបញ្ញាត្តិធំបំផុតរបស់ព្រះអម្ចាស់ (ម៉ាថាយ 28:19-20)។ បន្ទាប់ពីពួកគេបានប្រកាសដំណឹងល្អពួកគេបានទទួលព្រះគុណនៃព្រះវិញ្ញាណបរិសុទ្ធ (កាឡាទី 3:14) ។

ទីពីរ ការសម្រេចបំពេញ - គោលបំណងដែលម៉ាថាយបានប្រកាសនៅក្នុងគម្ពីរម៉ាថាយ 28: 18-20 គឺបង្កើតសិស្សនិងបង្កើតសហគមន៍អេម៉ាញូអែល។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការដើម្បីត្រាស់ហៅរាស្ត្ររបស់ទ្រង់ចេញពីលោកិយនេះបើយោងតាមការព្យាករណ៍របស់អេសាយ។ ចូរយើងក្លាយជាអ្នកដែលនាំអ្នកដំណឹងល្អទៅកាន់ពិភពលោក។

**12.ជ័យជន្នះយ៉ាងពេញលេញ(របាក្សត្រទី1,19:16-20:8)**

អារ៉ាមបានចាញ់សង្គ្រាមជាមួយប៉ាឡេស្ទីន ដើម្បីជួយជនជាតិអាំម៉ូន ប៉ុន្តែប៉ាឡេស្ទីនបានចាញ់ដោយសារភាពក្រអឺតក្រទមរបស់ពួកគេ។ អត្ថបទបានធ្វើអោយយើងនឹកឃើញដល់ជ័យជំនះយ៉ាងពេញលេញ។

ទីមួយ សិទ្ធិអំណាចរបស់ស្ថាននរកមិនអាចយកឈ្នះក្រុមជំនុំបានទេ។ អ៊ីស្រាអែលគឺជាព្រះវិហារ អារ៉ាមគឺជាមេប្រឆាំងទាស់នឹងព្រះគ្រីស្ទគឺជាសេចក្តីស្លាប់និងអំណាចវា។ ខ្មាំងសត្រូវទាំងអស់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់នឹងត្រូវវិនាសជាមិនខាន។

ទីពីរ ដោយប្រើកូនសោរនៃព្រះបានធ្វើឱ្យអ្នកជិតខាងភ្ញាក់។ ព្រះវិហារមានកូនសោរនៃនគរព្រះ។ នេះគឺជាដំណឹងល្អ។ ទោះបីជាអារក្សបានវាយប្រហារមកលើយើងក៏ដោយយើងអាចយកឈ្នះវាបានបាន ដោយសារដំណឹងល្អ។ យើងគួរតែរីករាយនឹងជ័យជម្នះដ៏អស្ចារ្យដោយប្រើកូនសោនេះ។ នៅគ្រាលំបាកដើម្បីនឹងស្តារឡើងវិញនូវគ្រួសារពិត យើងអាចសម្រេចកិច្ចការថ្មីដោយប្រើដំណឹងល្អ។

**13.ការអស្ចារ្យតាមរយ:ការលន់តួបាប(របាក្សត្រទី1, 21:1-17)**

ការធ្វើជំរឿនដែលប្រកាន់ជំហររឹងមាំខាងនយោបាយតាមរយ:ការរាប់កងទ័ព ធម្មតាគឺជាបញ្ហាប្រឈមចំពោះអាណាចក្ររបស់ព្រះជាម្ចាស់ជាជាងការប្រមូលពន្ធនៃដង្វាយធួន។ ដោយរឿងបែបនេះមនុស្ស 70.000 នាក់បានស្លាប់ដោយសារព្រះក្នុងមួយថ្ងៃ។ តើយើងរកឃើញសេចក្តីពិតរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច?

ទីមួយ ទ្រង់បានសង្កេតមើលបំណងចិត្ត (6)។ ទោះបីវាជាជំរឿនធម្មតាក៏ដោយ វាមកពីភាពក្រអឺតក្រទមរបស់ទ្រង់។ ទោះបីជាមានការជម្រុញរបស់សាតាំង (1) និងដំបូន្មានរបស់យ៉ូអាប់

(3,6) បានបណ្តេញទ្រង់ក៏ដោយលោភលន់របស់ទ្រង់បានធ្វើកិច្ចការនេះដោយគ្មានទីពឹង។ គ្រីស្ទបរិស័ទរស់នៅក្នុងពន្លឺនៃព្រះដែលបានមើលបំណងចិត្តរបស់ទ្រង់ជាជាងសកម្មភាពខាងក្រៅរបស់ទ្រង់។

ទីពីរ ទ្រង់ចូលចិត្តការប្រែចិត្ត (7)។ ក្នុងចំណោមកំហឹងដ៏ខ្លាំងរបស់ព្រះ ដាវីឌបានភ្ញាក់ដឹងខ្លួនដោយការលន់តួបាប។ ទោះបីជាទ្រង់មានគ្រោះថ្នាក់យ៉ាងខ្លាំងនៅក្នុងជីវិតរបស់ទ្រង់នៅពេលដែលទ្រង់បានធ្វើអំពើបាបម្តងទៀតក៏ដោយ នៅពេលនោះដែលព្រះបានស្តារទ្រង់យ៉ាងឆាប់រហ័ស។ ព្រះគុណរបស់ទ្រង់ពិតជាអស្ចារ្យណាស់។ នៅពេលដែលយើងសារភាពអំពើបាបរបស់យើងដោយដឹងពីទទួលខុសត្រូវ និងជឿជាក់លើសេចក្តីមេត្តារបស់ទ្រង់ នោះការអស្ចារ្យនឹងកើតឡើង។ចូរយើងរស់នៅដោយស្មោះត្រង់ចំពោះព្រះ(1យ៉ូហាន1:9)។

**14.អ្នកជឿដែលរស់នៅដូចជាសង្ឃ(របាក្សត្រទី1, 23:1-23)**

ដោយសារជីវិតដែលយកហិបសញ្ញាជាកណ្តាលនោះជាជីវិតរបស់ពួកគេ ព្រះបានទុកកុលសម្ព័ន្ធលេវីពិសេស (1-3)។ តើយើងរៀនអ្វីខ្លះអំពីបេសកកម្មនេះ?

ទីមួយ គេគួរតែសរសើរដល់ព្រះអម្ចាស់ (5)។ ដែលដាវីឌបានតែងតាំងអ្នកចំរៀងចំនួនបួនពាន់នាក់បានបង្ហាញពីសារៈសំខាន់នៃការសរសើរនៅក្នុងជីវិតរបស់ពួកគេ។ មូលហេតុដែលពួកបរិសុទ្ធដើម្បីទទួលដំណឹងល្អ ត្រូវតែរស់នៅដោយអរគុណនិងការសរសើរ គឺដើម្បីសម្រេចបាននូវសេចក្តីសង្ឃឹមនៃសេចក្តីសង្គ្រោះរបស់ពួកគេ (អេភេសូ 5:18, អេភ 1: 3)។ ពួកបរិសុទ្ធដែលបានត្រូវហៅជាសង្ឃក្នុងនាមជាស្តេចគួរបម្រើព្រះដើម្បីសរសើរតម្កើងព្រះ (ពេត្រុសទី 1 2: 9)។

ទីពីរ ទ្រង់គួរតែរស់នៅក្នុងភាពបរិសុទ្ធ (13) ដើម្បីក្លាយជាមនុស្សបរិសុទ្ធជារៀងរហូត៉ មានន័យថាគេបានថ្វាយខ្លួនដល់ព្រះអម្ចាស់។ ពួកគេគួរតែរក្សាភាពបរិសុទ្ធដើម្បីថ្វាយដង្វាយដល់ព្រះ។ ភាពបរិសុទ្ធមានន័យថាគេរស់នៅក្នុងពិភពលោក ប៉ុន្តែគេត្រូវតែរស់នៅដោយដឹងខ្លួនថាជាកម្មសិទ្ធរបស់ព្រះនៅលើពិភពលោក។ នេះគឺជាភាពឯកជនដ៏អស្ចារ្យរបស់ពួកបរិសុទ្ធ។យើងគួរតែត្រូវបានបំពេញដោយអំណាចនៃភាពបរិសុទ្ធ។

## 15.មេរៀនពីការថ្វាយបង្គំ(របាក្សត្រទី1, 24:1-31)

អត្ថបទដែលពន្យល់ពីមូលហេតុដែលអាយុរបស់ពួកគេត្រូវបានផ្លាស់ប្តូរនៅត្រឹមតែអាយុ 25 ឆ្នាំ 23 ឆ្នាំនិង 20 ឆ្នាំ ហើយមានតែក្រុមគ្រួសារអើរ៉ុនប៉ុណ្ណោះដែលគួរតែបម្រើតង្វាយ នោះបង្រៀនពីសារៈសំខាន់នៃការគោរពបូជាដល់យើង។ ហេតុអ្វីវាសំខាន់?

ទីមួយ ពីព្រោះការថ្វាយបង្គំគឺជាបញ្ហាដែលពឹងផ្អែកលើជីវិតនិងសេចក្តីស្លាប់ (1-2)។ មរណភាពរបស់ណាដាប់និងអ័ប៊ីហ៊ូវសម្រាប់ការថ្វាយតង្វាយមួយចំនួននៅក្នុងភាពស្រវឹងចំពោះព្រះហើយបានបង្កាត់ភ្លើងផ្សេងទៀតដល់ព្រះ។ បានបង្រៀនសារៈសំខាន់ខ្លាំងណាស់នៅក្នុងជីវិតរបស់រាស្ត្រនៃសេចក្តីសញ្ញា។ យើងគួរតែផ្តល់ការថ្វាយបង្គំរបស់យើងដោយវិញ្ញាណនិងសេចក្តីពិត ដើម្បីកុំឱ្យធ្លាក់ក្នុងសេចក្តីល្បួងដោយទម្លាប់ដែលមានការលាក់ពុត។

ទីពីរ ពីព្រោះវាជាការបម្រើបឋមនៅក្នុងជីវិតរបស់យើង (5)។ ព្រះបានធ្វើឱ្យពួកគេមិនឱ្យ ដើរតាមការថ្វាយបង្គំ ប៉ុន្តែត្រូវបម្រើតាមអំណោយទានរបស់ពួកគេដោយការលះបង់។ គ្រីស្ទបរិស័ទគួរតែចូលរួមក្នុងការថ្វាយបង្គំព្រះពិត ទោះបីជីវិតគ្រីស្ទបរិស័ទទាំងអស់គឺជាការថ្វាយបង្គំ ការថ្វាយបង្គំគួរតែជាការចម្បងនៅក្នុងជីវិតរបស់ពួកគេ។

ទីបី ពីព្រោះពួកគេគួរតែធ្វើតាមសេចក្តីពិត (3)។ ការហូរឈាមរបស់សត្វជានិមិត្តរូបនៃការសុគតរបស់ព្រះគ្រីស្ទ មិនគួរត្រូវបានផ្លាស់ប្តូរដើម្បីផ្តល់ការថ្វាយបង្គំដែលអាចទទួលយកបានទេ។ នៅទីបំផុតយើងអាចចូលទៅជិតព្រះដោយការជឿ តែកិច្ចការរបស់ព្រះគ្រីស្ទដែលជាការពិតនៃនិមិត្តរូបនៃដង្វាយធួនបាបដ៏អស់កល្បជានិច្ច(ហេព្រើរ4:16)។

## 16.ការបម្រើដែលជាចម្រៀងខាងវិញ្ញាណ(របាក្សត្រទី1, 25:1-31)

ដាវីឌបានតែងតាំងបុរសខាងវិញ្ញាណដែលជាកូនចៅរបស់អេសអេម ហេម៉ាន និងយូដូឌុន ហើយបានតែងតាំងពួកគេឱ្យបម្រើក្នុងការពន្យល់ផងដែរ។ តើចម្រៀងនេះមានចរិតលក្ខណៈអ្វី?

ទីមួយ វាគឺជាចម្រៀងដែលចេញមកពីភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធ (3)។ បទចំរៀងខាងវិញ្ញាណចេញពីដួងចិត្តដែលពោរពេញទៅដោយភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធ (អេភេសូរ 5: 18-20)។ ភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធ មានន័យថាភាពបរិបូរណ៍នៃព្រះ

បន្ទូលរបស់ព្រះជាម្ចាស់ (កូល៉ុស 3: 16)។ ការអានព្រះគម្ពីរដោយឧស្សាហ៍ព្យាយាម ធ្វើសញ្ជឹងគិត ការអធិស្ឋាននិងថ្វាយបង្គំ នោះយើងអាចស្គាល់ពិភពលោកបាន។
ទីពីរ វាជាបទចំរៀងដែលបុរសនោះថ្វាយខ្លួនឯងចំពោះព្រះ (6)។ ក្រុមគ្រួសារនីមួយៗយកឧបករណ៍របស់ខ្លួនមកថ្វាយព្រះ។ សំខាន់បំផុតយើងគួរលះបង់រូបកាយរបស់យើង ដែលជាឧបករណ៍ធម្មជាតិដល់ព្រះអម្ចាស់តែមួយ។ ព្រះពេញចិត្តនឹងការសរសើរនោះដែលចិត្តរាបទាបដើម្បីទទួលព្រះគុណដែលព្រះបានផ្តល់។ យើងគួរតែច្រៀងចម្រៀងនៅស្ថានសួគ៌ដែលពោរពេញទៅដោយការទះដៃអបអរសាទររបស់មនុស្ស។ (វិវរណៈ 4:10)។ យើងគួរតែរីករាយនឹងបទចម្រៀងយ៉ាងអស្ចារ្យ ដែលយើងអាចច្រៀងនៅកក្នុងលោកិយ៍ (វិវរណៈ 4:10)។

17. **អ្នកយាមទ្វារនៃព្រះវិហារ (របាក្សត្រទី 1, 26:1-19)**

ដូចដែលកំណាព្យបានសារភាពថាទ្រង់ចូលចិត្តមួយថ្ងៃបន្ថែមទៀតដើម្បីរស់នៅជាអ្នកថែរក្សាផ្ទះរបស់ព្រះ ជាជាងមួយពាន់ថ្ងៃនៅកន្លែងផ្សេងទៀត (5) យើងយល់ពីសារៈសំខាន់នៃវត្ថុដែលទាក់ទងជាមួយព្រះវិហារ ពីព្រោះយើងបានទទួលនូវព្រះគុណដ៏បរិបូណ៌។ (5) តាមរយៈកូនចៅរបស់អូបេតអេដុមដែលព្រះបានប្រើជាអ្នកថែរក្សាព្រះវិហារ។
ទីមួយ ព្រះពរពិតប្រាកដត្រូវតែមានតែព្រះប៉ុណ្ណោះ។ ដូច្នេះដើម្បីទទួលយកព្រះគឺជាពរពិត (របាក្សត្រទី 2 13:14)។ អូបេតអេដុមដែលបានបម្រើហិបសេចក្តីសញ្ញាអស់រយៈពេលបីខែបានថ្វាយភក្តីភាពចំពោះព្រះអស់ពីដួងចិត្ត។ អ្នកយាមទ្វារព្រះវិហារគួរតែការពារឧបករណ៍របស់ព្រះវិហារ។ ប្រសិនបើបំណងនឹងខូចយ៉ាងធ្ងន់ធ្ងរ ទ្រង់នឹងដួលនៅលើកន្លែងគ្រោះថ្នាក់ដូចជាឆ្មាថែរក្សាត្រីដែរ។
ទីពីរ ព្រះពរពិតនឹងមកដល់យើងតាមរយៈព្រះ។ តាមរយៈសកម្មភាពរបស់អូបេឌអេដុម ព្រះបានប្រទានពរដ៏អស្ចារ្យដល់ទ្រព្យសម្បត្តិនិងកូនៗរបស់ទ្រង់។ នៅពេលដែលយើងបានបម្រើព្រះវិហារ យើងគួរតែបម្រើដោយចិត្តរាបសានិងស្មោះត្រង់ដូចជាអ្នកយាមទ្វារ។ យើងគួរតែទទួលបាននូវកិត្តិយសកិត្តិយសដូចជាលោកម័រដេកាយដែលបានបម្រើព្រះជាអ្នកថែរក្សាទ្វារ (អេសធើរ3:3-4)។

**18.អ្នករក្សាបន្ទប់សុវត្ថិភាព(របាក្សត្រទី1,26:20-32)**

ចេញពីអត្ថបទយើងអាចរៀនការពីរយ៉ាង។

ទីមួយ ព្រះដែលជាព្រះអម្ចាស់និងជាម្ចាស់របស់យើងបានត្រាស់ហៅយើងជាអ្នកបម្រើរបស់ទ្រង់។ គ្រីស្ទបរិស័ទគួរតែរស់នៅជាអ្នកបម្រើដ៏ល្អដូចព្រះបានអនុញ្ញាតឱ្យថែរក្សាបន្ទប់សុវត្ថិភាពឱ្យជាប់នឹងរបស់ដ៏បរិសុទ្ធ។

ទីពីរ ព្រះចង់បង្ហាញឧទាហរណ៍ដោយត្រូវបានផ្តល់ការថ្វាយមួយចំនួនដោយពួកហោរានិងស្តេច (26-28) ដើម្បីធ្វើតាមគោលការណ៍នៃក្រុមជំនុំ។ គំរូដែលគោរពដល់ព្រះរបស់សាវកប៉ូលគឺទ្រង់ជាគ្រឹះនៃព្រះវិហារ ហើយបានបញ្ជាគំរូនៃភាពស្មោះត្រង់ចំពោះក្រុមជំនុំអេភេសូរដោយបង្ហាញពីគំរូនៃការគោរពព្រះដល់ធីម៉ូថេ។ តម្រូវការនេះក៏ត្រូវការនៅថ្ងៃនេះដែរ។ កូនប្រុសពីរនាក់របស់អេលី ហ៊ូនីនិងប៊ីនហាដែលបានមើលថែរក្សាបន្ទប់របស់ព្រះ បានមើលងាយវាត្រូវបានសម្លាប់ដោយព្រះនៅថ្ងៃមួយ។ គ្រីស្ទបរិស័ទដែលត្រូវបានហៅជាបូជាចារ្យ គួរតែស្មោះត្រង់ចំពោះបេសកកម្មរបស់អ្នកបម្រើដោយភាពបរិសុទ្ធនិងសុភាពរាបសា។

**19. ភាជន៍នៃភាពបរិសុទ្ធ (របាក្សត្រទី 1, 28:1-21)**

សេចក្តីពិតដែលគ្មានអ្នកណាអាចមើលឃើញព្រះអម្ចាស់បានដោយមិនមានភាពបរិសុទ្ធនិងភាពសុខសាន្តនោះឡើយ (ហេព្រើរ 12: 14)។ គឺជាការពិតនៅថ្ងៃរបស់ដាវីឌ។

ទីមួយ តើដាវីឌចង់បានអ្វី? ទ្រង់ចង់សាងសង់ព្រះវិហារនេះដោយសារការដឹងគុណរបស់ទ្រង់ដោយការអរគុណដល់ព្រះ ដើម្បីមានការប្រកបជាមួយព្រះ។ វាបានបង្ហាញថាទ្រង់បានរស់នៅក្នុងជីវិតដែលមានព្រះជាចំណុចកណ្តាល។ ព្រះវិហារជាកំណាល់ជើងរបស់ព្រះ ដែលជាកន្លែងដែលត្រូវបានតែងតាំងដោយព្រះ។ យោងទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលធ្វើការនៅក្នុងចិត្តរបស់យើង យើងគួរតែមានព្រះគុណគ្រប់គ្រាន់នៅក្នុងចិត្តរបស់យើង (ភីលីព 2: 13)។ ព្រះធ្វើការក្នុងចិត្តរបស់ទ្រង់។

របស់គេ" (17) ហើយការអត់ទោសបាបនិងសេចក្តីស្រឡាញ់នឹងគ្រប់គ្រងលើពួកគេនិងឥទ្ធិពលនៃឈាមរបស់ព្រះគ្រីស្ទនឹងត្រូវបានពោរពេញ (ហេព្រើរ10:17)។ សេចក្តីពិតដែលសាវ័កប៉ូលបានសារភាពថា គ្មានការដាក់ទោស គ្មានសត្រូវមករារាំង និងគ្មានអ្នកចោទប្រកាន់ទៀតឡើយ មានន័យថាផ្ទៃមេឃថ្មីនិងផែនដីថ្មីបានមកដល់នៅក្នុងព្រះគ្រីស្ទរួចហើយ។

ទីពីរ ជាពិភពលោកដែលរីករាយនឹងរាស្រ្តរបស់ទ្រង់ដូចជារបស់ដែលទ្រង់សព្វព្រះទ័យ។ ខ 18-19 មានបន្ទូលថា "ប៉ុន្តែចូលរីករាយនិងមានអំណររហូតទៅនៅក្នុងការដែលយើងបានបង្កើតមក មើលអញបានបង្កើតយេរូសាឡិមទុកជាសេចក្តីអំណរ ហើយរាស្ត្ររបស់នាងទុកជាសេចក្តីរីករាយ។ អញនឹងមានអំណរនៅក្នុងក្រុងយេរូសាឡិមនិងរីករាយនឹងរាស្ត្ររបស់អញ។ ហើយនឹងគ្មានសម្លេងនៃការទួញសោកឬសម្រែកនៃសេចក្តីវេទនាទៀតឡើយ។ ព្រះអម្ចាស់មានសេចក្តីអំណរនឹងរាស្ត្ររបស់ទ្រង់" (សេផានា 3:17)។

ទីបី វាជាផែនដីនៃព្រះពរអស់កល្ប។ ព្រះពរនៃជីវិត (20), ព្រះពរនៃការងារ (21-23), ព្រះពរនៃព្រះគុណ (24) និងព្រះពរនៃសេចក្តីសុខសាន្ត (25)។

**32. ថ្ងៃរបស់ព្រះអម្ចាស់ (អេសាយ 24:1-23)** ជំពូក 24 ដែលបានប្រៀបធៀបអនាគតរវាងផែនដីនិងនគររបស់ព្រះបង្ហាញថា មួយនឹងត្រូវវិនាស ប៉ុន្តែមួយទៀតនឹងនៅជាអស់កល្ប ពីព្រោះ "នៅក្នុងគ្រានោះ" ព្រះយេហូវ៉ានឹងធ្វើជាស្តេចនៅក្រុងយេរូសាឡិម (21-23)។

ទីមួយ នគររបស់ព្រះអម្ចាស់ជានគរដែលព្រះអម្ចាស់គ្រប់គ្រងលើ ហើយនឹងមានពេញដោយក្រុមជំនុំ។ ក្រុងស៊ីយ៉ូននិងយេរូសាឡិមចង្អុលទៅកាន់ក្រុមជំនុំនិងការយាងមកដល់នៃនគររបស់ព្រះអម្ចាស់និងការកាត់ទោសដល់លោកិយនឹងកើតឡើងក្នុងពេលតែមួយ។

ទីពីរ តាមរយៈការយាងមករបស់ព្រះគ្រីស្ទ នោះនគររបស់ព្រះបានមកដល់លើផែនដីនេះ។ នៅក្នុងព្រះវិញ្ញាណបរិសុទ្ធដែលព្រះអម្ចាស់គ្រប់គ្រងលើផែនដីនាពេលនេះ។ ដូច្នេះយើងគួរតែរំលឹកពីផលផ្លែរបស់ព្រះវិញ្ញាណ ដែលជាវត្តមាននៃនគររបស់ព្រះនៅក្នុងគ្រួសាររបស់យើងនិងជីវិតរបស់យើង។ ដូចជាសាវ័កប៉ូល នៅក្នុងបំណងរវាងការដែលមកដល់ហើយនិងមិនទាន់នៅឡើយ យើងគួរតែមើលឃើញការធានាអះអាងនៃសេចក្តីសង្គ្រោះនិងសេចក្តីសង្ឃឹមនៃការសម្រេចបំពេញនៃនគររបស់ព្រះ។

**33. សេចក្តីអំណរនៃសេចក្តីសង្គ្រោះ (អេសាយ 25:1-12)** តើអត្ថបទនិយាយអ្វីខ្លះអំពីសេចក្តីអំណររីករាយនៃសេចក្តីសង្គ្រោះ?

ទីមួយ តើសេចក្តីអំណរនៃសេចក្តីសង្គ្រោះចេញមកពីណា? ខ 1-5 ចូរសរសើរដល់សេចក្តីសង្គ្រោះដែលព្រះជាម្ចាស់បានសម្រេចបំពេញ។ តាមរយៈការព្រៀងទុករបស់ព្រះ ព្រះជាម្ចាស់បានទតមកក្រោមលើគ្រប់សត្រូវនិងបានដកគេចេញ (4-5) ។ ទ្រង់ប្រៀបដូចជាអ្នកដែលផ្គត់ផ្គង់ដល់អ្នកក្រ ជាសុវត្ថិភាពដល់អ្នកក្រីក្រនៅក្នុងសេចក្តីវេទនា និងជាទីជ្រកកោនពីព្យុះ ជាម្លប់ដែលការពារពីព្រះអាទិត្យ និងជាថ្មដារដែលការពារចេញពីកម្តៅព្រះអាទិត្យ ទ្រង់ស្មោះត្រង់ណាស់ ហើយទ្រង់បានសម្រេចសេចក្តីសង្គ្រោះ។

ទីពីរ តើសេចក្តីសង្គ្រោះចេញពីណាមកកាន់យើង? វានឹងកើតឡើងនៅក្នុងក្រុមជំនុំប្រៀបធៀបទៅនឹងភ្នំ (6-8)។ នៅក្នុងក្រុមជំនុំដែលជាសសរនិងជាគ្រឹះនៃសេចក្តីពិត ពិធីបុណ្យនៃសេចក្តីសង្គ្រោះនឹងកើតឡើង។

ទីបី តើអ្វីទៅជាអនាគតរបស់សេចក្តីសង្គ្រោះ? (1-12) វាជាសេចក្តីសង្គ្រោះដល់លោកិយទាំងមូល (3,7) ដែលរួបរួមខាងវិញ្ញាណនិងពេញដោយការបន្ទាបខ្លួន (10-12)។ យើងគួរតែរស់នៅក្នុងសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ (10-12)។

**34. សេចក្តីអំណរនៅក្នុងព្រះអម្ចាស់ (អេសាយ 26:1-21)** តើអ្វីទៅជាសេចក្តីសន្យាដែលព្រះអម្ចាស់បានផ្តល់ដល់រាស្ត្ររបស់ទ្រង់?

ទីមួយ ព្រះអម្ចាស់បានផ្តល់ផ្លូវដែលមានសុវត្ថិភាពដល់យើង (1-4) ហើយនៅក្នុងសេចក្តីក្រោធរបស់ទ្រង់ ព្រះទ្រង់បានធានាការការពារដ៏មានសុវត្ថិភាព (20-21)។

ទីពីរ ព្រះអម្ចាស់បានផ្តល់ផ្លូវដែលចម្រុងចម្រើនដល់យើង (7-9)។ "ផ្លូវរបស់មនុស្សសុចរិតនោះរាបស្មើ ទ្រង់បានធ្វើឱ្យផ្លូវរបស់ពួកសុចរិតបានរាបស្មើ។ នៅផ្លូវនៃសេចក្តីកាត់ទោសរបស់ទ្រង់ ព្រះអម្ចាស់អើយ យើងរង់ចាំទ្រង់ ព្រះនាមទ្រង់និងការចង់ចាំពីទ្រង់ជាសេចក្តីអំណរនៃព្រលឹងរបស់ពួកទូលបង្គំ។ ព្រលឹងរបស់ទូលបង្គំត្រូវការទ្រង់នៅពេលយប់ វិញ្ញាណរបស់ទូលបង្គំស្វែង

រកទ្រង់ដោយស្មោះនៅក្នុងទូលបង្គំ។ កាលដែលសេចក្តីក្រោធរបស់ទ្រង់នៅលើផែនដី នោះមនុស្សនៅលើលោកិយបានរៀនពីសេចក្តីសុចរិត។"
ទីបី ព្រះអម្ចាស់បានផ្តល់ផ្លូវដែលនឹងត្រូវបានលើក (12-15)។ ព្រះអម្ចាស់បានកំណត់បន្ទាត់ខណ្ឌនិងបានបង្កើតមនុស្សដែលគួរឱ្យគោរព។ យើងគួរតែរក្សាបញ្ញាត្តិទីបួននៅក្នុងជំនាន់មនុស្សដែលខ្មៅងងឹតនេះ ហើយរីករាយនឹងមរតករបស់យ៉ាកុបវិញ ហើយដើរនៅលើទីដ៏ខ្ពស់ដោយសារសេចក្តីអំណរនៅទីនោះ។

35. **សេចក្តីសង្គ្រោះដែលចេញមកពីព្រះអម្ចាស់ (អេសាយ 27:1-13)** ហេតុអ្វីបានជាសេចក្តីសង្គ្រោះចេញមកពីព្រះអម្ចាស់បានបើកឡើង?
ទីមួយ វាត្រូវបានសម្រេចដោយព្រះហស្តរបស់ព្រះអម្ចាស់។ នៅក្នុងខ 1 ព្រះហស្តដែលដល់សត្វពស់ធំដែលជាសាតាំងនោះជាព្រះអម្ចាស់។ នៅក្នុងខ 1 "នៅគ្រានោះ ព្រះយេហូវ៉ាទ្រង់នឹងយកដាវមុតក្លាដ៏ធំ ហើយមានកំឡាំងរបស់ទ្រង់ទៅធ្វើទោសដល់សត្វសំបើម ជានាគដែលរត់ពួន គឺសត្វសម្បើមជានាគក្ងិកក្ងក់នោះឯង ហើយទ្រង់នឹងសម្លាប់សត្វសម្បើមនោះដែលនៅក្នុងសមុទ្រ។" ជាព្រះហស្តដែលសម្លាប់សាតាំងទាំងស្រុង។ ជាចុងក្រោយអ្នកដែលយកមុខទាំងពីររបស់ដាវនឹងរក្សាក្រុមជំនុំនិងកាត់ទោសវាទៅ។
ទីពីរ ជាសេចក្តីសង្គ្រោះដែលរីករាយនឹងការការពាររបស់ព្រះអម្ចាស់ (2-6)។ ក្រុមជំនុំដែលប្រៀបធៀបទៅនឹងដើមទំពាំងបាយជូរនៅក្នុងផលនៃចម្ការ ជាផលផ្លែដែលស្រស់ស្អាតដោយការការពាររបស់ព្រះអម្ចាស់ (យ៉ូហាន 15:5)។
ទីបី ជាសេចក្តីសង្គ្រោះដែលសងលោះនូវសេចក្តីទុច្ចរិតរបស់យ៉ាកុប។ ជាថ្ងៃដែលសំអាតសេចក្តីទុច្ចរិតរបស់រាស្ត្រទ្រង់។ ព្រះអម្ចាស់បានស្តីបន្ទោសយ៉ាងសមស្របហើយរក្សាគេនៅក្នុងព្យុះ (7-8) ហើយដកអំពើបាបរបស់យ៉ាកុបចេញ (9) ធ្វើឱ្យពួកគេថ្វាយបង្គំព្រះយេហូវ៉ានៅលើភ្នំបរិសុទ្ធ (13)។ យើងគួរតែទទួលបានព្រះគុណដ៏អស្ចារ្យនេះពីព្រះអម្ចាស់។

36. **គ្រឹះនៃនគររបស់ព្រះ (អេសាយ 28:1-29)** អត្ថបទបានប្រៀបធៀបអេប្រាអ៊ីមទៅនឹង "ហើយផ្ការកំពុងតែស្រពោន ជាសេចក្តីលំអរដ៏រុងរឿងរបស់គេ ដែលនៅលើក្បាលច្រកភ្នំដុះដាល នោះនឹង

បានដូចជាផ្កាល្វាដែលទុំជាដំបូងមុនរដូវក្ដៅ ដែលកាលណាគេក្រលេកទៅឃើញ នោះក៏បេះមកដល់ដៃពមចូលទៅភ្លាម។" (4) វាបង្ហាញថាកាលដែលយើងមិនទទួលស្គាល់ព្រះអម្ចាស់ជាគ្រឹះរបស់យើង បើទោះជាយើងរស់នៅលើដីដ៏មានជីជាតិក៏ដោយ នោះយើងនឹងត្រូវវិនាស។ តើរូបភាពអ្វីដែលអ្នកចាកចេញពីព្រះបង្ហាញមក?

ទីមួយ វានឹងត្រូវបានកាត់បន្ថយ។ វាមានន័យថាជាការលុបបំបាត់និងការបំផ្លាញ (1-3)។ មកុដនឹងត្រូវបោះទៅដីដោយសារព្យុះទឹកកក ព្រុះនិងទឹកជំនន់។ ហើយមានន័យថាព្រះអម្ចាស់នឹងសង្កត់មកុដរបស់អ្នកដែលក្រអឺតក្រទម។

ទីពីរ វាមិនត្រូវបានរក្សាដោយព្រះអម្ចាស់ ខ 7-22 បង្ហាញថា បើទោះជាពួកគេជារាស្ត្ររបស់ព្រះអម្ចាស់ក៏ដោយ នៅពេលដែលពួកគេមិនប្រែចិត្តទៅកាន់ព្រះ ទ្រង់នឹងកាត់ទោសគេយ៉ាងជាក់។

ទីបី មានតែអ្នកដែលទុកចិត្តព្រះអម្ចាស់ដែលជាគ្រឹះរបស់ភ្នំស៊ីយ៉ូនទេ ដែលនឹងត្រូវបានសង្គ្រោះ។ ខ 16 ហេតុដែលថ្មមួយដុំបានដាក់នៅស៊ីយ៉ូនជាគ្រឹះ មានន័យថាប្រសិនបើអ្នកដែលឈររឹងមាំនៅលើថ្មនោះ នោះនឹងត្រូវបានសង្គ្រោះចេញពីសភាពដ៏អាក្រក់។ អ្នកដែលពឹងផ្អែកលើព្រះគ្រីស្ទមានសង្ឃឹមដ៏រស់នៅស្ថានភាពនោះ យើងត្រូវដើរតាមព្រះគ្រីស្ទដែលជាគ្រឹះដ៏ពិសេសរបស់យើង។

**37. ព្រះហស្តនៃការប្រៀនប្រដៅ (អេសាយ 29:1-14)** តើព្រះអម្ចាស់ប្រៀនប្រដៅអំពើបាបរបស់រាស្ត្រទ្រង់យ៉ាងដូចម្ដេច?

ទីមួយ ព្រះអម្ចាស់ប្រដៅពួកគេដោយការវាយប្រហាររបស់សត្រូវ (1-8)។ ព្រះអម្ចាស់ដាក់ទោសអ៊ីស្រាអែលដោយគ្រប់ជាតិសាសន៍ ប៉ុន្តែពួកគេមិនបានប្រែចិត្តពីបាបរបស់គេ នោះព្រះអម្ចាស់ដាក់ទោសពួកគេ។ ស្រុកបាប៊ីឡូន ស៊ីរ៉ី និងអេស៊ីបជាឧបករណ៍របស់ព្រះ។

ទីពីរ ព្រះអម្ចាស់ប្រដៅពួកគេដោយចាក់បង្ហូរវិញ្ញាណដែលធ្វើឱ្យពួកគេដេកលក់។ ខ 9-13 មានបន្ទូលថា "ចូរឱ្យអ្នករាល់គ្នាជាស្នាក់ស្ទើរ ហើយភាំងឆ្ងល់ចុះ ចូរឱ្យបិទភ្នែក ហើយធ្វើជាមនុស្សខ្វាក់ទៅ គេស្រវឹងតែមិនមែនដោយស្រាទំពាំងបាយជូរទេ គេទ្រេតទ្រោតទៅ តែមិនមែនដោយគ្រឿងស្រវឹងឡើយ។ ដ្បិតព្រះយេហូវ៉ាទ្រង់បានចាក់វិញ្ញាណ ដែលបណ្ដាលឱ្យលក់ស៊ប់មកលើ

អ្នករាល់គ្នា ក៏បានបិទភ្នែកអ្នករាល់គ្នាជាពួកហោរា ហើយបានគ្របភ្ជិតក្បាលអ្នករាល់គ្នាជាពួកមើលឆុត។ ការជាក់ស្តែងទាំងអស់បានត្រឡប់ដូចជាពាក្យក្នុងសៀវភៅ ដែលបិទត្រាហើយ ដល់អ្នករាល់គ្នា ជាសៀវភៅនេះទៅ តែអ្នកនោះឆ្លើយតបថាខ្ញុំមើលមិនបានទេ ពីព្រោះបិទត្រាហើយ។ ឱ្យគេបញ្ជូនដល់អ្នកដែលគ្មានចំណេះ ដោយពាក្យថា សូមអ្នកមើលសៀវភៅនេះ តែអ្នកនោះឆ្លើយតបវិញថា ខ្ញុំមិនចេះអក្សរទេ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលថា ហេតុដោយពួកសាសន៍នេះគេចូលមកជិតអញ ហើយគោរពប្រតិបត្តិដល់អញ ដោយសំដីនឹងបបូរមាត់របស់គេ តែបានដកចិត្តចេញទៅឆ្ងាយពីអញ ហើយការដែលកោតខ្លាចដល់អញគ្រាន់តែជាបង្គាប់របស់មនុស្ស ដែលបង្រៀនគេប៉ុណ្ណោះ។″ ការទស្សទាយរបស់សាការីចេញមកពីព្រះវិញ្ញាណ ប៉ុន្តែហោរាក្លែងក្លាយទស្សទាយចេញពីកិច្ចការរបស់ព្រះក្លែងក្លាយ។ ព្រះអម្ចាស់ប្រព្រឹត្តទៅលើបាបរបស់រាស្ត្រទ្រង់ដោយបល្ល័ង្គខាងក្រៅនិងដាវខាងក្នុង (យ៉ូហាន 15:1)។ ព្រះហស្តដែលមានជីវិតនៅក្នុងយើងនៅពេលនេះ។

38. **ព្រះហស្តនៃការស្តារឡើងវិញ (អេសាយ 29:17-24)** តើព្រះអម្ចាស់ស្តាររាស្ត្ររបស់ទ្រង់ឡើងវិញដោយរបៀបណា?

ទីមួយ ព្រះអម្ចាស់ស្តារពួកគេដោយការប្តូរនៃពិភពលោក។ ខគម្ពីរមានបន្ទូលថាឡេបាណន់នឹងត្រូវចាត់ទុកជាទឹកដីដែលមានជីជាតិនិងព្រៃ។

ទីពីរ ពួកគេប្តូរដោយការប្តូរជីវិតខាងវិញ្ញាណ។ ខ 15-16 ព្រមានថាអ្នកដែលលាក់អំពើបាបរបស់ខ្លួននឹងត្រូវបណ្តាសា ហើយខ 17-19 បានសន្យាថា លេបាណន់នឹងត្រូវប្តូរជាមានជីជាតិ អ្នកគនិងអ្នកខ្វាក់នឹងត្រូវបានផ្លាស់ប្រែ។

ទីបី ពួកគេផ្លាស់ប្តូរដោយការផ្លាស់ប្តូររបស់យ៉ាកុប។ ខ 22-24 បានសន្យាថាព្រះអម្ចាស់ជាអ្នករំដោះអ័ប្រាហាំនឹងប្តូរជាកុលសម្ព័ន្ធរបស់យ៉ាកុប។ នៅក្នុងសញ្ញាថ្មីដែលព្រះគ្រីស្ទបានយាងមក ការប្រដៅដែលគួរឱ្យខ្លាចមួយរបស់ព្រះយេហូវ៉ា (6) ជាការចាប់ផ្តើមនៅពេលតែមួយនៃកិច្ចការរបស់ព្រះវិញ្ញាណដែលព្រះគ្រប់គ្រងនៅតែបន្ត។ យើងគួរតែសម្រេចសេចក្តីសង្គ្រោះរបស់យើងនៅក្នុងសេចក្តីញាប់ញ័រនិងកោតខ្លាច។

**39. ភាពមិនស្មោះត្រង់និងសេចក្តីស្មោះត្រង់ (អេសាយ 29:25-33)** តើភាពស្មោះត្រង់របស់ព្រះនិងមនុស្សខុសគ្នាត្រង់ណា? (18-33)។

ទីមួយ ព្រះអម្ចាស់កំពុងរងចាំដើម្បីចាក់បង្ហូរព្រះគុណនិងសេចក្តីមេត្តមកលើពួកគេ (18)។ ទ្រង់កំពុងរង់ចាំពួកគេមួយថ្ងៃដូចជាមួយពាន់ឆ្នាំ មួយពាន់ឆ្នាំដូចជាមួយថ្ងៃ។

ទីពីរ ទ្រង់ជាព្រះនៃការព្យាបាល (26)។ ព្រះអម្ចាស់ទ្រង់ជះពន្លឺនៃការព្យាបាលដល់ពួកគេ។ បន្ទាប់មកពួកគេនឹងរត់ដូចជាកូនគោដែលចេញរួចពីរបង។

ទីបី ទ្រង់ជាព្រះដែលច្រៀនចម្រៀងដូចជាប៉ូលនិងស៊ីឡាស់ (29)។ ប៉ុន្តែទ្រង់ជាអ្នកកាត់ទោសដូចជាស៊ីរីត្រូវបានដកចេញមួយរំពេច (31-33)។ អ្នកដែលទុកចិត្តព្រះដែលស្មោះត្រង់នឹងមានពរ ពីព្រោះមនុស្សមិនគួរឱ្យទុកចិត្តទេ ប៉ុន្តែព្រះអម្ចាស់តែមួយប៉ុណ្ណោះដែលអាចជឿបាន។ យើងគួរតែបើកមាត់ធំទៅកាន់ព្រះអម្ចាស់ ហើយស្វែងរកព្រះគុណដ៏អស្ចារ្យរបស់ទ្រង់ ពីព្រោះទ្រង់ពិតជាឆ្លើយមកកាន់យើង។

**40. ការព្រមានដល់ស្រុកទីរ៉េ (អេសាយ 23:1-18)** តើអ្វីដែលអត្ថបទធ្វើឱ្យយើងគិតពីការសារភាពដ៏ល្ងីល្ងើរបស់អ្នកមាន? "ព្រលឹងរបស់ខ្ញុំ ចូរយើងរីករាយជាអស់កល្បដោយការផឹក។"

ទីមួយ អរិយធម៌ខាងសម្ភារៈដោយគ្មានព្រះនឹងត្រូវបំផ្លាញដោយសេចក្តីវិនាស (1-14)។ សេចក្តីចំរុងចម្រើនរបស់ស្រុកទីរ៉េ ដាស៊ីស និងស៊ីដូនត្រូវបានបោះបង់ចោល បង្ហាញពីការកាត់ទោសដល់មនុស្ស។ យើងគួរតែស្តាប់ទៅកាន់ពាក្យរបស់ពួកសាវ័កដែលស្រឡាញ់លុយនោះជាឫសគល់នៃការអាក្រក់ទាំងអស់។

ទីពីរ ហេតុដែលព្រះអម្ចាស់កាត់ទោសការខាងសម្ភារៈនិយមជាការកំណត់របស់ព្រះជាម្ចាស់ (8-9)។ ប៉ុន្តែព្រះអម្ចាស់បានសន្យាការស្តារឡើងវិញ ពីព្រោះចំណង់នៃការសម្ភារៈនិយមជាសេចក្តីវិនាសអន្តរាយ។ បន្ទាប់ពីគ្រានៃការប្រដៅមក ព្រះអម្ចាស់បានសន្យាការស្តារស្រុកទីរ៉េនិងស៊ីដូនឡើងវិញ (15-18)។ យើងគួរតែមើលទៅកាន់សិរីល្អនៃសេចក្តីសង្គ្រោះ។

**41. ចេស្តានៃការអធិស្ឋាន (អេសាយ 40:27-31)** ផ្នែកទីមួយនៃអត្ថបទសង្កត់លើការកំសាន្តចិត្ត

សេចក្តីសង្ឃឹម និងអំណាចជារបស់ព្រះ ប៉ុន្តែផ្នែកចុងក្រោយបង្ហាញពីការអញ្ជើញដោយស្មោះរបស់ព្រះជាម្ចាស់ហៅទៅកាន់ពិភពនៃការអធិស្ឋាន។ តើយើងបានរៀនអ្វីចេញពីការអធិស្ឋាននៅក្នុងអត្ថបទ?

ទីមួយ អង្គដែលយើងអធិស្ឋានទៅជាព្រះអម្ចាស់។ អ៊ីស្រាអែលបានស្វែងរកការជួយមួយចំនួនចេញពីរូបព្រះក្លែងក្លាយយ៉ាងល្វីល្វើ (18)។ ព្រះអម្ចាស់ដែលមានគ្រប់ចេស្តា ជាព្រះអាទិករ (15, 21-22) ទ្រង់មិនដែលស្គាល់ការនហត់នឿយនិងអស់កម្លាំងសោះ ហើយទ្រង់មិនដែលផ្ទុំលក់ មិនដែលងោកងុយ ទ្រង់ជាអង្គដែលការពារដែលទ្រង់មានប្រាជ្ញាដែលមិនអាចវាស់បាន។ មានតែទ្រង់ទេដែលយើងត្រូវទូលអង្វរទៅកាន់។

ទីពីរ យើងត្រូវតែស្វែងរកព្រះគុណនៅក្នុងព្រះអម្ចាស់។ ខ 27 បង្ហាញពីហេតុផលដែលព្រះអម្ចាស់មិនដែលទូញសោកនិងភាពល្វិញជូរចត់របស់ទ្រង់ជាសេចក្តីពិតដែលគេមិនបានស្គាល់ព្រះច្បាស់។

ទីបី អំណាចថ្មីនឹងមកកាន់អ្នកដែលរងចាំព្រះអម្ចាស់។ អេសាយជាអ្នកដែលបានប្រៀបធៀបម្នាក់នេះទៅនឹងអ្នកដែលក្មេងហើយរត់ដោយមានកម្លាំង (30-31) ហើយបានលើកឡើងដូចជាឥន្ទ្រីដែលរង់ចាំព្រះអម្ចាស់។

**42. ព្រះហស្តរបស់ព្រះយេហូវ៉ា (អេសាយ 51:9-16)** ពាក្យថា ព្រហស្តរបស់ព្រះយេហូវ៉ា មានន័យថាជាចេស្តារបស់ព្រះ (9) បង្ហាញចំនួន 11ដងនៅក្នុងអេសាយនៅក្នុងចំណោម 28 ដងនៅក្នុងគម្ពីរសញ្ញាចាស់ទាំងមូល (30:30, 40:10 48:14, 51:5,9 52:10 53:1 59:16 62:8 63:5,12)។ តើព្រះហស្តជាអ្វី?

ទីមួយ វាមានន័យថាជាគ្រឹះនៃរបស់ដែលត្រូវបានបង្កើតមកនិងសេចក្តីប្រោសលោះ។ មួយអង្គដែលធ្វើការនៅពីក្រោយការបង្កបង្កើត (13) និងសេចក្តីប្រោសលោះ (9-11) ជាព្រះអម្ចាស់តែប៉ុណ្ណោះ ដោយសាររបស់ដែលបង្កើតមកនិងសេចក្តីសង្គ្រោះត្រូវបានសម្រេចដោយសារចេស្តារបស់ទ្រង់។

ទីពីរ វាបង្ហាញមកតាមរយៈព្រះបន្ទូល។ ការអធិប្បាយ ការប្រកាសព្រះបន្ទូលមិនត្រូវបានបំបែកពីការបង្រៀនឡើយ ពីព្រោះការអធិប្បាយជាការប្រកាសព្រះបន្ទូលដែលបានកត់ទុក

របស់ព្រះ ជាព្រះគម្ពីរដោយពីអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ តាមរយៈការអធិប្បាយនោះសេចក្តីជំនឿត្រូវបានលូតលាស់ឡើងជាធម្មតា និងអាចទាក់ទងព្រះគុណខាងវិញ្ញាណ។
ទីបី កាលដែលយើងទុកចិត្តព្រះហស្តរបស់ព្រះ យើងនឹងផ្លាស់ប្តូរទៅជាមានភាពក្លាហាន (12-14)។ យើងគួរតែក្លាយជាគ្រីស្ទានដែលមានចេស្តាដោយសារជំនឿ។

**43. អ្នកបម្រើដែលទូលទុក្ខ (I) (អេសាយ 52:13-53:6)** តើសេចក្តីប្រោសលោះអ្វីដែលអ្នកបម្រើទូលទុក្ខបានសម្រេចបំពេញ?
ទីមួយ វាជាកិច្ចការដែលបានគ្រោងទុកមុនការបង្កបង្កើតលោកិយនេះ។ ទ្រង់បានសន្យា "មើលអ្នកបម្រើរបស់អញ នឹងប្រព្រឹត្តដោយប្រយត្នប្រយែង ទ្រង់នឹងបានដំកើងឡើង គេនឹងលើកទ្រង់ឡើងឱ្យគង់នៅទីខ្ពស់ណាស់" (13) ហើយ "ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាបានសព្វព្រហឫទ័យនឹងវាយទ្រង់ឱ្យជាំ ហើយឱ្យឈឺចាប់ កាលណាព្រះជន្មទ្រង់ត្រូវបានថ្វាយទុកជាយញ្ញបូជាលោះបាបហើយ នោះទ្រង់នឹងបានឃើញពូជពង្សរបស់ទ្រង់ ហើយនឹងចម្រើនព្រះជន្មទ្រង់ឱ្យយឺនយូរតទៅ ឯបំណងព្រះហឫទ័យនៃព្រះយេហូវ៉ា នឹងជឿនឡើងដោយព្រះហស្តទ្រង់។" (53:10) បង្ហាញថាព្រះអម្ចាស់មានគម្រោងរួចរាល់នៅក្នុងការបង្កបង្កើត (លោកុប្បត្តិ 3:15)។
ទីពីរ វាជាផែនការដែលមានផែនការដែលអស្ចារ្យលើសពីការស្រម៉ៃរបស់មនុស្ស។ ខ 14-15 បង្ហាញការភ្ញាក់ផ្អើលពីរ។ វាមានន័យថាទ្រង់ជាអ្នកធ្វើការដែលគួរភ្ញាក់ផ្អើលនោះ និងការដែលទ្រង់ទទួលការធ្វើទុក្ខទោសយ៉ាងអាក្រក់។ ដោយសារទ្រង់បានប្រសូត្រមក (1) ហើយត្រូវគេមើលងាយ ត្រូវរងទុក្ខនិងមានជម្ងឺ រាស្ត្រមិនគោរពទ្រង់ ហើយទ្រង់រស់នៅជាមនុស្សទូលទុក្ខ (3-4)។
ទីបី កាលដែលយើងជឿដល់ទ្រង់ ទ្រង់បានបង្ហាញពីការមានឥទ្ធិពល។ សេចក្តីប្រោសលោះជាព្រឹត្តិការណ៍ដែលទំនាយជាច្រើនដែលព្រះបានសម្រេច (1)។ យើងគួរតែសម្រេចសេចក្តីប្រោសលោះរបស់យើងដោយបដិសេធខ្លួនឯងនិងលីឈើឆ្កាង។

**44. អ្នកបម្រើដែលទូលទុក្ខ (II) (អេសាយ 53:6-9)** តើលក្ខណៈអ្វីដែលសេចក្ដីវេទនាបង្ហាញដល់យើង?

ទីមួយ វាជាសេចក្ដីរងទុក្ខជំនួស (6-7)។ ទ្រង់ត្រូវរងទុក្ខដោយគ្មានហេតុ។ "យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀនខ្លួន ហើយព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់។ ទ្រង់ត្រូវគេសង្កត់សង្កិន ហើយធ្វើទុក្ខ តែទ្រង់មិនបានហើបព្រះឱស្ឋសោះ គឺដូចជាចៀមគេដឹកទៅសំឡាប់ ហើយដូចជាចៀមដែលគនៅចំពោះពួកអ្នកកាត់រោមយ៉ាងណា ទ្រង់ក៏មិនបានហើយព្រះឱស្ឋសោះយ៉ាងនោះដែរ។" ខ4 មានបន្ទូលថា "ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា។" តើលក្ខណៈអ្វីដែលការរងទុក្ខមាន? ទីមួយ វាជាការរងទុក្ខ (6-7)។ ទ្រង់បានទទួលជម្ងឺរបស់យើង សេចក្ដីសោកសង្រេងរបស់យើង ហើយនៅខ 5 មានបន្ទូលថា ទ្រង់បានរងទុក្ខអំពើបាបរបស់យើង។ នៅខ 8 មានបន្ទូលថា ទ្រង់ត្រូវរងទុក្ខដោយសារសេចក្ដីរំលងរបស់រាស្ត្រទ្រង់។

ទីពីរ វាជាការរងទុក្ខដែលទ្រាំទ្រគ្រប់ទាំងការមើលងាយទាំងអស់ (7)។ ទ្រង់បាននៅស្ងៀមដូចជាចៀមនៅចំពោះអ្នកកាត់រោម។ កាលដែលទ្រង់ត្រូវថ្វាយរោមរបស់ទ្រង់ ទ្រង់បាននៅស្ងៀមរហូតដល់សម្រេចបំណាងដោយមិនបានរើសោះ។ ដូចជាចៀមដែលដឹកយកទៅសំឡាប់នៅទីស្ងាត់ ដូចជាអ៊ីសាក់នៅភ្នំម៉ូរី មិនមានសម្លេងតបទៅគេឡើយ។ ដូចសេចក្ដីពិតនេះ សេចក្ដីរងទុក្ខរបស់ទ្រង់មានពិត។ យើងគួរទៃរៀនលីឈើឆ្កាង។

**45. អ្នកបម្រើដែលទូលទុក្ខ (អេសាយ 53:10-12)** តើផលប្រយោជន៍អ្វីដែលសេចក្ដីស្លាប់របស់ព្រះគ្រីស្ទបានផ្ដល់ដល់យើង?

ទីមួយ ទ្រង់បានផ្គាប់ចិត្តដល់ព្រះអម្ចាស់ (10-11) – ទ្រង់បានសម្រេចព្រះហឫទ័យរបស់ព្រះយេហូវ៉ាទុកដូចជាដង្វាយសម្រាប់ការរំលង (ដង្វាយផ្សះផ្សា) តាមរយៈព្រឹត្តិការណ៍រាប់ពាន់នៅអតីតកាល ហើយហោរាដែលទ្រង់ជាដង្វាយតែមួយនៅក្នុងលោកិយនេះ។

ទីពីរ ព្រះអម្ចាស់បានធ្វើឱ្យរាស្ត្រទ្រង់បានរាប់ជាសុចរិត។ ការសុគតរបស់ទ្រង់បានសំអាត

គ្រប់ទាំងអំពើបាបរបស់រាស្ត្រទ្រង់ ហើយទ្រង់បានយកគេទៅកាន់ទីដ៏ខ្ពស់ហើយមានការប្រកបជាមួយគេ (11)។ ការដែលរាប់ជាសុចរិតដោយចំណេះដឹងរបស់ទ្រង់ ដែលត្រូវបានសម្រេចដោយការសងថ្លៃលោះរហូតដល់កម្រិតនិងវិធីសាស្ត្រទ្រង់ ដោយសារយើងមិនអាចឈររឹងមាំនៅចំពោះព្រះដ៏សុចរិតដោយគ្មានសេចក្តីសុចរិតឡើយ។
ទីបី ព្រះអម្ចាស់បានផ្តល់ព្រះគុណអស្ចារ្យដល់យើង។ ភាពស្មោកគ្រោកនិងអំពើបាបត្រូវបានដោះចេញ សេចក្តីសុខសាន្តនិងការព្យាបាលបានកើតឡើង (5)។ កាលដែលយើងមើលទៅកាន់គ្រាប់ពូជ នោះថ្ងៃរបស់ទ្រង់នឹងនៅជាអង្វែង (10)។ ដូចជាដានីយ៉ែលបានទាយតាមរយៈការស្លាប់របស់គាត់ ជាគោលបំណងរបស់កូនមនុស្សបានយាងមកនៅក្នុងលោកិយ ទ្រង់បានថ្វាយពួកគេដល់ព្រះអម្ចាស់។

**46. ផ្លូវនៃសេចក្តីសុខសាន្ត (អេសាយ 57:1-21)** ចំណង់របស់មនុស្សទុច្ចរិតនឹងត្រូវវិនាស ប៉ុន្តែមនុស្សសុចរិតនឹងទទួលបានផ្លូវនៃសេចក្តីសុខសាន្ត (2)។ តើយើងអាចរក្សាសន្តិភាពនៅក្នុងជីវិតយើងដោយរបៀបណា? ទីមួយ ការទួញសោក។ ខ 14-15 មានបន្ទូលថា បើទោះជាព្រះអម្ចាស់នៅទីដ៏ខ្ពស់បំផុតក៏ដោយ ប៉ុន្តែវត្តមានរបស់ទ្រង់នៅជាមួយអ្នកដែលលន់តួបាបហើយទ្រង់នឹងស្តារចិត្តរបស់គេឡើងជាថ្មី។ ខ 18 មានបន្ទូលថាព្រះអម្ចាស់ព្យាបាលមនុស្សរូដ្ឋច្នេះ។ នៅក្នុងការបង្រៀននៅលើភ្នំរបស់ព្រះអម្ចាស់ ការដែលយំសោកមានព្រះពរជាការកំសាន្តចិត្ត (ម៉ាថាយ 5:4)។ ព្រះអម្ចាស់គង់ជាមួយមនុស្សដែលបន្ទាបខ្លួន។ ការទួញសោកមានទំនាក់ទំនងជាមួយការបន្ទាបខ្លួន។ ខ 7 មានបន្ទូលថា រូបភាពនៃការគោរពព្រះក្លែងក្លាយជាការក្រអឺតក្រទម។ ចិត្តក្រអឺក្រទមមិនមានសេចក្តីសុខសាន្ត ហើយមិនអាចរួបរួមជាមួយទ្រង់បានទេ។ កាលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកកាន់យើង នោះទ្រង់នឹងដឹកនាំទៅកាន់បល្ល័ង្កនៃសេចក្តីសុខសាន្ត (ភីលីព 2:1-2)។

**47. ព្រះពរនៃការរក្សាថ្ងៃរបស់ព្រះអម្ចាស់ (អេសាយ 58:3-14)**

ទីមួយ ការរក្សាថ្ងៃសប្ប័ទជាបរិសុទ្ធ។ ដូចដែលព្រះអម្ចាស់បានចង្អុលបង្ហាញទីកន្លែងមួយ ជាសួនច្បារអេដែនទុកជាទីដែលមានការប្រកបរវាងព្រះអម្ចាស់និងអ័ដាម នោះព្រះអម្ចាស់បាន

កំណត់មួយថ្ងៃជាថ្ងៃប្រកបគ្នាទ្រង់នឹងអ័ដាម។
ទីពីរ តើយើងរក្សាថ្ងៃនោះដោយរបៀបណា? 1) ការគ្រប់គ្រងខ្លួនឯង។ ការគ្រប់គ្រងខ្លួនជាផលផ្លែខាងព្រះវិញ្ញាណបរិសុទ្ធ ជាសីលធម៌ដែលសំខាន់នៃជីវិតខាងសេចក្តីជំនឿ (3-4) 2) ដើរតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ - "កុំដើរតាមផ្លូវរបស់ឯងឡើយ" "បញ្ឈប់ការនិយាយស្តីផ្ទាល់ខ្លួន"។ ថ្ងៃនោះគួរតែជាព្រះអម្ចាស់នៅកណ្តាលជាពិត។ 3) ជីវិតដែលយកការថ្វាយបង្គំជាកណ្តាល - ដោយសារថ្ងៃជាថ្ងៃដែលគួរគោរព នោះយើងគួរតែចាត់ទុកជាថ្ងៃគួរគោរព។
ទីបី ព្រះអម្ចាស់បានសន្យាការបីយ៉ាងដល់អ្នកដែលរក្សាថ្ងៃព្រះអម្ចាស់។ 1) គេនឹងទទួលបានសេចក្តីអំណរចេញពីព្រះអម្ចាស់ 2) គេនឹងទទួលបានកិត្តិយសនៅក្នុងផែនដី។ 3) គេនឹងបានរីករាយនឹងមរតករបស់យ៉ាកុប។ ដូចជាភ្នំបានមកកាន់យើង នោះព្រះពររបស់ព្រះនឹងត្រលប់មកកាន់យើងដូចជាប្រភពនៃព្រះពរ។ (8-12) ដោយរក្សាថ្ងៃរបស់ព្រះអម្ចាស់ នោះយើងនឹងរីករាយនឹងព្រះពរនៅសួនអេដែន។

**48. ព្រះអម្ចាស់ជាអ្នកដែលមានជ័យជម្នះ (អេសាយ 42:1-26)** យើងអាចយកឈ្នះសង្គ្រាមរបស់យើងជាក់ស្តែង កាលណាយើងមើលឃើញការប្រយុទ្ធរបស់ព្រះជំនួសអោយយើង។
ទីមួយ ហេតុដែលព្រះអម្ចាស់បង្ហាញជាអ្នកចម្បាំង - ទ្រង់មានបន្ទូលថា " . (13) ព្រះអម្ចាស់ជាអ្នកចម្បាំង កាលដែលស្ត្រីមានផ្ទៃពោះបានស្រែកឡើង នោះបានបំផ្លាញសត្រូវយ៉ាងក្រៃលែងបើទោះជាពួកគេខ្លាំងក្លាក៏ដោយ (15-17)។ ហើយពិតណាស់ទ្រង់នឹងបង្កើតសេចក្តីយុត្តិធម៌ (4)។
ទីពីរ វិធីសាស្ត្រប្រយុទ្ធ - ទ្រង់ប្រយុទ្ធដោយភ្ជាក់ងារពីរ (1-2) 1) ទ្រង់ប្រយុទ្ធដោយការបន្ទាបខ្លួន (2) 2) ហើយទ្រង់សម្រេចដោយសេចក្តីមេត្តារបស់ទ្រង់។ និយាយដោយខ្លី ទ្រង់ប្រយុទ្ធដោយសេចក្តីស្រឡាញ់ដែលជាគោលការណ៍នៃកូនចៀម។ យើងគួរតែមើលទៅកាន់ព្រះអម្ចាស់ជាអ្នកចម្បាំងរាល់ថ្ងៃ ហើយពិសោធន៍ខ្លួនយើង និងដើរតាមឧទាហរណ៍របស់យើង យើងគួរតែឈ្នះសត្រូវ សាតាំង និងចំណង់បាប និងលោកិយ ពីព្រោះគ្រប់ជ័យជម្នះជារបស់យើងនៅក្នុងព្រះគ្រីស្ទ។

**49. យើងមានហេតុផលទៅក្នុងការច្រៀង (អេសាយ 54:1-17)** ហេតុអ្វីបានជាអេសាយជម្រុញ ?"(1)

ទីមួយ ដោយសារទ្រង់បានពង្រីកទឹកដីរបស់យើង។ នៅខ 3 ពួកគេបានច្រៀងការពង្រីកទឹកដីនឹងជម្រករបស់ពួកគេ។ វាជាការសន្យាដ៏អស្ចារ្យដែលជម្រកបានពង្រីកទៅកាន់ផ្នែកខាងស្តាំនិងខាងឆ្វេង។

ទីពីរ ដោយសារវាជាសេចក្តីស្រឡាញ់អស់កល្បរបស់ព្រះអម្ចាស់។ ព្រះអម្ចាស់បានសន្យាថាទ្រង់នឹងផ្តល់សេចក្តីមេត្តាអស់កល្បដល់ពួកគេ (8) ហើយព្រះអម្ចាស់នឹងទទួលខុសត្រូវសម្រាប់ការស្តីបន្ទោសរបស់ពួកគេនិងកែតម្រូវពួកគេ ហើយមិនចាកចេញពីព្រះអម្ចាស់ (10)។

ទីបី ពួកគេបានច្រៀង ពីព្រោះព្រះអម្ចាស់បានផ្តល់សេចក្តីសុខសាន្តដល់ពួកគេ (13-15)។ ព្រះអម្ចាស់បានប្រកាសឱ្យទទួលការបង្រៀនរបស់ព្រះអម្ចាស់ និងរីករាយសេចក្តីសុខសាន្ត (13), ការគៀបសង្កត់នឹងបាត់ទៅ សេចក្តីភ័យខ្លាចនឹងមិនអាចមកជិតបានឡើយ (14), ហើយម្នាក់ដែលវាយអ្នកនឹងត្រូវបានបំផ្លាញ (14)។ យើងគួរតែរស់នៅដូចជារាស្ត្រដែលសរសើរដល់ព្រះអម្ចាស់។

**50. សិរីល្អនៃសេចក្តីប្រោសលោះ (អេសាយ 43:1-28)** តើសេចក្តីប្រោសលោះអ្វីរបស់ព្រះមកដល់យើង?

ទីមួយ វាចាប់ផ្តើមជាមួយផែនការរបស់ព្រះអម្ចាស់។ ខ 1 មានន័យថាសេចក្តីប្រោសលោះជាកិច្ចការនៃការបង្កើតជាថ្មី។ វាមិនមែនជាការចៃដន្យ ប៉ុន្តែជាផែនការរបស់ព្រះមុនពេលបង្កើតលោកិយមកម្ល៉េះ ( 7, 21,25)។ សេចក្តីប្រោសលោះនេះត្រូវបានរៀបចំដោយព្រះផ្ទាល់ (អេភេសូ 1:4-6)។

ទីពីរ វាត្រូវបានសម្រេចដោយការត្រាស់ហៅផ្ទាល់របស់ព្រះអម្ចាស់។ ខ 1 និងខ 5-7 ចង្អុលថា ការដែលព្រះបានត្រាស់ហៅមនុស្សពីខាងជើងនិងខាងត្បូង មានន័យថាមនុស្សទាំងអស់ត្រូវតែមកកាន់ព្រះគ្រីស្ទ ពីព្រោះការត្រាស់ហៅរបស់ព្រះជាការជ្រើសរើស ទ្រង់មិនបានហៅមនុស្សណាម្នាក់ដោយមិនមានគោលបំណងនោះទេ។ សិរីល្អនឹងខិតចូលមកដោយការ

ដឹកនាំរបស់ព្រះ។ ខ្ញុំនឹងទៅកាន់ការថ្វាយសិរីល្អនៃសេចក្តីសុចរិត។ សេចក្តីសង្គ្រោះចេញពីប្រទេសអេស៊ីប (16-17) និងសេចក្តីសង្គ្រោះចេញពីបាប៊ីឡូន និងការរីករាយភាពបរិបូរណ៍នៃការរួបរួមរបស់អ្នកថ្វាយបង្គំព្រះផ្សេង នឹងសម្រេចដោយបំណងរបស់ព្រះអម្ចាស់ (20)។ មើលទៅកាន់ផ្កានៃសេចក្តីប្រោសលោះ យើងគួរតែថ្វាយខ្លួនយើងទៅកាន់ព្រះអម្ចាស់។

**51. ចូរមកកាន់ទឹក (អេសាយ 55:1-13)** តើយើងអាចរីករាយនឹងព្រះគុណនៃសេចក្តីសង្គ្រោះដែលគោរពដល់ព្រះយេហូវ៉ា និងសញ្ញាដ៏អស់កល្បដោយនៅអស់កល្បដោយរបៀបណា? (12-13)។

ទីមួយ យើងគួរតែស្គាល់ព្រះគុណដែលព្រះអម្ចាស់បានរៀបចំសម្រាប់យើង។ អត្ថបទបង្ហាញភាពបរិបូរណ៍នេះទុកជាការសន្យា។ មានសេចក្តីមេត្តានិងសេចក្តីស្រឡាញ់។ (7) ការផ្លាស់ប្រែឡើងវិញនៃព្រលឹង (3) សាច់ដែលល្អនិងធាត់ (3) ពេលដែលហូរហៀ (12) និងកិត្តិយសរបស់ព្រះអម្ចាស់ (13) នៅគុអាហារ។

ទីពីរ អ្នកដែលរៀបចំសម្រាប់យើង?(11) ទ្រង់ជាព្រះដែលមានគ្រប់អំណាចចេស្តា ជាព្រះដ៏ខ្ពស់បំផុត ព្រះដ៏បរិសុទ្ធ ជាព្រះមានឥទ្ធិឫទ្ធិចេស្តា ជាអង្គដែលបើកសម្តែង ជាមេទ័ព ជាអ្នកដឹកនាំ និងជាអ្នកសម្រេច។

ទីបី តើយើងត្រូវឆ្លើយតបយ៉ាងណា? ពួកគេគួរតែមកកាន់ទឹក។ ដែលជាការលន់តួបាបនិងសេចក្តីជំនឿ ដែលកាលគេស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ នោះពួកគេអាចទទួលពិសោធន៍ការផ្លាស់ប្រែដ៏អស្ចារ្យ។ តើសេចក្តីសន្យាបែបនេះមាននៅឯណាលើលោក? វាមិនមែនជាគុណដែលថោកៗនោះទេ ពីព្រោះព្រះអម្ចាស់បានទទួលបណ្តាសាទាំងអស់នៅលើឈើឆ្កាង។ យើងគួរតែមកកាន់ទឹកនេះ។

## II. យេរេមា

### ខ្លឹមសារគ្រួសៗ

1) យើងនឹងគិតពីកណ្ឌគម្ពីរយេរេមា នៅក្នុងរូបភាពនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ដោយដើរតាមការសាកល្បងនូវបុគ្គលិកលក្ខណៈនៃការបើកសំដែងរបស់យេរេមា។ យោងទៅតាមលំហូរនៃសេចក្តីប្រោសលោះ កណ្ឌគម្ពីរអេសាយត្រូវបានហៅថាជាដំណឹងល្អសំរាប់សញ្ញាចាស់ ដោយសារវាបានគូរនូវរូបភាពនៃការបើកសំដែងរបស់សញ្ញាថ្មី។ 700 ឆ្នាំមុនអេសាយបានបង្ហាញពីកំណើត ការសុគត ការរស់ឡើងវិញ និងការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ។ ដូច្នេះអេសាយបង្ហាញមកយើងនូវការបន្តនិងការកាត់ផ្តាច់រវាងសញ្ញាចាស់និងកណ្ឌគម្ពីរអេសាយ។ ជាចុងបញ្ចប់ កណ្ឌគម្ពីរអេសាយផ្តោតទៅលើការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។

**ក** យេរេមា 1:-25:13 ការប្រកាសនៃការវិនិច្ឆ័យទោសទាស់នឹងយូដានិងយេរូសាឡិម

1. **ការចម្រុងចម្រើនក្នុងភាពខ្វះខាត (យេរេមា 22:10-19)**

ព្រះអម្ចាស់បានគ្រោងទុកនូវជ័យជំនះនៅក្នុងសេចក្តីរងទុក្ខវេទនា មិនមែនសេចក្តីចម្រុងចម្រើននៅក្នុងភាពពេញបរិបូរណ៍នោះឡើយ។ ព្រះអម្ចាស់បានធ្វើឲ្យពួកគេនឹកចាំពីភាពសម្បូណ៌នៃពួកឪពុករបស់ពួកគេ ដើម្បីឲ្យពួកគេលន់តួបាបរបស់ពួកគេ។

ទីមួយ ហេតុនៃការរងទុក្ខលំបាក - ពួកគេបានកសាងផ្ទះរបស់ពួកគេជាមួយនឹងសេចក្តីទុច្ចរិតនិងភាពអយុត្តិធម៌។ ប្រសិនបើពួកគេបានប្រើស៊ីដាច្រើនដើម្បីនឹងធ្វើផ្ទះ ពីព្រោះពួកគេបានគិតនឹងក្លាយទៅជាស្តេច ពួកគេត្រូវបានធ្លាក់ចុះទៅជាមនុស្សដែលមានពុត (18-19)។ យើងគួរតែរកនូវសេចក្តីចម្រុងចម្រើនរបស់យើងឲ្យបានសមរម្យ ហើយជ័យជំនះរបស់យើងមិនបានចេញពពីវាំងនោះឡើយ ប៉ុន្តែចេញមកពីត្រសាលនៃទីរហោស្ថានវិញ។

ទីពីរ សេចក្តីចម្រុងចម្រើននៅក្នុងសេចក្តីទុក្ខលំបាក។ ប៉ុន្តែព្រះអម្ចាស់ដែលជាអង្គដែលរៀបចំផ្លូវនៅសមុទ្រក្រហមធ្វើឲ្យពួកគេរីកឡើងនៅក្នុងសេចក្តីអន្តរាយនិងសេចក្តីអាក្រក់។ បើទោះជាបុព្វបុរសយើងនៅសម័យចាស់ៗ ក៏មិនបានបរិភោគបរិដបូរណ៍ ហើយមិនបានផឹកទឹកស្រស់ ពួកគេមានសេចក្តីសុចរិតសំរាប់សេចក្តីចម្រើនរុងរឿង។ នេះជាស្នូលនៃសេចក្តីចម្រុងចម្រើន។ ហេតុ

ដែលព្រះអម្ចាស់បានបង្គាប់ទៅកាន់បងប្អូននៅក្នុងពេលក្រីក្រ នោះគឺត្រូវរក្សាសេចក្តីកោតខ្លាចដល់ព្រះអម្ចាស់។ យើងគួរតែព្យាយាមនៅជាប់នឹងព្រះគ្រីស្ទ យើងគួរតែដើតាមផ្លូវនៃសេចក្តីចម្រុងចម្រើន។

### 2. ការស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ (យេរេមា 22:20-30)

ហេតុនៃសេចក្តីអន្តរាយរបស់យូដា នោះជាទម្លាប់ជីវិត ដែលពួកគេត្រូវបានធ្លាក់ចុះទៅក្នុងការមើលងាយនូវព្រះបន្ទូលរបស់ព្រះ។ (21) ដូចជា ហូបនីនិងប៊ីនហាស នៅពេលដែលពួកគេបានមិនបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្នុងភាពយុវវ័យរបស់ពួកគេ គំនិតនិងទម្លាប់របស់ពួកគេត្រូវបានក្លាយជាអត្តចរិតនៅក្នុងពួកគេ។ ជាលទ្ធផល អ្នកដឹកនាំ មិត្តសម្លាញ់ និងស្តេចត្រូវបានទទួលការដាក់ទោសមកពីព្រះ។ ហេតុអ្វីបានជាទម្លាប់មកពីព្រះបន្ទូលជាព្រះពរដ៏អស្ចារ្យ?

ទីមួយ ពីព្រោះព្រះបន្ទូលរបស់ព្រះជាជីវិត។ នៅពេលដែលយើងស្តាប់ព្រះបន្ទូលរបស់ព្រះ ឥទ្ធិពល នឹងត្រូវបានបានបង្ហាញចេញមក ហើយនៅពេលដែលយើងដាក់ព្រះបន្ទូលរបស់ព្រះមក នោះយើងអាចនៅកន្លែងដែលមានសុវត្ថិភាពនៅក្នុងជីវិតរបស់យើ (យ៉ូហាន 15:7) នៅពេលដែលយើងស្គាល់ពិភពលោកនៃព្រះបន្ទូល យើងនឹងអាចមានការសរសើរជំកើង ការថ្វាយបង្គំ ការអធិស្ឋាន ការបំរើ គោលបំណង និងទស្សនៈដែលមានតម្លៃដែលត្រឹមត្រូវ។ បន្ទាប់មកពួកគេអាចរស់នៅជីវិតដែលពេញបរិបូរណ៍នៅក្នុងលោកិយ។

ទីពីរ ទស្សនៈរបស់ព្រះគម្ពីរត្រូវតែច្បាស់លាស់។ យើងគួរតែជឿថាព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ ហើយជាជីវិតរបស់អ្នកជឿ។ នៅពេលដែលអ្នកជឿត្រូវបានកើតជាថ្មី គេមានតួនាទីនឹងស្តាប់ព្រះបន្ទូលនិងប្រើប្រាស់ព្រះបន្ទូលនៅក្នុងជីវិតរបស់គេ។ យើងគួរតែស្តាប់បង្គាប់ទាំងព្រះបន្ទូលតូចមួយរបស់ព្រះនៅក្នុងជីវិតរបស់យើង។

### 3. សេចក្តីសង្គ្រោះដោយមែកដែលសុចរិត (យេរេមា 3:1-8)

អ្នកដឹកនាំខាងវិញ្ញាណរបស់យូដាសត្រូវបានទទួលទោសពីព្រះ សំរាប់ការដែលគេមិនបានថែរក្សាដល់ពួកគេ។ (1-2) ព្រះអម្ចាស់បានសន្យានឹងតាំងអ្នកដឹកនាំផ្សេងទៀត ដើម្បីនឹងសំរេចតាមព្រះហឫទ័យរបស់ទ្រង់។ នេះជាសេចក្តីសង្គ្រោះដែលព្រះអម្ចាស់បង្កើតឡើង ដោយការបញ្ជូនមែកដែលសុចរិត។ តើអ្វីទៅជាសេចក្តីសង្គ្រោះរបស់មែកដែលសុចរិត?

ទីមួយ នៅពេលដែលយើងត្រូវបានភ្ជាប់ទៅនឹងមែកដែលសុចរិត នោះយើងនឹងអាចទទួលបាន

សេចក្ដីសង្គ្រោះ។ មែកដែលសុចរិតជាព្រះយេស៊ូវគ្រីស្ទ។ (5) កាលដែលពេលនោះមកដល់នៅក្នុងលោកិយ មែកសុចរិតមួយនឹងត្រូវបានដុះឡើងចេញពីដាវីត។ ត្រួយមួយ មែកដែលទន់មួយនោះជាអង្គសង្គ្រោះរបស់យើង។

ទីពីរ ទ្រង់សោយរាជ្យលើពួកគេដូចជាស្ដេច។ ទ្រង់សោយរាជ្យលើពិភពលោកដោយប្រាជ្ញារបស់ទ្រង់ ដែលជាស្នូលនៃសេចក្ដីកោតខ្លាចរបស់ព្រះអម្ចាស់ ហើយបង្កើតឡើងនៅក្នុងលោកិយជាមួយនឹងភាពយុត្តិធម៌និងសេចក្ដីសុចរិត។ ហើយដោយចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ទ្រង់សំរេចបំពេញសេចក្ដីសង្គ្រោះរបស់គេ។

យើងគួរតែរំពឹងនូវសេចក្ដីសង្គ្រោះដ៏ពោរពេញរបស់ទ្រង់ ហើយគួរតែពឹងផ្អែកទៅលើទ្រង់។ យើងគួរតែបំរើព្រះអម្ចាស់ដោយបន្ទាបខ្លួន ដោយមានការធានាអះអាងនៃសេចក្ដីសង្គ្រោះ និងសុបិននៃសេចក្ដីសង្គ្រោះដ៏ពេញបរិបូរណ៍នៅក្នុងថ្ងៃរបស់យើង។

**4. ការចូលរួមនៃក្រុមប្រឹក្សារបស់ព្រះយេហូវ៉ា (យេរេមា 23:9-22)**

ហោរា សង្ឃ ស្ដេចរបស់យូដាមានការវេទនាដោយសារបាប សេចក្ដីកំផិត កំហុស និងសេចក្ដីទុច្ចរិតរបស់ពួកគេ។ (14-20) ហេតុអ្វីបានជារាស្ដ្ររបស់ព្រះធ្លាក់ចុះទៅទីដែលវេទនា?

ទីមួយ ពួកគេមិនបានទទួលនូវការបើកសំដែង។ ហោរាក្លែងក្លាយនិយាយព្រះបន្ទូលរបស់ទ្រង់ដោយខ្លួនពួកគេ ដោយមិនមានការបើកសំដែងនៅក្នុងចិត្តរបស់គេ។ (16) ការបើកសំដែងមិនបានចេញមកពីមនុស្សទេ តែបានចេញមកពីព្រះវិញ។ អ្នកជឿត្រូវបានកើតជាថ្មីម្ដងទៀតដោយសារការបើកសំដែង ហើយត្រូវបានលូតលាស់ឡើងនៅក្នុងការបើកសំដែងនោះ ហើយសេចក្ដីសង្គ្រោះរបស់គេត្រូវបានសំរេចបំពេញដោយការបើកសំដែង។ ដូច្នេះអ្នកដែលមិនបានទទួលការបើកសំដែងមិនដែលស្គាល់ព្រះទេ។ (ម៉ាថាយ 11:27) ក្រុមជំនុំត្រូវបានសំរេចដោយសារការបើកសំដែង។

ទីពីរ ពួកគេមិនបានចូលរួមនៅក្នុងក្រុមប្រឹក្សារបស់ព្រះយេហូវ៉ា។ ក្រុមប្រឹក្សារបស់ព្រះយេហូវ៉ាចង្អុលទៅកាន់គម្រោងការរបស់ព្រះ និងការក្រិតរបស់ទ្រង់។ (18,22) ការអធិស្ឋានមានន័យថាការចូលរួមនៅក្នុងក្រុមប្រឹក្សារបស់ព្រះ។ នៅពេលដែលយើងសូមទៅកាន់ព្រះអម្ចាស់ ហើយទទួលព្រះបន្ទូលរបស់ទ្រង់នៅក្នុងពេលអធិស្ឋាន។ ដូច្នេះ គ្រប់ពេលយើងគួរតែដើរតាមព្រះបន្ទូលរបស់ព្រះ ហើយយើងគួរតែគិតពីរបៀបដែលព្រះហឫទ័យទ្រង់នឹងត្រូវបានសំរេចនៅក្នុងការអធិស្ឋា

ន។

**5. បទពិសោធន៍ដូចជាភ្លើងនិងញញួរ (យេរេមា 23:23-40)**

អ្នកជឿត្រូវការបទពិសោធន៍របស់យេរេមា ដែលបានទទួលព្រះបន្ទូលរបស់ព្រះ ពីព្រោះគ្រឹះនៃក្រុមជំនុំនិងឬសនៃសេចក្តីជំនឿជាក់នូវការយល់ដឹងនៃគោលលិទ្ធិដែលត្រឹមត្រូវ។ តើអ្វីទៅជាបទពិសោធន៍ដែលដូចជាភ្លើងនិងញញួរនៅក្នុងព្រះបន្ទូលរបស់ព្រះ?

ទីមួយ វាជាបទពិសោធន៍នៃភ្លើង។ ភ្លើងជាសញ្ញានៃការវិនិច្ឆ័យទោស ការជ្រមុជនៃការវិនិច្ឆ័យទោស ហើយវាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលបានដកអំពើបាបចេញ ហើយធ្វើឲ្យពួកគេមានបំណងប្រាថ្នា ពីព្រោះព្រះបន្ទូលធ្វើការនៅក្នុងចិត្តដូចជាភ្លើង។ មានភ្លើងដែលក្លែងក្លាយ។ នៅក្នុងខ 26 រឿងសុបិនដែលហោរាបានមើលងាយព្រះបន្ទូលរបស់ព្រះ ហើយនិយាយពីការបង្រៀនដែលខុសឆ្គង មិនបានចេញមកពីព្រះវិញ្ញាណបរិសុទ្ធទេ ប៉ុន្តែចេញមកពីខ្លួនពួកគេផ្ទាល់។ ភ្លើងពិតប្រាកដជាភ្លើងរបស់ព្រះវិញ្ញាណបរិសុទ្ធ ពីព្រោះការយល់ព្រះបន្ទូលរបស់ព្រះជាចេស្តានៃព្រះវិញ្ញាណ។ បន្ទាប់មកយើងអាចទទួលបានចិត្តដែលស្អាត ចិត្តត្រជាក់ និងចិត្តដែលក្លៀវក្លា។

ទីពីរ វាជាបទពិសោធន៍នៃញញួរ។ បទពិសោធន៍ភ្លើងមានឥទ្ធិពលទៅលើការលូតលាស់ផ្ទាល់ខ្លួន ហើយបទពិសោធន៍ញញួរមានឥទ្ធិពលទៅលើព័ន្ធកិច្ច។ យេរេមាមានបទពិសោធន៍នូវព្រះបន្ទូលដែលផ្លាស់ប្រែនេះ។ ដូចជាញញួរ ការកត់ត្រានៃគំនិតរបស់យើង ទម្លាប់ចាស់ រនាំងដែលរឹងមាំ និយគោលលិទ្ធិខុសឆ្គងរបស់យើងនឹងត្រូវបានបំផ្លាញដោយព្រះបន្ទូលរបស់ព្រះ។ ដូច្នេះអ្នកដែលទទួលព្រះបន្ទូលរបស់ព្រះគួរតែនិយាយដោយស្មោះត្រង់។ (20) យើងត្រូវការសកម្មភាពនៃបទពិសោធន៍ដូច្នេះ។

**6. ផ្លែល្វាពីរកន្ត្រក (យេរេមា 24:1-10)**

និមិត្តនៃផ្លែល្វាពីរកន្ត្រកបង្ហាញពីការទស្សទាយនៃបុគ្គលដែលស្តាប់បង្គាប់ និងមិនស្តាប់បង្គាប់នៅក្នុងជីវិតអនាគតរបស់ពួកគេ។ តើអ្វីជាភាពផ្ទុយគ្នាត្រូវបានបង្ហាញនៅក្នុងពួកគេ?

ទីមួយ បើទោះជាអ្នកដែលស្តាប់បង្គាប់ត្រូវបានចាប់ខ្លួន ចុងក្រោយព្រះអម្ចាស់នឹងធ្វើឲ្យពួកគេបានទទួលនូវព្រះហឫទ័យរបស់ព្រះ បានបំរើទ្រង់ដោយអស់ពីចិត្ត ហើយបានស្គាល់ព្រះយ៉ាងជ្រៀលជ្រៅថែមទៀត។ (1-7) បើទោះជាយើងជួបនឹងការបៀតបៀនមួយចំនួនដូចជាមនុស្ស

ដែលបះបោរក៏ដោយ នៅពេលដែលយើងស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ នោះយើងនឹងទទួលបានផ្លូវដែលរស់។
ទីពីរ ប៉ុន្តែអ្នកដែលមិនស្តាប់បង្គាប់ព្រះនឹងត្រូវវិនាសដោយដាវ គ្រោះចង្រៃ និងគ្រោះអត់ឃ្លាន។ ដូចជារូបភាពរបស់កន្ត្រកដូចគ្នា ប៉ុន្តែអត្ថន័យខុសគ្នា អ្នកដែលស្តាប់ព្រះបន្ទូលរបស់ព្រះ ហើយអ្នកផ្សេងទៀតមិនស្តាប់បង្គាប់ព្រះបន្ទូល នោះពួកគេនឹងនាំមកនូវលទ្ធផលខុសគ្នាយ៉ាងច្បាស់។ អ្នកជឿដែលត្រូវបានត្រាស់នៅមកជាកូននៃការស្តាប់បង្គាប់ គួរតែផ្តោតទៅលើការស្តាប់បង្គាប់ដែលជាប់លាប់ ហើយភ្លក់នូវព្រះគុណដ៏អស្ចារ្យរបស់ព្រះ។

### 7. បេសកកម្មរបស់យេរេមា (យេរេមា 1:11-19)

តើយេរេមាដែលត្រូវបានហៅមកដោយព្រះហើយបានក្លាយជាហោរានឹងធ្វើយ៉ាងដូចម្តេច?
ទីមួយ គាត់ពឹងផ្អែកតែទៅលើព្រះដែលស្មោះត្រង់មួយអង្គប៉ុណ្ណោះ។ គាត់បានពឹងផ្អែកលើព្រះដែលមានគ្រប់ព្រះចេស្តាយ៉ាងខ្លាំងក្លា ដែលបង្ហាញពីនិម្មិតនៃដើមអាល់មុន (11) ដូចជាដំបងរបស់អេរ៉ុនត្រូវបានលាស់ឡើងដោយចេស្តារបស់ព្រះអម្ចាស់។
ទីពីរ ព្រះបានធ្វើឲ្យពួកគេក្រោកឈរឡើងនៅចំពោះព្រះ។ ព្រះបានបង្រៀនថា តាមរយៈនិម្មិតនៃភាជន៍ដែលត្រូវបានដាំពុះទៅកាន់ទិសខាងត្បូង នៅពេលអនាគតការឈ្លានពានរបស់ពួកបាប៊ីឡូននឹងត្រូវបានកើតឡើង ពីព្រោះពួកគេបានបំរើព្រះក្លែងក្លាយ។ (13-16)
ទីបី ព្រះអម្ចាស់បានធ្វើឲ្យពួកគេទ្រាំទ្រនឹងសេចក្តីភ័យខ្លាច។ (17-19) ព្រះអម្ចាស់បានសន្យាថា ព្រះនឹងក្លាយទៅជាទីក្រុងដែលរឹងមាំ ជាសសរដែក និងជញ្ជាំងស្ពាន់ ហើយបានលើកទឹកចិត្តដល់អ្នកដែលដូចជាកូនក្មេង។ យើងដែលជាអ្នកដែលត្រូវបានហៅមកសម្រាប់ព្រះគ្រីស្ទ គួរតែពឹងលើព្រះដែលស្មោះត្រង់ដ៏មានចេស្តា ហើយប្រកាសដោយក្លាហាន។

### 8. អំពើបាបរបស់យូដា (យេរេមា 2:1-28)

អំពើបាបរបស់អ៊ីស្រាអែលត្រូវបានបោះចេញពីព្រះ ប្រភពនៃទឹករស់ និងត្រូវបានក្លាយទៅជាចិត្តដែលពុករលួយ ហើយបាតបង់សេចក្តីជំនឿនៃសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា។ តើអំពើបាបនោះជាអ្វី?
ទីមួយ ការមិនជឿ (20) វាជាពេលដែលពួកគេបានដកនូវបន្ទុកនិងច្រវាក់របស់ព្រះចេញ។ ដូចជាត្រីដែលចេញពីទឹក បន្តិចក្រោយមកនឹងត្រូវស្លាប់ នៅពេលដែលយើងចាកចេញពីព្រះ

បន្ទូលរបស់ព្រះ រំពេចនោះនឹងចាប់ផ្តើមដោយសេចក្តីវិនាស។ សេចក្តីស្លាប់ដែលពេញលេញត្រូវបានពឹងលើលំនាំនៃពេលវេលា។

ទីពីរ បានប្រើការថ្វាយបង្គំព្រះក្លែងក្លាយ។ (22-25) ដូចជាសត្វនៅក្នុងតណ្ហាខាងផ្លូវភេទ អំពើធ្វើបាបដោយការប្រព្រឹត្តអំពើផិតក្បត់ អ្នកគោរពរូបព្រះក្លែងក្លាយត្រូវបានគ្រប់គ្រងដោយពួកគេ។ បើទោះជាមានបែបបទមួយចំនួនត្រូវបានបង្ហាញនៅខាងក្រៅការថ្វាយបង្គំខ្លួនឯង និងសេចក្តីលោភលន់ ត្រូវបានចាក់ឬសនៅក្នុងចិត្តរបស់ពួកគេជាព្រះរបស់ពួកគេ។

ទីបី អ្នកដឹកនាំដែលអាក្រក់។ (26) ពីព្រោះស្តេច សង្ឃ និងហោរាបានបាត់បង់សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ (ម៉ាថាយ 23:23) ពួកគេត្រូវបានគ្រប់គ្រងដោយសារជាតិបាបរបស់ខ្លួន។ វាមានន័យថាពួកគេបានបរាជ័យក្នុងការបដិសេធខ្លួនគេនិងការដើរតាមព្រះអម្ចាស់ដោយស្មោះត្រង់ (លូកា 9:23)។ យើងគួរតែត្រឡប់ទៅកាន់ព្រះភ្លាមមួយរំពេចចេញពីបាបដូច្នេះ។

## 9. **អំពើដែលមិនមានការលន់តួ** (យេរេមា 2:29-3:5)

ទីមួយ ពួកគេមិនបានលន់តួនូវអំពើបាបរបស់គេ ពីព្រោះពួកគេមិនមាននូវទំនួលខុសត្រូវ។ (35) ការអះអាងរបស់ពួកគេថា សេចក្តីក្រោធរបស់ព្រះបានដកចេញពីខ្ញុំ ចេញមកពីសេចក្តីងងឹតខាងវិញ្ញាណរបស់ពួកគេ។ យើងត្រូវការការសេចក្តីជំនឿដូចជាចោរដែលនៅខាងស្តាំនៃឈើឆ្កាង ហើយដូចជាអាកប្បកិរិយារបស់អ្នកទារពន្ធ ដែលគាត់បានសារភាពថាគាត់ជាអ្នកមានបាប។ ការនេះជាការលន់តួពិតប្រាកដ។ ព្រះគុណនេះចេញមកពីការស្វែងរកខ្លួនឯងនៅក្នុងពន្លឺនៃការបើកសំដែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ហើយពួកគេក៏មិនអាចលន់តួដោយចេញពីការខ្វះខាតនៃភាពស្មោះត្រង់ដែរ។ (43:1-5) នៅពេលដែលយើងលន់តួពិតប្រាកដចេញមកពីការនោះ។ យើងត្រូវការបទពិសោធន៍ដូចជាដាវីត ដោយការសញ្ជឹងគិតពីសេចក្តីស្រឡាញ់របស់ព្រះនិងភាពស្មោះត្រង់របស់ព្រះ។

ទីពីរ លទ្ធផលដែលមិនលន់តួបាបនោះជាមនុស្សដែលមានពុត។ ពួកគេបានបាត់បង់សេចក្តីអៀនខ្មាស់និងភាពស្មោះត្រង់ ហើយពួកគេត្រូវបានហាមឃាត់នូវការធ្លាក់ភ្លៀងមកមុន និងភ្លៀងបន្ទាប់មក ហើយបានក្លាយជាមនុស្សដែលលោភ នៅក្នុងរូបភាពនៃអ្នកដែលគោរព

កោតខ្លាចដល់ព្រះពួកគេប្រព្រឹត្តអំពើបាប។ យើងត្រូវការវិញ្ញាណនៃសេចក្តីពិតនៅក្នុងសម័យនៃសេចក្តីល្បួងនេះ។

**10. មកកាន់ព្រះយេហូវ៉ាវិញ (យេរេមា 3:19-4:4)**

នៅក្នុងសភាពបាបដ៏អាក្រក់ ការត្រាស់ហៅរបស់ព្រះត្រូវបានបន្ត (22.16-19)។ តើការលន់តួជាអ្វី?

ទីមួយ ការស្គាល់ថាសេចក្តីសង្គ្រោះចេញមកពីព្រះអម្ចាស់។ សេចក្តីសង្គ្រោះរបស់អ៊ីស្រាអែលចេញមកពីព្រះដ៏មានគ្រប់ទាំងព្រះចេស្តាដែលស្មោះត្រង់ ជាអង្គដែលរក្សាសេចក្តីសន្យារបស់ទ្រង់។ ពួកគេជារាស្ត្រ ជាអ្នកដែល ទោះបីជាពួកគេហៅព្រះអម្ចាស់ព្រះអម្ចាស់អើយក៏ដោយ ប៉ុន្តែពួកគេបះបោរទាសនឹងព្រះអម្ចាស់ ហើយបានអះអាងថាមានព្រះហឫទ័យរបស់ទ្រង់នៅក្នុងជីវិតរបស់ពួកគេ។

ទីពីរ ជាការដាំដំណាំនៅលើដីចាស់។ (3) ដូចជាគ្រាប់ពូជដែលបានធ្លាក់ទៅក្នុងបន្លា ដែលជាទ្រព្យសម្បត្តិរបស់គេ សេចក្តីខ្វល់ខ្វាយរបស់ពួកគេ និងសេចក្តីអរសប្បាយរបស់ពួកគេ (ម៉ាថាយ 13:7, 22) ពីព្រោះការប្រយុទ្ធរបស់យើងចេញមកពីចិត្តបែបដូច្នេះ។

ទីបី វាជាវិធីដែលបង្កើតនូវការកាត់ស្បែកនៅក្នុងចិត្តរបស់គេ។ ការកាត់ស្បែកចិត្ត ចង្អុលទៅកាន់ការកើតជាថ្មីតាមរយៈការលន់តួដោយស្មោះត្រង់និងសេចក្តីជំនឿ (រ៉ូម 2:28-29) នៅពេលដែលចំណិតនៃគ្រាប់ធញ្ញជាតិត្រូវបានដុះចេញ ក៏ដូចជាជីវិតថ្មីត្រូវបានបង្ហាញ នៅក្នុងកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចឃើញការថ្មី។ យើងគួរត្រឡប់ទៅកាន់ព្រះដែលមានព្រះជន្មរស់ដោយផ្ទាល់ដោយសេចក្តីជំនឿ។ (សាការី 1:3)

**11. នៅពេលដែលយើងត្រូវបានព្រមាន (យេរេមា 4:8-18)**

អត្ថបទបង្ហាញថា នៅពេលដែលសេចក្តីក្រោធរបស់ព្រះយេហូវ៉ាត្រូវបានលេចមកដូចជាការឈ្លានពានរបស់ពួកបាប៊ីឡូន អ្នកដែលត្រឡប់ទៅកាន់ព្រះយេហូវ៉ាត្រូវទទួលបានព្រះពរ។

ទីមួយ ហេតុដែលនាំឲ្យមានសេចក្តីក្រោធ នោះជាសាសនា។ ហេតុនោះជាការបះបោរនៃព្រះយេហូវ៉ា (17-18)។ នៅក្នុងខ 9 ការភ្ញាក់ផ្អើលរបស់ស្តេច សង្ឃ និងហោរា បង្ហាញពីការអាក្រក់ខាងវិញ្ញាណ។ នៅពេលដែលពួកគេចាកចេញពីព្រះ ដែលទ្រង់ជាប្រភពនៃទឹករស់

ពួកគេនឹងត្រូវក្លាយជាសំរាមនៃមនុស្សជាតិ។
ទីពីរ គ្មាននរណាគេចរួចពីហិង្សានៃបណ្តាសារនោះទេ។ វាបង្ហាញថាជាសេចក្តីអន្តរាយដ៏ធំ (6), ការភ្ញាក់ផ្អើលដ៏អស្ចារ្យ (9), ដាវ (10) នឹងត្រូវមកយ៉ាងរហ័សដូចជាឥន្ទ្រី។ (13)
ទីបី វិធីសាស្ត្រដើម្បីនឹងគេចវេសពីបណ្តាសារជាការលន់តួ។ នៅខ 1 ការលន់តួ សំដៅទៅលើការត្រឡប់ទៅកាន់ព្រះអម្ចាស់។ ការត្រឡប់ចេញពីគំនិតរបស់យើង ជាជំហានដំបូងនៃសេចក្តីសង្ឃឹម។ យើងគួរដើរតាមផ្លូវ។

**12. មនុស្សសុចរិត** (យេរេមា 5:1-19)

អ្នកសុចរិតនៅក្នុងអត្ថបទមិនមែនជាមនុស្សដែលត្រូវបានបន្សុតខាងសីលធម៌នោះទេ ប៉ុន្តែជាបុគ្គលដែលបានទទួលព្រះបន្ទូល និងបានលន់តួនិងស្តាប់បង្គាប់ដោយសេចក្តីជំនឿ។ ហេតុអ្វីបានជាយើងត្រូវការមនុស្សសុចរិត?
ទីមួយ ពួកគេរត់ចេញពីសេចក្តីវិនាសអន្តរាយ។ (1-2) ពីព្រោះសេចក្តីថ្ងៃនៃសេចក្តីអាក្រក់ យើងត្រូវការមនុស្សសុចរិត។ សេចក្តីសុចរិតចេញមកពីការស្តាប់បង្គាប់ដល់ព្រះបន្ទូល។ ពេលខ្លះព្រះបន្ទូលមកដូចជាភ្លើង (ការវិនិច្ឆ័យទោស) ហើយភ្លៀងដែលផ្អែម ហើយពេលខ្លះជាអំណាចនៃការព្យាបាលនៃមុខទាំងសងខាងរបស់ដាយ។ ព្រះបន្ទូលរបស់ព្រះផ្ទាល់ជាវិញ្ញាណ ជាជីវិត និងជាសេចក្តីសុចរិត។ អ្នកដែលសញ្ជឹងគិតលើព្រះបន្ទូលទាំងយប់ទាំងថ្ងៃជាមនុស្សដែលដើរតាមផ្លូវរបស់មនុស្សសុចរិត។ នៅក្នុងមនុស្សនោះមានពន្លឺ ហើយចេស្តាធ្វើការ ហើយចេស្តាធ្វើឲ្យរស់ឡើងវិញដល់អ្នកដទៃទៀត។
ទីពីរ ព្រះគុណដែលបើកទ្វារនៃសេចក្តីសង្ឃឹមនៅជ្រោះអាហ្កោលចេញមកពីអ្នកសុចរិតដូចជាយេរេមា។ សេចក្តីពិតដែលព្រះអម្ចាស់បង្ហាញកិច្ចការនៃសេចក្តីសង្គ្រោះនៅពេលថ្ងៃ តាមរយៈណូអេ និងអ័ប្រាហាំ ជាស្រមោលរបស់ព្រះគ្រីស្ទជាមនុស្សដែលសុចរិតពិត។ តាមរយៈព្រះគ្រីស្ទ យើងក្លាយជាអ្នកសុចរិត។ យើងគួរតែរស់នៅដូចជាអ្នកសុចរិតនៅក្នុងព្រះគ្រីស្ទ។

**13. អំពើបាបដែលបាំងព្រះគុណ (យេរេមា 5:20-31)**

ព្រះអម្ចាស់ដែលបានសោកសង្រេងដោយសារ គ្មានពួកគេណាម្នាក់ដែលសុចរិត របៀបដែលបញ្ចប់របស់យូដានោះអាក្រក់បំផុត។

ទីមួយ តើអ្វីបាបបែបណាដែលពួកគេបានប្រព្រឹត្ត? ការមិនអើពើខាងវិញ្ញាណ (21) មិនចេះទប់ចិត្តខ្លួនឯង (22), ការក្បត់ (23), ការពោរពេញដោយសេចក្តីកំហុស (27) អយុត្តិធម៌ ការគៀបសង្កត់ (28) និងសេចក្តីខុសឆ្គង និងសេចក្តីលោភលន់ (31) ចេញមកពីការមិនមានចិត្តដែលអរគុណ បើទោះជាពួកគេបានទទួលព្រះគុណរបស់ព្រះអម្ចាស់ ប៉ុន្តែមិនបានថ្វាយសិរីល្អដល់ទ្រង់ឡើយ។ (រ៉ូម 3:10-18) វាសំខាន់ណាស់ក្នុងការអរព្រះគុណសំរាប់ស្ថានភាពបច្ចុប្បន្ននៅក្នុងជីវិតរបស់យើង។

ទីពីរ អ្វីទៅជាលទ្ធផលនៃអំពើបាប? វាធ្វើឲ្យពួកគេបញ្ឈប់ព្រះគុណរបស់ព្រះអម្ចាស់ជាបន្ត។ ហេតុដែលបញ្ឈប់នូវភ្លៀងដើមរដូវនិងភ្លៀងចុងរដូវ ត្រូវបានបញ្ឈប់ទៅកាន់ព្រះ (អេសាយ 59:1-2)។ ការអធិស្ឋានជាកូនសោរដើម្បីបើកទ្វារកំណាប់។ ជាពរដែលយើងរក្សានូវជីវិតនៃព្រះគុណដោយការតភ្ជាប់ជាមួយនឹងព្រះ ដែលទ្រង់បានសន្យាពីព្រះគុណលើព្រះគុណ។

### 14. រីករាយនឹងព្រះបន្ទូល (យេរេមា 6:1-15)

យេរូសាឡិមដែលមិនលន់តួនឹងត្រូវបានធ្លាក់ចុះក្នុងសភាពដែលមិនមានរបៀបរៀបរយនិងការច្របូកច្របល់។ នៅក្នុងចំណោមការទាំងនោះ សេចក្តីសោកសៅ (3), ទីក្រុងដែលត្រូវបានដាក់ទោស (6), ទឹកដែលហូរចេញដោយសេចក្តីអាក្រក់ (7) និង ការផ្លាស់ប្តូរនូវឧបករណ៍ដែលបរិសុទ្ធនឹងត្រូវបានកើតឡើង។ (12)

ទីមួយ តើពួកគេចូលចិត្តធ្វើបាបអ្វី? មានដូចជា សេចក្តីលោភលន់ (13) ការខុសឆ្គង សុវត្ថិភាពខាងវិញ្ញាណ (14), ហិង្សា ចោរ និងការគៀបសង្កត់។ ទៅកាន់អ្នកដែលចូលចិត្តអំពើបាបឈ្នួលបាបជាសេចក្តីស្លាប់ សេចក្តីពិតនោះត្រូវបានអនុវត្ត។

ទីពីរ យើងគួរតែរីករាយនឹងព្រះបន្ទូលរបស់ព្រះ។ ហេតុដែលជាមូលដ្ឋាននោះ ថាពួកគេត្រូវបានធ្លាក់ចុះទៅក្នុងទីដែលអាក្រក់ ដែលមិនបានទទួលការកាត់ស្បែកនៅក្នុងត្រចៀករបស់គេ។ (10) ហើយពួកគេក៏បានបាត់បង់សេចក្តីអំណររបស់ពួកគេទៅលើព្រះបន្ទូល ដែលពួកគេអាចមាននៅពេលដែលពួកគេសិក្សាព្រះគម្ពីរ សញ្ជឹងគិតព្រះបន្ទូល និងស្តាប់បង្គាប់តាម។ ដូចជាបទពិសោធន៍របស់សាវ័កពីរនាក់នៅអេម៉ស នៅពេលដែលយើងរីករាយនឹងការអធិប្បាយ ការបកប្រែព្រះបន្ទូល នោះយើងអាចទទួលបាននូវពិភពលោកមួយដ៏អស្ចារ្យ។

## 15. ហេតុផលសំខាន់ដើម្បីនឹងព្រមានដល់ពួកកំពុត (យេរេមា 7:1-11)

អំពើបាបរបស់ជនជាតិយូដា ដែលបាននាំឱ្យមានសេចក្ដីហិនវិនាសគឺជាការលាក់ពុត។ ទោះបីជាពួកគេបានចូលទៅក្នុងទីអាសនាក៏ដោយ ពួកគេមិនមានជីវិតផ្លាស់ប្ដូរទេ។ ដូច្នេះ យេរេមាបានដាស់តឿនថា ផ្លូវរបស់អ្នកនិងការប្រព្រឹត្តរបស់អ្នកគួរតែត្រឹមត្រូវ។ តើយើងអាចយកឈ្នះបញ្ហានេះដោយរបៀបណា?

ទីមួយ នៅពេលយើងនៅជាប់នឹងភាពស្មោះត្រង់ យើងអាចយកឈ្នះវាបាន។ ពួកគេត្រូវបានធ្លាក់ចូលទៅក្នុងសេចក្ដីកំពុត ដោយការមើលងាយផ្នែកខាងក្រៅរបស់ស្រុកកាណាន ដោយសារតែជំនឿរបស់ពួកគេមិនជាប់ទាក់ទងនឹងកិច្ចការរបស់ពួកគេ។ ពួកគេបានធ្វើចោរចូលលួចនៅក្នុងព្រះវិហារ ដើម្បីបំពេញសេចក្ដីប៉ងប្រាថ្នារបស់គេ តែមិនមែនជាការថ្វាយបង្គំពិតដោយប្រើព្រះនាមនៃព្រះទេ។

ទីពីរ នៅពេលដែលយើងមានភ្នែករបស់ព្រះ យើងអាចយកឈ្នះការនោះបាន។ កិច្ចការដែលប្រើទស្សនវិស័យរបស់ព្រះ នឹងត្រូវបានអនុវត្តដោយការអធិស្ឋានដល់ព្រះដោយព្រះបន្ទូលរបស់ព្រះពិតប្រាកដ។ អ្នកជឿគួរតែមានភ្នែករបស់ព្រះ ដោយសារការអធិស្ឋានគឺជាមធ្យោបាយដ៏ល្អបំផុត ក្នុងការប្រើពាក្យនេះ អ្នកជឿដែលអធិស្ឋានអាចដឹងការពិតយ៉ាងត្រឹមត្រូវ។ យើងគួរតែចូលក្នុងបន្ទប់សម្ងាត់ ដើម្បីយកឈ្នះលើការលាក់ពុតនិងដើម្បីទទួលបានព្រះគុណត្រឹមត្រូវពីព្រះ។

## 16. ក្រុមជំនុំ ជាផ្ទះនៃសេចក្ដីអធិស្ឋាន (យេរេមា 7:1-20)

នៅក្នុងខ 1-15 ការពិតដែលថាពួកគេត្រូវបានគេដេញចេញពីស៊ីឡូ គឺជាសភាពដែលគួរឱ្យអាណិតបំផុត។ តើវាអាចជាសះស្បើយយ៉ាងដូចម្ដេច?

ទីមួយ យើងគួរតែស្គាល់ភាពពិតនៃអំពើបាបយ៉ាងត្រឹមត្រូវ។ ជំនឿដោយគ្មានអំពើ ការអធិស្ឋានដោយគ្មានចំណេះដឹង (13) ការអធិស្ឋានដោយគ្មានការស្ដាប់បង្គាប់ (15) គឺជាទុក្ខវេទនា។ នៅពេលយើងប្រែចិត្តអំពើបាបរបស់យើងដោយមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ នោះវានឹងត្រូវបានស្ដារឡើងវិញ។

ទីពីរ យើងគួរតែដកចេញអំពើអាក្រក់ហើយថ្វាយខ្លួនយើងដាច់ទៅចំពោះព្រះអម្ចាស់។ ការថ្វាយខ្លួននៅខ 18 គឺមានតម្លៃណាស់។ រ៉ូម 12: 1-2 ដែលជាការថ្វាយរូបរាងកាយរបស់គេ ជាការដង្វាយរស់ ដែគួរត្រូវបានពិនិត្យឡើងជានិច្ច។ ចិត្តនៃពួកបរិសុទ្ធនិងក្រុមជំនុំ ត្រូវបានផ្លាស់ប្តូរទៅជាផ្ទះនៃការអធិស្ឋាន។ ការអធិស្ឋានដែលមិនមែនជាកំហឹងនិងការឈ្លោះប្រកែក ប៉ុន្តែសេចក្តីថ្លៃថ្នូរនិងការគ្រប់គ្រងខ្លួនឯង ត្រូវបានទទួលដោយព្រះ។ នេះគឺជាវិធីព្យាបាល។ ថ្វីបើយើងបានធ្លាក់ចូលទៅក្នុងអំពើពុករលួយយ៉ាងខ្លាំងដោយគ្មានក្តីសង្ឃឹមនៅក្នុងជីវិតរបស់យើង ប្រសិនបើយើងអធិស្ឋានដល់ព្រះដូចជាហាណាក្នុងការចាក់វិញ្ញាណរបស់គាត់លើព្រះ។ ពិតប្រាកដណាស់ ស្នាដៃថ្មីនឹងធ្វើការនៅក្នុងជីវិតរបស់យើង។ យើងគួរតែត្រូវបានលើកឡើងនូវក្លិនឈ្ងុយនៃការអធិស្ឋានរបស់យើង។

### 17. រាស្ត្រនៃសេចក្តីពិត (យេរេមា 7:1-28)

ព្រះទាមទារឱ្យយើងក្លាយទៅជារាស្ត្រនៃសេចក្តីពិត។ ការបន្ទោសនេះចង្អុលបង្ហាញពីការមិនស្តាប់បង្គាប់សេចក្តីពិត។ តើយើងអាចក្លាយជារាស្ត្រនៃសេចក្តីពិតដោយរបៀបណា?

ទីមួយ យើងគួរទទួលស្គាល់ការខ្វល់ខ្វាយរបស់ព្រះ ដែលចង់បានការស្តាប់បង្គាប់ច្រើនជាងការថ្វាយដង្វាយ។ ព្រះចង់ឲ្យស្តាប់ទៅកាន់ព្រះសូរសៀងទ្រង់ច្រើនជាងការថ្វាយដង្វាយ។ (21-24) ការស្តាប់បង្គាប់គឺជាគ្រឹះនៃសេចក្តីសញ្ញានិងជាវិធីដើម្បីទទួលបានពរជ័យជាបន្ត។ (23) យើងយល់ពីតម្លៃនៃការគោរពប្រតិបត្តិហើយព្យាយាមធ្វើវា។

ទីពីរ យើងគួរស្តាប់សេចក្តីពិតឱ្យបានល្អ។ ដោយសារពួកគេមិនថ្វាយខ្លួនដាច់ដើម្បីធ្វើតាមព្រះបន្ទូល ហើយពួកគេបានក្លាយជាមនុស្សមានកជាឈើ (26) ពួកគេគួរតែថ្វាយខ្លួនដើម្បីគោរពតាមសេចក្តីពិត។ (28) នៅក្នុងពាក្យផ្សេងទៀត វាមានន័យថាការសិក្សាសេចក្តីពិតជាព្រះគម្ពីរ ដើម្បីប្រព្រឹត្តតាមព្រះបន្ទូល ដើម្បីដើរតាមគោលការណ៍។

ទីបី ពួកគេគួរតែឆ្លើយតបនឹងសេចក្តីពិត ដែលបានប្រកាសដោយពួកហោរា។ ព្រះជាម្ចាស់ធ្វើការតាមរយៈគ្រូគង្វាលនៅក្នុងព្រះវិហារ ដែលព្រះបានដាក់ព្រះបន្ទូលរបស់ទ្រង់នៅក្នុងពួកគេ ដូច្នេះយើងគួរតែស្រឡាញ់គាត់ ហើយដើរតាមផ្លូវនៃសេចក្តីពិតដើម្បីទទួលបានសេរីភាពពិត។

### 18. ហេតុផលនៃសេចក្តីក្រោធរបស់ព្រះអម្ចាស់ (យេរេមា 7:29-8:3)

ព្រះមានមូលហេតុ ដែលសេចក្តីខ្ញាល់របស់ព្រះគួរហូរចេញទៅស្រុកយូដា។ តើវាគឺជាអ្វី? ទីមួយ ការថ្វាយបង្គំរូបព្រះនៅលើអាសនៈ ដែលធ្លាប់ទីដែលព្រះនាមរបស់ព្រះត្រូវដាក់ដោយក្លាហាន។ (30) ការដែលល្មើសនឹងក្រឹត្យវិន័យទីមួយ ដែលជាគ្រឹះនៃគ្រប់បែបយ៉ាង។ ពួកគេបានជំនួសការថ្វាយបង្គំព្រះអាទិករ ទៅជាការថ្វាយបង្គំរបស់ដែលត្រូវបានបង្កើតមក ដែលជាក្រុមនៃស្ថានសួគ៌វិញ។ កំហឹងរបស់ព្រះស្ថិតនៅលើមនុស្សដែលមិនរក្សាបញ្ញត្តិដំបូងរបស់ព្រះ។

ទីពីរ ពួកគេបានថ្វាយការគោរពរបស់ពួកគេ ដែលពួកគេគួរតែថ្វាយដល់ព្រះតែមួយប៉ុណ្ណោះ។ ពួកគេបានបង្កើតវិហារនៅជ្រលងភ្នំហ៊ីមណូន ហើយបានថ្វាយកូនចៅរបស់ពួកគេ។ អំពើបាបដែលព្រះស្អប់បានធ្វើឱ្យព្រះគុណនៃព្រះបានចាកចេញពីពួកគេ។ (32-34, 8: 1-3) យើងគួរតែត្រឡប់ទៅកាន់ព្រះហើយថ្វាយខ្លួនដល់ទ្រង់ដោយសេចក្តីពិតនិងដោយវិញ្ញាណ។

### 19. សេចក្តីសង្ឃឹមរបស់អ៊ីស្រាអែល (យេរេមា 8:4-12)

ដូចជាមនុស្សម្នាក់នៅក្នុងអន្ទាក់ បាបនៃជនជាតិអ៊ីស្រាអែលគឺដើម្បីឈានដល់សភាពខ្លាំងក្លា។ ពួកគេបានធ្លាក់ចុះនៅក្នុងស្ថានភាពអសមត្ថភាពនិងមិនអាចប្រើប្រាស់បាន។ តើព្រះបានស្នើសុំអ្វីពីពួកគេ?

ដំបូង ព្រះបានធ្វើឱ្យពួកគេដឹងថាមិនអាចទៅរួចទេ។ ពួកគេដែលជាប់ទាក់ទងនឹងអារក្សសាតាំងបាននិយាយកុហក (5) មិនបានយកការឆ្លុះបញ្ចាំង (6) និងការស្គាល់ខុសស្គាល់ត្រូវ (7) ។ ចុងក្រោយពួកគេបានក្លាយជាមនុស្សដែលមានស្មារតីដូចសត្វ។ ពួកគេមិនមានប្រាជ្ញាទេ (8-9) ប្រជាជននិងអ្នកដឹកនាំរបស់ពួកគេ បានប្រព្រឹត្តអំពើពុករលួយ (10-11) និងត្រូវបានទម្លាក់ចូលទៅក្នុងសេចក្តីលោភលន់សេចក្តីមិនពិត និងងាយស្រួល។

ទីពីរ ព្រះបានធ្វើឱ្យពួកគេឆ្លើយតប។ ថ្វីបើព្រះចង់បានអប្បបរមាក៏ដោយ ពួកគេមិនបានឆ្លើយតបនឹងព្រះឡើយ។ ការមិនអើពើនឹងអារម្មណ៍ខ្មាស់អៀនបង្ហាញពីភាពស្មោះត្រង់យ៉ាងខ្លី។ ភាពស្មោះត្រង់បានធ្វើឱ្យព្រះវិញ្ញាណបរិសុទ្ធស្វែងរកនៅក្នុងព្រះគ្រីស្ទ។ ក្តីសង្ឃឹមនៃជំនាន់យើងគួរតែចាប់ផ្តើមដោយការស្តារឡើងវិញនូវភាពអាម៉ាស។

### 20. មនុស្សដែលមានវិន័យ (យេរេមា 8:13-22)

អត្ថបទគម្ពីរបង្ហាញពីគ្រោះថ្នាក់នៃប្រៀនប្រដៅនិងសេចក្ដីស្រឡាញ់របស់ព្រះ។ តើសេចក្ដីស្រឡាញ់របស់ព្រះនិងសេចក្ដីសុចរិតរបស់ព្រះនៅជាមួយគ្នាយ៉ាងដូចម្ដេច?

ទីមួយ វិន័យរបស់ព្រះ។ ពួកគេមិនមានផលផ្លែនៃវិន័យរបស់ព្រះ(13) និងគ្រោះដែលមិនអាចទ្រាំទ្របាន (17) បានកើនឡើង ហើយប្រសិទ្ធភាពនៃការព្យាបាលបានបាត់អស់ (21) ព្រោះព្រះហស្តរបស់ព្រះជាម្ចាស់បានចាកចេញ។ យុត្តិធម៌របស់ព្រះជាការដែលគួរឲ្យភ័យខ្លាចដូចជាដាវមុត។

ទីពីរ សេចក្ដីស្រឡាញ់របស់ព្រះ។ ថ្វីដ្បិតតែពួកគេអង្គុយនៅក្នុងភាពងងឹតក៏ដោយ ក៏សេចក្ដីស្រឡាញ់នៃព្រះនៅតែមានស្ថិតស្ថេរ ដូចព្រះអាទិត្យលាក់បាំងនៅក្នុងពពក។ ថ្វីបើយើងមិនមានកិច្ចការដែលមិនអាចព្យាបាលបានក៏ដោយ ប្រសិនបើយើងចុះចូលចំពោះព្រះយើងអាចមានផ្លូវដែលរស់។

### 21. ជីវិតដែលលីឈើឆ្កាង (យេរេមា9:1-16)

អត្ថបទគម្ពីរបង្ហាញពីអាកប្បកិរិយា ដែលផ្ទុកឈើឆ្កាងដែលព្រះចង់បាន ដែលសាសន៍យូដាប្រែទៅជាជ្រលងនៃទឹកភ្នែក (1-3) និងអាកប្បកិរិយានៃភាពបរិសុទ្ធ ដែលពួកគេគួរតែនៅតែម្នាក់ឯងនៅទីរហោស្ថាន។ (2) តើយើងអាចផ្ទុកឈើឆ្កាងនៅក្នុងពិភពលោកយ៉ាងដូចម្ដេច?

ទីមួយ យើងត្រូវតយុទ្ធប្រឆាំងនឹងការមិនពិត។ មិនពិតគឺជាឫសគល់នៃអំពើបាបទាំងអស់។ ភាពក្លែងក្លាយបានធ្វើឱ្យពួកគេនៅទីបំផុតចូលទៅថ្វាយបង្គំរូបព្រះ ហើយបានចាកចេញឆ្ងាយពីក្រិត្យវិន័យរបស់ព្រះ។ ការស្អប់ការកុហក និងស្ដាប់បង្គាប់សេចក្ដីពិតរបស់ព្រះគឺជាផ្លូវនៃសេចក្ដីពិត។

ទីពីរ យើងគួរស្រែកថ្ងូរនៅចំពោះព្រះ។ ទឹកភ្នែកប៉ុលនិងលោកម៉ូសេបានហួសពីការយល់បាន។ ការថ្ងូរនេះគួរតែត្រូវបានបង្ហាញនៅក្នុងពេលបច្ចុប្បន្ន។ ភាពងងឹតទំនើបបានឆ្លងកាត់ខ្សែបន្ទាត់គ្រោះថ្នាក់ខ្លាំងណាស់។ នៅពេលយើងទទួលខុសត្រូវនៅចំពោះព្រះ ហើយនៅមុខមនុស្សជាតិ យើងអាចមានក្ដីសង្ឃឹមដ៏អស្ចារ្យនៅក្នុងព្រះគ្រីស្ទ។ អ្នកដែលយំថ្ងូរនឹងទទួលបានពរ ពីព្រោះគាត់ទទួលបានការកំសាន្តចិត្តពីស្ថានសួគ៌។

## 22. អំនួតរបស់អ្នកជឿ (យេរេមា 9:17-26)

ថ្ងៃដែលត្រូវការអ្នកទួញសោក ហើយគួរតែបង្រៀងពីការទួញសោកទៅកាន់អ្នកផ្សេងទៀត ចេញមកពីការចាកចេញពីព្រះអម្ចាស់ ហើយការដែលពោរពេញដោយសេចក្តីអួតក្អេងក្អាង។ តើយើងត្រូវការការអួតដូចម្តេច?

ទីមួយ យើងគួរអួតពីការស្គាល់ព្រះ។ ការអួតពីខ្លួនឯងនិងពីលោកិយ នោះចេញមកពីអំពើបាបរបស់យើង។ នៅពេលដែលយើងរៀនពីសេចក្តីពិតតាមរយៈការប្រកបយ៉ាងជិតស្និតជាមួយនឹងព្រះ នោះយើងអាចស្គាល់ព្រះដោយបទពិសោធន៍តែម្តង។ ដោយសារការបើកសំដែងនៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចស្គាល់ព្រះ។ ចំណេះដឹងដ៏ហូរហៀរ នោះសំរាប់នឹងរីករាយនឹងជីវិតអស់កល្បជានិច្ច។ (អេភេសូ 1:17 យ៉ូហាន 17:3)។

ទីពីរ យើងគួរតែស្រឡាញ់សេចក្តីស្រឡាញ់របស់ព្រះ សេចក្តីយុត្តិធម៌របស់ទ្រង់ និងភាពស្មោះត្រង់របស់ទ្រង់។ ការស្គាល់ព្រះជាការដែលទាក់ទងទៅនឹងសេចក្តីស្រឡាញ់របស់ព្រះ និងសេចក្តីយុត្តិធម៌របស់ទ្រង់។ នេះជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនិងចេស្តាខាងវិញ្ញាណ។ ពីព្រោះសេចក្តីអំនួតរបស់យើងត្រូវតែបានដាក់លើទំនាក់ទំនងជាមួយនឹងព្រះ យើងគួរតែរៀនផ្ទុកឈើឆ្កាងចាប់ពីសភាពបច្ចុប្បន្ន។ យើងគួរតែយំសោកសំរាប់អំពើបាបនិងបញ្ហានៃសេចក្តីចំកួតនៃរូបព្រះក្លែងក្លាយរបស់យើង ដោយបង្ហាញពីសេចក្តីកោតខ្លាចដល់ព្រះអម្ចាស់។

## 23. មួយអង្គដែលយើងគួរតែកោតខ្លាចពិតប្រាកដ (យេរេមា 10:1-16)

យេរេមាដែលជាអ្នកបង្រៀនពីសេចក្តីល្ងីល្ងើនៃរូបព្រះក្លែងក្លាយ បង្ហាញពីសេចក្តីកោតខ្លាចដល់ព្រះ។

ទីមួយ សេចក្តីពិតនៃរូបព្រះក្លែងក្លាយ។ ហេតុដែលយើងគួរភ័យខ្លាចដល់រូបព្រះ មិនមែនដើម្បីឲ្យបានប្រទានពរដល់យើងនោះឡើយ។ (15) ផ្លូវរបស់រូបព្រះនោះគ្រាន់តែជាឧបករណ៍ដែលស្លាប់មួយប៉ុណ្ណោះ (8) ពួកគេបានជួបនឹងភាពល្ងង់ខ្លៅ សេចក្តីខុសឆ្គង សេចក្តីល្ងីល្ងើ និងសេចក្តីអាម៉ាស់។ (1) យើងគួរតែវាយទាស់ជាមួយនឹងរូបព្រះក្លែងក្លាយនៅក្នុងចិត្តរបស់យើង និងបំណងប្រថ្នាលោភលន់របស់យើង។

ទីពីរ ភាពដែលពិសេសរបស់ព្រះតែមួយគត់។ យើងគួរតែកោតខ្លាចដល់ព្រះ។ ហេតុអ្វីបានជា

យើងត្រូវកោតខ្លាចដល់ព្រះអម្ចាស់? ពីព្រោះដោយសារទ្រង់ជាអង្គដែលមហិមា (6), ជាស្តេចនៃគ្រប់ជាតិសាសន៍ (7), ជាស្តេចដែលមានព្រះជន្មគង់នៅ (10), ព្រះអាទិករនៃគ្រប់ជាតិសាសន៍ (16), ជាអ្នកវិនិច្ឆ័យទោស (10) និងជាប្រភពនៃគ្រប់ទាំងប្រាជ្ញា ចេស្តា និងការយល់ដឹង។ ប្រាជ្ញាដ៏ពិតគឺជាសេចក្តីកោតខ្លាចដល់ព្រះ។ យើងគួររស់នៅនៅក្នុងសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា ពីព្រោះចេញមកពីអណ្តូងនៃប្រាជ្ញា។

**24. ជីវិតដែលរក្សាការតាំងសញ្ញា (យេរេមា 11:1-17)**

ការតាំងសញ្ញារវាងព្រះអម្ចាសនិងអ៊ីស្រាអែល ត្រូវជាការចាប់ផ្តើមនៃសេចក្តីសង្គ្រោះ។ ស្នូលនៃការតាំងសញ្ញាជាសេចក្តីពិត ដែលព្រះជាម្ចាស់ហើយយើងជាអ្នកបំរើរបស់ព្រះ។ កិច្ចការដែលត្រូវបានផ្តល់មកដល់ពួកគេ គ្រាន់តែជាការស្តាប់បង្គាប់ ហើយប្រសិនបើគេមិនស្តាប់បង្គាប់ព្រះបន្ទូល ពួកគេនឹងត្រូវទទួលការដាក់ទោសដោយការមកដល់នូវគ្រោះចង្រៃ។ តើយើងគួរតែព្យាយាមធ្វើអ្វីនៅក្នុងការតាំងសញ្ញានៃព្រះគុណ?

ទីមួយ យើងគួរតែទទួលព្រះបន្ទូលនៃអណ្តូងនៃការព្រមាន។ ពួកអ្នកដែលស្តាប់ទៅកាន់ការព្រមានរបស់ព្រះ និងការជម្រុញដោយស្មោះត្រង់ដែលចូលទៅក្នុងសេចក្តីវិនាសរបស់គេ។ យើងគួរតែស្តាប់ទៅកាន់ព្រះបន្ទូលដោយឆាប់រហ័ស។ (យ៉ាកុប 1:19)

ទីពីរ យើងគួរតែមានចិត្តដែលកោតខ្លាច។ នៅក្នុងខ 8, ការផ្ទៀងស្តាប់ព្រះបន្ទូលដែលចេញមកពីចិត្តដែលក្រអឺតក្រទម។ យើងគួរតែព្យាយាមរក្សាចិត្តដែលរាបទាបនៅចំពោះព្រះដោយស្មោះត្រង់។

ទីបី យើងគួរតែព្យាយាមបង្កលើតផលផ្លែល្អ ដូចជាដើមអូលីវខៀវខ្ចី (16), យើងគួរតែអនុវត្តតាមព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរបស់យើង។ យើងគួរតែរីករាយនឹងសេចក្តីសន្យាដ៏ស្មោះត្រង់ដោយការរក្សានូវការតាំងសញ្ញា។

**25. ផ្លូវនៃឈើឆ្កាង (យេរេមា11:18-12:6)**

យើងគួរតែគិតពីព្រះគ្រីស្ទដែលទ្រង់បានរងទ្រាំនូវអំពើបាបរបស់លោកិយនៅក្នុងរូបភាពនៃហោរាដែលទួញសោក សង្រេង ហើយយំយែក។ តើយើងអាចផ្ទុកឈើឆ្កាងដោយរបៀបណា?

ទីមួយ យើងគួរតែផ្ទុកឈើឆ្កាងដោយការរក្សាអត្តចរិតដែលស្ងប់ស្ងាត់នៃកូនចៀម។ ខ 19

បង្ហាញពីអ្នកបំរើនៃការរងទុក្ខវេទនាដូចកូនចៀមដែលនៅស្ងៀម ដែលឈរនៅមុនអ្នកកាត់រោម។ ការខិតចូលជិតដោយស្ងៀមស្ងាត់ជាការផ្ទុកឈើឆ្កាងនៅក្នុង អេសាយ 53:។ ការដើរដោយស្ងៀមស្ងាត់មានន័យថាការផ្ទុកឈើឆ្កាង។ ទៅកាន់ព្រះហឫទ័យរបស់ព្រះគ្រីស្ទ ដែលទ្រង់បានប្រកាន់ទំនួលខុសត្រូវ ដែលជាចេស្តាដ៏អស្ចារ្យជាមួយការកំសាន្តពីស្ថានសួគ៌ នឹងចាក់បង្ហូរមកលើពួកគេ។

ទីពីរ យើងគួរតែផ្ទុកឈើឆ្កាងដោយការផ្ទុកនូវអត្តន័យ។ ខ 3 មានបន្ទូលថា ការស្គាល់ខ្ញុំ ឃើញខ្ញុំ សង្កេតខ្ញុំ ហើយនៅក្នុងខ 20 ចង្អុលទៅកាន់ព្រះអម្ចាស់ ដែលទ្រង់ស្គាល់ពីការទួញសោក។ ការផ្ទុកឈើឆ្កាងមានន័យថា គេទទួលស្គាល់ថាមានតែព្រះដែលជាចេស្តារបស់គេសំរាប់នឹងធ្វើការដោយចេស្តារបស់ទ្រង់។ បើទោះជាយើងស្នាក់នៅទីដ៏ងងឹតក៏ដោយ នៅពេលដែលយើងរស់នៅដោយការធានាអះអាងរបស់ហាបាគុក នោះព្រះអម្ចាស់នឹងធ្វើឲ្យពួកគេរត់នៅទីដ៏ខ្ពស់បំផុត។ បន្ទាប់ពីឈើឆ្កាង អំណោយពីស្ថានសួគ៌នឹងត្រូវបានសន្យា។ (ម៉ាថាយ 5:10-11)

### 26. លក្ខណៈទាំងពីរនៃសេចក្តីស្រឡាញ់របស់ព្រះ (យេរេមា 12:7-17)

តើលក្ខណៈអ្វីដែលអត្ថបទ សេចក្តីស្រឡាញ់របស់ព្រះនៅក្នុងខ 13,15 បាននាំមក?

ទីមួយ វាមានលក្ខណៈនៃសេចក្តីសុចរិត ដែលស្អប់អំពើបាប ដើម្បីនឹងវិនិច្ឆ័យបាប។ នៅក្នុងការប្រៀបធៀបរាស្ត្ររបស់ទ្រង់នៅក្នុងព្រះ (7), ជំនួញ (7-8) ពណ៌ចំរុះ (9) ចម្ការទំពាំងបាយជូរ (10) និងដី (13), សេចក្តីស្រឡាញ់របស់ទ្រង់ត្រូវបានបង្ហាញភ្លាម ហើយមិនបានលន់តួអំពើបាប ទ្រង់បានវិនិច្ឆ័យទោសពួកគេដោយគ្មានមេត្តាពីព្រោះតាមរយៈការប្រៀនប្រដៅអ្នកជឿ នឹងត្រូវក្លាយដូចជាមាសសុទ្ធ។

ទីពីរ វាត្រូវបានបង្ហាញមកដោយព្រះគុណទាំងស្រុងដោយគ្មានតម្លៃ។ នេះជារូបភាពនៃការតាំងសញ្ញានៃព្រះគុណ។ នៅក្នុងខ 15 ព្រះនៃសេចក្តីមេត្តាបានត្រឡប់ភ្លាមមកកាន់ការតាំងសញ្ញារបស់ទ្រង់។ បើទោះជាគេជាអ្នកគោរពព្រះក្លែងក្លាយដែលមិនស្គាល់ព្រះ ព្រះបានបើកទ្វារឲ្យទទួលបានព្រះគុណជាក់ច្បាស់ដោយសារសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់។

**27. របៀបយកឈ្នះសេចក្តីអំណួត (យេរេមា 13:15-27)**

ភាពឆ្មើងឆ្មៃរបស់យូដានៅក្នុងអត្ថបទ ជាហេតុផលមូលដ្ឋានសំរាប់បណ្តាសារដោយខ្លួនគេ។ (17) តើអំពើបាបជាអ្វី ហើយយើងអាចយកឈ្នះវាដោយរបៀបណា?

ទីមួយ ភាពឆ្មើងឆ្មៃបង្ហាញពីប្រភេទនៃការអួតអាងដោយគិតថាខ្លួនជាព្រះ។ អ្នកដែលប្រើនូវអំពើអាក្រក់ (23) មនុស្សដែលផិតក្បត់ខាងវិញ្ញាណ (27) នឹងត្រូវមានសេចក្តីខ្មាស់ (16)។ អ្នកជឿពិតត្រូវបានគ្រប់គ្រងដោយព្រះគុណនិងសេចក្តីសុខសាន្ត។ (អេភេសូ 4:1)។

ទីពីរ ផ្លូវដើម្បីនឹងយកឈ្នះសេចក្តីក្រអឺតក្រទម នោះជាការថ្វាយសិរីល្អដល់ព្រះតែមួយអង្គប៉ុណ្ណោះ។ (16) ការផ្លាស់ប្តូរបល្ល័ង្ក ដែលត្រូវតែយកព្រះជាព្រះដែលមានព្រះជន្មរស់នៅ។ (15-16) ប្រសិនបើអ្នកណាដែលថ្វាយសិរីល្អដល់ព្រះ នោះគេនឹងមានសង្ឃឹម ពីព្រោះព្រះគុណរបស់ព្រះចេញមកពីការនោះឯង។ អ្នកជឿដែលក្រលេកទៅកាន់សេចក្តីក្រអឺតក្រទមនាសម័យនេះ គួរតែបោះចោលនូវចិត្តដែលអួតក្អេងក្អាងចេញពីជីវិតគេ។ នៅពេលដែលយើងជ្រើសរើសយកផ្លូវចង្អៀតនៅក្នុងចំណោមផ្លូវដ៏ធំទូលាយបណ្តោះអាសន្ននេះ ដូចជាភាពក្លាហានដែលគោរពដល់មនុស្សជាតិ នោះព្រះទ្រង់នឹងប្រើពួកយើង។ យើងគួរតែក្លាយទៅជាឧបករណ៍ដែលសំរាប់ប្រើរហូតដល់ចុងបញ្ចប់។

**28. របៀបដោះស្រាយការស្រេកខាងវិញ្ញាណ (យេរេមា 14:1-18)**

រដូវស្ងួតហែង សង្គ្រាមនិងគ្រោះទុរភិក្ស (1-6) ដែលបង្ហាញពីសញ្ញានៃការវិនិច្ឆ័យទោសរបស់យេរូសាឡិម បានព្រមានពីភាពហួតហែង និងបង្ហាញពីវិធីសាស្រ្តក្នុងការយកឈ្នះលើការនោះ។

ទីមួយ ហេតុផលដែលនាំឲ្យមានភាពហួតហែងខាងវិញ្ញាណ នោះចេញមកពីការកាត់ផ្តាច់ការប្រកបជាមួយនឹងព្រះជាម្ចាស់។ (10-11) ពីព្រោះអំពើបាបចេញមកពីការមើលងាយនូវការបើកសំដែងរបស់ព្រះ (13-14)។ នៅពេលដែលយើងពិនិត្យមើលទៅលើការនោះ ពួកគេបានទទួលយកការសន្យានៅការបង្រៀនក្លែងក្លាយដោយផ្ទាល់ នៅពេលដែលយើងជាប់ទៅនឹងការបង្រៀនក្លែងក្លាយ នោះយើងនឹងត្រូវចាកចេញពីព្រះគុណរបស់ព្រះ។ យើងអាចរក្សាការប្រកបដ៏រស់ជាមួយនឹងព្រះ នៅពេលដែលយើងទទួលព្រះបន្ទូលរបស់ព្រះដោយបន្ទាបខ្លួនដូចជាកូនក្មេង។

ទីពីរ របៀបរួចផុតពីភាពហួតហែងខាងវិញ្ញាណ នោះជាការថ្វាយនូវការទូលអង្វរដោយយំសោកទៅកាន់ព្រះអម្ចាស់ (7-9)។ យេរេមាបានស្វែងរកនូវការផ្លាស់ប្រែ។ នៅពេលដែលគាត់អធិស្ឋានថា ព្រះអម្ចាស់ធ្វើការសំរាប់ព្រះនាមទ្រង់មិនត្រូវបានបោះចោល ពួកគេអាចគេចផុតអភមង្គលទាំងនេះ ពីព្រោះអ្នកអធិស្ឋានពិតប្រាកដ ចាប់ផ្តើមជាមួយការសំរេចចិត្តទទួលព្រះជាទីមួយ។

**29. ជំហាននៃការស្តារឡើងវិញ (យេរេមា 14:19-15:9)**

ព្រះមិនបានឆ្លើយតបបើទោះជាម៉ូសេនិងសាំយ៉ូអែលសុំទៅកាន់ទ្រង់ក៏ដោយ ពីព្រោះអំពើបាបរបស់យេរូសាឡិមនោះធំណាស់។ តើយើងអាចយកឈ្នះសេចក្តីអស់សង្ឃឹមនោះដោយរបៀបណា?

ទីមួយ គោលបំណងត្រូវតែផ្លាស់ប្តូរ (21)។ ការដែលរស់នៅសំរាប់ឈ្មោះរបស់គេនឹងត្រូវបានផ្លាស់ប្តូរទៅជា ការដែលរស់នៅសំរាប់ព្រះអម្ចាស់វិញ។ ការស៊ី ការផឹកសំរាប់ថ្វាយសិរីល្អដល់ព្រះអម្ចាស់ ជាគោលបំណងរបស់យើង មានសង្ឃឹម (I កូរិនថូស 10:31)។

ទីពីរ វិធីសាស្ត្ររបស់យើងគួរតែត្រូវបានផ្លាស់ប្តូរ (21)។ សង្ឃឹមជាការចងចាំពីការតាំងសញ្ញាចាស់ ដែលត្រូវបានភ្លេចជាយូរមកហើយ។ ការតាំងសញ្ញានៃលោហិតរបស់ព្រះគ្រីស្ទមានប្រសិទ្ធិភាពអស់កល្បជានិច្ចនៅក្នុងពេលណាដែលអស់សង្ឃឹម។ ព្រះលោហិតរបស់ព្រះយេស៊ូវជាផ្លូវតែមួយគត់នៃការស្តារឡើងវិញ។

ទីបី ប្រាកដណាស់ ពួកគេត្រូវតែផ្លាស់ប្តូរ (22)។ ការផ្លាស់ប្តូរពិតប្រាកដមានន័យថាជាការចូលជិតបល្ល័ង្កដើម្បីនឹងកោតខ្លាចដល់ព្រះយេហូវ៉ា។ ការស្តារឡើងវិញដ៏ពិតជាការរក្សានូវចិត្តដែលស្រឡាញ់។ បន្ទាប់មកព្រះអម្ចាស់នឹងត្រូវបានដំកើងឡើងហើយនឹងបានរីករាយនូវព្រះគុណរបស់ទ្រង់។

**30. ពួកបរិសុទ្ធប្រថ្នាចង់បានព្រះគុណ (យេរេមា 16:1-9)**

នៅពេលដែលព្រះដកសេចក្តីសុខសាន្តរបស់ខ្ញុំ និងដកសេចក្តីស្រឡាញ់និងសេចក្តីមេត្តាចេញ (5) មានបន្ទូលថា ថ្ងៃបានធ្លាក់ទៅជាសេចក្តីងងឹតសូន្យនិងទៅជាសេចក្តីច្របូកច្របល់យ៉ាងខ្លាំង។ នៅទីនេះយើងរៀនពីជីវិតដែលយកព្រះគុណជាមានតម្លៃក្រៃលែង។

ទីមួយ យើងគួរតែទទួលការព្រមានមកពីព្រះដោយការបន្ទាបខ្លួន។ ព្រះអម្ចាស់មានបន្ទូលថា

ពួកគេមិនគួររីករាយដោយការបញ្ឈប់នូវគ្រោះមហន្តរាយ ដែលឪពុកម្តាយរបស់ពួកគេនឹងត្រូវបានសម្លាប់នៅក្នុងសមរភូមិនោះទេ (2) ហើយពួកគេមិនគួរចូលទៅបុណ្យខ្មោចឡើយ ពីព្រោះថ្ងៃនោះនឹងមិនមានអ្នកយំសង្រេងនិងអ្នកកំសាន្តចិត្តនោះឡើយ ហើយពីព្រោះព្រះបានដកនូវសេចក្តីអំណរចេញពីកូនក្រមុំកូនកំលោះ នោះពួកគេមិនគួរចូលទៅផ្ទះដែលមានការរៀបការដែរ (8)។

ទីពីរ ពួកគេគួរតែចង់បានព្រះគុណនិងសេចក្តីសុខសាន្តរបស់ព្រះ ពីព្រោះព្រះបានកាត់ផ្តាច់ព្រះហស្តនៃព្រះគុណរបស់ព្រះ។ បើមិនមានព្រះគុណ ក៏គ្មានសេចក្តីសុខសាន្តដែរ។ ការប្រាថ្នាចង់បានព្រះគុណនៅលើព្រះគុណ មិនមែនការអស់សង្ឃឹម តែជាព្រះគុណនៅក្នុងជីវិតរបស់យើង។

**31. ពេលព្រលឹមនៃសេចក្តីប្រោសលោះ (យេរេមា 16:10-21)**

បើទោះជាយូដាត្រូវបានធ្លាក់ចុះទៅក្នុងសេចក្តីទុច្ចរិត ជាងការដែលឪពុកដើមរបស់គេដែលថ្វាយបង្គំរូបព្រះ សេចក្តីមិនជឿ និងការមិនស្តាប់បង្គាប់នោះ ហើយបានបំរើរូបព្រះនៅជីវិតក្នុងគុកនៅបាប៊ីឡូន ព្រះបានសន្យានូវសេចក្តីសង្គ្រោះដ៏អស្ចារ្យដល់ពួកគេ។

ទីមួយ ព្រះអម្ចាស់ប្រទាននូវសេចក្តីសង្គ្រោះនៃព្រះគុណ (14-15)។ ទ្រង់បានប្រទាននូវព្រះគុណដែលឥតលក្ខខណ្ឌដល់ពួកគេ ដែលជាព្រះគុណដែលឥតលក្ខខណ្ឌមួយខុសពីព្រះគុណ ដែលព្រះបានផ្តល់នៅប្រទេសអេស៊ីបនិងបាប៊ីឡូន។ វាបង្ហាញពីសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទជាដំបូង។

ទីពីរ ព្រះបង្ហាញពីសេចក្តីសុចរិតរបស់ព្រះអម្ចាស់។ ការបង្ហាញពីសេចក្តីសុចរិតរបស់ព្រះផ្ទាល់ដោយការប្រៀនប្រដៅពួកគេ តាមរយៈគ្រប់ជាតិសាសន៍ដូចជាអ្នកនេសាទនិងអ្នកប្រមាញ់ ដើម្បីនឹងចាំងពន្លឺនៃសេចក្តីសុចរិតរបស់ទ្រង់ដូចជាពន្លឺដ៏ភ្លឺចែងចាំងនៃថ្ងៃត្រង់។ ទីបីដំណើរការនៃការលន់តួនឹងត្រូវបានកើតឡើងនៅក្នុងគ្រប់ជាតិសាសន៍។ នៅពេលដែលគ្រប់ជាតិសាសន៍វិលត្រលប់ទៅកាន់ព្រះអម្ចាស់ដោយការយល់ដឹងនូវសេចក្តីអសាឥតការរបស់ពួកគេ ព្រះទ្រង់នឹងបំពេញគេដោយចំណេះដឹងរបស់ព្រះ ដែលធ្វើឲ្យពួកគេស្គាល់ព្រះយេហូវ៉ាជាសុវត្ថិភាព ជាចេស្តា និងជាទីជ្រកកោណរបស់ខ្ញុំ។ ព្រលឹមនៃសេចក្តីសង្គ្រោះដ៏អស្ចារ្យនឹងត្រូវបានសំរេចបំពេញដោយការយាងមករបស់ព្រះគ្រីស្ទ។ ហើយយើងរស់នៅក្នុងនោះរួចទៅ

ហើយ យើងរីករាយនឹងពន្លឺ (I ពេត្រុស 1:8)។

**32. ចូររក្សាថ្ងៃសប្ប័ថ (យេរេមា 17:19-27)**

អត្ថបទព្រមានពីអំពើបាបដែលប្រព្រឹត្តបាបនៅក្នុងបញ្ញាត្តិទីបួន និងបង្ហាញពីព្រះពរនៃបញ្ញាត្តិនោះ។ នៅទីនេះតើយើងនឹងរៀនអ្វីអំពីថ្ងៃសប្ប័ថ?

ទីមួយ ពួកគេគួរតែរក្សាថ្ងៃបរិសុទ្ធ។ សេចក្តីពិតដែលព្រះអម្ចាស់បញ្ចប់កិច្ចការនៃការបង្កបង្កើត ហើយបានញែកថ្ងៃចេញពីថ្ងៃផ្សេងទៀតទុកជាថ្ងៃបរិសុទ្ធ។ ពីព្រោះព្រះអម្ចាស់បានញែកថ្ងៃនោះចេញពីថ្ងៃដទៃទៀត (លោកុប្បត្តិ 2:1-3)។ នៅក្នុងកិច្ចការនៃប្រាំមួយថ្ងៃទៀត ចិត្តដ៏ងងឹតរបស់ពួកគេនឹងត្រូវបានបញ្ឈប់ ហើយនឹងត្រូវធ្វើឲ្យពួកគេបានបើកចំហរឡើងទៅកាន់ព្រះអម្ចាស់ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការដោយសេរីសំរាប់ការបង្កើតជាថ្មី (កាល់វីន)។

ទីពីរ ពួកគេព្យាយាមថ្វាយបង្គំព្រះអម្ចាស់។ ហេតុដែលមិនត្រូវធ្វើការ គឺដើម្បីនឹងផ្ទុកនូវបន្ទុកដែលជាការថ្វាយខ្លួនដើម្បីថ្វាយបង្គំ (21)។ ពួកគេគួរតែព្យាយាមបញ្ឈប់ការបង្កើតជាថ្មី និងមិនត្រូវធ្វើកិច្ចការផ្ទាល់ខ្លួន ហើយចាត់ទុកថ្ងៃនោះជាថ្ងៃដែលគួរឲ្យគោរព (អេសាយ 58:13-14)។ នៅពេលដែលគេរក្សាការទាំងនោះជាបន្ត ការថ្វាយបង្គំនឹងត្រូវបន្ត ប្រសិនបើពួកគេបដិសេធវា ព្រះទ្រង់នឹងដុតដំណាក់របស់គេចោល។

**33. សេចក្តីជំនឿនៃភាពជាព្រះអម្ចាស់ (យេរេមា 18:1-17)**

តើព្រះដែលបានទូញសោកដោយសារសេចក្តីពុករលួយរបស់យូដាបង្រៀនមកកាន់យើង?

(13,17) សេចក្តីកំពុតរបស់ពួកគេដែលបានមើលងាយនូវអភ័យឯកសិទ្ធិនៃរាស្ត្រដែលបានរើសតាំង ហើយបានស្អប់នូវការលន់តួចេញពីសេចក្តីទុច្ចរិតរបស់ពួកគេ ដែលចេញមកពីការមិនអើពើនឹងភាពជាព្រះអម្ចាស់។ ជំនឿលើការដៅខុសពីការជឿលើកម្មវាសនាដែលចង្អុលពីអាកប្បកិរិយាគ្រឿងយន្ត ពីព្រោះមួយរាប់បញ្ចូលទាំងសិរីភាពនៃការជ្រើសរើស។ ដូច្នេះយើងគួរតែមើលថា សេចក្តីសង្គ្រោះរបស់យើងចេញមកពីព្រះហស្តរបស់ព្រះអម្ចាស់ (6)។ នៅពេលដែលពួកគេលន់តួបាបរបស់ពួកគេ ព្រះសន្យានឹងត្រឡប់នូវបំណងព្រះហឫទ័យរបស់ទ្រង់វិញ។ ប្រសិនបើប្រទេសណាបែត្រឡប់ចេញពីសេចក្តីទុច្ចរិតរបស់ពួកគេ នោះព្រះអម្ចាស់នឹតត្រឡប់មកឲ្យពរដល់គេ ប៉ុន្តែប្រសិនបើគេមិនត្រឡប់ចេញទេ ព្រះអម្ចាស់នឹងចាក់

មកលើគេនូវគ្រោះចង្រៃ (9-10)។ ព្រះពររបស់ព្រះអម្ចាស់និងបណ្ដាសារ មិនមែនពឹងទៅលើការត្រិះរិះរបស់មនុស្សនោះទេ។ យើងអាចលន់តួបាបរបស់យើងដោយសេចក្ដីជំនឿ ដែលព្រះអម្ចាស់ផ្ដល់នូវកាដូពិសេសមកដល់យើង (អេភេសូ 2:8-9)។ យើងដែលដូចជាដីឥដ្ឋនៅក្នុងដៃរបស់ជាងស្មូន យើងគួរតែទទួលភាពជាអម្ចាស់របស់ទ្រង់ ហើយគួរតែសំរេចបំពេញសេចក្ដីសង្គ្រោះរបស់យើងជាមួយនឹងសេចក្ដីកោតខ្លាចនិងភាពញាប់ញ័រ។ យើងគួរសរសើរភាពជាអម្ចាស់ដ៏មានអំណាចគ្រប់គ្រងអស្ចារ្យរបស់ទ្រង់។

**34. ការព្រមានដោយការបង្ហាញពីភាជន៍ (យេរេមា 19:1-20:6)**

ហេតុដែលយេរូសាឡិមត្រូវបានដាក់ទោស រហូតដល់ជ្រលងហ៊ីមនូនត្រូវបានប្ដូរទៅជាជ្រលងពិឃាត នោះចេញមកពីការបះបោរទាស់នឹងព្រះបន្ទូលរបស់ព្រះហើយបានរឹងរុសដោយការថ្វាយបង្គំរូបព្រះរបស់គេ។

ទីមួយ យើងមើលឃើញនូវសេចក្ដីស្រឡាញ់របស់ព្រះ ដែលបង្កើតបំណងព្រះហឫទ័យទ្រង់។ ការព្រមានរបស់ព្រះដែលបង្ហាញពីការបំបែកភាជន៍ទុកជាឧទាហរណ៍ បានបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះដើម្បីនឹងបង្កើតសេចក្ដីសុចរិតរបស់ព្រះអម្ចាស់ (1-10)។ ហើយព្រះអម្ចាស់បានផ្ដល់មកដើម្បីនឹងឲ្យត្រឡប់ចេញពីអំពើបាបរបស់ពួកគេដោយការពន្យល់ពីមូលហេតុ (11-13)។ យើងមើលឃើញនូវបំណងរបស់ព្រះដែលបង្កើតសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទចេញពីអត្ថបទ។

ទីពីរ យើងឃើញពីសេចក្ដីកោតខ្លាចនៃការវិនិច្ឆ័យទោស។ លទ្ធផលដែលបំបែកការតាំងសញ្ញា គួរតែក្លាយទៅដូចជាក្រុងសូដុម និងក្រុងកូម៉ូរ៉ា និងជ្រលងអាគើ។ ការដឹងខ្លួនរបស់ពួកគេនៃជ័យជំនះក្នុងគ្រាបណ្ដោះអាសន្ននឹងត្រូវបានសងដោយព្រះ។ ចុងបញ្ចប់នៃបាសុលនោះវេទនាបំផុត (20:1-9)។ យើងគួរតែបង្កើតសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទនៅក្នុងជីវិតរបស់យើង។

**35. ផ្លូវនៃឈើឆ្កាង (យេរេមា 20:7-18)**

អត្ថបទបង្ហាញអ្វីដែលជាផ្លូវរបស់ឈើឆ្កាង នោះតាមរយៈកិច្ចការរបស់ហោរា។

ទីមួយ ឈើឆ្កាងត្រូវបានដើរតាមដោយការរងទុក្ខ។ ហេតុដែលយេរេមាត្រូវបានចំអកដោយមនុស្សអស់ជាយូរថ្ងៃ នោះជាសាររបស់គាត់នៃការវិនិច្ឆ័យទោស។ ប្រសិនបើគាត់រក្សាភាព

ស្មៀមស្ងាត់សំរាប់សេចក្តីទុក្ខវេទនាយ៉ាងខ្លាំងរបស់គាត់ នោះគាត់មិនអាចទ្រាំទ្របាននោះទេ (9)។ គាត់ត្រូវបានធ្លាក់ចុះទៅជាមនុស្សដែលមានការបាក់ទឹកចិត្តដូចជាយ៉ូបដែរ (14-18)។ ហោរាបានទ្រាំទ្រនូវទុក្ខវេទនានៃឈើឆ្កាង។

ទីពីរ ឈើឆ្កាងជាទ្វារទៅកាន់សិរីល្អ។ ប៉ុន្តែទុក្ខវេទនានៃឈើឆ្កាងសន្យានូវសិរីល្អ (11)។ ពីព្រោះព្រះយេហូវ៉ាបានបំបាក់មនុស្សទុច្ចរិត ហើយធ្វើឲ្យពួកសុចរិតបានឈ្នះពិតប្រាកដ។ ទ្រង់ជាព្រះដែលដោះនូវបញ្ហារបស់ពួកសុចរិត។

ទីបី ផ្លូវនៃឈើឆ្កាងនឹងត្រូវបានដើរតាមដោយព្រះគុណរបស់ព្រះ។ សេចក្តីពិតដែលបានទ្រាំទ្រឈើឆ្កាងហើយដើរនៅក្នុងការសរសើរនោះជាភស្តុតាង ដែលព្រះទ្រង់ស្គាល់ហើយស្រឡាញ់គេ (12-13)។ នេះជាការចាក់បង្ហូរនូវព្រះវិញ្ញាណបរិសុទ្ធ (រ៉ូម 5:5)។ អ្នកដែលដើរនៅផ្លូវនៃឈើឆ្កាង នឹងបានទទួលសេចក្តីស្រឡាញ់របស់ព្រះដោយព្រះវិញ្ញាណបរិសុទ្ធ។ យើងមិនគួរបាត់បង់ឱកាសក្នុងការទទួលចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនោះឡើយ។

### 36. ផ្លូវនៃជីវិត (យេរេមា 21:1-14)

តើការទូលអង្វរដែលសេដេគា ជាអ្នកដែលបានព្យាយាមធ្វើទាស់នឹងគោលការណ៍អន្តោប្រវេសន្តដែលបានសូម បានឆ្លើយតបដោយរបៀបណា?

ទីមួយ ព្រះបំបែកបំបាក់នូវវិធីសាស្ត្ររបស់មនុស្ស (3-7)។ សេចក្តីពិតដែលព្រះបានបំផ្លាញពួកគេដោយដាវនៃពួកឆាល់ដីន ដោយគ្រោះចង្រៃ និងដោយគ្រោះទុរភិក្ស នោះចេញមកពីការមើលងាយនូវបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ព្រះហឫទ័យរបស់ព្រះនឹងអាចត្រូវបានបង្កើតដោយបំណងរបស់មនុស្ស។

ទីពីរ នៅពេលដែលយើងធ្វើនូវវិធីសាស្ត្ររបស់ព្រះ នោះផ្លូវដែលរស់នឹងត្រូវបានបើកចំហរឡើង (8-14)។ព្រះអម្ចាស់ដែលបានដាក់ផ្លូវនៃជីវិត និងផ្លូវនៃសេចក្តីស្លាប់ បានផ្តល់ផ្លូវជីវិតដោយការស្តាប់បង្គាប់ដល់បញ្ញាត្តិ។ នៅពេលដែលគេស្តាប់បង្គាប់បញ្ញាត្តិទ្រង់ នៅក្នុងការស្តាប់នោះអ្នកដែលបះបោរនឹងត្រូវមានជីវិតរស់នៅ។ ស្តេចដែលទុកចិត្តលើពាក្យរបស់ហោរាក្លែងក្លាយ បានជួបនូវចុងបញ្ចប់ដ៏អាក្រក់បំផុត។ បើទោះជាវាជាវិធីដែលល្ងីល្ងើនៅក្នុងទស្សនៈរបស់មនុស្សក៏ដោយ ប្រសិនបើអ្វីមួយដែលដាក់នៅក្នុងព្រះហស្តរបស់ព្រះ កិច្ចការដែលចម្រុងចម្រើននឹងកើតមានឡើង ពីព្រោះនគររបស់ព្រះនឹងត្រូវបានតាំងឡើង មិនមែនដោយ

ប្រាជ្ញានិងការអស្ចារ្យ ប៉ុន្តែដោយវិធីល្វីល្វើរបស់ការផ្សាយដំណឹងល្អវិញ។

**37. ព្រះបន្ទូលរបស់ព្រះអម្ចាស់ (យេរេមា 26:1-15)**

តើការត្រឡប់ទៅកាន់ព្រះឥលូវនេះដែលអត្ថបទនិយាយនេះមានន័យយ៉ាងដូចម្តេច? (3,13) ទីមួយ វាជាព្រះបន្ទូលដែលមានសេចក្តីស្រឡាញ់បរិបូរ។ បើទោះជាព្រះបានបញ្ជូនហោរាទៅកាន់ពួកគេជាបន្តបន្ទាប់ តែពួកគេមិនបានស្តាប់ទៅកាន់សាររបស់ទ្រង់ឡើយ (5)។ ជាចុងក្រោយព្រះនឹងបញ្ជូនហោរា(ព្រះយេស៊ូវ)ទៅកាន់ពួកគេ។ ព្រះអម្ចាស់ដែលបានបញ្ជូនសាររបស់ទ្រង់តាមរយៈរបៀបនិងវិធីសាស្ត្រជាច្រើន នឹងបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយទៅកាន់ពួកគេនៅគ្រាចុងក្រោយ (ហេព្រើរ 1:1-2)។

ទីពីរ នៅពេលដែលគេស្តាប់ព្រះបន្ទូលរបស់ព្រះ ឥទ្ធិពលនឹងត្រូវបានបើកសំដែង។ ទីពីរ វាជាព្រះបន្ទូលដែលមានប្រសិទ្ធិភាពនៅពេលដែលស្តាប់ទៅកាន់ព្រះបន្ទូលទ្រង់ (13)។ អ្នកដឹកនាំនិងរាស្ត្រដែលស្តាប់ទៅកាន់ការព្រមាននៃការលន់តួ ព្យាយាមសំឡាប់ហោរា ពីព្រោះចិត្តរបស់គេទៅជាងងឹត។

ទីបី វាត្រូវបានប្រកាសតាមរយៈស្មារតីដែលល្អរបស់ហោរា (15)។ ជំនួសដោយការដែលគេទទួលបាននូវការភ័យខ្លាចនៃសេចក្តីស្លាប់ គេបានប្រកាសព្រះបន្ទូលរបស់ព្រះដោយក្លាហានទៅកាន់ពួកគេ ដោយសារជំនួយមកពីព្រះវិញ្ញាណបរិសុទ្ធ។ វាបង្ហាញពីការប្រកាសដែលល្អរបស់ព្រះគ្រីស្ទនៅចំពោះលោកពីឡាត់ (I ធីម៉ូថេ 6:12)។ ពីព្រោះការស្លាប់ជំនួសរបស់ព្រះគ្រីស្ទ ប្រសិនបើអ្នកណាលន់តួបាបរបស់គេហើយទទួលការអត់ទោសរបស់ទ្រង់ នោះគេនឹងអាចទទួលនូវព្រះគុណដ៏អស្ចារ្យពីព្រះ។

**38. សេចក្តីសង្ឃឹមដែលរីកសាយនៅក្នុងការបាក់ទឹកចិត្ត (យេរេមា 29:1-14)**

ការបើកសំដែងរបស់យេរេមាដែលចេញមកពិព្រះ ជាប្រាជ្ញានៃព្រះវិញ្ញាណបរិសុទ្ធ សម្រាប់នឹងប្រាប់ដល់អ្នកជាប់គុកពីរបៀបរស់នៅ។

ទីមួយ គាត់គួរតែរស់នៅក្នុងជីវិតធម្មតានៅលើផែនដី។ ខ 4-6 មានបន្ទូលថា ពួកគេគួរតែធ្វើឲ្យមានការចំរុងចំរើននៅក្នុងជីវិតគ្រួសារ និងជីវិតរៀបការ ដែលមិនត្រូវបានបំផ្លាញនៅកន្លែងនោះ។ នៅពេលដែលយើងភ្ជាប់ទៅនឹងការបើកសំដែងរបស់ព្រះ សង្ឃឹមដែលមានការងឿងឆ្ងល់របស់យើងនឹងត្រូវលេចមក។

ទីពីរ យើងគួរតែអធិស្ឋានសំរាប់សេចក្តីសុខសាន្តនៅផែនដី។ ខ7 មានបន្ទូលថា សេចក្តីសុខសាន្តរបស់គេនឹងមានឥទ្ធិពលទៅលើសេចក្តីសុខសាន្តរបស់គេ។ បើទោះជាគេនៅក្នុងការប្រដៅរបស់ព្រះអម្ចាស់ក៏ដោយ ក៏ពួកគេនៅតែស្រឡាញ់ព្រះនិងការផ្តល់មករបស់ទ្រង់នឹងត្រូវបានផ្លាស់ប្តូរ។ បើទោះជាពួកគេបានទទួលគ្រោះចង្រៃ ប្រសិនបើពួកគេត្រឡប់មក ហើយអធិស្ឋានទៅកាន់ព្រះអម្ចាស់ ព្រះអម្ចាស់នឹងឆ្លើយតបទៅកាន់ពួកគេ។ ប៉ុន្តែពួកគេត្រូវតែប្រយត្ននឹងការថ្វាយបង្គំរូបព្រះ។

បើទោះជាពួកគេនៅជាប់នឹងការទាំងនោះ ក៏ពួកគេមិនបានបន្ធូរបន្ថយដែរ ហើយបំរើតែព្រះយេហូវ៉ាប៉ុណ្ណោះ។ ដូច្នេះបន្ទាប់ពី៧០ឆ្នាំ នោះគេនឹងត្រឡប់ទៅកាន់ទឹកដីរបស់ជាតិសាសន៍របស់គេ ដើម្បីនឹងរក្សានូវការតាំងសញ្ញារបស់ដាវីត។ បើទោះជាយើងរស់នៅក្នុងវប្បធមិខាងសាច់ឈាមក៏ដោយោ នៅពេលដែលយើងស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ នោះយើងនឹងមើលឃើញកិច្ចការដ៏អស្ចារ្យ។

### 39. ការគោរពនូវការបើកសំដែង (យេរេមា 29:15-32)

អត្ថបទបង្រៀនពីអកប្បកិរិយាដែលត្រឹមត្រូវនៃការបើកសំដែង ដោយការបង្ហាញទីបញ្ចប់របស់អ្នកដែលមិនស្តាប់បង្គាប់ដល់ការបើកសំដែង។

ទីមួយ ព្រះអម្ចាស់បានបញ្ជូនការបើកសំដែងដោយឧស្សាហ៍ទៅកាន់ពួកគេ។ តាមរយៈហោរាជាច្រើន ព្រះអម្ចាស់បានសង្កត់ធ្ងន់លើសារៈសំខាន់ ហើយបានបង្រៀនសេចក្តីស្រឡាញ់របស់ព្រះ (19), ដោយការបះបោរជាមួយនឹងសេចក្តីដ៏រឹងរូស ព្រះបានអនុញ្ញាតឲ្យត្រូវស្លាប់ដោយដាវ សង្គ្រាម និងគ្រោះចង្រៃ។ ប្រសិនបើយើងឈររឹងមាំនៅចំពើព្រះ ដែលទ្រង់ធ្វើការតាមរយៈព្រះគម្ពីរ យើងអាចទទួលនូវផ្លូវដែលរស់ (ហេព្រើរ 1:1-2)។

ទីពីរ នៅពេលដែលយើងមើលងាយនូវការបើកសំដែង គ្រប់ទាំងអំពើបាបនឹងលូតលាស់ឡើង (23)។ ដូចជា អាហាប សេដេគា និងអាម់ម៉ា នៅពេលយើងមិនផ្លាស់ប្តូរការកំផិតនិងសេចក្តីខុសឆ្គង នោះការដែលត្រូវបានបង្អាប់នឹងត្រូវបានកើតឡើង។ គេផ្ទាល់រួមទាំងកូនចៅគេនឹងត្រូវវិនាស។ ដូច្នេះអ្នកសរសេរហេព្រើរបានបង្រៀនយ៉ាងយកចិត្តទុកដាក់ពីឫសដែលល្វីងនិងអ្នកដែលត្រូវបណ្តាសារ ហើយអ្នកដែលត្រូវបានទម្លាក់ចេញពីព្រះគុណ។ (ហេព្រើរ 12:15-17)។

## ខ កណ្ឌគម្ពីរនៃការរំលែកទុក្ខ (30-33)

### 1. សេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ (យេរេមា 30:1-7)

តើយូដាមានសេចក្តីសង្ឃឹមអ្វី?

ទីមួយ វាជាសេចក្តីសង្គ្រោះដែលព្រះបានធ្វើឲ្យពួកគេត្រឡប់មកវិញ (3,8)។ ខគម្ពីរបង្ហាញពីព្រះដែលប្រោសឲ្យជា ដែលបានស្តារទឹកដីកាណាន និងរាជ្យរបស់ស្តេចដាវីត និងសាច់ឈាមថ្មីត្រូវបានលូតលាស់ឡើងចេញពីដំបៅដ៏ធ្ងន់ធ្ងរ (17)។ បើទោះជាសេចក្តីសង្គ្រោះរបស់មនុស្សនឹងត្រូវបរាជ័យ ប៉ុន្តែសេចក្តីសង្គ្រោះរបស់ព្រះនឹងនៅជាប់ជាអស់កល្ប។

ទីពីរ វាជាសេចក្តីសង្គ្រោះដែលទទួលបានសេចក្តីសុខសាន្ត។ ព្រះបានផ្តល់សេចក្តីសុខសាន្ត និងការសំរាកដល់ពួកគេ (10)។ លំហូរនៃពីធីបុណ្យព្រះគុណបង្ហាញពីសេចក្តីសុខសាន្តនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងដំណឹងល្អ។ សេចក្តីស្រឡាញ់របស់ព្រះដែលបានបង្ហូរនៅក្នុងព្រះវិញ្ញាណបរិសុទ្ធនោះជាសេចក្តីសុខសាន្ត (រ៉ូម 5:5)។

ទីបី វាជាសេចក្តីសង្គ្រោះដែលបង្កើតសេចក្តីយុត្តិធម៌។ សេចក្តីពិតដែលព្រះប្រដៅពួកគេដោយសារសេចក្តីយុត្តិធម៌ជាសាធារណៈ គឺជាអ្វីដែលព្រះបានសន្យារួចហើយជាមួយអ័ប្រាហាំ (លោកុប្បត្តិ18:19)។ ដែលសន្យានោះនឹងត្រូវបានសំរេចបំពេញនៅក្នុងព្រះគ្រីស្ទ។ សេចក្តីយុត្តិធម៌ និងសេចក្តីសុខសាន្តកើតឡើងនៅក្នុងគ្រាចុងក្រោយ ចង្អុលទៅកាន់ការផ្លាស់ប្រែយ៉ាងអស្ចារ្យ។ យើងគួរតែសរសើរព្រះដែលធ្វើឲ្យមានការផ្លាស់ប្រែដោយចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។ សេចក្តីទុច្ចរិតយ៉ាងក្រៃលែងនៅគ្រារបស់យើង នឹងត្រូវរលាយបាត់ទៅដោយការទទួលព្រះបន្ទូលរបស់ព្រះបានល្អ។ យើងគួរតែដើរតាមសេចក្តីសុចរិតនៃព្រះបន្ទូលដោយខ្ជាប់ខ្ជួន។

### 2. ព្រះគុណនៃការស្តារឡើងវិញ (យេរេមា 30:18-2)

សេចក្តីសង្គ្រោះដែលព្រះផ្ទាល់បង្កើត នោះជាការស្តារឡើងវិញរបស់ព្រះ (22)។ តើធាតុអ្វីខ្លះដែលមាន?

ទីមួយ វាជាការស្តារឡើងវិញនៃការអរព្រះគុណ (19)។ ប្រសិនបើយើងមានការអរគុណនិងចម្រៀងដោយអរសប្បាយនៅក្នុងយើង នោះវាបានបញ្ជាក់ពីសេចក្តីសង្គ្រោះរបស់យើងរួចទៅហើយ។ ភស្តុតាងនៃអ្នកដែលបានទទួលដំណឹងល្អបង្ហាញពី ចម្រៀង ការសរសើរដំកើង ការអរព្រះគុណ និងសេចក្តីកោតខ្លាច (អេភេសូ 5:18-19)។
ទីពីរ វាជាការស្តារឡើងវិញនៃសេចក្តីក្លាហាន (20-22)។ វាមានន័យថាដំណែងរបស់ពួកគេត្រូវបានស្តារមកវិញនៅក្នុងការខិតទៅជិតបល្ល័ង្កនៃព្រះគុណ។ នៅពេលដែលដាវីតអនុញ្ញាតមេបីបូសេតចូលរួមតុរបស់គាត់ ព្រះគ្រីស្ទបានធ្វើឲ្យយើងទទួលព្រះគុណ។ យើងដែលជាអ្នកស្តាប់បង្គាប់នៅក្នុងការបន្ទាបខ្លួន ហើយចូលទៅដោយការស្តាប់បង្គាប់ យើងអាចទទួលព្រះគុណជាថ្មី និងព្រះគុណថ្មីពីព្រះ (ហេព្រើរ 4:16, 10:20)។
ទីបី ការស្តារឡើងវិញនៃភាពចម្រុងចម្រើន (19)។ ប្រសិនបើយើងបានស្តារឡើងនូវអភ័យឯកសិទ្ធិរបស់យើង នៅក្នុងការចូលទៅកាន់បល្ល័ង្កព្រះជាមួយនឹងចិត្តដែលអរគុណ នោះយើងនឹងទទួលបានភាពចម្រុងចម្រើនខាងវិញ្ញាណនៅក្នុងព្រះគ្រីស្ទ។ យើងគួរតែបើកមាត់របស់យើងឲ្យធំ ហើយសូមដោយការរំពឹងទុកនូវភាពចម្រុងចម្រើននិងជ័យជំនះ។

**3. ពេលដែលគេមូលមកនៅភ្នំស៊ីយ៉ូន (យេរេមា 31:1-9)**

នៅពេលដែលការស្តារឡើងវិញនឹងត្រូវសំរេច ជាថ្ងៃនៃសញ្ញាថ្មី។ ព្រះគុណនៅក្នុងសញ្ញាចាស់ដូចជាភ្លៀងដែលស្រទន់ត្រូវបានផ្លាស់ប្តូរនៅក្នុងព្រះគុណនៅក្នុងសញ្ញាថ្មីដូចជាការងូតទឹក។ តើព្រះគុណជាអ្វី?
ទីមួយ វាជាពេលទទួលព្រះគុណរបស់ព្រះ (1-3) ការសំរាកនៃព្រះគុណ។ សេចក្តីស្រឡាញ់ដែលគ្មានទីបញ្ចប់នឹងត្រូវចាក់មកនៅលើពួកគេ។ ប៉ូលបានភ្ញាក់ផ្អើលដោយការមើលឃើញប្រព័ន្ធបង្ហូរព្រះគុណទៅកាន់ពួកគេនៅក្នុងព្រះគ្រីស្ទ (II កូរិនថូស 6:2)។ ដូច្នេះយើងគួរតែឆ្លើយតបដោយការបន្ទាបខ្លួន។
ទីពីរ វាជាពេលដែលខិតចូលជិតព្រះ (4-6)។ វាជាគ្រានៃសេចក្តីសង្គ្រោះដ៏អស្ចារ្យ ដែលទទួលសេចក្តីជំនួយរបស់ព្រះដោយការមកកាន់បល្ល័ង្ករបស់ទ្រង់។ យើងត្រូវការសំណូមពរវិជ្ជមាន ពីព្រោះទំនាក់ទំនងដែលស្និតស្នាលរវាងឪពុកនិងកូន។

ទីបី វាជាពេលដែលប្រមូលផ្តុំនៅស៊ីយ៉ូន (8)។ នៅពេលដែលពួកគេបង្កើតប៉មបាបិល ពួកគេត្រូវបានខ្ចាត់ខ្ចាយទៅគ្រប់ទិស ពេលនេះព្រះវិញ្ញាណប្រមូលពួកគេនៅក្នុងព្រះគ្រីស្ទ ជាស៊ីយ៉ូនដ៏ពិត (អេសាយ 2:2)។ អ្នកជឿដែលព្យាយាមប្រមូលដោយព្យាយាមជាគ្រីស្ទានដែលធំពេញវ័យ។ យើងគួរតែជម្រុញគ្នាទៅវិញទៅមក ហើយព្យាយាមប្រមូលនូវពួកជំនុំ។

**4. ចិត្តដូចជាសួនច្បារនៃប្រភពទឹក (យេរេមា 31:10-20)**

ព្រះគុណរបស់ព្រះជាការផ្លាស់ប្រែ ដូចជាសួនច្បារនៃប្រភពទឹក។ វាជាអ្វី?

ទីមួយ វាជាការស្តារឡើងវិញនៃសួនច្បារអេដែន។ អេដែនជាកន្លែងសំរាប់នឹងទំនាក់ទំនងជាមួយនឹងព្រះ ពីព្រោះព្រះអម្ចាស់បានអញ្ជើញអ័ដាមដូចជាភ្ញៀវរបស់ទ្រង់ ហើយទ្រង់ចង់ជួបនៅទីនោះ ដូចជាទីបរិសុទ្ធ និងព្រះវិហារ ពីព្រោះព្រះគ្រីស្ទបានសំរេចបំពេញនូវទំនាក់ទំនងដែលបាត់បង់ ដោយការសុគតរបស់ទ្រង់។

ទីពីរ វាជាការស្តារឡើងវិញនូវភាពពោរពេញដោយប្រេង (20-22)។ ការស្តារឡើងវិញដែលសង្ឃត្រូវបានបំពេញប្រេង ជាជីវិតដែលព្រះវិញ្ញាណបំពេញនៅក្នុងជីវិត (អេភេសូ 5:18 l ថែសាឡូនិច 1:6)។ យើងបានទទួលព្រះគុណនៃព្រះវិញ្ញាណបរិសុទ្ធ ហើយយើងក៏ត្រូវការព្រះគុណថែមទៀត ដែលព្រះចាក់មកតែងតែសម្រាប់ការបន្សុត។ គ្រីស្ទានដែលស្វែងរកដោយព្យាយាមនឹងទទួលបាន (កិច្ចការ 19:2)។

ទីបី វាជាការស្តារឡើងវិញនៃជីវិតដែលពេញដោយព្រះគុណ។ សេចក្តីមេត្តារបស់ព្រះនឹងត្រូវបានបង្ហូរមក ដែលជា ភាពផ្អែមល្ហែមនៃព្រះគុណនឹងចេញមកពីខាងលើ។ ទីកន្លែងនៃបញ្ហានឹងផ្លាស់ប្រែទៅជាសួនច្បារមានទឹកបរិបូរ។

**5. ការបង្កបង្កើតរបស់ថ្មី (យេរេមា 31:21-30)**

សេចក្តីសង្គ្រោះដែលព្រះផ្ទាល់បង្កើត ចេញមកពីការស្តារឡើងវិញនៃការតាំងសញ្ញា (22)។ តើព្រះគុណជាអ្វី?

ទីមួយ វាជាការស្តារឡើងវិញនៃការសន្យារបស់អ័ប្រាហាំ (21-23)។ នៅពេលដែលពួកគេស្នាក់នៅកាណានទៅតាមផ្លូវធំទៅកាន់ទីបរិសុទ្ធ គេនឹងទទួលបានពរពីព្រះ (ជនគណនា 6:24-

26 លោកុប្បត្តិ 12:4)។ នេះជាវិញ្ញាណដែលយើងគួរតែទទួលនៅក្នុងព្រះគ្រីស្ទ (កាឡាទី 3:14)។

ទីពីរ វាជាការស្តារឡើងវិញនូវអត្ថន័យពិត (25-26)។ អត្ថន័យដែលព្រះបានផ្តល់ទៅកាន់អ្នកសំណព្វ ត្រូវបានផ្តល់ដោយការទំនាក់ទំនងជាមួយនិងព្រះ។ អ្នកដែលចូលដោយការអធិស្ឋាននិងព្រះបន្ទូលរបស់ព្រះ នឹងរីករាយនូវសេចក្តីសុខសាន្តនិងព្រះគុណនៃព្រះវិញ្ញាណនឹងផ្តល់មក។

ទីបី វាជាការស្តារឡើងវិញនូវសេចក្តីសុចរិត (27-30)។ សេចក្តីអន្តរាយនៃអតីតកាលត្រូវបានប្តូរទៅជាការសាងសង់នាបច្ចុប្បន្ន។ សេចក្តីបំណងរបស់ព្រះនឹងត្រូវបានសំរេចការមួយនេះ។ សេចក្តីសុចរិតនៃសេចក្តីសង្គ្រោះរបស់គ្រីស្ទាន នឹងត្រូវបានសំរេចជាមួយនឹងការអនុវត្តនូវកិច្ចការរបស់ព្រះវិញ្ញាណ។ នៅពេលដែលយើងជួបបញ្ហាណាមួយ យើងគួរតែជៀការបង្កបង្កើតការថ្មី ហើយរំពឹងនូវការធំ ហើយខិតចូលជិតដោយសេចក្តីជំនឿ។ (ភីលីព 4:6-7)

**6. ការតាំងសញ្ញាថ្មី (យេរេមា 31:31-40)**

ការស្តារឡើងវិញនៃកាណាន បង្ហាញពីការរៀបចំមុខងារ ដូចជាការស្តារឡើងវិញនូវការតាំងសញ្ញារបស់អ័ប្រាហាំរហូតដល់ការតាំងសញ្ញាថ្មីរបស់ព្រះគ្រីស្ទមកដល់។ វាត្រូវបានបំបែកទៅជាការតាំងសញ្ញាចាស់ (31-32)។

ទីមួយ បើទោះជាសេចក្តីសង្គ្រោះរបស់អេស៊ីបនិងបាប៊ីឡូនតែងតែបានសំរេច សេចក្តីសង្គ្រោះនៃការតាំងសញ្ញាថ្មីសំរេច ពីព្រោះព្រះផ្ទាល់ជាអ្នកធ្វើ។

ទីពីរ ព្រះបានផ្ទុកក្រឹត្យវិន័យនៅក្នុងចិត្តរបស់គេ (33)។ វាជាអាថិកំបាំងដែលអនុញ្ញាតព្រឹត្តិការណ៍សំរាប់ព្រះសរសេរចុះនៅលើថតចិត្តរបស់គេ។ មានន័យថាការកើតជាថ្មីនៃវិញ្ញាណផ្លាស់ប្រែដោយមនសិការល្អ។ អ្នកដែលត្រូវបានតែងតាំងបានធ្វើឲ្យយើងស្គាល់ព្រះ (34, I យ៉ូហាន 2:20)។

ទីបី គ្រប់អំពើបាបត្រូវបានសំអាត។ ពួកគេមិនចាំអំពើបាបរបស់ពួកគេទៀតឡើយ (34)។ ទីលំនៅរបស់គេនឹងត្រូវផ្លាស់ប្តូរទៅជាទីជំរក (38-40)។ យើងគួរតែអរគុណព្រះតែមួយប៉ុណ្ណោះ ពីព្រោះយើងនៅក្នុងការតាំងសញ្ញាថ្មី។

### 7. លទ្ធផលរបស់អ៊ីកាបុត (បរិទេវ 1:1-11)

យេរេមានដែលជាអ្នកបានសង្កេតរូបភាពរបស់យូដាដែលមិនបានស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ បាននិយាយថា អ៊ីកាបុតដែលមានន័យថា សិរីល្អរបស់ព្រះត្រូវបាត់បង់ (6)។ តើអត្ថបទបង្ហាញពីស្ថានភាពអាក្រក់អ្វី?

ទីមួយ វាត្រូវបានធ្លាក់ចុះទៅកន្លែងដែលដាច់តែឯង (1-2)។ ពួកគេបានជួបនូវភាពស្ងប់ស្ងាត់នៅទីរហោស្ថាន (យេរេមា 17:)។ ដែលគេបានពឹងផ្អែកលើឈាម ហើយបានចាកចេញពីព្រះ ហើយចំអែតដោយកិច្ចការរបស់ស្ត្រីមេម៉ាយ (8-11)។ យូដាដែលបានគ្រប់គ្រងលើពួកគោរពព្រះក្លែងក្លាយ បានក្លាយជាទាសកររបស់គ្រប់សាសន៍ដោយគ្មានការកំសាន្តចិត្តសោះ។ កំណាប់ដ៏មានតម្លៃរបស់ពួកគេត្រូវបានលួចអស់ដោយអ្នកគោរពរូបព្រះក្លែងក្លាយ ពីព្រោះពួកគេបានធ្វើបាបយ៉ាងធំក្រៃលែង (8)។

## III. បរិទេវ

### 1. ការអធិស្ឋានរបស់អ្នកជឿ (បរិទេវ 1:12-22)

តើយើងរៀនអ្វីតាមរយៈអាកប្បកិរិយារបស់យេរេមា ដែលមានទំនួលខុសត្រូវទៅកាន់លោកិយដែលពេញដោយការទួញសោកនិងបញ្ហា?

ទីមួយ អ្នកដែលអធិស្ឋានគួរតែប្រយត្នពីស្ថានភាពបច្ចុប្បន្ន (12-21)។ តើការអធិស្ឋានអ្វីដែលយើងរៀនតាមរយៈយេរេមា ជាអ្នកដែលមានទំនួលខុសត្រូវនូវអំពើបាបរបស់យូដា ហើយបានសូមការវិនិច្ឆ័យទោសដល់ពួកសត្រូវ? ទីមួយ ការអធិស្ឋានគួរតែមើលទៅកាន់ស្ថានភាពបច្ចុប្បន្ន (12-21)។ ពួកយូដាដែលបានចាកចោលសិរីល្អរបស់ព្រះអម្ចាស់ បានបាត់បង់អំណាច ហើយមិនមានការកំសាន្តចិត្ត (17), មិនមានអ្នកដឹកនាំខាងវិញ្ញាណ (19) ហើយបានបន្ថែមនូវទុក្ខវេទនាថែមទៀត (20)។ វាជាភស្តុតាងថាគេបានទទួលប្រដៅ។ យើងដែលត្រូវបានត្រាស់ហៅជាសង្ឃ គួរតែទួញសោកនូវស្ថានភាពបច្ចុប្បន្នរបស់យើង។

ទីពីរ គេគួរតែជាបុគ្គលដែលអធិស្ឋានការអធិស្ឋានរបស់សង្ឃ (16-22)។ សេចក្តីសង្គ្រោះនៃការសន្យាពីមុន ជាសេចក្តីសង្គ្រោះនៃពេលបច្ចុបន្ននិងអនាគត។ "ខ្ញុំ" ជាយេរេមាដែលមាន

ទំនួលខុសត្រូវលើអំពើបាបរបស់ប្រជារាស្ត្ររបស់ខ្លួន បានយំសោកដោយទឹកភ្នែកនិងការទូញសង្រេង។ តាមរយៈការដង្វាយអធិស្ឋាននេះ ព្រះបានសំរេចនូវកិច្ចការបន្ទាប់ពី៧០ឆ្នាំ។ យើងត្រូវការការអធិស្ឋានរបស់សង្ឃដើម្បីនឹងយកឈ្នះការវាយប្រហារពីខ្មាំងសត្រូវ ដើម្បីនឹងជំនួសឲ្យបញ្ហា និងដើម្បីចូលជិតបល្ល័ង្ក។ ប្រសិនបើយើងមានការអធិស្ឋាន នោះយើងមានសេចក្តីសង្ឃឹម។

**2. ការស្តារឡើងវិញចេញពីសេចក្តីក្រោធរបស់ព្រះ (បរិទេវ 2:1-10)**

នេះជាភស្តុតាងដែលសេចក្តីក្រោធរបស់ព្រះត្រូវបាននៅពីក្រោយដោយសេចក្តីទុច្ចរិតនិងការមិនកោតខ្លាចដល់ព្រះ (រ៉ូម 1:18-19)។ តើយើងអាចស្តារឡើងវិញចេញពីសេចក្តីក្រោធដោយរបៀបណា?

ទីមួយ យើងមើលឃើញរូបភាពដែលបានដក់ព្រះគុណរបស់ទ្រង់ចេញ (1-7)។ ការយកចេញនៃព្រះគុណរបស់ព្រះ ចេញមកពីអំពើបាបនៃការបះបោរ ពីព្រោះសភាពដ៏អាក្រក់ដែលអំណាចរបស់គេត្រូវបានធ្លាក់ចុះ នោះចេញមកពីការចាកចេញពីការបើកសំដែងរបស់ព្រះ។ អ្វីដែលយើងគួរតែកាន់នោះមានតែព្រះគម្ពីរ។

ទីពីរ ការលន់តួជារបៀបនៃការស្តារឡើងវិញ (10)។ នៅពេលដែលយើងទទួលខុសត្រូវហើយលន់តួអំពើបាបរបស់យើង ព្រះនឹងផ្តល់សេចក្តីមេត្តាហើយស្តារពួកគេឡើង។ ដូចជាយ៉ូស្វេបានអង្គុយនៅលើដីអស់ពេញមួយថ្ងៃ ហើយបានលន់តួអំពើបាបរបស់គេ សេចក្តីសង្ឃឹមត្រូវបានកើនឡើង ហើយការអធិស្ឋានតមរបស់មរឌីខាយ បានធ្វើឲ្យអ៊ីស្រាអែលបានរួចពីគ្រោះនៃសេចក្តីស្លាប់។ អ្នកដែលលន់តួពិតប្រាកដសំរាប់ពេលនេះជាអ្នកដឹកនាំពិតប្រាកដ។ បន្ទាប់មកទ្វារស្ថានសួគ៌នឹងបើកឡើង ហើយផែនដីនឹងត្រូវកន្លងទៅ។

**3. ទឹកភ្នែកដែលយំនៅចំពោះបល្ល័ង្ក (បរិទេវ 2:11-22)**

នៅក្នុងអត្ថបទដែលចាប់ផ្តើមជាមួយការទូញសោក យើងរកឃើញថាផ្កានៃសេចក្តីសង្ឃឹមនៅក្នុងការបាក់ទឹកចិត្ត។

ទីមួយ វាជាបញ្ហាចម្បងក្នុងការដើរតាមការបើកសំដែងខុសឆ្គង (14)។ ការដើរតាមគំនិតរបស់

មនុស្សដោយការស្វែងរកដោយងាយៗ បាននាំនូវការវិនាសដល់ខ្លួន នៅពេលដែលពួកគេស្តាប់ទៅកាន់ពាក្យរបស់ហោរា ហើយស្តាប់បង្គាប់ដោយចិត្តបន្ទាបចុះ នោះព្រះនឹងអនុញ្ញាតនូវផ្លូវដែលច្បាស់នៅក្នុងជីវិតរបស់គេ (យេរេមា 29:4-8)។
ទីពីរ គ្រោះបានកើតឡើងដោយមិនអាចនិយាយចេញ (12)។ កូនក្មេងបានស្លាប់នៅនឹងទ្រូងរបស់ម្តាយដោយសារការខ្វះអាហារ។ ពួកគេបរិភោគទារករបស់គេ មនុស្សប្រុសនិងមនុស្សស្រីដេកនៅលើផ្លូវ (20-22)។ ជាចុងក្រោយ សិរីល្អរបបស់យេរូសាឡិមបានក្លាយជាការដែលត្រូវចំអកនៅក្នុងចំណោមជាតិសាសន៍ទាំងអស់ (13, 15-18)។
ទីបី មានតែការអធិស្ឋានដោយស្មោះត្រង់ដែលនឹងស្វែងរកព្រះភក្ត្ររបស់ព្រះ នោះជាផ្លូវដែលរស់ (18-19)។ ព្រះបានសន្យាថា តាមរយៈគំរូរបស់ហោរានេះ ប្រសិនបើពួកគេយំហើយសូមដល់ទ្រង់ នោះព្រះនឹងធ្វើឲ្យពួកគេរស់នៅដោយវិធីរបស់ព្រះ។ (បរិទេវ 29:12-13)

4. **ហោរាដូចជាសង្ឃ (បរិទេវ 3:1-18)**
 យេរេមាបានធ្វើការទាយដូចជាហោរា ដោយជាសង្ឃដែលមានទំនួលខុសត្រូវនិងការលន់តួបាប (2:18-19)។
ទីមួយ គាត់បានជំនួសកន្លែងនៃទុក្ខលំបាករបស់រាស្ត្រខ្លួន (1) គាត់បានលន់តួបាបរបស់យេរូសាឡិមនៅជំនួសអំពើបាបរបស់ពួកគេ។ "ទុក្ខលំបាករបស់ខ្ញុំ" "ក្រុមគ្រួសាររបស់ខ្ញុំ" "ឆ្អឹងរបស់ខ្ញុំ" "សេចក្តីងងឹតរបស់ខ្ញុំ" "ច្រវាក់របស់ខ្ញុំ" បញ្ជាក់ពីការនោះ ពីព្រោះគាត់រៀន pesemisism and octimissm ដោយព្រះវិញ្ញាណបរិសុទ្ធ។
ទីពីរ គាត់បានទទួលស្គាល់ភាពជាអម្ចាស់នៃភាពជាម្ចាស់។ គាត់បានឃើញការប្រដៅដ៏រន្ធត់របស់ព្រះ។ ហើយគាត់បានឃើញថា ពួកគេបានរស់នៅក្នុងសេចក្តីងងឹតដោយសេចក្តីក្រោធរបស់ព្រះយេហូវ៉ា កំពុងហូរមកជាមួយទុក្ខវេទនានិងជង្វាយ ហើយត្រូវបានចងដោយច្រវាក់ដូចជាខ្លាឃ្មុំនិងតោ (1-11)។ ហើយគាត់ក៏បានសង្កេតឃើញថាពួកគេបានចាកចេញពីសេចក្តីសុខសាន្តរបស់ព្រះ (17) ហើយពួកគេបានបាត់បង់សេចក្តីសង្ឃឹមទៅកាន់ព្រះយេហូវ៉ា (18)។ ដូចជាហោរាម្នាក់នេះ ដែលយើងគួរតែរស់នៅនៅក្នុងព្រះគ្រីស្ទទៅកាន់លោកិយ។ បន្ទាប់មកយើងអាចដើរលើផ្លូវនៃសិរីល្អរបស់ព្រះ (រ៉ូម 8:18)។

## 5. ជីវិតដែលពេញដោយព្រះអម្ចាស់ (បរិទេវ 3:19-39)

ចិត្តដែលមានទំនួលខុសត្រូវរបស់ហោរាត្រូវបានពេញដោយការអង្វរនិងសេចក្តីសង្ឃឹមដល់ព្រះអម្ចាស់ (19-23) ពីព្រោះគេត្រូវបានបិទបាំងដោយសេចក្តីមេត្តារបស់ព្រះនិងការស្តារនៅក្នុងសេចក្តីបាក់ទឹកចិត្ត។ ទាំងនេះបង្ហាញដោយការស៊ូទ្រាំរបស់ទ្រង់ (25-26)។

ទីមួយ ទ្រង់មានសេចក្តីមេត្តាយ៉ាងក្រៃ (22)។ ការផ្លាស់ប្តូរទុក្ខវេទនានិងភាពទុរភិក្ស ការឈឺចាប់ និងដង្កូវឈើនៅក្នុងសេចក្តីសង្ឃឹម ចេញមកពីសេចក្តីមេត្តារបស់ព្រះ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះត្រូវបានបង្ហូរចេញមកដោយព្រះវិញ្ញាណបរិសុទ្ធ (រ៉ូម 5:5)។

ទីពីរ ទ្រង់ស្មោះត្រង់ខ្លាំងណាស់ (23)។ សេចក្តីស្រឡាញ់របស់ទ្រង់បង្ហាញតាមរយៈប្រភពភាពស្មោះត្រង់របស់ទ្រង់។ ហោរាដែលភ្លក់សេចក្តីស្មោះត្រង់ បានរីករាយការនោះរាល់ព្រឹកហើយបានទទួលចេស្តាថ្មី។ ម៉ូសេបានបំរើព័ន្ធកិច្ចដ៏លំបាករបស់គាត់ដោយការទទួលសេចក្តីស្រឡាញ់របស់ព្រះរាល់តែព្រឹក (ទំនុកដំកើង 90:14)។

ទីបី ទ្រង់ជាព្រះអម្ចាស់នៃការស្តារឡើងវិញ។ ចិត្តរបស់ហោរានៅតែដាក់នូវភាពជាអម្ចាស់ដែលមានគ្រប់អំណាចរបស់ព្រះ។ ទ្រង់ចង់ឲ្យគេបំរើព្រះហឫទ័យរបស់ព្រះ ពីព្រោះទ្រង់គ្រប់គ្រងគ្រប់យ៉ាងនៅក្នុងលោកិយ។ យើងគួរតែព្យាយាមទៅកាន់គោលដៅ ដោយការពេញដោយសេចក្តីពោរពេញរបស់ព្រះ (អេភេសូ 3:19)។

## 6. គំរូនៃការអធិស្ឋានទូលអង្វរ (បរិទេវ 3:40-54)

ការអធិស្ឋានទូលអង្វរជំនួសសំរាប់សេចក្តីត្រូវការរបស់អ្នកដទៃមានតែទៅកាន់អ្នកជឿ។ តើអត្ថបទបង្ហាញអ្វីអំពីការទូលអង្វរជំនួស?

ទីមួយ បង្រៀនពីការលន់តួនៃសហគមន៍ (40- 41)។ ក្រុមជំនុំដែលបានបង្ហាញ "ពួកយើង" គួរតែសាកល្បងខ្លួនឯង ហើយបំបាក់រនាំងដែលទាស់នឹងព្រះ ហើយចូលទៅជិតព្រះដោយចិត្តដែលខ្មៅខ្វាំ (43-47)។ នៅក្នុងពេលទូលអង្វរជំនួស កិច្ចការជីវិតនឹងត្រូវបានកើតឡើង។

ទីពីរ គេថ្វាយនូវការសំណូមដែលស្មោះត្រង់។ ការអធិស្ឋានពិតរបស់ហោរាដោយទឹកភ្នែករបស់គាត់ ដូចជាប្រភពទឹកដែលមានពេញដោយឥទ្ធិពលនៃព្រះវិញ្ញាណតាមរយៈព្រះបន្ទូល

របស់ព្រះ។ ដូចជាស្ដេចហេសេគានិងហាណា នៅពេលដែលយើងអធិស្ឋានទៅកាន់ព្រះដោយស្មោះត្រង់ នោះវានឹងមានឥទ្ធិពលនៅក្នុងព្រះគ្រីស្ទ។

ទីបី គាត់អធិស្ឋានរហូតដល់ព្រះឆ្លើយតប។ គោលបំណងនៃការទូលអង្វរជំនួសដោយការសូម ការស្វែងរក និងការគោះទ្វារ គឺដើម្បីនឹងទទួលនូវសេចក្ដីមេត្តារបស់ព្រះ (50)។ គ្រប់បញ្ហាធំដូចភ្នំ ដើមទ្វាធំ និងដើមឧទុម នឹងត្រូវបានដកចេញដោយសេចក្ដីជំនឿជាប្រាកដ (ម៉ាថាយ 21:19-22)។ យើងគួរតែក្លាយជាអ្នកមានជ័យជំនះនៅក្នុងការអធិស្ឋានទូលអង្វរជំនួសដោយនៅក្នុងលោកិយដែលមានពេញដោយការលំបាក។

**7. ការអធិស្ឋានតាមរយៈចិត្ត (បរិទេវ 3:55-66)**

ទឹកភ្នែករបស់ហោរាបាននាំនូវចម្លើយដែលអាចិកំបាំងអស្ចារ្យ។ នៅពេលដែលគេត្រូវបានវាយប្រហារនៅក្នុងសេចក្ដីវេទនាដោយការបង្រៀនខុសឆ្គងដោយគ្រូក្លែងក្លាយ នៅពេលដែលគាត់អធិស្ឋានទៅកាន់ព្រះដោយសេចក្ដីជំនឿ ព្រះអម្ចាស់នឹងដោះស្រាយបញ្ហារបស់គេ។ តើយើងរៀនអ្វីនៅត្រង់នេះ?

ទីមួយ វាជាការអធិស្ឋាននៃជំនឿ (55- 58)។ នៅក្នុងចិត្តងងឹតយ៉ាងជ្រៅដូចជារណ្ដៅដែលគ្មានបាត អ្វីដែលគាត់ធ្វើនោះជាការអធិស្ឋានទៅកាន់ព្រះអម្ចាស់ (55)។ គាត់បានចាក់បង្ហូរវិញ្ញាណរបស់គាត់ចេញនៅលើព្រះដូចហាណា (55)។ គាត់បានអធិស្ឋានដោយការហៅព្រះនាមរបស់ព្រះដែលស្ងៀមស្ងាត់ (58) ពីព្រោះគាត់មានចិត្តដែលទទេរស្អាតដោយការយំស្រែកទៅកាន់ព្រះ ព្រះបានដោះបញ្ហារបស់គាត់ដោយព្រះគុណរបស់ទ្រង់ (58)។

ទីពីរ គាត់បានអធិស្ឋាននៅក្នុងកាលមានការវាយប្រហារយ៉ាងធ្ងន់ធ្ងរពីសត្រូវ (60-65)។ គាត់បានអធិស្ឋាននៅក្នុងស្ថានភាពដែលពិបាក ដែលសត្រូវរបស់គាត់បានសងសឹក បានចំអកនិងរិះគន់រាល់ថ្ងៃទាស់នឹងគាត់ ដោយគ្មានសេចក្ដីសុខសោះ។ ការដាក់បណ្ដាសារទៅកាន់សត្រូវរបស់គាត់ ចេញមកពីបំណងសំរាប់ការបង្កើតសេចក្ដីសុចរិតរបស់ព្រះ (60)។ នៅពេលដែលយើងហៅទៅកាន់ព្រះអម្ចាស់នៅក្នុងសេចក្ដីវេទនា យើងពិតជាត្រូវបានសង្គ្រោះចេញពីស្ថានភាពដ៏អាក្រក់។

**8. ជីវិតដែលនៅជាប់នឹងព្រះគ្រីស្ទ (បរិទេវ 4:1-10)**

ការទូលអង្វររបស់យេរេមាជាលទ្ធផលនៃការបើកភ្នែកខាងវិញ្ញាណ។ សេចក្តីទុក្ខលំបាករបស់ពួកគេដែលចាកចេញពីព្រះគុណរបស់ព្រះ បានក្លាយដូចជាអំបិលដែលគ្មានជាតិ។

ទីមួយ តើគ្រោះអ្វីដែលគាត់ឃើញ? គាត់បានឃើញថាទីបរិសុទ្ធត្រូវបានបំផ្លាញ (1) ហើយកូនប្រុសរបស់ស៊ីយ៉ូននឹត្រូវវិនាសដូចជាភាជន៍ដី (2) ហើយពួកគេត្រូវរងរបួសយ៉ាងឃោឃៅ (3-4) ជាងអំពើបាបរបស់សូដុម (6) ស្បែកស្ងួត (7,8) ហើយបរិភោគកូនខ្លួនដោយការអត់ឃ្លាន (10)។ លើសពីនោះទៀត ការដែលគួរឲ្យរន្ធត់បំផុតនោះជាភាពខ្សត់ខាងវិញ្ញាណរបស់អ្នកដែលបានចាកចេញពីព្រះគ្រីស្ទ។

ទីពីរ តើអ្វីទៅជាជីវិតដែលនៅជាប់នឹងព្រះអម្ចាស់? មានន័យថា ពួកគេគួរតែយកជីវិតដែលកោតខ្លាចរបស់ព្រះអម្ចាស់ ដែលជាចិត្តដែលខ្នះខ្នែងដែលថ្វាយបង្គំព្រះនៅក្នុងការនោះ។ នៅពេលដែលយើងផ្តោតទៅលើជីវិតដែលជាប់នឹងព្រះគ្រីស្ទដោយជាប់លាប់ និងការប្រកប ការស៊ូទ្រាំ យើងអាចនឹងរីករាយនឹងជីវិតដែលពេញបរិបូរណ៍ (យ៉ូហាន 10:10)។

**9. ចូរបង្កើតអំណាចខាងវិញ្ញាណ (បរិទេវ 4:11-22)**

នៅពេលពួកគេបាត់បង់តួនាទីនៃទីបរិសុទ្ធ ភាពជាអ្នកដឹកនាំខាងវិញ្ញានត្រូវបានបំផ្លាញ ហើយគ្មានសង្ឃឹមនៅក្នុងពួកគេទេ។ តើអំណាចនោះត្រូវបានស្តារឡើងវិញដោយរបៀបណា?

ទីមួយ ហេតុអ្វីបានជាអំណាចនោះត្រូវបានធ្លាក់ចុះ? ពីព្រោះអ្នកដឹកនាំ ហោរា និងសង្ឃបានប្រព្រឹត្តអំពើបាប ហើយបានធ្វើឲ្យពួកគេដើរវង្វេង(13,16)។ នៅកន្លែងដែលការបើកសំដែងត្រូវបានមើលងាយ យើងមិនអាចបង្កើតអំណាចបានទេ។ យើងគួរតែស្គាល់ថា យើងត្រូវស្គាល់ការបើកសំដែងពិសេស ជាព្រះគម្ពីរជាមុន ហើយស្តាប់បង្គាប់ហើយប្រកាសព្រះបន្ទូលទៅកានលោកិយ។

ទីពីរ តើវាត្រូវបានស្តារឡើងវិញដោយរបៀបណា? ការយាងមករបស់ព្រះមេស៊ីនឹងស្តារឡើងវិញនូវការវិនាស។ នៅពេលដែលព្រះមេស៊ី ដែលទ្រង់ប្រៀបធៀបនៃរន្ធច្រមុះនឹងមកកាន់ផែនដីជាប្រាកដ អ្នកគោរពព្រះក្លែងក្លាយជាមួយគ្នានឹងទទួលបានសេចក្តីអំណរពិត ដោយ

ការជឿលើដំណឹងល្អរបស់ព្រះគ្រីស្ទ (20) យើងដែលនៅជាប់នៅក្នុងដំណឹងល្អគួរតែចំរើនកំឡាំងខាងក្នុងរបស់យើង ហើយស្តារនូវអំណាចគ្រួសារ និងក្រុមជំនុំរបស់យើងឡើងវិញ ហើយគួរតែធ្វើឲ្យសហគមន៍របស់យើងបានជាថ្មីដោយព្រះគុណរបស់ព្រះវិញ្ញាណបរិសុទ្ធ។

**10. ចូរស្វែងរកស្តារជាថ្មីឡើងវិញ (បរិទេវ 5:1-22)**

យេរេមានជាអ្នកដែលបានសង្កេតពីការបំផ្លាញពិតនៅក្នុងប្រទេសរបស់គាត់ បានបញ្ចប់សៀវភៅរបស់គាត់ជាមួយនឹងការជម្រុញការស្តារជាថ្មីរបស់ពួកគេ ឲ្យស្វែងរកព្រះភក្ត្ររបស់ព្រះអម្ចាស់ (1,21)។ តើអ្វីទៅជាការស្តារជាថ្មីនៅក្នុងព្រះគម្ពីរ?

ទីមួយ ភាពចាំបាច់នៃការស្តារជាថ្មី – គាត់ឃើញគ្រប់កិច្ចការទាំងអស់ត្រូវបានប្តូរទៅជាអ្នកគោរពរូបព្រះ ហើយបានក្លាយជាកូនដែលត្រូវបោះបង់ចោលនិងជាស្ត្រីមេម៉ាយ (2-4) ហើយបានក្លាយជាស្ថានភាពដែលអាក្រក់ (7) ហើយគំរូសីលធម៌របស់នៃអ្នករាជការ ចាស់ទុំ មនុស្សចាស់ មនុស្សក្មេង ក្រមុំត្រូវបានបំផ្លាញ (11-15) ហើយចិត្តដែលត្រេកអរត្រូវបានទៅជាកន្ទប (15)។ លក្ខខណ្ឌទាំងនេះទាមទារការស្តារឡើងវិញដ៏ពិត។

ទីពីរ ការចាប់ផ្តើមការស្តារជាថ្មី – ការអធិស្ឋានទូលអង្វររបស់អ្នកបរិសុទ្ធគួរតែបានលើកឡើង។ ដូចជាថ្ងៃរបស់អេណុស មានការស្តារជាថ្មីឡើងវិញបានកើតឡើង ដោយការស្រែកហៅទៅរកព្រះនាមរបស់ព្រះជាចុងក្រោយ (លោកុប្បត្តិ 4:26)។ នៅពេលដែលយើងស្រែកហៅទៅកាន់ព្រះអម្ចាស់ដោយការលន់តួនិងសេចក្តីជំនឿ ព្រះអម្ចាស់នឹងមានចិត្តដែលឆេះឆួល ហើយទ្រង់នឹងចាក់បង្ហូរនូវវិញ្ញាណនៃការស្តារជាថ្មីដល់ពួកគេ។ ជាចុងក្រោយ តាមប្រវត្តិសាស្ត្រ ការអធិស្ឋានរបស់ហោរា និងអ្នកដែលកោតខ្លាចដល់ព្រះ បានធ្វើឲ្យពួកគេត្រឡប់ទៅកាន់កាណាន (ដានីយ៉ែល 9:2)។ ពេលបច្ចុប្បន្នរបស់យើងត្រូវការការស្តារជាថ្មីដូច្នេះដោយកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ។

## IV អេសេគាល

នៅពេលយើងពិនិត្យមើលសាររបស់អេសេគាលនៅក្នុងទស្សនៈនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះយើងសង្កេតមើលទស្សនៈនៃការប្រោសលោះដូចខាងក្រោម៖ ១) វាគឺជាសេចក្តីសង្គ្រោះនៃសេចក្តីសុចរិតដែលព្រះជាម្ចាស់អាចទទួលយកបាន (អេសេគាល ១៨១៩,៣៣: ១៣,១៨២០, ១៨: ២០,២២). ២ ) ហើយសេចក្តីសុចរិតនេះគឺជាបទដ្ឋាននៃការវាយតម្លៃនៃភាពជាព្រះ។ ៣) នៅពេលដែលពួកគេប្រែចិត្តពីអំពើទុច្ចរិតរបស់ពួកគេហើយរស់នៅក្នុងភាពសុចរិត នោះព្រះជាម្ចាស់នឹងប្រទានសេចក្តីមេត្តាករុណាដល់ពួកគេ (ឧ. ៥៥: ៩). ៣) នៅពេលពួកគេប្រែចិត្តពីអំពើបាបរបស់ពួកគេហើយចូលទៅជិតព្រះដ៏សុចរិតព្រះនឹងប្រទានសេចក្តីមេត្តាករុណាដល់ពួកគេ។ សេចក្តីសុចរិតផ្ទាល់ខ្លួនគឺជាល័ក្ខខ័ណ្ឌនៃសេចក្តីសង្គ្រោះរបស់ពួកគេហើយសេចក្តីសុចរិតផ្ទាល់ខ្លួនរបស់ខ្ញុំនឹងមិនត្រូវបានបន្ថែមសម្រាប់សេចក្តីសង្គ្រោះរបស់អ្នកដទៃឡើយ (ឧ. ៣៣:១៩).នេះគឺជាការស្រាវជ្រាវមួយដែលថានៅក្នុងដែនដីដែលព្រះបានគ្រប់គ្រងប្រវត្តិសាស្ត្រដែលជាលំហូរនៃសេចក្តីសញ្ញាប្រវត្តិសាស្ត្រដែលត្រូវបានប្រោសលោះ។ តើលំហូរនៃទ្រឹស្តីធិបតេយ្យបានបង្ហាញយ៉ាងដូចម្តេចនៅក្នុងជីវិតរបស់ពួកគេ? និយាយម្យ៉ាងទៀត តាមខទាំងបីនោះគឺអេសេគាល ១: ១-២៨, ៣៧: ១-១៤ និង ៤៧: ១-១២ នឹងត្រូវបានសិក្សា។ ហើយវាបង្ហាញថាភាពពិតនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះដោយសង្កេតមើលដូចខាងក្រោម: ១). ការងាររបស់ព្រះវិញ្ញាណនៃសិរីល្អ ២). ខ្យល់នៃព្រះវិញ្ញាណបរិសុទ្ធ ៣). ទឹកនៃព្រះវិញ្ញាណបរិសុទ្ធ។

### I. កិច្ចការនៃសិរីល្អ - ព្រះវិញ្ញាណ

១) គំនិតខាងទ្រឹស្តីនៃសិរីរុងរឿង - ព្រះវិញ្ញាណត្រូវបានសម្តែងដោយ MG Kline នៅក្នុងសៀវភៅរបស់គាត់ដែលមានឈ្មោះថា Kingdom Prologue ។ គាត់បានគិតថា merahapet ("ព្រះវិញ្ញាណនៃព្រះកំពុងរេរានៅលើផ្ទៃទឹក" លោកុប្បត្តិ១២) គឺជាគំនិតនៃការប្រោសលោះដ៏

សំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃការប្រោសលោះ។ និយាយម្យ៉ាងទៀតវាគឺជាវត្តមានរបស់ព្រះដែលបង្ហាញបល្ល័ង្ករបស់ព្រះជាម្ចាស់។ គាត់បាននិយាយអំពីព្រឹត្តិការណ៍នៃការប្រោសលោះនៃពួកជំនុំនៅវាលរហោស្ថានដែលជាជនជាតិអ៊ីស្រាអែលដូចជាលោកស្តេផាន (កិច្ចការ ៧: ៣៨) ។ អេសេគាលដែលត្រូវបានគេហៅថាជា«ហោរានៃព្រះវិញ្ញាណ»ដូចជាលោកម៉ូសេបានសង្កេតឃើញសិរីរុងរឿង – ព្រះវិញ្ញាណ នៃសកម្មភាពប្រោសលោះនៅការជិះជាន់របស់អេហ្ស៊ីបបង្ហាញពីការលេចចេញនូវភាពរុងរឿងនៅលើមនុស្សដែលបានចូលរួមក្នុងការជិះជាន់របស់បាប៊ីឡូនក្នុងជំពូកមួយ។

ជាពិសេសអេសេគាលជំពូក មួយបានបង្ហាញថាសិរីរុងរឿង - ព្រះវិញ្ញាណបានយកចិត្តទុកដាក់អ៊ីស្រាអែលនៅលើទឹកដីសន្យាដើម្បីសម្រេចបាននូវគោលដៅដ៏អស់កល្បរបស់ទ្រង់ដែលបានបង្ហាញពីទ្រីស្តីនៅលើពិភពលោក។

បន្ទាប់មក អេសេគាល បានផ្តោតលើការងារនៃសិរីល្អនៅក្នុងការនិមិត្តដំបូងរបស់គាត់។ សិរីរុងរឿងត្រូវបានបង្ហាញនៅក្នុងជីវិតបួនដែលមានផ្ទៃកផ្សេងគ្នា។ មនុស្ស ឥន្ទ្រី គោ និងតោ។ នេះគឺជាទស្សនៈមួយទៀតនៃផ្ទៃកបួនដែលវិវរណៈបានបង្ហាញ (វិវរណ ៥: ៧-៨) ។ នៅពេលយើងសំឡឹងមើយ ពីការច្នៃប្រឌិតដ៏រស់រវើកនៃជំពូកមួយនៅលើក្រដាស យើងប្រហែលជាត្រូវច្រឡំក្នុងការធ្វើរូបនៃសត្វចម្លែកៗ។ ប៉ុន្តែនៅពេលដែលយើងសង្កេតមើលឃ្លារបស់អេសេគាលដោយយកចិត្តទុកដាក់យើងទទួលបានការយល់ដឹងខ្លះៗអំពីអត្ថន័យពិតចេញពីនិមិត្ត។ លើសពីនេះទៅទៀតនៅពេលដែលយើងឃើញសកម្មភាពយ៉ាងលឿនរបស់កង់ក្នុងកង់ដែលកំពុងឆេះយើងយល់ពីភាពពិតនៃការងាររបស់ព្រះវិញ្ញាណបរិសុទ្ធដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ព្រះ។ ដូច្នេះអត្ថបទត្រូវបានបញ្ចប់ដោយការលេចចេញនូវរូបភាពនៃវិញ្ញាណនៃសិរីរុងរឿង«ដូចជារូបរាងរបស់ធ្នូដែលមាននៅក្នុងពពកនៅថ្ងៃមានភ្លៀងនោះគឺដូចជាពន្លឺភ្លឺនៅជុំវិញ។ នេះគឺជាការលេចចេញជារូបរាងនៃសិរីរុងរឿងរបស់ព្រះអម្ចាស់។ ហើយនៅពេល

ដែលខ្ញុំបានឃើញវា ខ្ញុំបានក្រាបចុះហើយខ្ញុំបានលឺសំលេងរបស់មួយនិយាយថា៉ (អេសេគាល ២:២៨)

ចំពោះខគម្ពីរការបកស្រាយតាមបែបប្រពៃណីមានទំនោរទៅនឹងចលនានៃសិរីល្អរបស់ shekinah (អេសេគាល ៤០: ៣៤-៣៨ សំដៅលើអេសេគាល ២៥: ១៨-២២, ពង្សា ទី១ ៨: ៦-១១) ។ភាពស្រដៀងគ្នានៃព្រះគម្ពីរដែលនៅជិតបំផុតទៅនឹងនិមិត្តនេះគឺនៅក្នុងកំណាព្យរបស់អ៊ីស្រាអែលជាពិសេសទំនុកតម្កើងដែលពណ៌នាអំពីព្រះអម្ចាស់ យេវ៉េ rakeb ba arabot ជាអ្នកជិះពពក និង yoseb kerubim ដែលសោយរាជ្យនៅលើចេរូប៊ីន។ (NICOT នៅលើសៀវភៅ អេសេគាល, ទំព័រ 105-106) ប៉ុន្តែយើងសង្កេតឃើញថារូបរាងខាងក្រៅនេះបង្ហាញពីសិរីរុងរឿងរបស់វិញ្ញាណឬព្រះអម្ចាស់ មានរូបរាងដូចមនុស្សសម្រាប់ការបង្ហាញឧទាហរណ៍នៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះតាមទស្សនៈនៃការប្រោសលោះរបស់ព្រះ។ យើងអាចបកស្រាយបានថាការពិតគឺព្រះគ្រីស្ទដែលបានចាប់កំណើតមកឬសិរីល្អ - ព្រះវិញ្ញាណ។ អេសេគាលបានឃើញព្រះគ្រីស្ទនៅក្នុងសិរីល្អ - វិញ្ញាណដែលជាប្រធានបទនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

### II ខ្យល់នៃព្រះវិញ្ញាណបរិសុទ្ធ - អេសេគាល ៣៧

បន្ទាប់មកសិរីរុងរឿង – សិរីល្អនៃព្រះវិញ្ញាណបានបង្ហាញនិមិត្តរូបមួយទៀតនៅក្នុងអេសេគាលជំពូក ៣៧ គឺដូចជាខ្យល់បក់ទៅក្នុងជ្រលងនៃសេចក្តីស្លាប់ដើម្បីធ្វើឱ្យឆ្អឹងស្ងួតបានរស់ឡើងវិញ។ ដរាបណាដង្ហើមនៅមាននៅលើសាកសពពួកនោះគេត្រូវបានរស់ឡើងវិញដោយអំណាចរបស់ព្រះហើយក្លាយជាទាហានដ៏អស្ចារ្យ។ នេះមានន័យថាប្រទេសអ៊ីស្រាអែលដែលត្រូវបានគេបោះបង់ចោលនឹងត្រូវបានស្តារឡើងវិញដោយព្រះវិញ្ញាណដើម្បីសំរេចបាននូវអាណាចក្រ (អេសេគាល ៣៧: ១១-១៤) រួចទ្រង់មានបន្ទូលថា៖ «កូនមនុស្សអើយឆ្អឹងទាំងនេះជាពូជពង្សអ៊ីស្រាអែលទាំងមូល។ មើលចុះគេនិយាយថា៉ ឆ្អឹងយើងរាលគ្នាស្ងួតហួត

ហែងហើងទីសង្ឃឹមរបស់យើងក៏បាត់អស់ទៅ។ យើងរាលគ្នាត្រូវបានកាត់ចេញស្រលះផង។ ម្នាល រាស្ត្រយើងអើយ! : អញនឹងបើកផ្នូរខ្មោចរបស់ឯងរាល់គ្នា ហើយនឹងធ្វើឲ្យឯងរាល់គ្នាឡើងចេញពីផ្នូរមក រួចនឹងនាំឯងអ្នករាល់គ្នាឲ្យចូលទៅក្នុងស្រុកអ៊ីស្រាអែលវិញ។ ឱរាស្ត្រអញអើយ ឯងរាល់គ្នានឹងដឹងថាអញនេះជាព្រះយេហូវ៉ា ក្នុងកាលដែលអញបើកផ្នូររបស់ឯងឲ្យឯងបានឡើងចេញពីនោះមក។ គ្រានោះអញនឹងដាក់វិញ្ញាណរបស់អញសនៅក្នុងឯងរាល់គ្នា ឯងនឹងមានជីវិតរស់ឡើង ហើយអញនឹងតាំងឯង ឲ្យអាស្រ័យនៅ ក្នុងស្រុកដែលជារបស់ឯង នោះឯងរាលគ្នានឹងដឹងថា គឺអញជាព្រះយេហូវានេះ បានចេញវាចាហើយ ក៏បានសំរេចតាមផង នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា។

និមិត្តរូបនេះត្រូវបានពិពណ៌នាថាជាការងាររបស់ព្រះវិញ្ញាណបរិសុទ្ធដូចជាដង្ហើម។ នៅក្នុងបទគម្ពីរពាក្យប្រៀបធៀបនៃកិច្ចការរបស់ព្រះវិញ្ញាណត្រូវបានបង្ហាញឱ្យដឹងនៅក្នុងការបង្កើតមនុស្ស (លោកុប្បត្តិ ២: ៧) និងនៅក្នុងការងើបឡើងវិញនៃការកាត់ទោសទឹកជំនន់របស់ណូអេនៅក្នុងគម្ពីរសញ្ញាចាស់ (លោកុប្បត្តិ ៨: ១) ។ហើយនៅក្នុងព្រះគម្ពីសញ្ញាថ្មី វាបានបង្ហាញពីដង្ហើមដែលព្រះអម្ចាស់ដែលបានរស់ឡើងវិញ បានផ្លុំខ្យល់ចេញពីព្រះឱសទ្រង់ទៅកាន់ពួកសិស្សរបស់ទ្រង់ (យ៉ូហាន ២០:២២) និងជាខ្យល់បក់បោកយ៉ាងខ្លាំងនៃព្រឹត្តិការណ៍ថ្ងៃបុណ្យទី៥០ ។ (កិច្ចការ ២: ២) នៅពេលដែលប្រជាជននៃសេចក្តីសញ្ញានៅបាប៊ីឡូនត្រូវការកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដូចជាខ្យល់ឬព្យុះដើម្បីធ្វើអោយរូបព្រះបានបង្កើតរូបឆ្លុះឡើងវិញ ទោះបីស្ថានភាពបច្ចុប្បន្នរបស់ពួកគេមានសេចក្តីទុក្ខលំបាកដូចជាឆ្អឹងស្ងួតនៅជ្រលងភ្នំនៃសេចក្តីស្លាប់សិរីរុងរឿងនៃព្រះវិញ្ញាណឬ វត្តមានរបស់ព្រះបាននាំពួកគេដូចជាសសរនៃពពកនិងបង្គោលភ្លើងបានធ្វើចំពោះដូនតារបស់ពួកគេ។ ការងារនៃខ្យល់ - ព្រះវិញ្ញាណបង្កើតពួកគេឡើងវិញជាប្រជាជននៃសេចក្តីសញ្ញាដែលបានស្តារឡើងវិញ។

លើសពីនេះទៅទៀតការងារនៃខ្យល់ - ព្រះវិញ្ញាណបានបង្កើតព្រឹត្តិការណ៍ជាច្រើននៅក្នុងរូបរាងខាងក្រៅដែលបានចង្អុលបង្ហាញពីលក្ខណៈពិសេសនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

នៅគ្រាលំបាកដូចខាងក្រោមនេះ។ ១) ព្រះចេស្តានៃការជាសះស្បើយបានចេញពីអ្នកប្រោសលោះរបស់ព្រះយេហូវ៉ា។ (៤) អំណាចព្យាបាលពិតប្រាកដគឺព្រះនិងព្រះបន្ទូលរបស់ទ្រង់។ បន្ទាប់មកទ្រង់មានបន្ទូលថា៖ «មើលឆ្អឹងទាំងនេះហើយនិយាយទៅពួកគេថាឆ្អឹងស្ងួតអើយសូមស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់! ២) អំណាចដែលបានរស់ឡើងវិញបានចេញពីព្រះបន្ទូលរបស់ព្រះយេហូវ៉ា (៨-១០) ឆ្អឹងស្ងួតត្រូវបានរស់ឡើងវិញដោយព្រះបន្ទូលរបស់ព្រះដែលជាកិច្ចការនៃការបង្កើតឡើងវិញនៃព្រះវិញ្ញាណ (ជ។ ៣: ៧-៨) ។ ៣) អំណាចនៃការផ្លាស់ប្រែជាថ្មីគឺសិរីរុងរឿង (១៤) «អញនឹងដាក់វិញ្ញាណរបស់អញទៅលើ ឯងហើយឯងនឹងមានជីវិតរស់នៅហើយអញនឹងអោយឯងរស់នៅលើទឹកដីរបស់ឯង។ ពេលនោះឯងរាល់គ្នានឹងដឹងថាអញពិតជាព្រះយ៉េហូវ៉ា។ ព្រះអម្ចាស់មានព្រះបន្ទូលថា "ក៏បានសំរេចផង" - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ ព្រះន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធបានធ្វើឱ្យពាក្យរបស់មនុស្សទៅជា។ (ធីម៉ូថេទី២ ៣: ១៦-១៧) នៅក្នុងព័ន្ធកិច្ចឬបេសកកម្មរបស់យើងអាចទទួលបានព្រឹត្តិការណ៍បែបនេះដោយការងារខ្យល់នៃព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែលគ្រូអធិប្បាយប្រកាសព្រះបន្ទូលរបស់ព្រះយ៉ាងស្មោះត្រង់ព្រះវិញ្ញាណនឹងដំណើរការនៅក្នុងក្រុមជំនុំរបស់យើង។ ម្យ៉ាងទៀតការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនឹងត្រូវបាននាំមកដោយព្រះវិញ្ញាណបរិសុទ្ធ។

### III ទឹកនៃព្រះវិញ្ញាណបរិសុទ្ធ

អេសេគាល ៤៧ បានបង្ហាញពីនិមិត្តរូបនៃសិរីល្អនៃព្រះវិញ្ញាណបរិសុទ្ធទៅកាន់ការស្តាឡើងវិញនូវរូបឆ្លុះរបស់ព្រះក្នុងជ្រលងនៃសេចក្តីស្លាប់នៃជីវិតនៅបាប៊ីឡូន។ បើយើងសង្កេតទៅមើលព្រឹត្តិការក្នុងការស្តាឡើងវិញនៅអុ៊ស្រាអែលជំពូក ៤០:៤៨ ព្រះវិហារថ្មី(៤០: ១- ៤៣: ១១) បញ្ញាត្តិថ្មី (៤៣:១២-៤៦:២៤) ទឹកដីថ្មី (៤៧:១-៤៨:២៩) ទីក្រុងថ្មី (៤៨: ៣០-៣៥)។ មួយទៀត វាជាការស្តារឡើងវិញនៃការបើកសំដែងរបស់ព្រះ។ ការលេចឡើងរបស់ព្រះបាន

បង្កើតការងារនៃទឹករស់ នៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងចក្ខុវិស្ស័យនៃ ទឹករស់គឺបានចាប់ផ្តើមជាមួយនឹងចិត្តដែលទ្វាប់ខ្លួន បានផ្លាស់ប្តូរព្រះវិហារឲ្យក្លាយទៅជា ភាពជាព្រះដ៏បរិបូរណ៍ (អេភេសូរ ៣៖១៩) ហើយបានព្យាបាលដោយព្រះវិញ្ញាណបរិសុទ្ធ គ្រប់ទាំងស្ថានភាពលំបាក់។ វាជាការពិតដែល នគរព្រះបានមកលើផែនដីគឺព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានសំដែងយ៉ាងច្បាស់ បានរៀបរាប់ពីព្រះពរនឹងការបំពេញសំរេច ទាមទា នូវសេចក្តីសុចរិត សេចក្តីមេត្តាករុណា នឹងសេចក្តីស្មោះត្រង់។ វាមានតែមួយគត់ដែលបានបើកសំដែងដោយសេចក្តីសង្គ្រោះ ប៉ុន្តែសេចក្តីសុចរិត សេចក្តីមេត្តាករុណា នឹង សេចក្តីស្មោះត្រង់ ដូចជាផលផ្លែនៃសេចក្តីសង្គ្រោះ។ ព្រះបានបើកសំដែងរូចរាល់នូវសេចក្តីជំនុំជំរះដ៏អស្ចារ្យតាបរយះការនិមិត្តរបស់ អេសេគាល ដូចខ្យល់នៃព្រះវិញ្ញាណ។ ទឹករស់ នៅក្នុងព្រះគម្ពីរយ៉ូហាននឹង ខ្យល់នៅក្នុងព្រះគម្ពីរកិច្ចការ មានទំនាក់ទំនងយ៉ាងស្និទ្ធ ទៅនឹងការងារនៃព្រះវិញ្ញាណនៅក្នុងការនិមិត្តរបស់អេសេគាល។ សេចក្តីសង្គ្រោះរបស់យើងបានឡោមព័ទ្ធយ៉ាងច្បាស់នូវសេចក្តីស្មោះត្រង់។ ដូច្នេះការសិក្សាពីរមនុស្ស គឺនរណាជានេពន្ធ ៊គឺសេចក្តីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ បានចង្អុលបង្ហាញនូវគោលបំណងបីគឺ សេចក្តីមេត្តាករុណា ព្រះគុណរបស់ព្រះ នឹងអំណាចរបស់ព្រះ នឹងទំនួលខុសត្រូវផ្ទាល់ខ្លួននៅក្នុង អេសេគាល។ បញ្ហានេះបានចូលមកកាន់ការងារនៃសិរីល្អនៃព្រះវិញ្ញាណបរិសុទ្ធ គឺជាផលផ្លែនៃការស្តាឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

**សេចក្តីសន្និដ្ឋានៈ**

វត្តមានរបស់ព្រះដែលបានសម្តែងជាមួយលោកម៉ូសេត្រូវបានបង្ហាញជាថ្មីម្តងទៀតតាមរយៈការបើកសម្តែងរបស់អេសេគាលនៅបាប៊ីឡូនដូចនៅអេស៊ីប។ សិរីរុងរឿងនៃព្រះវិញ្ញាណបានការពារពួកគេហើយធ្វើអោយពួកគេវិលត្រឡប់ទៅស្រុកកាណានវិញតាមរយៈអានុភាពដ៏ខ្លាំងក្លានៃព្រះវិញ្ញាណដូចជាខ្យល់និងទឹករស់។ ប៉ុន្តែនេះគ្រាន់តែជាស្រមោលរបស់ហោរាគឺព្រះយេស៊ូគ្រិស្តនិងកិច្ចការរបស់ព្រះអង្គប៉ុណ្ណោះ។ យើងមើលឃើញការងារពេញលេញនៅ

ក្នុងព្រះគ្រីស្ទហើយរីករាយនឹងពួកគេដោយការបន្តនៅក្នុងការបើកសំដែងរបស់ទ្រង់។ នៅសម័យបច្ចុប្បន្នប្រសិនបើព្រះវិហារកម្ពុជាមើលពីភាពពិតនៃសិរីល្អនៃព្រះវិញ្ញាណពួកគេនឹងទទួលបានបទពិសោធន៍ដ៏អស្ចារ្យ។

តង្វាយក្រអូប អញនឹងទទួលឯងរាល់គ្នាទុកដូចជាក្លិនក្រអូប ក្នុងកាលដែលអញបាននាំឯងចេញពីសាសន៍ដទៃហើយប្រមូលឯងពីអស់ទាំងស្រុកដែលឯងត្រូវខ្ចាត់ខ្ចាយទៅនោះ អញនឹងបានបរិសុទ្ធក្នុងពួកឯងរាល់គ្នានៅចំពោះភ្នែកនៃអស់ទាំងសាសន៍ដទៃ(អេសេគាល ២០: ៤១)។ ព្រះដែលបានជំនុំជំរះអំពើបាបរបស់យូដាបានបង្ហាញពីការសង្គ្រោះនៃថ្ងៃជំនុំជំរះចុងក្រោយ។ វាគឺជាសេចក្តីសង្គ្រោះនៃភាពជាព្រះរបស់ទ្រង់ មិនមែនជាការសង្គ្រោះរបស់មនុស្សទេជាអំណាចរបស់ព្រះ។ ហើយព្រះវិញ្ញាណបរិសុទ្ធមានវត្តមាននៅលើចិត្តរបស់ពួកគេហើយបានផ្លាស់ប្តូរចិត្តរបស់ពួកគេឲ្យដូចជារូបកាយដែលទន់ភ្លន់។ ហើយបានធ្វើឱ្យពួកគេរស់នៅសំរាប់ទ្រង់នឹងតាមបំណង់ព្រះហរទ័យរបស់ទ្រង់។ ជីវិតដែលថ្វាយដង្វាយដែលព្រះទទួលយកដូចជាក្រអូប និងមានឥទ្ធិពលលើពិភពលោក។ មានតែការរស់នៅដូចដែលម៉ារាបានថ្វាយដង្វាយរបស់នាងទៅព្រះគ្រិស្តប៉ុណ្ណោះដែលអាចលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

**1. អេសេគាល (២២: ១-៦)**

១) «ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ» (១) កិច្ចការរបស់ហោរាអេសេគាលតែងតែពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត។ យោងទៅតាមស្ថានការណ៍នីមួយៗព្រះបន្ទូលរបស់ព្រះយេហូវ៉ាបានទៅដល់ហោរាដែលជាលក្ខណៈវិនិច្ឆ័យនៃព័ន្ធកិច្ចរបស់គាត់។ ជីវិតនៃការសង្គ្រោះបន្ទាប់ពីការសង្គ្រោះនៃគ្រីស្ទបរិស័ទគឺដើម្បីសំរេចគោលដៅដោយទទួលបានព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការប្រកាន់ខ្ជាប់ជានិច្ចនូវព្រះបន្ទូលរបស់ព្រះគឺមានតម្លៃណាស់។ យើងគួរតែរក្សាដួងចិត្តខ្សោយខាងវិញ្ញាណដែលរៀបចំដើម្បីទទួលបានការ

បើកសម្តែងដោយឥតគិតថ្លៃពីព្រះជាម្ចាស់។ ព្រះពរ ម៉ាថាយ ៥: ៣ គឺជាពរដ៏ធំបំផុត។ យើងគួររង់ចាំព្រះជាម្ចាស់ជានិច្ចហើយគួរតែទទួលយកភាពគ្រប់គ្រាន់ដោយព្រះគុណរបស់ព្រះ។

២) «កូនមនុស្សអើយ ចូរបែរមុខទៅក្រុងយេរូសាឡឹមហើយប្រកាសប្រឆាំងនឹងទីសក្ការៈ។ ទំនាយប្រឆាំងនឹងទឹកដីអ៊ីស្រាអែល»។ (២) ការធ្លាក់ចុះរបស់មន្ត្រីរបស់សាសន៍យូដាបានធ្វើអោយសង្គមមានសភាពវេទនា។ បន្ទាប់មកបាបបានបំផ្លាញមូលដ្ឋានគ្រឹះនៃក្រឹត្យវិន័យដប់ប្រការគឺការបះបោរប្រឆាំងនឹងឪពុកម្តាយរបស់គេ ការបៀតបៀនដល់ជនចម្លែក ការធ្វើទុក្ខទោសដល់ក្មេងកំព្រា និងមេម៉ាយ និងសីលធម៌ផ្លូវភេទរបស់សាច់ញាតិគេ។ ការវាយតម្លៃរបស់ព្រះអម្ចាស់របស់យើងចំពោះពិភពលោកថាជាមនុស្សអាក្រក់និងជាមនុស្សកំផិតត្រូវបានបង្ហាញនូវកូនចៅជំនាន់ក្រោយរបស់ពួកគេ។ គឺពួកដែលស្មោះត្រង់នឹងពាក្យរបស់គេត្រូវបានបណ្តុះបណ្តាលដោយទំនាក់ទំនងមិនស្មោះត្រង់ជាមួយមនុស្ស។

ចេញពីស្ថានភាពនេះដែលយើងមើលឃើញពីអំពើបាបរបស់យើង ដូចជាប្រជាជនយូដាប្រសិនបើយើងចង់គេចចេញយើងគួរតែរំលឹកពីអំពើបាបនិងទទួលខុសត្រូវហើយប្រែចិត្តពីអំពើបាបរបស់យើង។ នៅក្នុងប្រទេសកម្ពុជាការបើកសំដែងនេះកើតឡើងដោយសារព្រះគុណរបស់ព្រះ។

**2. ភស្តុតាងនៃ សេចក្តីជុំនុំជំរះ (Eschatological) អេសេគាល (១១:១៩)**

«រួចអញនឹងឲ្យគេមានចិត្តតែមួយហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងរាល់គ្នាអញនឹងដកចិត្តដែលរឹងដូចថ្មពីរូបសាច់គេចេញហើយនឹងឲ្យមានចិត្តជាសាច់វិញ។ (អេសេគាល ១១:១៩) សេចក្តីតាំងសញ្ញានៃព្រះគុណបានចាប់ផ្តើមជាមួយ អ័ប្រាហាំត្រូវបានសម្រេចបំពេញដោយការផ្លាស់ប្តូរចិត្តរបស់ប្រជាជនរបស់គាត់។ ទោះបីជាពួកគេស្នើសុំការការស្តាប់បង្គាប់តាមទំនាក់ទំនងនៃការតាំងសញ្ញាក៏ដោយពួកគេត្រូវបានបរាជ័យនៅក្នុងគ្រប់ទាំងអស់។ ពីព្រោះអ្វីៗទាំងអស់ដែលចេញពីមនុស្សគឺខ្លីដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានធ្វើការរបស់។ ព្រះបានបញ្ជូនវិញ្ញាណបរិសុទ្ធទៅពួកគេដើម្បីបំពេញការសន្យារបស់

គាត់ហើយផ្លាស់ប្តូរនូវចិត្តនៃសេចក្តីលោភលន់។ ការផ្លាស់ប្តូរសថ្មីផ្តល់ឱ្យចិត្តថ្មីនិងក្លាយជាចិត្តដែលទន់ភ្លន់ដូចជាសាច់ឈាម ចិត្តសុភាពគឺ ព្រះគុណរបស់ទ្រង់បានស្ថិតនៅក្នុងចិត្តហើយបើកចិត្តទៅកាន់ព្រះ ហើយយើងក៏រស់នៅដើម្បីទទួលយកព្រះបន្ទូលរបស់ព្រះ។ គឺចំពោះអ្នកដែលព្យាយាមបង្កើតសេចក្តីមេត្តាករុណា សេចក្តីសុខសាន្ត និងគុណធម៌។ មានតែមនុស្សទេដែលមានអំណរនឹងព្រះពរនៃសេចក្តីតាំងសញ្ញានេះ។

**3. សេចក្តីសង្គ្រោះផ្ទាល់ខ្លួន (អេសេគាល ១៤:១៤)**

ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា៖ «ទោះបើមនុស្សទាំងបីនាក់នេះ គឺណូអេ ដានីយ៉ែល និងយ៉ូប បាននៅក្នុង ស្រុកនោះគង់តែសេចក្តីសុចរិតរបស់អ្នកទាំងនោះ បានប្រកាសអំពី ព្រះជាម្ចាស់ (អេសេគាល ១៤: ១៤)។ តាមរយៈអាយុនឹងសេចក្តីពិតរបស់សេចក្តីសង្គ្រោះ ផ្ទាល់ខ្លួនទាំងមូល។មុនពេលដែលព្រះបានសង្គ្រោះអំពើបាបដោយជំនឿរបស់គេ។ គ្មាននរណាម្នាក់អាចបន្ថែមសេចក្តីសង្គ្រោះរបស់គេបានទេ។ ណូអេដែលថ្លែងពីទីបន្ទាល់អំពីសេចក្តីសុចរិតដានីយ៉ែលដែលជាអ្នកគោរពព្រះដែលប្រកាសពីសេចក្តីសុចរិតដល់ពួកអ្នកមិនជឿហើយនៅក្នុង ការរងទុក្ខរបស់យ៉ូបយ៉ាងខ្លាំងដែលក្រលេកមើលអ្នកដែលផ្សះផ្សា ត្រូវបានសង្គ្រោះដោយសារជំនឿរបស់ពួកគេ។ ដូច្នេះមានតែអ្នកផ្សះផ្សា គឺព្រះគ្រិស្តយេស៊ូប៉ុណ្ណោះ។ ចក្ខុវិស័យរបស់យ៉ាកុបដែលយ៉ាកុបបានមើលឃើញថាពួកទេវតានិងការយាងចុះនៅលើជណ្តើរត្រូវបានសម្រេចដោយសេចក្តីពិតនៃការ ផ្សះផ្សារបស់ព្រះគ្រីស្ទ។ក៏ដូចជាគម្ពីរសញ្ញាចាស់មិនដែលបានជៀសចេញពីផ្នែកនេះដែរ។ សេចក្តីសង្គ្រោះរបស់អ៊ីស្រាអែលកើតចេញពីការកោតខ្លាចដល់ព្រះអម្ចាស់ដែលជាសេចក្តីជំនឿដែលពឹងផ្អែកលើព្រះគ្រីស្ទដែលនឹងមកនាពេលអនាគត (១ ធីម៉ូថេ ២: ៥)។

**4. ចិត្តថ្មី (អេសេគាល ១៨:៣១)**

"ចូរបោះបង់ចោលអំពើរំលងទាំងប៉ុន្មានរបស់ឯង ដែលឯងរាល់គ្នាប្រព្រឹត្តនោះហើយឲ្យខ្លួនមានចិត្តថ្មី នឹងវិញ្ញាណថ្មីចុះ! ហេតុអ្វីបានជាពូជពង្សអ៊ីស្រាអែលត្រូវស្លាប់? »។ ព្រះដែលជួយ

សង្គ្រោះព្រលឹងដែលមើលមិនឃើញ គឺមិនមែនរូបកាយទេ ចំរើនកំលាំង នឹងចិត្ត ឲ្យក្លាយជាចិត្តដែលទន់ភ្លន់ នឹងចិត្ត ដែលមានអំនួតទៅជាចិត្តដែលបន្ទាប់ខ្លួន។ នៅពេលយើងទៅកន្លែងនោះយើងអាចរៀនគោរពប្រតិបត្តិហើយអាចបដិសេធខ្លួនយើងហើយផ្ទុកឈើឆ្កាងរបស់ព្រះ។ ព្រលឹងដែលបានបង្កើតឡើងវិញដែលព្រះបានឲ្យជីវិតថ្មីត្រូវបានបើកសំដែងឱ្យដឹងតាមរយៈការផ្លាស់ប្តូរភាពងងឹតទៅជាពន្លឺនិងសេចក្តីស្លាប់ទៅក្នុងជីវិត។ សាររបស់អេសេគាលក៏ផ្តោតលើការផ្លាស់ប្តូរចិត្តថ្មីផងដែរ។ គ្រីស្ទបរិស័ទដែលបានទទួលការបើកសម្តែងពេញលេញទទួលបានបទពិសោធន៍នៃការបើកសំដែងជារៀងរាល់ថ្ងៃដោយទទួលបានព្រះបន្ទូលនៃព្រះគម្ពីរ។

**1. អេសេគាល (១៦: ១៥-២២)**

១) អ៊ីស្រាអែលដែលកាន់កាប់តំណែងកិត្តិយសបានដើរទៅរកផ្លូវកំផិតជាមួយនឹងអំណោយទាំងអស់របស់ព្រះ។ វាចង្អុលបង្ហាញអំពីការថ្វាយបង្គំរូបព្រះ។ ពួកគេបានថ្វាយសម្លៀកបំពាក់តុបតែង ម្ហូបអាហារនិងកូន ៗ របស់ពួកគេទុកជាតង្វាយថ្វាយរូបព្រះ។ ពួកគេជាកម្មសិទ្ធរបស់ព្រះក្លែងក្លាយ។ ជីវិតនៃជំនឿបន្ទាប់ពីការសង្គ្រោះគួរតែត្រូវបានបង្ហាញពីជីវិតដើម្បីសងគុណដល់ព្រះ។ ទោះបីជាយើងត្រូវបានសេចក្តីសង្គ្រោះភ្លាមដោយសេចក្តីជំនឿគួររស់នៅពង្រឹងជីវិតលើសេចក្តីជំនឿ (១៥)។

២) អំពើផិតក្បត់ខាងវិញ្ញាណរបស់ជនជាតិអ៊ីស្រាអែលបានកើតចេញពីសេចក្តីស្រលាញ់ដំបូង។ (២២) នៅពេលពួកគេបានរស់ឡើងវិញនៅពេលពួកគេបាននឹកចាំពីព្រះគុណរបស់ព្រះអង្គហើយចូលទៅជិតព្រះដោយបន្ទាបខ្លួន។

**2. អេសេគាល (១៩: ១-១៥)**

១)  បទចំរៀងដែលសោកសៅរបស់អេសេគាលនៃជនជាតិអ៊ីស្រាអែលបង្ហាញពីការរីកលូតលាស់របស់ព្រះជាម្ចាស់ (១) ពាក្យប្រៀបធៀបនៃសត្វតោពីរក្បាល គឺយេហូយ៉ាគីនដែលត្រូវបានគេចាប់ខ្លួននៅបាប៊ីឡូននិងហ្សីឌាដែលនៅសេសសល់។ អ្វីដែលគាត់បានក្បត់បាប៊ីឡូននិងអ្វីដែលគាត់បានភ្ជាប់ទៅនឹងប្រទេសអេហ្ស៊ីបគឺជាអំពើបាបដែលបានបដិសេធបំណាង់ព្រះហារទ័យរបស់របស់ព្រះ។ ទីបំផុតនៅពេលដែលអ៊ីស្រាអែលបាត់បង់សិទ្ធិអំណាចខាងវិញ្ញាណមេដឹកនាំនយោបាយត្រូវបានបាត់ខ្លួនហើយធ្លាក់ចូលក្នុងភាពច្របូកច្របល់យ៉ាងខ្លាំងនឹងទុក្ខសោក។ តាមពិតនេះគឺជាចម្រៀងដ៏ពិរោះនៅសម័យរបស់យើង។ អ្នកដឹកនាំខាងវិញ្ញាណពិតបង្កើតឆន្ទៈរបស់ព្រះហើយលះបង់ខ្លួនឯងចំពោះព្រះអម្ចាស់។ យើងគួរតែស្នើសុំអ្នកដឹកនាំបែបនេះដល់ព្រះ។

២)  ដូចជាអ៊ីស្រាអែលប្រៀបដូចជាដើមទំពាំងបាយជូរជាប់នឹងព្រះយេហូវ៉ាដូចគ្រីស្ទានជាប់នឹងព្រះគ្រីស្ទនោះគាត់បង្កើតផលផ្លែជាច្រើន។ (១០) អ្វីដែលទ្រង់រួបរួមជាមួយយើងកើតចេញពីសេចក្តីស្រលាញ់ដែលបានបង្កើតឡើងវិញពីព្រោះនៅទីនេះរាល់ជីវិតត្រូវបានបង្កើតឡើង។ ប៉ុន្តែចិត្តរបស់យើងចូលចិត្តធ្វើតាមសាច់ឈាមដោយចាកចេញពីព្រះគ្រីស្ទ។ អំណាចនៃការផ្លាស់ប្តូរគឺអាចបំផ្លាញវាបាន។ មានតែអំណាចរបស់ព្រះគ្រីស្ទប៉ុណ្ណោះដែលអាចគ្រប់គ្រងអំណាចនេះបាន។ យើងគួរតែដើរតាមផ្លូវតូចចង្អៀតដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។

**3. អេសេគាល (១២:១៧-២៨)**

១ព្រះវិញ្ញាណបរិសុទ្ធតាមរយៈសេចក្តីទុក្ខលំបាកវេទនារបស់ពួកយូដាបានបង្ហាញដល់អេសេគាល។ ស្រុកយូដាដែលពោរពេញទៅដោយអំពើហឹង្សាត្រូវនឹងសេចក្តីវេទនា។ គឺអស់អ្នកដែលបោះបង់ចោលព្រះបន្ទូលរបស់ព្រះជាម្ចាស់សុទ្ធតែជាមនុស្សអាក្រក់ហើយទៅតាមលទ្ធ

របស់គេគឺសេចក្ដីជំនុំជំរះ។ ការល្អ បាននាំមកនូវព្រះពរ ប៉ុន្តែលទ្ធផលនៃអំពើហឹង្សាគឺសេចក្ដីវេទនា។ រូបឆ្លុះរបស់ព្រះ សេចក្ដីសុចរិត មេត្តាករុណា និងភាពស្មោះត្រង់គឺជាផលផ្លែនៃពន្លឺ។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកមកកាន់យើងនោះចិត្តអាក្រក់នឹងត្រូវបានផ្លាស់ប្តូរទៅជាចិត្តដែលល្អតាមរយះការផ្លាស់ប្រែ និងជំនឿ។ ការល្អកើតចេញពីអតចរិតរបស់ព្រះ(១៩) ។ជីវិតរបស់ជនជាតិអ៊ីស្រាអែលពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយះការបើកសម្តែង ការបើកសម្តែង (១២)ដែលអាក្រក់ មានន័យថាជា ប្រភពនៃសេចក្តីអាក្រក់ទាំងអស់ ដែលបានរស់នៅ។ពួកគេអះអាងថាការទំនាយរបស់ព្រះមិនអាចសម្រេចបាននឹងជាសេចក្តីឥតប្រយោជន៍ទទេ ហើយពួកគេព្យាយាមបំភ្លេចវាចោល។ ពាក្យនេះគឺជារូបឆ្លុះមិនពិតដែលមនុស្សតែងតែសុបិនចង់ធ្វើឱ្យមានភាពល្បីល្បាញ។មនុស្សសម័យថ្មីអះអាងថានៅពេលដែលពេលវេលានឹងដើរទៅមុខអ្វីៗទាំងអស់ប្រែជាល្អដោយការបើកសម្តែង។ ដោយសារតែការបើកសម្តែងនិយាយថាសេចក្តីសង្គ្រោះនិងការជំនុំជំរះនៅពេលតែមួយនៅពេលយើងក្រោកឈរនៅចំពោះព្រះដោយស្មោះត្រង់នោះយើងអាចក្លាយជាមនុស្សដែលបន្ទាប់ខ្លួន។ នៅទីនោះយើងរស់នៅក្នុងការចូលមកនិងឆ្ពោះទៅរកទុទិដ្ឋិនិយមនិងសុទិដ្ឋិនិយម។

## ឯកសារយោង


Adams, Jay, *Pastoral Theology*

Beeke, Joel, *Puritan Theology*

Calvin, John, *Golden Booklet of the True Christian Life*

Calvin, John, *The Eternal Truth in All Time*

Frame, John, *Christian Life*

Kline, M G, *Kingdom Prologue*

Kline, M G, *The Glory in the Midst*

Morgen, Christopher & Peterson, Robert, A, *The Glory of God*

Owen, John, *Biblical Theology*

Vos, Geerhardus, *Biblical Theology*

Wiiliamson, G. I., *Essay of Reformed Position*

Williamson, G. I., *Westminster Confession*

Author- **White Young Jeon,** *CEMF & CRFI president*

- Biblical Theology (O.T), Expository Preaching and Puritanism
- D. Min., Westminster Theological Seminary, CA, USA (1996)
- M.Div., Hapdong Presbyterian Theological Seminary, South Korea (1981)
- B.A., Chong Shin Theological Seminary, South Korea (1978)
- Taught in International Theological College and Seminary in Cambodia (Chairman of Old Testament)
- Taught in International Reformed Theological College & Seminary, USA (Preaching Professor)

**-------------------------------------------------------------**

Published date: February 16 2020 in Cambodia

Published place: Cambdia Reformed Faith Institute

Editor: Ms Charany Yeoun, CEMF Staff in Cambodia